01575433

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

ឯកសារលេខ D308/3/1/20

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០៤/១/០៧-០៩-២០០៩-អវតក/កសចស (អបជ ៥០)

**<u>អង្គបុរេជំនុំជម្រះ</u>**

**ចំពោះមុខ៖** ចៅក្រម ប្រាក់ គីមសាន ជាប្រធាន
ចៅក្រម Oliver BEAUVALLET
ចៅក្រម នីយ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 29 / 06 / 2018
ម៉ោង (Time/Heure) : 9:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**កាលបរិច្ឆេទ៖** ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១៨
**ភាសាដើម៖** ខ្មែរ/អង់គ្លេស/បារាំង
**ចំណាត់ថ្នាក់៖** សាធារណៈ

---

# សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)

---

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តី អ៊ឹម ចែម**
ប៊ិត ស៊ាងលីម
Wayne JORDASH

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

# មាតិកា

I. ប្រវត្តិនីតិវិធី ........ 1

II. បទដ្ឋាននៃការពិនិត្យលើបណ្ដឹងឧទ្ធរណ៍ ........ 10

III. ភាពអាចទទួលយកបាន ........ 12

IV. បញ្ហាបឋម ........ 14

ក. ការពន្យារពេលចេញដីកាដំណោះស្រាយ (សំអាងហេតុ) ........ 14

ខ. លក្ខណៈនៃដីកាដំណោះស្រាយ (សំអាងហេតុ) ........ 16

១. ការចេញដីកាដំណោះស្រាយជាដីកាពីរដាច់ពីគ្នា ........ 16

២. ការបំបែកសំណុំរឿង និងលក្ខណៈរបស់ដីកាដំណោះស្រាយ ........ 18

គ. ការពិចារណាទៅលើភស្តុតាង ........ 20

១. គោលការណ៍សេរីភាពនៃភស្តុតាង ........ 21

ក. ភាពអាចទទួលយកបាននៃភស្តុតាង ដែលទទួលបានដោយការធ្វើទារុណកម្ម ........ 22

ខ. តម្លៃជាភស្តុតាង នៃរបាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះឆ្នាំ ១៩៩៧ និងឆ្នាំ ១៩៩៨ ........ 23

គ. តម្លៃជាភស្តុតាងនៃការធ្វើសម្ភាសន៍ដែលមិនមែនជាកំណត់ហេតុស្ដាប់ចម្លើយ ........ 23

ឃ . តម្លៃជាភស្តុតាងនៃចម្លើយជាសាធារណៈរបស់ អ៊ឹម ចែម ........ 26

២. បទដ្ឋាននៃភស្តុតាង ........ 27

ឃ. ដំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ........ 29

១. សារណា ........ 29

២. ការពិភាក្សា ........ 32

ក. រឿងក្ដីដែលអ.វ.ត.ក បានទទួល ........ 33

ខ. រឿងក្ដីដែលអ.វ.ត.ក មិនបានទទួល ........ 34

១. យុត្តាធិការឥស្សរចិត្ត ........ 34

២. ច្បាប់ជាធរមានរបស់ អ.វ.ត.ក ........ 35

៣. សេចក្តីសន្និដ្ឋាន.....37

V. **ការពិចារណាលើអង្គសេចក្តី**.....38

VI. **សេចក្តីសម្រេច**.....38

VII. **យោបល់របស់ចៅក្រម ប្រាក់ គីមសាន, ចៅក្រម ន៉យ ចុល និងចៅក្រម ហួត វុទ្ធី**.....40

VIII. **យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET**.....43

**ក. មូលដ្ឋានទី ១ ៖ ការចោទប្រកាន់អំពីការខកខានក្នុងការពិចារណាទៅលើ**.....43

**បទចោទដែលពុំត្រូវបានចោទជាផ្លូវការ**.....43

១. សារណា.....43

២. កិច្ចពិភាក្សា.....49

ក. សេចក្តីជូនដំណឹងអំពីបទចោទ និងវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ.....49

ខ. សិទ្ធិរបស់សហព្រះរាជអាជ្ញាក្នុងការអន្តរាគមន៍នៅក្នុងកិច្ចដំណើរការនីតិវិធី.....53

គ. ភារកិច្ចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញសេចក្តីសម្រេចលើអង្គហេតុ ទាំងអស់.....54

**ខ. មូលដ្ឋានទី ២ ៖ ការចោទប្រកាន់អំពីការខកខានក្នុងការឆ្លើយតបអង្គហេតុ ក្នុងដីកាដំណោះស្រាយ (សំអាងហេតុ)**

.......55

១. សារណា.....55

២. ការពិភាក្សា.....60

ក. មូលដ្ឋានទី២(១)៖ ការបោសសម្អាតនៅភូមិភាគពាយ័ព្យ.....63

ខ. មូលដ្ឋានទី២(២)៖ អាពាហ៍ពិពាហ៍ដោយបង្ខំ.....72

គ. មូលដ្ឋានទី២(៣) ៖ ឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិវៀតណាម.....74

ឃ. មូលដ្ឋានទី២(៤) ៖ ឧក្រិដ្ឋកម្មប្រឆាំងខ្មែរក្រោម.....83

ង. មូលដ្ឋានទី២(៥) ៖ ការធ្វើទុក្ខម្នេញទៅលើក្រុមនានា និងឧក្រិដ្ឋកម្មផ្សេងៗទៀត.....88

១.ការធ្វើទុក្ខបុកម្នេញទៅលើកម្មាភិបាលភូមិភាគពាយ័ព្យ.....89

២.ការធ្វើទុក្ខបុកម្នេញទៅលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ 90

៣.ការធ្វើទុក្ខបុកម្នេញទៅលើប្រជាជនចាម 94

៤. ការធ្វើទុក្ខបុកម្នេញទៅលើប្រជាជនចិន ប្រជាជនឡាវ និង ជនជាតិភាគតិចខ្មែរលើ 95

៥. ការធ្វើទារុណកម្មនៅមន្ទីសន្តិសុខភ្នំទ្រយោង 96

៦.ការធ្វើទារុណកម្មនៅមន្ទីរសន្តិសុខវត្តចំការខ្នុរ និងទីតាំងសម្លាប់មនុស្សវត្តចំការខ្នុរ 101

៧. លក្ខខណ្ឌរស់នៅអមនុស្សធម៌នៅមន្ទីសន្តិសុខភូមិចក្រី 107

៨. ការដាក់ក្នុងមន្ទីឃុំឃាំង និង ការបាត់ខ្លួនដោយបង្ខំនៅវត្តអង្គសីរីមាលី 110

ច. ការពិចារណាបន្ថែម 113

១. ការដ្ឋានទំនប់ត្រពាំងថ្ម 115

២. វត្តព្រះនេត្រព្រះ និងទីតាំងពាក់ព័ន្ធ 124

៣. មន្ទីរសន្តិសុខភូមិចក្រី និងទីតាំងសម្លាប់មនុស្សព្រៃតារ៉ុត 130

៤. មន្ទីសន្តិសុខវត្តចម្ការខ្នុរ និងវាលពិឃាត 138

**គ. មូលដ្ឋានទី៣៖ កំហុសដែលបានចោទប្រកាន់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមរូបភាពជាការសម្លាប់រង្គាល** 142

១. សារណា 142

ខ. ការពិភាក្សា 146

**ឃ. មូលដ្ឋានទី៤៖ កំហុសដែលបានបានចោទប្រកាន់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមអំពើអមនុស្សធម៌ផ្សេងទៀតតាមរយៈការបាត់ខ្លួនដោយបង្ខំ** 151

១. សារណា 151

២. ការពិភាក្សា 155

**ង. ទទ្បីករណ៍ទី ៥ និងទី ៦៖ ការចោទប្រកាន់អំពីកំហុសផ្លូវនានាពាក់ព័ន្ធនឹងការសន្និដ្ឋានទៅលើមុខងាររបស់ អ៊ឹម ចែម ជាលេខាស្រុកកោះអណ្ដែត និង សមាជិកគណៈកម្មាធិការតំបន់ ១៣** 163

១. សារណា 163

២. ការពិភាក្សា ........ 168

ក.ការសំអាងទៅលើការប្រកាសរបស់ អ៊ឹម ចែម នៅក្រៅដំណើរការតាមផ្លូវតុលាការ ........ 169

ខ.សាវតាផ្ទាល់ខ្លួនរបស់ អ៊ឹម ចែម មុនឆ្នាំ ១៩៧៥ ........ 170

គ.មុខងាររបស់ អ៊ឹម ចែម ជាប្រធានសមាគមនារីនៅតំបន់ ១៣ ........ 173

ឃ.មុខងាររបស់ អ៊ឹម ចែម ក្នុងនាមជាលេខាស្រុកកោះអណ្ដែត ........ 176

ង.មុខងាររបស់ អ៊ឹម ចែម ក្នុងនាមជាសមាជិកគណៈកម្មាធិការតំបន់ ១៣ ........ 183

៣. សេចក្ដីសន្និដ្ឋាន ........ 187

**ច. សេចក្ដីសន្និដ្ឋានអំពីយុត្តាធិការបុគ្គល** ........ 188

១. សេចក្ដីសង្ខេបនៃការសន្និដ្ឋាន ........ 189

២.ការវាយតម្លៃទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ........ 191

៣. ការវាយតម្លៃលើតួនាទី និងការទទួលខុសត្រូវរបស់ អ៊ឹម ចែម ........ 194

៤. សេចក្ដីសន្និដ្ឋាន ........ 197

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានទទួល “បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)” (“បណ្តឹងឧទ្ធរណ៍”) ដែលបានដាក់នៅថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៧[1]

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ករណីខ្វែងយោបល់គ្នាមួយនៅចំពោះមុខអង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ៧១(២) ដោយរាយការណ៍ថា សហព្រះរាជអាជ្ញាជាតិជំទាស់ទៅនឹងការកាត់ទោសទៅលើបទល្មើសថ្មីៗដែលត្រូវបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[2] ។ នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណាទៅលើករណីខ្វែងយោបល់គ្នានេះ[3]។

២. នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ដោយស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតបើកកិច្ចស៊ើបសួរប្រឆាំងនឹង អ៊ឹម ចែម *ក្នុងចំណោមចំណុចផ្សេងទៀត* ពាក់ព័ន្ធនឹងការចោទប្រកាន់មួយចំនួនពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង ការរំលោភបំពានក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ (“ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣”)[4]។ ការចោទប្រកាន់បន្ថែមទៀតត្រូវបានដាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមប្រាំទៀត ដែលត្រូវ

---

[1] សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (“សំណុំរឿង ០០៤/១”) (អ.ប.ជ ៥០) បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (ហេតុសំអាង) ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៧ និងការជូនដំណឹងនៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/1 (“បណ្តឹងឧទ្ធរណ៍”)។

[2] ករណីខ្វែងយោបល់គ្នាលេខ ០០១/១៨-១១-២០០៨-អ.វ.ត.ក/អ.ប.ជ សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីអង្គហេតុ និងសំអាងហេតុ ចំពោះករណីខ្វែងយោបល់គ្នា អនុលោមតាមវិធាន ៧១(២) ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1។

[3] ករណីខ្វែងយោបល់គ្នាលេខ ០០១/១៨-១១-២០០៨-អ.វ.ត.ក/អ.ប.ជ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ D1/1.3។

[4] សំណុំរឿងលេខ ០០៤/២០-១១-២០០៨-អ.វ.ត.ក/ក.ស.ច.ស ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1 (“ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ (D1)”)។

បានដាក់នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១[5] ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមស្តីពីតំបន់១")[6] ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១១[7] ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ")[8] និង ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៦ [9]។

៣. នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិបានជូនដំណឹងដល់ អ៊ឹម ចែម ថា គាត់គឺជាជនសង្ស័យមួយរូបនៅក្នុងសំណុំរឿង ០០៤ និងបានជូនដំណឹងអំពីសិទ្ធិរបស់គាត់ក្នុងការទទួលបានការតំណាងផ្លូវច្បាប់តាមការជ្រើសរើសរបស់គាត់ និងសិទ្ធិចូលពិនិត្យមើលសំណុំរឿង [10]។

៤. ករណីខ្វែងយោបល់គ្នាជាសម្ងាត់រវាងសហចៅក្រមស៊ើបអង្កេតត្រូវបានចុះកំណត់ហេតុនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣ និង ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤។

---

[5] សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០៤") ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ ឯកសារលេខD២៧ មើលផងដែរ សំណុំរឿង០០៤ សេចក្តីសម្រេចអំពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ ឯកសារលេខD២៧/៣។

[6] សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០៤") ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី កក្កដា ឆ្នាំ ២០១១ កថាខណ្ឌ D65 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមស្តីពីតំបន់១ (D65)")។

[7] សំណុំរឿង ០០៤ ចម្លើយតបនឹងដីកាសន្និដ្ឋានបញ្ជូនរឿងទៅពិនិត្យ ចុះថ្ងៃទី៥ ខែវិច្ឆិកាឆ្នាំ២០១៥ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទាក់ទងនឹងវត្តអង្គតាមាក់ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ២០១១ ឯកសារលេខ D២៥៤/១។

[8] សំណុំរឿង ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D191 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ (D191)")។

[9] សំណុំរឿង០០៤ ចម្លើយតបទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីវិសាលភាពនៃកិច្ចស៊ើបសួរទៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងតំបន់១ និង៤ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ និង ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៦ ឯកសារលេខD២៧១/១ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីវិសាលភាពនៃកិច្ចស៊ើបសួរ (D២៧២/១)")។

[10] សំណុំរឿង ០០៤ ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន២១(១)(ឃ)] ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ និងបានដាក់នៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១២ ឯកសារ D108។

៥. នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាកោះឱ្យបង្ហាញខ្លួនលើកដំបូងនៅ អ.វ.ត.ក នៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤[11] ដែលសហមេធាវីការពារក្ដី អ៊ឹម ចែម ("សហមេធាវី") បានជំទាស់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត[12] និងអង្គបុរេជំនុំជម្រះ[13]។ នៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤ អង្គបុរេជំនុំជម្រះបានច្រានចោលសំណើសុំព្យួរការអនុវត្តដីកាកោះ[14]។ បន្ទាប់ពី អ៊ឹម ចែម មិនបានអនុវត្តតាមដីកាកោះ[15] នៅថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តជាតិបានចេញដីកាបង្គាប់ឱ្យនាំខ្លួន [16] ដែលនៅតែមិនត្រូវបានយកមកអនុវត្តនៅឡើយ និងចុងក្រោយត្រូវបានចាត់ទុកជាមោឃៈ នៅខែកុម្ភៈ ឆ្នាំ២០១៦[17]។

---

[11] សំណុំរឿង ០០៤ ដីកាកោះឱ្យបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ និងបានដាក់នៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ A150។

[12] *សូមមើល* សំណុំរឿង ០០៤ លិខិតពីសហមេធាវីការពារក្ដី អ៊ឹម ចែម ផ្ញើជូនសហចៅក្រមស៊ើបអង្កេតឆ្លើយតបទៅនឹងដីកាកោះ ចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ A151/2។ សំណុំរឿង ០០៤ ការឆ្លើយតបទាក់ទងនឹងទម្រង់បែបបទនៃការប្រគល់ដីកាកោះជូន អ៊ឹម ចែម ចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៤ និង បានដាក់នៅថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ A122/6។ *សូមមើល* សំណុំរឿង ០០៤ សំណើសុំបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម ស្នើសុំឱ្យបញ្ជូនសំណើសុំមោឃភាពដីកាកោះហៅអ្នកស្រី និងសហមេធាវីការពារក្ដីគាត់ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤ ទៅអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ D207។ សំណុំរឿង ០០៤ ដីកាសម្រេចលើសំណើសុំបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម ស្នើសុំឱ្យបញ្ជូនសំណើសុំមោឃភាពដីកាកោះហៅអ្នកស្រី និងសហមេធាវីការពារក្ដីគាត់ទៅអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ និងបានដាក់នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ D207/1។

[13] *សូមមើល* សំណុំរឿង ០០៤ សំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម សុំព្យួរការអនុវត្តដីកាកោះហៅអ្នកស្រីឱ្យមកបង្ហាញខ្លួនជាលើកដំបូង ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ និង បានដាក់នៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ A122/6.1/1។

[14] សំណុំរឿង ០០៤ (អ.ប.ជ ០៩) សេចក្ដីសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម សុំព្យួរការអនុវត្តដីកាកោះហៅអ្នកស្រីឱ្យមកបង្ហាញខ្លួនជាលើកដំបូង ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ A122/6.1/2 (សេចក្ដីសម្រេច) និង ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ A122/6.1/3 (សំអាងហេតុ)។

[15] *សូមមើល* សំណុំរឿង ០០៤ កំណត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងការបង្ហាញខ្លួនជាលើកដំបូងរបស់ អ៊ឹម ចែម ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ A150/2។ សំណុំរឿង ០០៤ អ៊ីមែលពីសហមេធាវីអន្តរជាតិ ផ្ញើជូនសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤ និងបានដាក់នៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ A150/2/2.1។

[16] សំណុំរឿង ០០៤ ដីកាបង្គាប់ឱ្យនាំខ្លួន ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤ និងបានដាក់នៅថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ C1។

[17] *សូមមើល* សំណុំរឿង ០០៤ ដីកាសម្រេចដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោយការពិនិត្យ*ដោយកំបាំងមុខ* ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D239 ("ដីកាសម្រេចដាក់ឱ្យស្ថិតក្រោយការពិនិត្យ*ដោយកំបាំងមុខ* (D239)") កថាខណ្ឌ ២៣-៣០។

01575441



៦. នៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោយការពិនិត្យ *ដោយកំបាំងមុខ*[18] និងបានរៀបរាប់លម្អិតអំពីបទចោទនៅក្នុងឧបសម្ព័ន្ធនៃសេចក្តីសម្រេចនោះ (" ការសម្រេចចោទប្រកាន់កំបាំងមុខ")[19]។ សហមេធាវីបានប្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាសម្រេចដាក់ឱ្យស្ថិតក្រោយការពិនិត្យ *ដោយកំបាំងមុខ* នៅថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥[20] ហើយនៅថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១៦ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណាមួយចំនួន[21]។

៧. នៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតបានអញ្ជើញភាគីឱ្យដាក់សារណាអំពីចំណុចថាតើ អ៊ឹម ចែម គួរត្រូវបានចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់" ឬស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ពាក់ព័ន្ធនឹងយុត្តាធិការបុគ្គល[22]។ សហមេធាវី[23] សហព្រះរាជអាជ្ញាអន្តរជាតិ[24] និងសហព្រះរាជអាជ្ញាជាតិ[25] បានដាក់សេចក្តីសន្និដ្ឋាន នៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៥។

---

[18] *សូមមើល* ដីកាសម្រេចដាក់ឱ្យស្ថិតក្រោយការពិនិត្យ*ដោយកំបាំងមុខ* (D239)។ *សូមមើលផងដែរ* សំណុំរឿង ០០៤ លិខិតពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិផ្ញើជូនប្រធានគណៈកម្មការសន្តិសុខ អ.វ.ត.ក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥ និងបានដាក់នៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D238។

[19] សំណុំរឿង ០០៤ ឧបសម្ព័ន្ធសម្ងាត់៖ ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង អ៊ឹម ចែម ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D239.1 ("ការជូនដំណឹងអំពីបទចោទប្រកាន់ (D239.1)")។

[20] សំណុំរឿង ០០៤ បណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អ៊ឹម ចែម ប្រឆាំងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឱ្យស្ថិតក្រោយការពិនិត្យ*ដោយកំបាំងមុខ* ចុះថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ D239/1/2។

[21] សំណុំរឿង ០០៤ (អ.ប.ជ ១៩) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឱ្យស្ថិតក្រោយការពិនិត្យ*ដោយកំបាំងមុខ* ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ និងបានដាក់នៅថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ D239/1/8។

[22] សំណុំរឿង ០០៤ សំណើសុំឱ្យដាក់សារណាថាតើ អ៊ឹម ចែម គួរត្រូវបានចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់" និង/ឬស្ថិតក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៥ និងបានដាក់នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ D251។

[23] សំណុំរឿង ០០៤ សេចក្តីសង្កេតរបស់អ្នកស្រី អ៊ឹម ចែម ស្តីពីបញ្ហាថាតើអ្នកស្រីគួរត្រូវបានចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់" ឬ បុគ្គលម្នាក់ស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ D251/4។

[24] សំណុំរឿង ០០៤ សារណាលើបញ្ហាថាតើ អ៊ឹម ចែម គួរត្រូវបានចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់" ឬ ក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែរឬយ៉ាងណា ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ D251/5។

៨. នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ភាគីថា សហចៅក្រមស៊ើបអង្កេតបានចាត់ទុកថា កិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម ត្រូវបានបញ្ចប់ហើយ ("សេចក្តីជូនដំណឹងអនុលោមតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង")[26] ។ នៅថ្ងៃដដែលនោះ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ភាគីថា ពួកគេមានបំណងលើកលែងការចោទប្រកាន់ប្រឆាំង អ៊ឹម ចែម ដោយសារពុំមានយុត្តាធិការបុគ្គល និងមានបំណងបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងរូបគាត់ [27]។

៩. នៅថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេតបានបង្គាប់ឱ្យបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំង អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤ និងបង្កើតសំណុំរឿងថ្មីមួយ គឺសំណុំរឿង ០០៤/១ [28]។

១០. នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេតបានបញ្ជូនសំណុំរឿងទៅសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ដោយបានអញ្ជើញសហព្រះរាជអាជ្ញាឱ្យដាក់ដីកាសន្និដ្ឋានស្ពាពរក្នុងរយៈពេលបីខែខាងមុខ ("ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ")[29]។

១១. នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាជាតិ[30] និងសហព្រះរាជអាជ្ញាអន្តរជាតិ[31] បានដាក់ដីកាសន្និដ្ឋានស្ពាពរអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ដាច់ដោយឡែកពីគ្នា ("ដីកាសន្និដ្ឋាន

---

[25] សំណុំរឿង ០០៤ សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាជាតិ អំពីការអនុវត្តធន្មានុសិទ្ធិរបស់ ស.ច.ស លើករណី អ៊ឹម ចែម យោងតាមឯកសារលេខ D251 ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ D251/6។

[26] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D285 ("សេចក្តីជូនដំណឹងអនុលោមតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង (D285)")។

[27] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងអំពីគោលបំណងលើកលែងការចោទប្រកាន់ប្រឆាំង អ៊ឹម ចែម និងបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D286 ("សេចក្តីជូនដំណឹងអំពីគោលបំណងលើកលែងការចោទប្រកាន់ និងបំបែកកិច្ចដំណើរការនីតិវិធី (D286)")។

[28] *សូមមើល* ដីកាសម្រេចបំបែកសំណុំរឿងទាក់ទង អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤ ចុះថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D286/7 ("ដីកាសម្រេចបំបែកសំណុំរឿង (D286/7)")។

[29] សំណុំរឿង ០០៤/១ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យយោងតាមវិធានផ្ទៃក្នុង ៦៦(៤) ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ ឯកសារ D304 ("ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ (D304)")។

[30] សំណុំរឿង ០០៤/១ ដីកាសន្និដ្ឋានស្ពាពរទាក់ទងករណី អ៊ឹម ចែម អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ D304/1 ("ដីកាសន្និដ្ឋានស្ពាពររបស់សហព្រះរាជអាជ្ញាជាតិ (D304/1)")។

[31] សំណុំរឿង ០០៤/១ ដីកាសន្និដ្ឋានស្ពាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ប្រឆាំង អ៊ឹម ចែម ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ D304/2 ("ដីកាសន្និដ្ឋានស្ពាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D304/2)")។

ស្ពាពររបស់សហព្រះរាជអាជ្ញាជាតិ” និង “ដីកាសន្និដ្ឋានស្ពាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ”)។ អ៊ីម ចែម បានដាក់ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ពាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ (“ចម្លើយតបរបស់ អ៊ីម ចែម ទៅនឹងដីកាសន្និដ្ឋានស្ពាពរ”)[32]។

១២. នៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញផ្នែកសេចក្ដីសម្រេចនៃដីកាដំណោះស្រាយ (“ដីកាដំណោះស្រាយ (ផ្នែកសេចក្ដីសម្រេច)”)[33] ដោយសហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា អ.វ.ត.ក ពុំមានយុត្តាធិការបុគ្គលលើ អ៊ីម ចែម ទេ លើកលែងបទចោទប្រកាន់នឹងរូបគាត់ និងជូនដំណឹងដល់ភាគីថា សំអាងហេតុនឹងចេញនៅពេលក្រោយ។ នៅថ្ងៃដដែល សហចៅក្រមស៊ើបអង្កេតបានលើកចោលរាល់ពាក្យស្នើរសុំរបស់ភាគីរដ្ឋប្បវេណី។[34]

១៣. នៅថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើសុំការអនុញ្ញាតដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ផ្នែកសេចក្ដីសម្រេច) ក្រោយពីផ្ដល់សំអាងហេតុពេញលេញ[35] ដែលទទួលបានការអនុញ្ញាតពីអង្គបុរេជំនុំជម្រះនៅថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៧ [36]។

---

[32] សំណុំរឿង ០០៤/១ ចម្លើយតបរបស់អ្នកស្រី អ៊ីម ចែម ទៅនឹងដីកាសន្និដ្ឋានស្ពាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងអ្នកស្រីតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ បានដាក់ជាភាសាអង់គ្លេសនៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦ និងជាភាសាខ្មែរនៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៧ ឯកសារ D304/6។ *សូមមើលផងដែរ* សំណុំរឿង ០០៤/១ ដីកាសម្រេចលើសំណើរបស់អ្នកស្រី អ៊ីម ចែម សុំដាក់សារណាតបទៅនឹងដីកាសន្និដ្ឋានស្ពាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ជាភាសាអង់គ្លេសជាមុនសិន ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D304/5/1។

[33] សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ (ផ្នែកសេចក្ដីសម្រេច) ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧ ឯកសារ D308 (“ដីកាដំណោះស្រាយ (ផ្នែកសេចក្ដីសម្រេច)”)។

[34] សំណុំរឿង ០០៤/១ ដីកាសម្រេចទទួលយកពាក្យសុំរបស់ភាគីរដ្ឋប្បវេណី ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧ ឯកសារ D307

[35] សំណុំរឿង ០០៤/១ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ ក្រោយការផ្ដល់សំអាងហេតុពេញលេញរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១៧ ឯកសារ D308/1។

[36] សំណុំរឿង ០០៤/១ ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ ក្រោយការផ្ដល់សំអាងហេតុពេញលេញរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៧ ឯកសារ D308/2 (“ដីកាសម្រេចលើសំណើសុំដាក់បណ្ដឹងឧទ្ធរណ៍ក្រោយការផ្ដល់សំអាងហេតុពេញលេញ (D308/2)”)។

01575444



១៤. នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ (សំអាងហេតុ) ("ដីកាដំណោះស្រាយ (សំអាងហេតុ)") ដោយបានផ្តល់សំអាងហេតុពេញលេញចំពោះសេចក្តីសម្រេចរបស់ខ្លួន[37]។

១៥. នៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ(សំអាងហេតុ)[38] និងបានដាក់សារណាលើបណ្តឹងឧទ្ធរណ៍ នៅថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៧[39]។

១៦. នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៧ សហមេធាវីជាតិតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំការអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ[40]។ ក្រោយពេលស្តាប់សេចក្តីសន្និដ្ឋានពីភាគី[41] នៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៧ អង្គបុរេជំនុំជម្រះបានបដិសេធសំណើនោះ និងបានអញ្ជើញសហមេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមប

---

[37] សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D308/3 ("ដីកាដំណោះស្រាយ (សំអាងហេតុ)")។

[38] សំណុំរឿង ០០៤/១ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D308/3/1។

[39] *សូមមើលខាងលើ* លើងទំព័រ ១។

[40] សំណុំរឿង ០០៤/១ សំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ សុំពន្យារពេល និងសុំការអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងដីកាដំណោះស្រាយ (សំអាងហេតុ) ជាភាសាអង់គ្លេសសិន ដោយសំណៅជាភាសាខ្មែរនឹងដាក់តាមក្រោយ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៧ និង បានដាក់នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/4។

[41] *សូមមើល* សំណុំរឿង ០០៤/១ ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងសំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ សុំពន្យារពេល និងសុំការអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងដីកាដំណោះស្រាយមានសំអាងហេតុ ជាភាសាអង់គ្លេសសិន ដោយសំណៅជាភាសាខ្មែរនឹងដាក់តាមក្រោយ (D308/3/1/4) ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/5។ សំណុំរឿង ០០៤/១ ការឆ្លើយតបរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិទៅនឹងចម្លើយតបរបស់ អ៊ឹម ចែម (D308/3/1/5) ទៅនឹងសំណើសុំពន្យារពេល និងសុំការអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងដីកាដំណោះស្រាយ (សំអាងហេតុ) ជាភាសាអង់គ្លេសសិន ដោយសំណៅជាភាសាខ្មែរនឹងដាក់តាមក្រោយ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/6។ សំណុំរឿង ០០៤/១ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងសំណើសុំរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/7។

ណ្តឹងរដ្ឋប្បវេណីឲ្យដាក់សារណា ដោយកម្រិតត្រឹមបញ្ហាស្តីពីស្ថានភាពរបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា [42]។

១៧. នៅថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៧ សហមេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សារណាអំពីស្ថានភាពរបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ("សារណាស្តីពី អ.វ.ត.ក")[43] ដែលសហមេធាវីការពារក្តី អ៊ឹម ចែម បានឆ្លើយតបនៅថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៧ [44]។ សហព្រះរាជអាជ្ញាទាំងពីរពុំបានធ្វើការឆ្លើយតបទេ។

១៨. អនុលោមតាមសេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះ[45] នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៧ សហមេធាវីបានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ [46] ហើយ នៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៧[47] សហព្រះរាជអាជ្ញាអន្តរជាតិបានធ្វើការឆ្លើយតប [48]។

---

[42] សំណុំរឿង ០០៤/១ (PTC50) សេចក្តីសម្រេចលើសំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិ ពាក់ព័ន្ធនឹងការដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ និងការអញ្ជើញឲ្យដាក់សារណា ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/8 ("សេចក្តីសម្រេចអញ្ជើញឲ្យដាក់សារណាស្តីពី អ.វ.ត.ក (D308/3/1/8)")។

[43] សំណុំរឿង ០០៤/១ សារណារបស់សហមេធាវីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអំពីជំហររបស់ អវ. កម្ពុជាប់ច្បាប្រព័ន្ធក្នុងក នៅ.ត. ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារ D308/3/1/9 ("សារណាស្តីពី អ.វ.ត.ក (D308/3/1/9)")។

[44] សំណុំរឿង ០០៤/១ ចម្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងសារណារបស់ ស.ម.ត.ដ ស្តីពីជំហរ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា (D308/3/1/9) ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ឯកសារ D308/3/1/18 ("ចម្លើយតបទៅនឹងសារណាស្តីពី អ.វ.ត.ក (D308/3/1/18)")។

[45] សំណុំរឿង ០០៤/១ (PTC50) សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អ៊ឹម ចែម ដើម្បីសុំពន្យារពេល និងបង្កើនចំនួនសន្លឹករបស់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/3។ *សូមមើលផងដែរ* សំណុំរឿង ០០៤១/ សំណើបន្ទាន់របស់ អ៊ឹម ចែម ដើម្បីសុំពន្យារពេល និងបង្កើនចំនួនសន្លឹករបស់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) (D308/3/1/1) ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/2។

[46] សំណុំរឿង ០០៤/១ ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារ D308/3/1/11 ("ចម្លើយតប")។

[47] *សូមមើល* សំណុំរឿង ០០៤/១ (PTC50), សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំពេលវេលាបន្ថែមដើម្បីដាក់ការឆ្លើយតប ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារ D308/3/1/12 ដូចក្នុង សំណុំរឿង ០០៤/១, សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំពេលវេលាបន្ថែមដើម្បីឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ចុះថ្ងៃទី ១៣ ខែ កញ្ញា

១៩. បន្ទាប់ពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់ភាគី[49] នៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧ អង្គបុរេជំនុំជម្រះបានចេញដីកាកំណត់កាលបរិច្ឆេទសវនាការស្តាប់សេចក្តីសន្និដ្ឋានលើបណ្តឹងឧទ្ធរណ៍[50] ។ ការស្តាប់សេចក្តីសន្និដ្ឋានលើបណ្តឹងឧទ្ធរណ៍ត្រូវបានធ្វើឡើងជាអសាធារណៈនៅថ្ងៃទី ១១ និងទី ១២ ខែ ធ្នូ ឆ្នាំ ២០១៧[51]។

---

ឆ្នាំ ២០១៧ ឯកសារ D308/3/1/10។

[48] សំណុំរឿង ០០៤/១ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៧ ឯកសារ D308/3/1/13 ("ការឆ្លើយតប")។

[49] សំណុំរឿង ០០៤/១ សេចក្តីជូនដំណឹងរបស់អង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥០) ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៧។ សំណុំរឿង ០០៤/១ សហមេធាវី សេចក្តីស្នើលម្អិតសម្រាប់សវនាការផ្ទាល់មាត់នៅក្នុងសំណុំរឿង ០០៤/១ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៧ ឯកសារ D308/3/1/14។ សំណុំរឿង ០០៤១/ សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្តីពីសវនាការអង្គបុរេជំនុំជម្រះទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងលើដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៧ ឯកសារ D308/3/1/15។ សំណុំរឿង ០០៤/១ សហមេធាវី ចម្លើយតបទៅនឹងការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្តីពីសវនាការការអង្គបុរេជំនុំជម្រះទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងលើដីកាដំណោះស្រាយ (ហេតុសំអាង) (D308/3/1/15) ចុះថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ឯកសារ D308/3/1/16។ សំណុំរឿង ០០៤/១ សវនាការរបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១៧ និងបានដាក់នៅថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០១៧ ឯកសារ D308/3/1/17។

[50] សំណុំរឿង ០០៤/១ (PTC50) ដីកាកំណត់កាលបរិច្ឆេទសវនាការរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ឯកសារ D308/3/1/19។

[51] សំណុំរឿង ០០៤/១ (PTC50) កំណត់ហេតុជាលាយលក្ខណ៍អក្សរស្តីពីសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (PTC50) ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៧ ឯកសារ D308/3/1/19/1។ សំណុំរឿង ០០៤/១(PTC50) កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៧ និងបានដាក់នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៧ ឯកសារ D308/3/1/19/1.1។ សំណុំរឿង ០០៤/១ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (PTC50) ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៧ ឯកសារ D308/3/1/19/1.2 ("ប្រតិចារឹកថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៧ (D308/3/1/19/1.2)")។ សំណុំរឿង ០០៤/១ (PTC50) កំណត់ហេតុជាលាយលក្ខណ៍អក្សរស្តីពីសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (PTC50) ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៧ ឯកសារ D308/3/1/19/2 ។ សំណុំរឿង ០០៤/១ (PTC50) កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៧ ឯកសារ D308/3/1/19/2.1 ("ប្រតិចារឹកថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៧ (D308/3/1/19/2.1)")។

## II. បទដ្ឋាននៃការពិនិត្យលើបណ្តឹងឧទ្ធរណ៍

២០. ការកំណត់ថាតើ អ៊ឹម ចែម ស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ហើយថាតើ គាត់ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់អ.វ.ត.ត.ក ឬទេនោះ គឺជាសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិ[52]។ ទោះជាយ៉ាងណាក្តី ឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតក្នុងការកំណត់លើចំណុចនេះគឺជាឆន្ទានុសិទ្ធិតុលាការ និងមិនអនុញ្ញាតឱ្យបំពេញកិច្ចតាមអំពើចិត្តទេ តែត្រូវអនុវត្តទៅតាមគោលការណ៍ច្បាប់ដែលមានច្បាស់លាស់[53] ។ ទាក់ទិននឹងចំណុចនេះ ពាក្យថា "មេដឹកនាំជាន់ខ្ពស់" និង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" គឺជាព្រំដែនយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក [54] ។ ទោះបីភាពបត់បែននៃពាក្យទាំងនេះតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតមានសិទ្ធិអំណាចមួយចំនួនក៏ដោយ តែឆន្ទានុសិទ្ធិនេះមិនមែនគ្មានព្រំដែន និងចៀសផុតពីការត្រួតពិនិត្យរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នោះទេ។ ហេតុនេះ អង្គបុរេជំនុំជម្រះនឹងពិនិត្យទៅលើការកំណត់របស់សហចៅក្រមស៊ើបអង្កេតដែលថា អ៊ឹម ចែម មិនស្ថិតក្នុងប្រភេទជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែលមិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់តុលាការ ដោយប្រើប្រាស់បទដ្ឋាននៃការពិនិត្យលើបណ្តឹងឧទ្ធរណ៍ដែលអនុវត្តចំពោះសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិ។

២១. សេចក្តីសម្រេចមួយអាចត្រូវបានបដិសេធចោល ក្នុងករណីដែលសេចក្តីសម្រេចនោះ (១) ផ្អែកលើការបកស្រាយច្បាប់ជាមូលដ្ឋានមិនបានត្រឹមត្រូវ (*គឺ* កំហុសអង្គច្បាប់) ដែលនាំឱ្យសេចក្តីសម្រេចនោះគ្មានសុពលភាព (២) ផ្អែកលើការសន្និដ្ឋានលើអង្គហេតុមិនត្រឹមត្រូវច្បាស់ក្រឡែត (*គឺ* កំហុសអង្គហេតុ) ដែលបណ្តាលឱ្យមានភាពមិនយុត្តិធម៌ និង/ឬ (៣) មានភាពអយុត្តិធម៌ ឬមិនសមហេតុសមផល ដែលជាការ

---

[52] សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក ("សំណុំរឿង ០០១") សាលដីកា ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 ("សាលដីកានៃសំណុំរឿង ០០១ (F28)") កថាខណ្ឌ ៦២-៧៤, ៧៩។ *សូមមើលផងដែរ* ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៩។ ចម្លើយតប កថាខណ្ឌ ១០-១២។ ការឆ្លើយតប កថាខណ្ឌ ៤។

[53] សូមមើល *ការកាត់ទោសឧក្រិដ្ឋជនសង្គ្រាមធំៗនៅចំពោះមុខតុលាការយោធាអន្តរជាតិ* Nuremberg ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៤៥-ថ្ងៃទី ១ ខែ តុលា ឆ្នាំ ១៩៤៦ ភាគ I ទំព័រ ២៥៦។

[54] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ដែលបានចុះហត្ថលេខានៅថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣ និងចូលជាធរមាននៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ("កិច្ចព្រមព្រៀងបង្កើត អ.វ.ត.ក") មាត្រា ២(១)។ ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ ដោយបញ្ចូលវិសោធនកម្មដែលប្រកាសឱ្យប្រើនៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៤ នស/រកម/១០០៤/០០៦ ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក") មាត្រា ២ថ្មី។

01575448



បំពានលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត និងបង្ខំឱ្យធ្វើការសន្និដ្ឋាន ដោយពួកគាត់មិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានប្រយ័ត្នប្រយែង។ អាចនិយាយម្យ៉ាងទៀតថា ត្រូវបង្ហាញឱ្យ ឃើញថា សហចៅក្រមស៊ើបអង្កេត មានកំហុស ឬមានការបំពារបំពាន ដែលមានអានុភាពទៅលើការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន[55]។

២២. នៅក្នុងបរិបទនៃសេចក្ដីសម្រេចតាមឆន្ទានុសិទ្ធិ ជាធម្មតា អង្គបុរេជំនុំជម្រះនឹងបញ្ជូនសេចក្ដីសម្រេចនេះឱ្យទៅសហចៅក្រមស៊ើបអង្កេតធ្វើការពិចារណាសាជាថ្មី[56] និងចេញសេចក្ដីសម្រេចរបស់ខ្លួនតែក្នុងកាលៈទេសៈពិសេសប៉ុណ្ណោះ [57] ។ ក្នុងករណីជាក់លាក់នៃបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ "វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង ស្នើឡើងថា អង្គបុរេជំនុំជម្រះមានអំណាចចេញដីកាដំណោះស្រាយថ្មីមួយ ឬចេញដីកាដំណោះស្រាយដែលបានកែប្រែរួច។ ដីកានេះនឹងយកមកធ្វើជាមូលដ្ឋាននៃការជំនុំ

[55] *សូមមើលឧទាហរណ៍* សំណុំរឿង ០០៤ (អ.ប.ជ ៥២) សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងសេចក្ដីសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទនៅគុកលេខ ៨ និងនៅស្រុកបាកានថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកសារ D365/3/1/5 កថាខណ្ឌ ១៥។ សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០៤/២") (អ.ប.ជ ៣៦) សាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទីដប់របស់ អោ អាន ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៧ ឯកសារ D343/4 កថាខណ្ឌ ១២។ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០២") (អ.ប.ជ ៦៧) សាលដីកាស្ដីពីការពិចារណាឡើងវិញ ទៅលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D365/2/17 ("សាលដីកាចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១០ នៃសំណុំរឿង ០០២ (D365/2/17)") កថាខណ្ឌ ៣៦។ សំណុំរឿង ០០២ (អ.ប.ជ ៤៦) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីការណែនាំឱ្យពិចារណាឡើងវិញលើសំណើសុំ D153, D172, D173, D174, D178 និង D284 ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារ D300/1/7 ("សាលដីកាចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១០ នៃសំណុំរឿង ០០២ (D300/1/7)") កថាខណ្ឌ ១៤។ សំណុំរឿង ០០២ (អ.ប.ជ ៥២) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំសម្ភាសន៍បុគ្គលដូចរាយនាមនៅក្នុងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ស្ដីពីការបាត់ខ្លួនដោយបង្ខំ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារ D310/1/3 ("សាលដីកាចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១០ នៃសំណុំរឿង ០០២ (D310/1/3)") កថាខណ្ឌ ១៥-១៦។

[56] *សូមមើលឧទាហរណ៍* សំណុំរឿង០០២ សេចក្ដីសម្រេចលើសំណើសុំសំភាសន៍ D310/1/3 កថាខណ្ឌ ១៦។ សំណុំរឿង ០០២ សេចក្ដីសម្រេច លើការពិចារណាឡើងវិញនៃសំណើសុំ (D300/1/7) កថាខណ្ឌ ១៩, ២៦។

[57] សាលដីកាចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១០ នៃសំណុំរឿង ០០២ (D365/2/17) កថាខណ្ឌ ៦៧។

01575449



ជម្រះ"[58] ។ លើសពីនេះទៀត "អង្គបុរេជំនុំជម្រះបានសម្រេចកាលពីលើកមុនថា ខ្លួនបានបំពេញតួនាទីជាសភាស៊ើបសួរតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជានៅក្នុង អ.វ.ត.ក" ហើយ "នៅពេលទទួលបានដីកាលើកលែងការចោទប្រកាន់ ដោយសារព្រះរាជអាជ្ញា ឬដើមបណ្តឹងរដ្ឋប្បវេណីធ្វើការប្តឹងឧទ្ធរណ៍ សភាស៊ើបសួរត្រូវ "ធ្វើការស៊ើបសួររឿងក្តីនេះ ដោយខ្លួនឯង"[59]។

## III. ភាពអាចទទួលយកបាន

២៣. បណ្តឹងឧទ្ធរណ៍ត្រូវបានដាក់អនុលោមតាមវិធាន ៦៧(៥) និង វិធាន ៧៥(២) នៃវិធានផ្ទៃក្នុង[60]។

២៤. សហមេធាវីមិនបានជំទាស់ទៅនឹងភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍នេះទេ លើកលែងតែមូលដ្ឋានទី៣ និង មូលដ្ឋានទី៤ប៉ុណ្ណោះ[61] ។ ពួកគាត់ជំទាស់ថា សំអាងហេតុដែលថា អ.វ.ត.ក ពុំមានយុត្តាធិការបុគ្គលនោះ រារាំងទាំងសហចៅក្រមស៊ើបអង្កេត និងទាំងអង្គបុរេជំនុំជម្រះ មិនឱ្យធ្វើសេចក្តីសន្និដ្ឋាន ឬពិនិត្យឡើងវិញលើសេចក្តីសន្និដ្ឋានណាមួយ ពាក់ព័ន្ធនឹងបទល្មើស ឬភវនីយភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អ៊ឹម ចែម[62]។ ពួកគាត់អះអាងបន្ថែមទៀតថា មូលដ្ឋានទី៣ និងមូលដ្ឋានទី៤ ជំទាស់ទៅនឹងប្រភេទជាក់លាក់នៃបទល្មើស ដូច្នេះហើយមិនស្ថិតក្នុងវិសាលភាពអំណាចក្នុងការពិនិត្យលើបណ្តឹងឧទ្ធរណ៍របស់អង្គបុរេជំនុំជម្រះទេ[63]។

---

[58] សំណុំរឿង ០០១ (អ.ប.ជ ០២) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ D99/3/42 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៃសំណុំរឿង ០០១ (D99/3/42)") កថាខណ្ឌ ៤០ ("អង្គជំនុំជម្រះសាលាដំបូងទទួលយកបណ្តឹង ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ឬ តាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ"។ នៅក្នុងសន្ទានុក្រមនៃវិធានផ្ទៃក្នុង ពាក្យថា "ដីកាបញ្ជូនរឿងទៅជំនុំជម្រះ" សំដៅលើ "ដីកាដំណោះស្រាយដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ឬ តាមសាលដីការបស់អង្គបុរេជំនុំជម្រះ បញ្ជូនជនត្រូវចោទទៅជំនុំជម្រះ")។

[59] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៃសំណុំរឿង ០០១ (D99/3/42) កថាខណ្ឌ ៤១-៤២ (លុបជើងទំព័រ)។

[60] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១។

[61] ចម្លើយតប កថាខណ្ឌ ១៦-២៣ ៧៥ និង ៩២។

[62] ចម្លើយតប កថាខណ្ឌ១៧-១៩ ៧៥ ៩២។ មើលផងដែរ ការឆ្លើយតប កថាខណ្ឌ ៤៥ និង៤៩។

[63] ចម្លើយតប កថាខណ្ឌ ២០-២៣, ៧៥-៩២ យោងទៅលើសំណុំរឿង ០០២ (PTC145&146), សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធារិទ្ធ ជំទាស់ទៅនឹងដីការដំណោះស្រាយថ្ងៃទី ១៥ ខែ កុម្ភះ ឆ្នាំ ២០១១, D427/2/15 &

01575450



២៥. អង្គបុរេជំនុំជម្រះសូមរម្លឹកថា អនុលោមតាមវិធាន ៦៧(៥) នៃវិធានផ្ទៃក្នុង "ដីកាដំណោះស្រាយនេះបើកផ្លូវប្តឹងឧទ្ធរណ៍ដូចមានចែងក្នុងវិធាន ៧៤"។ ជាងនេះទៀត អនុលោមតាមវិធាន ៧៤(២) នៃវិធានផ្ទៃក្នុង "សហព្រះរាជអាជ្ញាអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងគ្រប់ដីការបស់សហចៅក្រមស៊ើបអង្កេត"។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ និងសារណាលើបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ទៅតាមពេលវេលាដែលបានកំណត់នៅក្នុងវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុង និងទៅតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះ[64]។

២៦. ពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃមូលដ្ឋានទី៣ និងមូលដ្ឋានទី៤ នៃបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះបដិសេធការជំទាស់នានារបស់សហមេធាវី។ ការសម្រេចថាពុំមានយុត្តាធិការបុគ្គលនោះ មិនមែនមិនអាចពិនិត្យមើលឡើងវិញបាននោះឡើយ[65] ហើយអង្គបុរេជំនុំជម្រះ ដែលជាអង្គជំនុំជម្រះពិនិត្យមើលលើបណ្តឹងឧទ្ធរណ៍ ប្រាកដជាអាចពិនិត្យមើលលើសេចក្តីសន្និដ្ឋាននានាដែលនាំឱ្យមានការសម្រេចបែបនេះ រួមទាំងសេចក្តីសន្និដ្ឋានទាំងឡាយណាពាក់ព័ន្ធនឹងអត្ថិភាពនៃបទល្មើស ឬភវនីយភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ អ៊ឹម ចែម។ យុត្តិសាស្ត្រដែលសហមេធាវីបានយកមកធ្វើជាសំអាង ទាក់ទិននឹងវិសាលភាពអំណាចក្នុងការពិនិត្យមើលឡើងវិញរបស់អង្គបុរេជំនុំជម្រះ[66] ពាក់ព័ន្ធបន្ថែមទៀតទៅនឹងបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ចំណែកឯបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិនេះ អនុលោមតាមវិធាន ៧៤(២) នៃវិធានផ្ទៃក្នុង។ ដូច្នេះ ការជំទាស់នានារបស់សហមេធាវីមិនត្រឹមត្រូវឡើយ។

២៧. ហេតុនេះ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបាន។

---

D427/3/15 (សំណុំរឿង ០០២ បណ្តឹងឧទ្ធរណ៍នៃដីការដំណោះស្រាយ (នួន ជា និង អៀង ធារិទ្ធ)(D27/2/15 & D27/3/15), កថាខណ្ឌ ៦២ ដូចក្នុង ចម្លើយតប កថាខណ្ឌ ៤៤, ៥០ យោងទៅលើសំណុំរឿង ០០១ បណ្តឹងឧទ្ធរណ៍នៃដីកាដំណោះស្រាយ (D99/3/42) កថាខណ្ឌ ៥៩-៨១ និង ប្រតិចារឹកថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៧ (D308/3/1/19/1.2), ទំព័រ ៧១ ។

[64] ដីកាសម្រេចលើសំណើសុំដាក់បណ្តឹងឧទ្ធរណ៍ក្រោយការផ្តល់សំអាងហេតុពេញលេញ (D308/2)។

[65] ដូចយោងខាងលើ កថាខណ្ឌ ២០ ។

[66] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (ឯកសារ D427/2/15 & ឯកសារ D427/3/15) កថាខណ្ឌ ៥៩-៦២។

## IV. បញ្ហាបឋម

### ក. ការពន្យារពេលចេញដីកាដំណោះស្រាយ (សំអាងហេតុ)

២៨. អង្គបុរេជំនុំជម្រះរម្លឹកឡើងវិញថា អនុលោមតាមវិធាន ២១(៤) នៃវិធានផ្ទៃក្នុង កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ត្រូវបញ្ចប់ "ក្នុងរយៈពេលមួយសមស្រប"។ គោលការណ៍នេះមានចែងនៅក្នុងមាត្រា ៣៥*ថ្មី* នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងដែលជាចំណុចសំខាន់នៅក្នុងមាត្រា ១៤(៣)(គ) នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ទោះបីពុំមានពេលវេលាកំណត់ច្បាស់លាស់នៅក្នុងវិធានផ្ទៃក្នុងក៏ដោយ តែវាជាកាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេតដែលត្រូវចេញដីកាដំណោះស្រាយក្នុងពេលវេលាមួយសមស្រប។ ក្នុងនាមជាស្ថាប័នដែលត្រួតពិនិត្យនៅដំណាក់កាលស៊ើបអង្កេត អង្គបុរេជំនុំជម្រះយល់ថាជាការចាំបាច់ដែលត្រូវដោះស្រាយបញ្ហានេះ។

២៩. នៅក្នុងសំណុំរឿងនេះ សហចៅក្រមស៊ើបអង្កេតបានចេញសំអាងហេតុនៃដីកាដំណោះស្រាយនៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ ដោយបិទបញ្ចប់កិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម ក្នុងរយៈពេលដប់ប្រាំបីខែក្រោយពេលជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរនៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥[67]។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា តាំងពីដំបូងមក សំណុំរឿងនេះត្រូវបានបញ្ជូនទៅសហព្រះរាជអាជ្ញា ក្នុងគោលបំណងឱ្យសហព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានស្ថាពររបស់ខ្លួននៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦[68] *ពោលគឺ* ជាងប្រាំមួយខែ ក្រោយពេលមានការសម្រេចទៅលើសំណើសុំបំពេញកិច្ចស៊ើបសួរចុងក្រោយនៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៦ និងមិនមែនបញ្ជូនសំណុំរឿងនេះ "ជាបន្ទាន់" ដូចដែលតម្រូវដោយវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុងនោះទេ[69]។ ការសម្រេចសេចក្តីនេះឆ្លុះបញ្ចាំងពីមាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលចែងថា ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ "ពីរថ្ងៃ" ក្រោយជូនដំណឹងថា ការស៊ើបសួរបានបញ្ចប់។ ទោះបីអង្គបុរេជំនុំជម្រះដឹងថា ដីកាបំបែកកិច្ចដំណើរការនីតិវិធីដែលបានចេញនៅថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦[70] ព្រមទាំងការដាក់ជំនួសសហមេធាវីអន្តរជាតិ[71] អាចបណ្តាលឱ្យមានការ

---

[67] *សូមមើល* សេចក្តីជូនដំណឹងអនុលោមតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង (ឯកសារ D285)។

[68] *សូមមើល* ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ (ឯកសារ D304)។

[69] *សូមមើល* សំណុំរឿង ០០៤ ដីកាសម្រេចលើសំណើរបស់ អ៊ឹម ចែម សុំដាក់បង្ហាញសំណៅគ្មានការកោសលុបនៃប្រតិចារឹកសំណុំរឿង ០០២ និងឯកសារពាក់ព័ន្ធនឹងគាត់ និងលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិឆ្លើយតបទៅនឹងសេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៦ ឯកសារ D289។

[70] *សូមមើល* ដីកាសម្រេចបំបែកសំណុំរឿង (ឯកសារ D286/7)។

ពន្យារពេលខ្លះក៏ដោយ តែអង្គជំនុំជម្រះយល់ថា កាលៈទេសៈទាំងនេះមិនអាចធ្វើយុត្តិកម្មចំពោះការពន្យារពេលប្រាំមួយខែក្នុងការចេញដីកាបញ្ជូនសំណុំរឿងទៅពិនិត្យនោះទេ វាជាការរំលោភបំពានលើវិធាន ៦៦ (៤) នៃវិធានផ្ទៃក្នុង។

៣០. ជារួម អង្គបុរេជំនុំជម្រះយល់ឃើញថា ដំណើរការរៀបរៀងសេចក្តីព្រាងដីកាដំណោះស្រាយរយៈពេលដប់ប្រាំបីខែ (សំអាងហេតុ) ពុំសមហេតុផលទេ។ អង្គបុរេជំនុំជម្រះពិចារណាទៅលើភាពស្មុគស្មាញមានកម្រិតនៃសំណុំរឿង ដូចបានបង្ហាញឡើងតាមរយៈចំនួនបទចោទ[72] ការណ៍ដែលកិច្ចស៊ើបសួរត្រូវបានបញ្ចប់ក្នុងរយៈពេលប្រាំបួនខែកន្លះ ចាប់តាំងពីការជូនដំណឹងអំពីបទចោទ និងការបង្ហាញអំពីចេតនាលើកលែងបទចោទចាប់តាំងពីថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥[73] ព្រមទាំងអាយុ និងស្ថានភាពរបស់ជនត្រូវចោទ សាក្សី និង ជនរងគ្រោះ។ ផ្ទុយទៅវិញ អង្គបុរេជំនុំជម្រះគូសបញ្ជាក់ថា ដោយសារជនត្រូវចោទមិនត្រូវបានឃុំខ្លួន អនុលោមតាមវិធាន ៦៦(៥) នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាមានរយៈពេលបីខែក្នុងការចេញដីកាសន្និដ្ឋានស្ថាពរដែលមានសំអាងហេតុ ហើយ មេធាវីការពារក្តីមានរយៈពេលមួយខែក្នុងការឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរនោះ[74]។ ទោះបីការប្រៀបធៀបមានប្រយោជន៍តិចតួចក្នុងការវាយតម្លៃអំពីភាពសមហេតុផលនៃការពន្យារពេល ដោយផ្អែកលើភាពជាក់ស្តែងនៃរឿងក្តីនីមួយៗក៏ដោយ តែអង្គជំនុំជម្រះយល់ថា មានភាពពាក់ព័ន្ធដែលត្រូវកត់សម្គាល់ថា ដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០១ ត្រូវបាន

---

[71] *សូមមើល* សំណុំរឿង ០០៤/១ លិខិតពីក្រុមមេធាវីការពារក្តីអ្នកស្រី អ៊ឹម ចែម ផ្ញើជូនសហចៅក្រមស៊ើបអង្កេត ពាក់ព័ន្ធនឹងមរណភាពរបស់លោក John R.W.D. Jones QC ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦ និងបានដាក់នៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៦ ឯកសារ D302។ សំណុំរឿង ០០៤/១ លិខិតពីអង្គការគាំពារការការពារក្តីផ្ញើជូនសហចៅក្រមស៊ើបអង្កេត ពាក់ព័ន្ធនឹងការចាត់តាំងសហមេធាវីបរទេសការពារក្តីអ្នកស្រី អ៊ឹម ចែម ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៦ ឯកសារ D303។

[72] *សូមមើល* ការជូនដំណឹងអំពីបទចោទប្រកាន់ (D239.1)។ អ៊ឹម ចែម ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ឃាតកម្ម ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ពន្ធនាគារ ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងទៀត) និងការរំលោភបំពានលើមាត្រា ៥០១ និង មាត្រា ៥០៦ (អំពើមនុស្សឃាត) នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ នៅទីតាំងឧក្រិដ្ឋកម្មចំនួនពីរគឺ៖ មន្ទីរសន្តិសុខភ្នំត្រយោង និង ការដ្ឋានព្រែកស្ពានស្រែង។

[73] *សូមមើល* សេចក្តីជូនដំណឹងអំពីគោលបំណងលើកលែងការចោទប្រកាន់ និងបំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ D286)។

[74] *សូមមើល* សំណុំរឿង ០០៤/១ សេចក្តីជូនដំណឹងមេធាវីការពារក្តី អំពីកាលបរិច្ឆេទកំណត់ក្នុងការឆ្លើយតបទៅនឹងដីកាសន្និដ្ឋានតាមវិធាន ៦៦(៥) របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D304/4។

ចេញក្នុងរយៈពេលបីខែ ហើយដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២ ត្រូវបានចេញនៅក្នុងរយៈពេលប្រាំបីខែ ក្រោយពេលបញ្ចប់កិច្ចស៊ើបសួរ[75]។

៣១. ដោយពិចារណាទៅលើហេតុផលខាងលើនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ការពន្យារពេលដប់ប្រាំបីខែក្នុងការចេញដីកាដំណោះស្រាយ (សំអាងហេតុ) ក្រោយពេលបញ្ចប់កិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម ពុំសមាមាត្រទេ ហើយអង្គជំនុំជម្រះយល់ឃើញថា វាជាការពន្យារពេលមួយហួសហេតុមិនសមហេតុផល។

## ខ. លក្ខណៈនៃដីកាដំណោះស្រាយ (សំអាងហេតុ)

### ១. ការចេញដីកាដំណោះស្រាយជាដីកាពីរដាច់ពីគ្នា

៣២. វិធាន ៦៧(៤) នៃវិធានផ្ទៃក្នុងតម្រូវថា "ដីកាដំណោះស្រាយត្រូវតែមានសំអាងហេតុ"[76] ហើយថា "ភាគីមានសិទ្ធិជាមូលដ្ឋានដើម្បីបានទទួលដំណឹងអំពីហេតុផលនៃសេចក្ដីសម្រេចណាមួយ"[77] ។ នៅក្នុងសំណុំរឿងនេះ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ (សេចក្ដីសម្រេច) នៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧ និងបានចេញដីកាដំណោះស្រាយ (សំអាងហេតុ) នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ គឺរយៈពេលបួនខែកន្លះក្រោយមក ដែលមានសំអាងហេតុពេញលេញដើម្បីបញ្ជាក់អំពីសេចក្ដីសម្រេចរបស់

---

[75] *សូមមើល* សំណុំរឿង ០០១ សេចក្ដីជូនដំណឹងស្ដីពីការបញ្ចប់កិច្ចស៊ើបសួរ ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០៨ និង ត្រូវបានដាក់នៅថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០៨ ឯកសារ D108/48។ សំណុំរឿង ០០១ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៨ ឯកសារ D99 (សំណុំរឿង ០០១ ដីកាដំណោះស្រាយ (D99))។ សំណុំរឿង ០០២ សេចក្ដីជូនដំណឹងស្ដីពីការបញ្ចប់កិច្ចស៊ើបសួរ ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១០ ឯកសារ D317។ សំណុំរឿង ០០២ ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ និងត្រូវបានដាក់នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D427(សំណុំរឿង ០០២ ដីកាដំណោះស្រាយ (D427)) ។

[76] *សូមមើល* សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៃសំណុំរឿង ០០១ (ឯកសារ D99/3/42) កថាខណ្ឌ ៣៨ ("សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការច្រានចោលអំពើទាំងឡាយ ឬបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ត្រូវផ្ដល់សំអាងហេតុ ដូចមានចែងយ៉ាងច្បាស់នៅក្នុងវិធាន ៦៧(៤) នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះក៏រម្លឹកផងដែរថា វាគឺជាបទដ្ឋានអន្តរជាតិ ដែលសេចក្ដីសម្រេចរបស់តុលាការ ទាមទារឱ្យមានការផ្ដល់សំអាងហេតុ")។

[77] សំណុំរឿង ០០២ (អ.ប.ជ ៦៧) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្ដីពីសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿងដែលនឹងជួយដល់ការបញ្ជាក់អំពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ D365/2/10 កថាខណ្ឌ ២៤។



PRE-TRIAL E.C.C.C.

ខ្លួនក្នុងការប្រានចោលបទចោទប្រកាន់ទៅលើ អ៊ឹម ចែម។ អង្គបុរេជំនុំជម្រះយល់ឃើញថា អង្គជំនុំជម្រះមានកាតព្វកិច្ចក្នុងការពិនិត្យទៅលើបណ្តឹងឧទ្ធរណ៍ ដើម្បីសម្រេចថាតើ ការចេញដីកាដំណោះស្រាយជាដីកាពីរដាច់ពីគ្នា ស្របទៅនឹងវិធាន ៦៧(៥) នៃវិធានផ្ទៃក្នុង ឬយ៉ាងណា។

៣៣. ទោះបីក្នុងកាលៈទេសៈមួយចំនួន ការចេញសំអាងហេតុនៅពេលក្រោយមកទៀត អាចបំពេញទៅតាមកាតព្វកិច្ចក្នុងការចេញដីកាសម្រេចដែលមានសំអាងហេតុក៏ដោយ តែអង្គបុរេជំនុំជម្រះយល់ឃើញថា វិធីសាស្ត្រនេះមិនអាចអនុវត្តចំពោះដីកាដំណោះស្រាយបានទេ បើតាមលក្ខខណ្ឌតម្រូវជាក់ស្តែងដែលមានចែងនៅក្នុងវិធាន ៦៧(៥) នៃវិធានផ្ទៃក្នុង និង ភាពជាក់លាក់នៃកិច្ចនីតិវិធីនេះ ដែលបញ្ចប់កិច្ចស៊ើបសួរជាផ្លូវការរួចហើយ។ អង្គបុរេជំនុំជម្រះរម្លឹកឡើងវិញថា សហចៅក្រមស៊ើបអង្កេតត្រូវបំពេញតួនាទីរបស់ខ្លួន *(functus officio)* ជាបន្ទាន់ បន្ទាប់ពីបានចុះហត្ថលេខាលើផ្នែកសេចក្តីសម្រេចនៃដីកាដំណោះស្រាយរួច។

៣៤. លើសពីនេះទៀត នៅក្នុងសំណុំរឿងនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ផលប្រយោជន៍របស់ជនត្រូវចោទ និងជនរងគ្រោះ តាមវិធានផ្ទៃក្នុង ២១(១) និង (៤) មិនត្រូវបានការពារយ៉ាងល្អប្រសើរតាមរយៈការចេញដីកាពីរដាច់ដោយឡែកពីគ្នាទេ ទោះបីសហចៅក្រមស៊ើបអង្កេតយល់ថាជាការចាំបាច់ត្រូវអនុវត្តទៅតាមគោលការណ៍នៃកិច្ចដំណើរការនីតិវិធីឱ្យបានឆាប់រហ័ស និងគោរពសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានលទ្ធផលនៃកិច្ចដំណើរការនីតិវិធីដែលត្រូវសម្រេចឱ្យបានឆាប់តាមតែអាចធ្វើទៅបាន[78] ក៏ដោយ។ ផ្ទុយទៅវិញ ការចេញដីកាដំណោះស្រាយជាដីកាពីរដាច់ពីគ្នាបានបង្កឱ្យមានភាពច្របូកច្របល់ និង ភាពមិនច្បាស់លាស់ផ្នែកនីតិវិធី ជាពិសេសពាក់ព័ន្ធនឹងការពន្យារពេលកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ ដែលជាចុងក្រោយត្រូវបានអូសបន្លាយរហូតទាល់តែក្រោយពេលចេញដីកាដំណោះស្រាយ (សំអាងហេតុ) រួច[79]។ ជនត្រូវចោទ និងជនរងគ្រោះបានទទួលការជូនដំណឹងចាប់តាំងពីថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ ថា សហចៅក្រមស៊ើបអង្កេតមានបំណងលើកលែងបទចោទ ដោយសារកង្វះយុត្តាធិការបុគ្គល[80]។ អង្គបុរេជំនុំជម្រះក៏រម្លឹកផងដែរអំពីការសន្និដ្ឋានរបស់អង្គជំនុំជម្រះនាពេលកន្លងមកថា កិច្ចស៊ើបសួរមិនត្រូវបានបញ្ចប់ក្នុងរយៈពេលសមស្របទេ ហើយដោយសារមានសំអាងហេតុដូចគ្នានេះដែរ អង្គជំនុំជម្រះសម្រេចថា ការពន្យារពេលបួនខែកន្លះ ចន្លោះពីពេលចេញសេចក្តីសម្រេច និងពេលចេញ

[78] ដីកាដំណោះស្រាយ (សេចក្តីសម្រេច) កថាខណ្ឌ ១២-១៣។

[79] *សូមមើល* ដីកាសម្រេចលើសំណើសុំដាក់បណ្តឹងឧទ្ធរណ៍ក្រោយការផ្តល់សំអាងហេតុពេញលេញ (ឯកសារ D308/2)។

[80] *សូមមើល* សេចក្តីជូនដំណឹងអំពីគោលបំណងលើកលែងការចោទប្រកាន់ និងបំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ D286)។

សំអាងហេតុ រយៈពេលជាប់ប្រាំបីខែក្រោយពេលជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ ជាការមិនត្រឹមត្រូវទេ បើតាមវិធាន ២១(៤) នៃវិធានផ្ទៃក្នុង។

៣៥. ហេតុនេះ បន្ទាប់ពីពិនិត្យទៅលើបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះយល់ឃើញថា កិច្ចដំណើរការនីតិវិធី និងការកំណត់អំពីលទ្ធផលចុងក្រោយនៃកិច្ចដំណើរការនីតិវិធី ត្រូវបានអូសបន្លាយ ដោយសារការចេញដីកាដំណោះស្រាយដែលពុំមានសំអាងហេតុ (សេចក្តីសម្រេច) និងការចេញសំអាងហេតុជាក្រោយ។

## ២. ការបំបែកសំណុំរឿង និងលក្ខណៈរបស់ដីកាដំណោះស្រាយ

៣៦. ដោយហេតុថា សហចៅក្រមស៊ើបអង្កេតទទួលយកអង្គហេតុ (*in rem*) មកពិនិត្យ និងមិនទទួលយកបុគ្គល (*in personam*) មកពិនិត្យនោះ អង្គបុរេជំនុំជម្រះយល់ឃើញថា ជាការចាំបាច់ដែលត្រូវបញ្ជាក់បំភ្លឺអំពីផលប៉ះពាល់នៃ "ការបំបែកសំណុំរឿង អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤" ដែលបានប្រកាសនៅថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦[81] ដើម្បីកំណត់អំពីលក្ខណៈនៃដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៤/១ និងដើម្បីដោះស្រាយបញ្ហានានាដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍។

៣៧. អនុលោមតាមវិធាន ៥៣(១) នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាត្រូវបើកការស៊ើបសួរ "ដោយបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅសហចៅក្រមស៊ើបអង្កេតប្រឆាំងនឹងបុគ្គលមួយ ឬ ច្រើនរូប ឬប្រឆាំងនឹងអញ្ញាតជន"។ អនុលោមតាមវិធាន ៥៥(២) នៃវិធានផ្ទៃក្នុង "សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបសួរតែអង្គហេតុណា ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមប៉ុណ្ណោះ" [82] ។ ហេតុនេះ សហចៅក្រមស៊ើបអង្កេតមានចំណងកាតព្វកិច្ចចំពោះបញ្ហាដែលត្រូវយកមកសម្រេចនៅចំពោះមុខ តែក៏មានកាតព្វកិច្ចស៊ើបអង្កេតទៅលើអង្គហេតុទាំងអស់ដែលខ្លួនទទួលយកមកពិនិត្យដែរ[83] មានន័យថា សហចៅក្រមស៊ើបអង្កេតត្រូវសម្រេចទៅលើអង្គហេតុ

---

[81] ដីកាសម្រេចបំបែកសំណុំរឿង (ឯកសារ D286/7) កថាខណ្ឌ ៤, ៧។

[82] *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ១២៥។

[83] សំណុំរឿង ០០៣ (អ.ប.ជ ២០) សាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចលើពាក្យសុំរបស់ មាស មុត ស្នើឱ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និងចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D134/1/10 (សំណុំរឿង ០០៣ សេចក្តីសម្រេចថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ (D134/1/10)) មតិយោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BWANA កថាខណ្ឌ ១៣។

ទាំងអស់នេះ នៅពេលចេញដីកាដំណោះស្រាយ និងមិនត្រឹមតែទៅលើអង្គហេតុដែលត្រូវបានចោទប្រកាន់ជាផ្លូវការនោះទេ។

៣៨. អនុលោមតាមវិធាន ៥៥(៤) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតអាចចោទប្រកាន់បន្ថែម "ចំពោះបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា បុគ្គលនោះអាចជាអ្នកទទួលខុសត្រូវក្នុងការប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទោះបីជាបុគ្គលទាំងនោះមិនមានឈ្មោះក្នុងដីកាក៏ដោយ"។ និយាយម្យ៉ាងទៀត នៅក្នុងសំណុំរឿងដដែល ការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌដែលអាចត្រូវបានចោទប្រកាន់ចំពោះជនសង្ស័យដែលមានឈ្មោះ ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា និងចោទប្រកាន់ចំពោះអញ្ញាតជន ដែលអត្តសញ្ញាណរបស់ជននោះអាចត្រូវបានបញ្ចេញឱ្យដឹងតាមរយៈកិច្ចស៊ើបសួរដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត។ ប្រសិនបើមានការបំបែកសំណុំរឿងការចោទប្រកាន់លើអង្គហេតុដដែលនោះអាចត្រួតគ្នានៅក្នុងសំណុំរឿងដែលបានបង្កើតថ្មី ដោយហេតុថា វាពាក់ព័ន្ធទៅនឹង "បុគ្គលដែលត្រូវបានបំបែកចេញពីសំណុំរឿង" ទន្ទឹមនឹងនោះ វាក៏នៅមានសេសសល់នៅក្នុងសំណុំរឿងដើមដែរ ប្រសិនបើវាពាក់ព័ន្ធទៅនឹងជនសង្ស័យដែលមានឈ្មោះ ឬអញ្ញាតជនផ្សេងទៀតដែលអាចត្រូវបានកំណត់អត្តសញ្ញាណក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ។

៣៩. សរុបមក មានតែអង្គហេតុប៉ុណ្ណោះដែលអាចយកមកបំបែកបាន។ ការពិត អង្គបុរេជំនុំជម្រះសង្កេតឃើញថា នៅក្នុងករណីនៃការបំបែកសំណុំរឿងពាក់ព័ន្ធនឹង ឌុច សហចៅក្រមស៊ើបអង្កេតបានចេញដីកាបង្គាប់យ៉ាងត្រឹមត្រូវឱ្យ "បំបែកសំណុំរឿង ឌុច *ចំពោះអង្គហេតុប្រព្រឹត្តនៅក្នុងក្របខណ្ឌ ស ២១*" ចំណែក "*អង្គហេតុដទៃទៀតដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ* [...] ពាក់ព័ន្ធនឹង ឌុច ឬ ជនផ្សេងទៀតដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ"[84] ត្រូវស៊ើបសួរក្រោមលេខសំណុំរឿងផ្សេង។

៤០. ហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា តាមរយៈការបង្គាប់ឱ្យ "បំបែកសំណុំរឿង អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤"[85] សហចៅក្រមស៊ើបអង្កេតបានបំបែកដោយប្រយោលនូវការចោទប្រកាន់ពីបទព្រហ្មទណ្ឌទាំងអស់ប្រឆាំងនឹង អ៊ឹម ចែម ដើម្បីបង្កើតសំណុំរឿង ០០៤/១ មិនមែនជាការបំបែកបុគ្គលទេ។

[84] សំណុំរឿង ០០១ ដីកាបំបែកសំណុំរឿង ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ ឯកសារ D18 ទំព័រ ២ (គូសបញ្ជាក់បន្ថែម)។

[85] ដីកាសម្រេចបំបែកសំណុំរឿង (ឯកសារ D286/7) កថាខណ្ឌ ៧។

អង្គបុរេជំនុំជម្រះសូមលើកឡើងនូវផលវិបាកចំនួនបីដែលកើតចេញពីការសម្រេចបែបនេះ។ ទីមួយ រាល់ការចោទប្រកាន់ពីបទព្រហ្មទណ្ឌទាំងអស់ប្រឆាំងនឹង អ៊ឹម ចែម មានភាពត្រួតគ្នា និងប្រមូលផ្តុំនៅក្នុងសំណុំរឿង ០០៤/១ ដោយពុំមានការចោទប្រកាន់ណាមួយសេសសល់នៅក្នុងសំណុំរឿង ០០៤ ទេ។ ទីពីរ ដីកាសម្រេចដែលរងការជំទាស់ពិតជាបង្កើតនូវដីកាដំណោះស្រាយមួយតាមអត្ថន័យនៃអ.វ.ត.ក បើតាមអត្ថន័យនៃវិធាន ៦៧(៣)(ក) នៃវិធានផ្ទៃក្នុង ហើយមិនត្រឹមតែជាដីកាសម្រេចទៅលើកង្វះយុត្តាធិការប៉ុណ្ណោះទេ។ ទីបី រាល់ការចោទប្រកាន់ពីបទព្រហ្មទណ្ឌទាំងអស់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម រួមទាំងការចោទប្រកាន់នានាដែលត្រួតគ្នានៅក្នុងសំណុំរឿង ០០៤/១ ប្រឆាំងនឹង អ៊ឹម ចែម ក៏នៅមានសេសសល់ក្នុងសំណុំរឿង ០០៤ ដែរ ប្រឆាំងនឹងបុគ្គលដែលមានឈ្មោះ ឬ អញ្ញាតជនផ្សេងទៀត ហើយនឹងតម្រូវឲ្យសហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាស្តាពរមួយ នៅពេលចេញដីកាដំណោះស្រាយនៅក្នុងសំណុំរឿងក្រោយនេះ។

### គ. ការពិចារណាទៅលើភស្តុតាង

៤១. សហចៅក្រមស៊ើបអង្កេត បានទុកមួយជំពូកនៃដីកាដំណោះស្រាយ (សំអាងហេតុ) សម្រាប់ "ការពិចារណាទៅលើភស្តុតាង" ដោយពិភាក្សាអំពីភាពអាចជឿជាក់បាន និងតម្លៃជាភស្តុតាងនៃប្រភេទភស្តុតាងនានា[86] ដែលខុសពីដីកាដំណោះស្រាយកន្លងមក ក្នុងសំណុំរឿង ០០១ និងសំណុំរឿង ០០២ គឺមិនបានពិភាក្សាអំពីបញ្ហាបែបនេះទេ[87]។ ហេតុដូច្នេះសហចៅក្រមស៊ើបអង្កេត បានព្យាយាមពន្យល់អំពីវិធីសាស្ត្ររបស់ពួកគាត់ ដោយការបង្ហាញនូវគោលការណ៍នានា ដែលជាមូលដ្ឋានសម្រាប់សំអាងហេតុរបស់ពួកគាត់ ដោយមានគោលដៅគាំទ្រដល់ការយល់ឃើញផ្នែកអង្គហេតុនាពេលបន្ទាប់របស់ខ្លួន។

៤២. ប៉ុន្តែការពិចារណាបែបនេះ មិនមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក វិធានផ្ទៃក្នុង ឬក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឡើយ ហើយបើតាមទស្សនៈរបស់អង្គបុរេជំនុំជម្រះ ការពិចារណាបែបនេះប្រហែលជាមិនចាំបាច់ និងគ្មានប្រយោជន៍ឡើយ។ កាតព្វកិច្ចតែមួយរបស់សហចៅក្រមស៊ើបអង្កេតអនុលោមតាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង គឺចេញដីកាលើកលែងការចោទប្រកាន់ ប្រសិនបើ ក្នុងចំណោមអង្គហេតុផ្សេងៗទៀត "ពុំមានភស្តុតាងគ្រប់គ្រាន់ ដើម្បីផ្តន្ទាទោសជនត្រូវចោទ"។

---

[86] ដីកាដំណោះស្រាយ(សំអាងហេតុ) កថាខណ្ឌ ១០៣ ដល់១៣៩។

[87] សូមមើលសំណុំរឿង ០០១ ដីកាដំណោះស្រាយ (D99), សំណុំរឿង ០០២ ដីកាដំណោះស្រាយ (D427) សំណុំរឿង ០០២ ដីកាលើកលែងការចោទប្រកាន់ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១០ ឯកសារ D420។

៤៣. អង្គបុរេជំនុំជម្រះយល់ឃើញថាជាការចាំបាច់ដែលត្រូវពិនិត្យ (១) ថាតើសហចៅក្រមស៊ើបអង្កេតមានកំហុសឆ្គងដែរឬទេ ក្នុងការវាយតម្លៃទៅលើភាពអាចជឿជាក់បាន និងតម្លៃជាភស្តុតាងនៃភស្តុតាងទាំងនោះ និង (២) ថាតើសហចៅក្រមស៊ើបអង្កេត បានអនុវត្តបទដ្ឋាននៃភស្តុតាងត្រឹមត្រូវដែរឬទេ។

### ១. គោលការណ៍សេរីភាពនៃភស្តុតាង

៤៤. ការប្រមូលភស្តុតាងនៅចំពោះមុខ អ.វ.ត.ក ត្រូវបានកំណត់ដោយគោលការណ៍សេរីភាពនៃភស្តុតាង ដែលជាលក្ខណៈពិសេសនៃប្រព័ន្ធច្បាប់ស៊ីវិល។ និយាយម្យ៉ាងទៀត ភស្តុតាងទាំងអស់គឺអាចទទួលយកបាន[88] ដូចមានចែងក្នុងវិធាន ៨៧ នៃវិធានផ្ទៃក្នុង។ បន្ថែមលើនេះទៀត ភស្តុតាងទាំងអស់ ជាទូទៅគឺមានតម្លៃជាភស្តុតាងស្មើគ្នា[89]។ មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានឆ្លុះបញ្ចាំងពីគោលការណ៍នេះ ដោយកំណត់ថា "សហចៅក្រមស៊ើបអង្កេត អាចផ្អែកទៅលើមូលដ្ឋាននៃព័ត៌មាន *ដែលទទួលបានពីស្ថាប័ននានា*"[90]។ លើសពីនេះទៀត មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា បានចែងថា លើកលែងបទប្បញ្ញត្តិច្បាប់ផ្ទុយពីនេះ ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌ អាចជូនបានដោយសេរី។ តុលាការថ្លឹងថ្លែងដោយឥស្សរចិត្ត អំពីតម្លៃភស្តុតាងដែលគេដាក់ជូនមកខ្លួនពិនិត្យ ដោយផ្អែកទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន។ មាត្រា ៤២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង បានចែងដូចគ្នាថា បទល្មើសអាចត្រូវបានបង្ហាញភស្តុតាង តាមគ្រប់ទម្រង់នៃភស្តុតាង ហើយចៅក្រមត្រូវសម្រេចផ្អែកលើ ជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន។

៤៥. នៅក្នុងការពិចារណាទៅលើភស្តុតាង សហចៅក្រមស៊ើបអង្កេតបានពិភាក្សាជាបន្តបន្ទាប់ នូវភាពអាចទទួលយកបាន និងតម្លៃជាភស្តុតាងនៃ៖ ការធ្វើសម្ភាសន៍ដែលមិនមែនជាកំណត់ហេតុស្តាប់ចម្លើយដែលបង្កើតឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត [91] ភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម[92] របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះឆ្នាំ ១៩៩៧ និងឆ្នាំ ១៩៩៨ [93] និងការផ្តល់ចម្លើយជាសាធារណៈរបស់ អ៊ឹម ចែម[94]។

---

[88] Jean. PRADEL, *Procédure pénale*, 14th ed. ឆ្នាំ ២០០៨-ឆ្នាំ២០០៩, Cujas, ទំព័រ ៣៦៥។

[89] Frédéric. DEBOVE, François. FALLETTI និង Emmanuel. DUPIC, *Précis de droit pénal et de procédure pénale*, 5th ed. ឆ្នាំ២០១៣ Presses Universitaires de France ទំព័រ ៦៩៧។

[90] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា, មាត្រា ២៣ថ្មី (ការបញ្ជាក់បន្ថែម)។

[91] ដីកាដំណោះស្រាយ(សំអាងហេតុ) កថាខណ្ឌ ១០៣ ដល់ ១០៨។

[92] ដីកាដំណោះស្រាយ(សំអាងហេតុ) កថាខណ្ឌ ១០៩ ដល់ ១១២។

01575459



### ក. ភាពអាចទទួលយកបាននៃភស្តុតាង ដែលទទួលបានដោយការធ្វើទារុណកម្ម

៤៦. អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេត បន្ទាប់ពីបានរំឭកពីច្បាប់ជាធរមានស្តីពីភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម[95] "មិនពិចារណា" យ៉ាងជាក់ច្បាស់ ទៅលើភស្តុតាងរបស់សាក្សី ដែលផ្អែកទៅលើ ឬជាប់ទាក់ទងនឹងអង្គការលេខរបស់រដ្ឋបាលតំបន់៥ ដែលត្រូវបានបង្កើតឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយប្រើប្រាស់ឈ្មោះដែលយកចេញពីចម្លើយសារភាពរបស់មន្ទីរ ស-២១។ ដូចគ្នានេះដែរ សហចៅក្រមស៊ើបអង្កេត "មិនពិចារណា" ទៅលើផ្នែកនៃកំណត់ហេតុស្តាប់ចម្លើយ ឯកសារ D219/477 ដែលយោងទៅរកចម្លើយសារភាពរបស់មន្ទីរ ស-២១[96]។

៤៧. អង្គបុរេជំនុំជម្រះសូមរំឭកថា ប្រសិនបើភស្តុតាងណាមួយ ត្រូវបានចាត់ទុកថាមានកំហុសឆ្គងផ្នែកនីតិវិធី និងរំលោភបំពានទៅលើសិទ្ធិរបស់ភាគី សហចៅក្រមស៊ើបអង្កេតមិនអាចមិនពិចារណាទៅលើភស្តុតាងនោះ ដោយមិនបញ្ជូនមកអង្គបុរេជំនុំជម្រះ ដើម្បីស្នើសុំធ្វើមោឃភាព ផ្អែកតាមវិធាន ៧៦(១) នៃវិធានផ្ទៃក្នុងឡើយ [97] ។ ដើម្បីផលប្រយោជន៍នៃដំណើរការល្អនៃការស្វែងរកយុត្តិធម៌ សហចៅក្រមស៊ើបអង្កេតត្រូវតែប្តឹងមកអង្គបុរេជំនុំជម្រះ មុនពេលចេញដីកាដំណោះស្រាយ(សំអាងហេតុ) អំពីសំណើសុំមោឃភាពដោយមានសំអាងហេតុ ទៅលើភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម ដែលមាននៅក្នុងសំណុំរឿង ហើយដែលសហចៅក្រមស៊ើបអង្កេតពិចារណាថា ត្រូវទុកជាមោឃៈ ហើយមានចេតនាមិនពិចារណា។

---

[93] ដីកាដំណោះស្រាយ(សំអាងហេតុ) កថាខណ្ឌ ១១៣ ដល់ ១៣៥។

[94] ដីកាដំណោះស្រាយ(សំអាងហេតុ) កថាខណ្ឌ ១៣៦ ដល់ ១៣៩។

[95] ដីកាដំណោះស្រាយ(សំអាងហេតុ) កថាខណ្ឌ ១០៩ ដល់ ១១១។

[96] ដីកាដំណោះស្រាយ(សំអាងហេតុ) កថាខណ្ឌ ១១២។

[97] តាមពិតទៅអង្គបុរេជំនុំជម្រះ នៅក្នុងសំណុំរឿង ០០៤ បានទទួលសំណើសុំធ្វើមោឃភាព ផ្នែកដែលរងការជំទាស់ នៃកំណត់ហេតុស្តាប់ចម្លើយសាក្សី ឯកសារ D219/477 ដែលមិនត្រូវបានពិចារណានៅក្នុងដីកាដំណោះស្រាយ(សំអាងហេតុ)។ សូមមើល សំណុំរឿង ០០៤ (អបជ ៥៣) ឧបសម្ព័ន្ធ ខ នៃសំណើរបស់ យឹម ទិត្យ សុំមោឃភាពភស្តុតាង ដែលទទួលបានដោយការធ្វើទារុណកម្ម ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៨ ឯកសារ D372/1/3.3 ទំព័រ ៥។

01575460



## ខ. តម្លៃជាភស្តុតាង នៃរបាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះឆ្នាំ ១៩៩៧ និងឆ្នាំ ១៩៩៨

៤៨. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេត បានពិនិត្យទៅលើខ្លឹមសារនៃ របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះឆ្នាំ ១៩៩៧ និងឆ្នាំ ១៩៩៨ ដោយពិភាក្សាអំពីវិធីសាស្ត្រ និងភាពមិនស៊ីសង្វាក់គ្នានៃរបាយការណ៍ទាំងនេះ ហើយបានប្រៀបធៀបព័ត៌មានដែលបានលើកឡើង នៅក្នុងរបាយការណ៍ទាំងនេះ ជាមួយប្រភពដែលមានស្រាប់ដទៃទៀត។ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានជាក់លាក់ទៅលើព័ត៌មានដែលមាននៅក្នុងរបាយការណ៍ទាំងនេះ ទាក់ទងនិងចំនួនជនរងគ្រោះ ហើយបានធ្វើសេចក្តីសន្និដ្ឋានជាចុងក្រោយថា របាយការណ៍នេះមិនអាចជឿជាក់បាន និងមានតម្លៃជាភស្តុតាងតិចតួច [98]។ អង្គបុរេជំនុំជម្រះសូមសង្កត់ធ្ងន់ថា របាយការណ៍ទាំងនេះនៅមានក្នុងសំណុំរឿង ហើយអាចយកមកធ្វើការពិចារណា នៅពេលវាយតម្លៃទៅលើចំនួនជនរងគ្រោះ និងបញ្ហាដទៃទៀត ទោះបីជាមានការសន្និដ្ឋានពីសហចៅក្រមស៊ើបអង្កេតអំពីតម្លៃជាភស្តុតាងដ៏តិចតួចរបស់របាយការណ៍ទាំងនេះក៏ដោយ។

## គ. តម្លៃជាភស្តុតាងនៃការធ្វើសម្ភាសន៍ដែលមិនមែនជាកំណត់ហេតុស្តាប់ចម្លើយ

៤៩. សហចៅក្រមស៊ើបអង្កេតបានសម្រេចថា កំណត់ហេតុស្តាប់ចម្លើយ ដែលបង្កើតឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត នៅក្នុងអំឡុងពេលស៊ើបអង្កេត "ត្រូវបានរៀបចំក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងជាកម្មវត្ថុនៃការការពារជាក់លាក់ផ្នែកច្បាប់ និងនីតិវិធី ដូច្នេះហើយត្រូវទទួលបាននូវសច្ចធារណ៍នៃភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន" [99]។ តែផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតបានសម្រេចថា "សេចក្តីថ្លែងការណ៍ ឬភស្តុតាងដទៃទៀត ដែលត្រូវបានប្រមូលដោយមិនមានការត្រួតពិនិត្យមើលតាមផ្លូវតុលាការ ដោយស្ថាប័នណាមួយដែលមិនស្ថិតក្នុង អ.វ.ត.ក នោះ មិនត្រូវទទួលបាននូវសច្ចធារណ៍បែបនេះឡើយ" [100]។ សហចៅក្រមស៊ើបអង្កេតបដិសេធមិនអនុវត្តនូវសច្ចធារណ៍នៃភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាននៃភស្តុតាង ចំពោះ "ការស្តាប់ចម្លើយដែលធ្វើឡើងដោយ សហព្រះរាជអាជ្ញាក្នុងអំឡុងពេលស៊ើបអង្កេតបឋមរបស់ពួកគេ" [101] ព្រមទាំងចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋ

[98] ដីកាដំណោះស្រាយ(សំអាងហេតុ) កថាខណ្ឌ ១៣១ ដល់ ១៣៥។

[99] ដីកាដំណោះស្រាយ(សំអាងហេតុ) កថាខណ្ឌ ១០៣។

[100] ដីកាដំណោះស្រាយ(សំអាងហេតុ) កថាខណ្ឌ ១០៤។

[101] ដីកាដំណោះស្រាយ(សំអាងហេតុ) កថាខណ្ឌ ១០៥។

ប្បវេណី ដែលតាមទស្សនៈរបស់សហចៅក្រមស៊ើបអង្កេត "ពុំអាចទទួលបាននូវសច្ចធារណ៍នៃភាពអាចជឿជាក់បាន ហើយត្រូវទទួលបាននូវតម្លៃជាភស្តុតាងទាបប៉ុណ្ណោះ ប្រសិនបើកាលៈទេសៈនៃការកត់ត្រាពាក្យសុំតាំងខ្លួននោះ មិនមានភាពច្បាស់លាស់"[102]។

៥០. អង្គបុរេជំនុំជម្រះសូមរំឭកថា សំណុំរឿងទាំងមូលត្រូវស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរបស់សហចៅក្រមស៊ើបអង្កេត គឺមិនមែនត្រឹមតែភស្តុតាងដែលការិយាល័យសហចៅក្រមស៊ើបអង្កេតបានបង្កើតឡើងនោះឡើយ[103]។

៥១. បន្ថែមលើនេះទៀត អង្គបុរេជំនុំជម្រះសូមរំឭកថា សហចៅក្រមស៊ើបអង្កេត ធ្វើការវាយតម្លៃដោយសេរីទៅលើតម្លៃជាភស្តុតាងនៃភស្តុតាងដែលប្រមូលបានក្នុងពេលធ្វើការស៊ើបអង្កេត[104] ហើយច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក មិនបានបញ្ញត្តិអំពីវិធាននានា ពាក់ព័ន្ធនឹងការវាយតម្លៃទៅលើភាពគ្រប់គ្រាន់នៃភស្តុតាងសម្រាប់ការចោទប្រកាន់នោះឡើយ។ តាមពិតទៅគឺមិនមានមូលដ្ឋានសម្រាប់ការញែកចេញពីគ្នានូវចម្លើយនានា ដោយផ្អែកទៅលើប្រភពនៃចម្លើយនោះឡើយ។ ភស្តុតាងទាំងអស់សុទ្ធតែអាចទទួលយកបាន ហើយជាទូទៅទទួលបាននូវសច្ចធារណ៍នៃភាពអាចជឿជាក់បាន តាមផ្លូវច្បាប់ដូចៗគ្នា ប្រសិនបើភស្តុតាងទាំងនោះត្រូវបានប្រមូលមកដោយស្របច្បាប់។

៥២. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា នៅក្នុងប្រពន្ធ័ដែកស្សរដេញដោល ដែលផ្អែកលើភស្តុតាងជាលាយលក្ខណ៍អក្សរ គឺជាកំហុសអង្គច្បាប់ ដែលធ្វើការអះអាងជាទូទៅអំពីតម្លៃជាភស្តុតាងនៃប្រភេទភស្តុតាងជាក់លាក់មួយចំនួន ដែលនាំឱ្យមានការបង្កើតនូវឋានានុក្រមនៃភស្តុតាងផ្អែកលើលក្ខណៈនៃភស្តុតាង ដោយមិនផ្អែកលើខ្លឹមសារនៃភស្តុតាង ហើយជាលទ្ធផល ផ្តល់នូវទម្ងន់តិចជាង ចំពោះភស្តុតាងដែលប្រមូលបានដោយស្ថាប័នដទៃ ដោយសារតែមូលហេតុផ្លូវការប៉ុណ្ណោះ។ លក្ខណៈវិនិច្ឆ័យពាក់ព័ន្ធតែមួយគត់ គួរតែជាឥទ្ធិពលដែលខ្លឹមសារនៃភស្តុតាងនោះអាចមានទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងបញ្ហាថាតើមានភស្តុតាងគ្រប់គ្រាន់ឬអត់ សម្រាប់ការចោទប្រកាន់នោះ។

---

[102] ដីកាដំណោះស្រាយ(សំអាងហេតុ) កថាខណ្ឌ ១០៧។

[103] សូមមើលជាឧទាហរណ៍ វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង។ មាត្រា ១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា ១២៧។

[104] សូមមើលខាងលើ កថាខណ្ឌ ៤៤ ។

៥៣. អង្គបុរេជំនុំជម្រះក៏ពិចារណាផងដែរថា ទោះបីជាតម្លៃជាភស្តុតាងនៃសម្ភារៈជាក់លាក់ណាមួយ ដែលពេលនៅដាច់តែឯង អាចមានតម្លៃតិចតួចក្តី ប៉ុន្តែការពិតដែលថាសម្ភារៈនោះមានភាពពាក់ព័ន្ធខ្លះ គឺមានន័យថាសម្ភារៈទាំងនោះ ចាំបាច់ត្រូវតែយកមកពិចារណា[105]។

៥៤. អង្គបុរេជំនុំជម្រះយល់ឃើញថាជាបញ្ហាយ៉ាងជាក់លាក់ ក្នុងការច្រានចោលជាមុនជាទូទៅនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនឱ្យទទួលបាននូវសច្ចធារណ៍នៃភាពអាចជឿជាក់បាន ហើយត្រូវទទួលបាននូវ "តម្លៃជាភស្តុតាងទាបប៉ុណ្ណោះ" ដោយផ្អែកទៅលើកាលៈទេសៈនៃការកត់ត្រាពាក្យសុំតាំងខ្លួននោះ[106]។ អ.វ.ត.ក គឺជាតុលាការដំបូងគេ ដែលធ្វើការជំនុំជម្រះឧក្រិដ្ឋកម្មអន្តរជាតិជារួម ដែលផ្តល់នូវឱកាសឱ្យជនរងគ្រោះបានចូលរួមដោយផ្ទាល់នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី[107]។ អនុលោមតាមវិធាន ២៣ ស្ទួន នៃវិធានផ្ទៃក្នុង ដើម្បីឱ្យបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន អ្នកដាក់ពាក្យសុំត្រូវតែ "បង្ហាញជាលទ្ធផលដោយផ្ទាល់ ពីបទឧក្រិដ្ឋយ៉ាងហោចណាស់មួយ នៃបទឧក្រិដ្ឋជាច្រើន ដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ ថាខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬផ្លូវចិត្ត ដែលអាចជាមូលដ្ឋានសម្រាការទាមទារសំណងផ្លូវចិត្ត និងសមូហភាព"។ ហេតុដូច្នេះ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានដាក់ក្នុងគោលដៅដើម្បីជួយរួមចំណែកដល់ការស៊ើបអង្កេតតាមផ្លូវតុលាការនោះ ចាំបាច់ត្រូវតែទទួលបាននូវការពិចារណាយ៉ាងពេញលេញ ដោយសហចៅក្រមស៊ើបអង្កេត។

៥៥. ហេតុដូច្នេះ ប្រសិនបើសហចៅក្រមស៊ើបអង្កេត បដិសេធ*ជាបឋម*នូវសច្ចធារណ៍នៃភាពអាចជឿជាក់បានសម្រាប់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយផ្តល់នូវតម្លៃជាភស្តុតាងទាបជាងភស្តុតាងដទៃទៀតដែលប្រមូលបានដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ពេលនោះសហចៅក្រមស៊ើបអង្កេត អាចខ្លួនឯងផ្ទាល់ ឬតាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស នឹងជាប់កាតព្វកិច្ចត្រូវស្តាប់ចម្លើយអ្នក

[105] សូមមើលជាឧទាហរណ៍ តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន *Special Court for Sierra Leona ("SCSL") រដ្ឋអាជ្ញា តទល់នឹង Norman, Fofana និង Kondewa* SCSL-04-14-AR65, Fofana – បណ្តឹងសាទុក្ខប្រឆាំងដីកាសម្រេចបដិសេធមិនឱ្យនៅក្រៅឃុំ, អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី១១ ខែមីនា ឆ្នាំ ២០០៥ កថាខណ្ឌ ២៣។ សូមមើលផងដែរ តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន *រដ្ឋអាជ្ញា តទល់នឹង Sesay, Kallon និង Gbao*, សេចក្តីសម្រេចលើសំណើរបស់ Gbao សុំដកចេញនូវភស្តុតាងដាក់បន្ទុករបស់សាក្សីលោក Koker អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៥ កថាខណ្ឌ ៩។

[106] ដីកាដំណោះស្រាយ(សំអាងហេតុ) កថាខណ្ឌ ១០៧។

[107] សូមមើលជាឧទាហរណ៍ វិធាន ២៣ នៃវិធានផ្ទៃក្នុង។

ដាក់ពាក្យសុំទាំងអស់ ក្នុងនាមជាសាក្សី ដោយពិចារណាថាពួកគាត់មាននូវព័ត៌មានដែលនាំទៅដល់ការស្វែងរកការពិត។ តាមពិតទៅ ជនរងគ្រោះ និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មាននូវព័ត៌មានផ្ទាល់ អំពីអង្គហេតុពាក់ព័ន្ធ ហើយភាពអាចជឿជាក់បាននៃភស្តុតាងរបស់ពួកគេ គួរត្រូវបានវាយតម្លៃទៅតាមករណីនីមួយៗ។ ការពិតដែលថាពួកគាត់មានផលប្រយោជន៍ផ្ទាល់ខ្លួន នៅក្នុងលទ្ធផលនៃសំណុំរឿងនោះ មិនគួរបណ្តាលឲ្យមានសច្ចធារណ៍ជាស្វ័យប្រវត្តិថា ភស្តុតាងរបស់ពួកគាត់ មិនសូវគួរឲ្យជឿជាក់នោះឡើយ[108]។

៥៦. និយាយម្យ៉ាងទៀត ការកំណត់ថានានុក្រមមិនត្រឹមត្រូវទៅលើភស្តុតាង ដែលកំណត់ឡើងដោយសហចៅក្រមស៊ើបអង្កេត ដោយបានបដិសេធនូវសច្ចធារណ៍នៃភាពអាចជឿជាក់បាន និងផ្តល់នូវតម្លៃជាភស្តុតាងទាបជាទូទៅ ទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចជាការបង្ហាញនូវកំហុសឆ្គងធ្ងន់ធ្ងរក្នុងការបំពេញកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង។ បន្ថែមលើនេះទៀត ការកំណត់ថានានុក្រមនេះ នឹងមានផលវិបាកដល់ការកម្រិតទៅលើប្រសិទ្ធិភាពនៃសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមក្នុងតុលាការ យោងតាមអត្ថន័យនៃមាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក វិធាន ២១ នៃវិធានផ្ទៃក្នុង និងសេចក្តីសម្រេចរបស់មហាសន្និបាត អំពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះ[109] បើទោះបីជា អ.វ.ត.ក ស្ថិតក្នុងចំណោមតុលាការដែលមានលក្ខណៈជាតុលាការអន្តរជាតិដំបូងៗ ដែលបានផ្តល់ដល់ជនរងគ្រោះ នូវតួនាទីមួយនៅក្នុងកិច្ចដំណើរការនីតិវិធីក្តី។

## ឃ. __តម្លៃជាភស្តុតាងនៃចម្លើយជាសាធារណៈរបស់ អ៊ឹម ចែម__

៥៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេត បានធ្វើការពិចារណាទៅលើចម្លើយដែល អ៊ឹម ចែម បានផ្តល់ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា អង្គការយុវសន្តិភាព និងផលិតកម្មស្នាយលីងចូ

108 សូមមើល Goran. SLUITER និងអ្នកដទៃទៀត, នីតិវិធីព្រហ្មទណ្ឌអន្តរជាតិ។ វិធាន និងគោលការណ៍ Oxford University Press ឆ្នាំ ២០១៣ ទំព័រ ១៣៥៣ ដល់ ១៣៥៤។

109 សូមមើលមហាសន្និបាតអង្គការសហប្រជាជាតិ *សេចក្តីប្រកាសស្តីពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយសារឧក្រិដ្ឋកម្មនិងការរំលោភបំពានអំណាច* ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៨៥ A/RES/40/34 *នៅក្នុងឧបសម្ព័ន្ធពិសេស* កថាខណ្ឌ ៤ ដល់ ៥។ សូមមើលផងដែរ មហាសន្និបាតអង្គការសហប្រជាជាតិ *សេចក្តីណែនាំនិងគោលការណ៍មូលដ្ឋាន ស្តីពីសិទ្ធិទទួលបានឧបាស្រ័យនិងសំណង សម្រាប់ជនរងគ្រោះ ដោយការរំលោភបំពានធ្ងន់ធ្ងរទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ* ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៥, A/RES/60/147, មហាសន្និបាតអង្គការសហប្រជាជាតិ កថាខណ្ឌ ១២ ដល់១៤។



PRE-TRIAL E.C.C.C

ត[110] ប៉ុន្តែបាន "ផ្តល់ទម្ងន់តិចតួចជាងការស្តាប់ចម្លើយ ដែលបានធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត" យោងតាម "វិធីសាស្ត្រដែលបានអនុវត្តនៅក្នុងសំណុំរឿង ០០២ និងវិធានទូទៅនៃការវាយតម្លៃលើភស្តុតាង"[111]។

៥៨. យោងតាមសំអាងហេតុដូចបានលើកឡើងខាងលើ អង្គបុរេជំនុំជម្រះបញ្ជាក់ឡើងវិញថា វាជាការមិនត្រឹមត្រូវឡើយក្នុងការវាយតម្លៃទៅលើតម្លៃជាភស្តុតាងនៃភស្តុតាងទាំងនោះ ដោយផ្អែកទៅលើប្រភពរបស់ភស្តុតាង ដោយមិនផ្អែកទៅលើតម្លៃខាងក្នុងរបស់ភស្តុតាង និងការកំណត់ឋានានុក្រមជាទូទៅសម្រាប់ភស្តុតាង។

៥៩. អង្គបុរេជំនុំជម្រះយល់ឃើញទៀតថា ប្រសិនបើសហចៅក្រមស៊ើបអង្កេតយល់ឃើញថា ចម្លើយរបស់ជនសង្ស័យ ដែលបានផ្តល់ទៅឱ្យស្ថាប័នដទៃទៀត មិនមានលក្ខណៈគ្រប់គ្រាន់ សម្រាប់ការស្វែងរកការពិត ដោយសារតែប្រភពនៃចម្លើយនោះ សហចៅក្រមស៊ើបអង្កេតចាំបាច់ គួរតែអញ្ជើញជនសង្ស័យមកផ្តល់ចម្លើយឱ្យការិយាល័យរបស់ខ្លួន បន្ទាប់ពីសហមេធាវីរបស់ជនសង្ស័យ ទទួលបានសិទ្ធិចូលពិនិត្យមើលសំណុំរឿង។ អង្គបុរេជំនុំជម្រះមិនឃើញមានការចង្អុលបញ្ជាក់ណាមួយ ថាមានករណីបែបនេះឡើយ។

### ២. បទដ្ឋាននៃភស្តុតាង

៦០. អង្គបុរេជំនុំជម្រះសង្កេតឃើញថា ទោះបីជាសហចៅក្រមស៊ើបអង្កេត បានរំឭកអំពីភវនីយភាពបទដ្ឋាននៃភស្តុតាង[112] នៅក្នុងជំពូកស្តីពីការពិចារណាទៅលើភស្តុតាងក្តី តាមពិតទៅ សហចៅក្រមស៊ើប

---

[110] អង្គបុរេជំនុំជម្រះកត់សម្គាល់ថា នៅក្នុងជំពូកស្តីពីការពិចារណាទៅលើភស្តុតាង សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា មានតែសេចក្តីថ្លែងការណ៍ចំនួនពីរប៉ុណ្ណោះក្នុងចំណោមសេចក្តីថ្លែងការណ៍ទាំងបីដែល អ៊ឹម ចែម បានផ្តល់ជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានយកមកពិចារណានៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ)។ សូមមើល ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៣៩ និងជើងទំព័រ ២៥១ ដែលយោងទៅរក សំណុំរឿង ០០៤/០១ បទសម្ភាសន៍ជាមួយ អ៊ឹម ចែម ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា , បទសម្ភាសន៍ជាមួយ អ៊ឹម ចែម ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ ឯកសារ D123/1/5.1a។ សំណុំរឿង ០០៤/០១, បទសម្ភាសន៍ជាមួយ អ៊ឹម ចែម ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៧, ឯកសារ D123/1/5.1c។ ប៉ុន្តែចំពោះសេចក្តីថ្លែងការណ៍ទីបីដែល អ៊ឹម ចែម បានផ្តល់ជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានយោងនៅកន្លែងផ្សេង នៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) ដូច្នេះហើយសេចក្តីថ្លែងនេះ ត្រូវបានលើកយកមកធ្វើការពិចារណាផងដែរ។ សូមមើល ដីកាដំណោះស្រាយ(សំអាងហេតុ) ជើងទំព័រ ៣០០ និង ៣០៦ យោងទៅរកសំណុំរឿង ០០៤០១/, បទសម្ភាសន៍ជាមួយ អ៊ឹម ចែមដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ ឯកសារ D123/1/5.1b។

[111] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៣៩។

អង្កេតបានពឹងផ្អែកទៅលើយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល ដើម្បីកំណត់គោលការណ៍សម្រាប់វាយតម្លៃទៅលើភស្តុតាង[113]។

៦១. អង្គបុរេជំនុំជម្រះពិចារណាថា នៅត្រង់ចំណុចនេះ ជាការចាំបាច់ដែលត្រូវរំឮកថា បទដ្ឋានដែលអនុវត្តនៅដំណាក់កាលជំនុំជម្រះ គឺមានលក្ខណៈខ្ពស់ជាងបទដ្ឋានដែលគួរត្រូវបានអនុវត្ត នៅដំណាក់ស៊ើបអង្កេតតាមផ្លូវតុលាការ។ អនុលោមតាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង លក្ខខណ្ឌវិនិច្ឆ័យសម្រាប់ការចេញដីកាដំណោះស្រាយ គឺអត្ថិភាពនៃ ""ភស្តុតាងគ្រប់គ្រាន់ ដើម្បីផ្តន្ទាទោសជនត្រូវចោទ"។ នៅក្នុងដីកាដំណោះស្រាយសំណុំរឿង ០០២ សហចៅក្រមស៊ើបអង្កេតបានសម្រេចទៅលើអ្វី ដែលពួកគាត់បានពិចារណាថាជាបទចោទគ្រប់គ្រាន់៖

> នៅក្នុងដំណាក់កាលស៊ើបសួរមុនអង្គសេចក្តីនេះ មិនមានការតម្រូវឱ្យបង្ហាញអំពីពិរុទ្ធភាព របស់ជនត្រូវចោទនោះទេ (អង្គជំនុំជម្រះសាលាដំបូង គឺជាស្ថាប័នតែមួយគត់ ដែលមានសមត្ថកិច្ចក្នុងការធ្វើដូច្នេះ) ប៉ុន្តែចាំបាច់ត្រូវមានការបង្ហាញអំពី "ភវនីយភាព" នៃពិរុទ្ធភាព (មានន័យថា ស្ថានភាពដែលលើសពីលទ្ធភាពដែលអាចកើតមានធម្មតា)។ ហេតុដូច្នេះការវាយតម្លៃអំពីភស្តុតាងដាក់បន្ទុក នៅក្នុងដំណាក់កាលនេះ មានលក្ខណៈខុសពីសញ្ញាណនៃ "ជំនឿស៊ប់" របស់ចៅក្រមនៅក្នុងដំណាក់កាលជំនុំជម្រះ ប៉ុន្តែភស្តុតាងនៅក្នុងសំណុំរឿង ត្រូវមានលក្ខណៈខ្លាំងក្លា និងស៊ីសង្វាក់គ្រប់គ្រាន់ ដើម្បីឱ្យមានតម្លៃជាភស្តុតាងបន្ទាល់[114]។

៦២. ទោះបីជាសញ្ញាណនៃ "បទចោទគ្រប់គ្រាន់" ដែលសហចៅក្រមស៊ើបអង្កេត ចាំបាច់ត្រូវតែពិចារណា ក្នុងការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់ គឺមានភាពលំបាកក្នុងការធ្វើសនិទានកម្មក្តី ប៉ុន្តែច្បាស់ណាស់ថា លក្ខខណ្ឌតម្រូវផ្លូវច្បាប់ សម្រាប់កិច្ចដំណើការនីតិវិធីតាមផ្លូវតុលាការ វិវឌ្ឍន៍ជាបន្តបន្ទាប់ចាប់ពីត្រឹមលទ្ធភាព ឈានទៅដល់ "ភវនីយភាព" ឬ "ភាពអាចជឿជាក់បាន" នៃពិរុទ្ធភាពនៅក្នុងពេលស៊ើបអង្កេត ដើម្បីបង្ហាញភស្តុតាងនៃពិរុទ្ធភាពបែបនេះឱ្យហួសពីវិមតិសង្ស័យ នៅដំណាក់កាលជំនុំជម្រះ [115] ។ លើសពីនេះទៅទៀត អង្គបុរេជំនុំជម្រះពិចារណាថា "បទចោទគ្រប់គ្រាន់" ឆ្លើយតប*ជាអប្បបរមា* ចំពោះវិធាន ៥៥(៤) នៃវិធានផ្ទៃក្នុង "មានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់"

---

[112] សូមមើល ដីកាដំណោះស្រាយ(សំអាងហេតុ) កថាខណ្ឌ ២។

[113] សូមមើលជាឧទាហរណ៍ ដីកាដំណោះស្រាយ(សំអាងហេតុ) ជើងទំព័រ ១៧៩ ដល់ ១៨៩, ២៤៩ ដល់ ២៥០។

[114] សំណុំរឿង ០០២ ដីកាដំណោះស្រាយ ឯកសារ D427 កថាខណ្ឌ ១៣២៣ (ដោយលប់ចេញនូវជើងទំព័រ)។

[115] សូមមើល Christian. GUÉRY, "Les paliers de la vraisemblance pendant l'instruction préparatoire", *La Semaine Juridique,* Ed. No. 24 ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៨។

ដែលចង្អុលបញ្ជាក់ថា បុគ្គលម្នាក់អាចត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មមួយ ដូច្នេះ ហើយត្រូវសហចៅក្រមស៊ើបអង្កេតបញ្ជូនទៅជំនុំជម្រះ។

៦៣. ចៅក្រមនៃអង្គបុរេជំនុំជម្រះនឹងពិនិត្យទៅតាមមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នីមួយៗ ក្នុងករណីដែលពាក់ព័ន្ធ និងតាមករណីនីមួយៗ ថាតើសហចៅក្រមស៊ើបអង្កេត បានអនុវត្តបទដ្ឋាននៃភស្តុតាងត្រឹមត្រូវដែរឬទេ។

## ឃ. ដំណើររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា

៦៤. សហចៅក្រមស៊ើបអង្កេតបានសម្រេច នៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) ថា ច្បាប់ អ.វ.ត.ក. ទៅលើយុត្តាធិការលើរូបបុគ្គល មានអានុភាពមិនរាប់បញ្ចូល "យុត្តាធិការបុគ្គល ឬយុត្តាធិការបទល្មើស របស់តុលាការកម្ពុជាធម្មតាទៅលើព្រឹត្តិការណ៍នានា *ដែលស្ថិតក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក* ឡើយ"[116] ឧទាហរណ៍ ដូចជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គបុរេជំនុំជម្រះបានអញ្ជើញឱ្យភាគី ដាក់សារណាលើការសម្រេចដែលរងការជំទាស់នេះ[117] ហើយដែលអង្គជំនុំជម្រះនឹងដោះស្រាយនៅក្នុងផ្នែកនេះ។

### ១. សារណា

៦៥. សហមេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងថា ការសន្និដ្ឋានថាច្បាប់ អ.វ.ត.ក មិនរាប់បញ្ចូលយុត្តាធិការលើរូបបុគ្គល ឬយុត្តាធិការលើបទល្មើស របស់តុលាការកម្ពុជាធម្មតាទៅលើព្រឹត្តិការណ៍ដែលស្ថិតក្នុង យុត្តាធិការពេលវេលារបស់ អ.វ.ត.ក នោះ ដីកាដំណោះស្រាយ(សំអាងហេតុ) អះអាងថា នឹងដកចេញនូវយុត្តាធិការរបស់តុលាការកម្ពុជាធម្មតាដែលវិនិច្ឆ័យលើឧក្រិដ្ឋកម្មណាមួយក្នុងសម័យខ្មែរក្រហម រួមទាំងឧក្រិដ្ឋកម្មទាំងឡាយណា ដែលស្ថិតក្រៅយុត្តាធិការដែលមានកម្រិត របស់ អ.វ.ត.ក ផង[118]។ សហមេធាវីអះអាងថា ការនេះ "អាចនឹងមានផលប៉ះពាល់អវិជ្ជមានយ៉ាងធ្ងន់ធ្ងរ" លើផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះផ្សេងៗនៃរបបខ្មែរក្រហម ហើយដីកាដំណោះស្រាយនេះ "ធ្វើឱ្យខូចមរតករបស់ អ.វ.ត.ក យ៉ាងធ្ងន់ធ្ងរ ដោយការ

---

[116] ដីកាដំណោះស្រាយ (ហេតុសំអាង) កថាខណ្ឌ ២៣ (គូសបញ្ជាក់បន្ថែម)។

[117] សេចក្តីសម្រេចអញ្ជើញឱ្យដាក់សារណា អំពីដំណើររបស់ អក.ត.វ. (ឯកសារ D308/3/1/8) កថាខណ្ឌ ១២ ដល់១៣។

[118] សារណាអំពីដំណើររបស់ អក.ត.វ. (ឯកសារ D308/3/1/9) កថាខណ្ឌ ៣ ។១ ,

រៀបចំឱ្យមានតុលាការមួយ ដែលការលើកលែងទោសស្មើរតែទាំងស្រុង លើឧក្រិដ្ឋកម្មឃោរឃៅក្នុងសម័យខ្មែរក្រហម ត្រូវបានអនុវត្តក្នុងប្រទេសកម្ពុជា តាមរយៈយន្តការនេះ”[119]។

៦៦. សហមេធាវីអះអាងបន្ថែមទៀតថា កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ដែលច្បាប់ស្តីពីការបង្កើត អ.វ.ត.ក គឺជាផ្នែកសំខាន់មួយនៃកិច្ចព្រមព្រៀងនោះ ចាំបាច់ត្រូវតែបកស្រាយអនុលោមតាមគោលការណ៍ ដែលមានចែងនៅក្នុងអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់នៃសន្ធិសញ្ញា[120]។ ដោយសារតែមិនមានបទប្បញ្ញត្តិនៅក្នុងកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ចែងអំពីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងដោយកម្មាភិបាលខ្មែរក្រហមថ្នាក់ទាប ឬដោយបុគ្គលដែលស្ថិតក្រៅ យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក និងដោយសារតែមិនមានបទប្បញ្ញត្តិណាមួយចែងពាក់ព័ន្ធនឹងការលុបយុត្តាធិការនោះ[121] តុលាការកម្ពុជា ធម្មតា នៅរក្សាយុត្តាធិការរបស់ខ្លួន ទៅលើឧក្រិដ្ឋកម្មដែលមិនស្ថិតក្រោម យុត្តាធិការរបស់ អ.វ.ត.ក[122]។ តាមទស្សនៈរបស់សហមេធាវី “ការបកស្រាយយ៉ាងវែងអន្លាយរបស់ ក.ស.ច.ស លើយុត្តាធិការផ្តាច់មុខរបស់ អ.វ.ត.ក” [123] គឺជាឧទាហរណ៍នៃការចេញហួសច្បាប់ ហើយនាំទៅដល់លទ្ធផលដែលមិនសមហេតុផល តាមមាត្រា ៣១ នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់នៃសន្ធិសញ្ញា ជាពិសេសធ្វើឱ្យផ្លាស់ប្តូរអធិបតេយ្យភាពរបស់កម្ពុជា និងបង្កើតនូវការលើកលែងទោសជាទូទៅ [124] ដែលរំលោភបំពានទៅលើបទដ្ឋានអាជ្ញាព្រឹត្ត [125]។

៦៧. សហមេធាវីតំណាងអតីត អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បានបន្ថែមទៀតថា ការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេតអំពីយុត្តាធិការផ្តាច់មុខរបស់ អ.វ.ត.ក “ត្រូវបានជំទាស់ដោយប្រវត្តិនៃការចរចារបស់ អ.វ.ត.ក និងការអនុវត្តជាបន្តបន្ទាប់ ក៏ដូចជាគោលការណ៍ច្បាប់

---

[119] សារណាអំពីជំហររបស់ អក.ត.វ. (ឯកសារ D308/3/1/9) កថាខណ្ឌ ៦។

[120] សារណាអំពីជំហររបស់ អក.ត.វ. (ឯកសារ D308/3/1/9) កថាខណ្ឌ ៩។

[121] សារណាអំពីជំហររបស់ អក.ត.វ. (ឯកសារ D308/3/1/9) កថាខណ្ឌ ១០។

[122] សារណាអំពីជំហររបស់ អក.ត.វ. (ឯកសារ D308/3/1/9) កថាខណ្ឌ ៨។១០ , សូមមើលផងដែរ សំណុំរឿង ០០៤១/ សេចក្តីថ្លែងការណ៍របស់ សាស្ត្រាចារ្យ David SCHEFFER ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D308/3/1/9.2 (“ សេចក្តីថ្លែងការណ៍របស់ សាស្ត្រាចារ្យ SCHEFFER (ឯកសារ D308/3/1/9.2)”) កថាខណ្ឌ ៨។

[123] សារណាអំពីជំហររបស់ អក.ត.វ. (ឯកសារ D308/3/1/9) កថាខណ្ឌ ១៣។

[124] សារណាអំពីជំហររបស់ អក.ត.វ. (ឯកសារ D308/3/1/9) កថាខណ្ឌ ១១ ដល់១៥។ សូមមើលផងដែរ សេចក្តីថ្លែងការណ៍របស់ សាស្ត្រាចារ្យ SCHEFFER (ឯកសារ D308/3/1/9.2) កថាខណ្ឌ ៦។

[125] ប្រតិចារិកថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៧ ឯកសារ) D308/3/1/19/1.2) ទំព័រ ១៥ ដល់១៦។

អន្តរជាតិ ដែលត្រូវបានទទួលស្គាល់ជាទូទៅផងដែរ"[126]។ សហមេធាវីជំទាស់ថា ការពិតដែល "អ្នកធ្វើសេចក្តីព្រាង មិនបានប្រមើលមើលទុកថា អ.វ.ត.ក នឹងកាត់ទោសបុគ្គលគ្រប់រូបដែលរំលោភលើច្បាប់អន្តរជាតិ ក្នុងអំឡុងពេលដែលពាក់ព័ន្ធ *មិនបាន*នាំដល់ការសន្និដ្ឋានដែលថា ជនទាំងនោះគឺជាបុគ្គល *តែមួយក្រុម* ដែលអាចនឹងត្រូវកាត់ទោសនោះឡើយ"[127]។

៦៨. សហមេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី "ស្នើសុំដោយក្តីគោរពដល់អង្គបុរេជំនុំជម្រះថា ពុំគួរបណ្តែតបណ្តោយឱ្យសហចៅក្រមស៊ើបអង្កេត ប៉ុនប៉ងជល្មើមអធិបតេយ្យភាពរបស់កម្ពុជា ដោយរំលោភច្បាប់អន្តរជាតិ និងច្បាប់កម្ពុជា លើបញ្ហាដ៏សំខាន់បែបនេះនោះទេ"[128]។ ហេតុដូច្នេះសហមេធាវី ស្នើដល់អង្គបុរេជំនុំជម្រះ "ដោះស្រាយសំអាងហេតុដែលមានការភាន់ច្រឡំ នៅក្នុងដីកាដំណោះស្រាយ នៅលើវិសាលភាពនៃយុត្តាធិការផ្តាច់មុខរបស់ អ.វ.ត.ក និងប្រកាសថា កម្រិតដែលតុលាការកម្ពុជាសាមញ្ញមានសមត្ថភាពលើផ្លូវច្បាប់ និងស្ថាប័នក្នុងការដោះស្រាយឧក្រិដ្ឋកម្ម ក្នុងសម័យខ្មែរក្រហម គឺជាបញ្ហាមួយដែលត្រូវប្រគល់ដល់តុលាការទាំងនោះ ឱ្យសម្រេចដោយខ្លួនឯង"[129]។

៦៩. សហមេធាវីការពារក្តី អ៊ឹម ចែម បានឆ្លើយតបថា សារណាស្តីពី អ.វ.ត.ក គួរត្រូវបានសម្រេចថាមិនអាចទទួលយកបាន[130]។ ប្រសិនបើតុលាការកម្ពុជាធម្មតា អាចសម្រេចពីកម្រិតនៃយុត្តាធិការរបស់ពួកគេ ទៅលើឧក្រិដ្ឋកម្មសម័យខ្មែរក្រហម អង្គបុរេជំនុំជម្រះនឹងមិនមែនជាវេទិការដ៏សមស្របមួយ សម្រាប់ផ្តល់នូវដំណោះស្រាយដែលបានស្នើសុំនោះទេ[131]។ សហចៅក្រមស៊ើបអង្កេតគ្រាន់តែសន្និដ្ឋានថា កង្វះយុត្តាធិការនៃតុលាការកម្ពុជាធម្មតា មិនត្រូវមានផលប៉ះពាល់ផ្នែកគោលនយោបាយ មកលើការអនុវត្តឆន្ទានុសិទ្ធិរបស់ពួកគាត់ពាក់ព័ន្ធនឹងយុត្តាធិការបុគ្គល[132] ដែលជាការសន្និដ្ឋានមួយតម្រូវឱ្យមានជាមុន ដើម្បីកម្រិតកំណត់ទៅលើលក្ខណៈនៃឆន្ទានុសិទ្ធិផ្ទាល់របស់ខ្លួន ហើយមិនបានសំដៅលើឆន្ទានុសិទ្ធិតុលាការកម្ពុ

---

[126] សារណាអំពីជំហររបស់ អក.ត.វ. (ឯកសារ D308/3/1/9) កថាខណ្ឌ ១៦។

[127] សារណាអំពីជំហររបស់ អក.ត.វ. (ឯកសារ D308/3/1/9) កថាខណ្ឌ ១៧។ សូមមើលផងដែរ កថាខណ្ឌ ១៨ ដល់២៥។ សេចក្តីថ្លែងការណ៍របស់ សាស្ត្រាចារ្យ SCHEFFER (ឯកសារ D308/3/1/9.2) កថាខណ្ឌ ៧។៩ ,

[128] សារណាអំពីជំហររបស់ អក.ត.វ. (ឯកសារ D308/3/1/9) កថាខណ្ឌ ៣១។

[129] សារណាអំពីជំហររបស់ អក.ត.វ. (ឯកសារ D308/3/1/9) កថាខណ្ឌ ៣១ ដល់៣២។

[130] ចម្លើយតបចំពោះ សារណាអំពីជំហររបស់ អ.វក.ត. (ឯកសារ D308/3/1/18) កថាខណ្ឌ ៤ ដល់១១។

[131] ចម្លើយតបចំពោះ សារណាអំពីជំហររបស់ អក.ត.វ. (ឯកសារ D308/3/1/18) កថាខណ្ឌ ៦។

[132] ចម្លើយតបចំពោះ សារណាអំពីជំហររបស់ អក.ត.វ. (ឯកសារ D308/3/1/18) កថាខណ្ឌ ៧ យោងទៅរកដីកាដំណោះស្រាយ (ហេតុសំអាង) កថាខណ្ឌ ២៥។

ជាធម្មតានោះឡើយ[133]។ ហេតុដូច្នេះ សហមេធាវីបានអះអាងថា បញ្ហាតែមួយគត់ដែលតម្រូវឱ្យអង្គបុរេជំនុំជម្រះធ្វើការពិចារណានោះ គឺថាតើ សហចៅក្រមស៊ើបអង្កេត មានកំហុសឆ្គងដែរឬទេ ក្នុងការសន្និដ្ឋានថាការអនុវត្តឆន្ទានុសិទ្ធរបស់ពួកគាត់ មិនត្រូវបានប៉ះពាល់ដោយគោលនយោបាយទូទៅណាមួយ ទាក់ទងយុត្តាធិការរបស់តុលាការកម្ពុជាធម្មតា ទៅលើឧក្រិដ្ឋកម្មពាក់ព័ន្ធ[134]។

៧០. ជាជម្រើសមួយផ្សេងទៀត សហមេធាវីបានលើកឡើងករណីថា អង្គបុរេជំនុំជម្រះគួរគាំទ្រដល់ការសម្រេចដែលថា តុលាការកម្ពុជាធម្មតា មិនមានយុត្តាធិការទៅលើឧក្រិដ្ឋកម្មទាំងអស់ក្នុងសម័យខ្មែរក្រហម[135]។ សហមេធាវីអះអាងថា កម្ពុជាបានអនុវត្តសិទ្ធិអធិបតេយ្យភាពរបស់ខ្លួន ដោយជ្រើសរើសការមិនបន្តជំនុំជម្រះបន្ថែមទៀតទៅលើ បទល្មើសនៅក្នុងសម័យខ្មែរក្រហម[136] ហើយថា រដ្ឋាភិបាលបានបញ្ជាក់ម្តងហើយម្តងទៀត ពីការជំទាស់របស់ខ្លួន ចំពោះការកាត់ទោសទាំងឡាយណា ក្រៅតែពីការកាត់ទោសមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ដែលជាការប្រឆាំងនឹងគោលបំណង នៃការបង្រួបបង្រួមជាតិ និងស្ថិរភាពនយោបាយ[137]។ តាមទស្សនៈនេះ ភាពអសកម្មផ្នែកនីតិបញ្ញត្តិ និងដំណើរការចោទប្រកាន់របស់រដ្ឋាភិបាល ទាក់ទងនឹងការកាត់ទោសបន្ថែមទៀតបានបង្ហាញថា កម្ពុជាបានសម្រេចកម្រិតកំណត់ ទៅលើតុលាការធម្មតារបស់ខ្លួន និងដកហូតយុត្តាធិការថ្នាក់ជាតិចំពោះឧក្រិដ្ឋកម្មទាំងអស់នៅក្នុងរបបខ្មែរក្រហម[138] ដូចដែលបានគាំទ្រតាមរយៈ ប្រវត្តិនៃការចរចារបស់ អ.វ.ត.ក[139]។

៧១. ទាំងសហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ មិនបានដាក់សារណាទោះជាលាយលក្ខណ៍អក្សរក្តី ឬដោយផ្ទាល់មាត់ក្តីនោះឡើយ សម្រាប់បញ្ហាមួយនេះ។

### ២. ការពិភាក្សា

៧២. ជាដំបូង អង្គបុរេជំនុំជម្រះសូមរំឭកថា អ.វ.ត.ក គឺជាស្ថាប័នឯករាជ្យមួយ ដែលស្ថិតក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជា ហើយមិនមានយុត្តាធិការក្នុងការកាត់សេចក្តី លើសកម្មភាពរបស់ស្ថាប័នដទៃទៀត

---

133 ចម្លើយតបចំពោះ សារណាអំពីដំហររបស់ អក.ត.វ. (ឯកសារ D308/3/1/18) កថាខណ្ឌ ៨។

134 ចម្លើយតបចំពោះ សារណាអំពីដំហររបស់ អក.ត.វ. (ឯកសារ D308/3/1/18) កថាខណ្ឌ ១០។

135 ចម្លើយតបចំពោះ សារណាអំពីដំហររបស់ អក.ត.វ. (ឯកសារ D308/3/1/18) កថាខណ្ឌ ១២ ដល់៣៥។

136 ចម្លើយតបចំពោះ សារណាអំពីដំហររបស់ អក.ត.វ. (ឯកសារ D308/3/1/18) កថាខណ្ឌ ១៤ ដល់១៥។

137 ចម្លើយតបចំពោះ សារណាអំពីដំហររបស់ អក.ត.វ. (ឯកសារ D308/3/1/18) កថាខណ្ឌ ២៥ ដល់២៦។

138 ចម្លើយតបចំពោះ សារណាអំពីដំហររបស់ អក.ត.វ. (ឯកសារ D308/3/1/18) កថាខណ្ឌ ២៩។

139 ចម្លើយតបចំពោះ សារណាអំពីដំហររបស់ អក.ត.វ. (ឯកសារ D308/3/1/18) កថាខណ្ឌ ១៦ ដល់២១។

ឡើយ[140]។ ហេតុដូច្នេះសហចៅក្រមស៊ើបអង្កេត និង អង្គបុរេជំនុំជម្រះ មិនមានយុត្តាធិការក្នុងការសម្រេចទៅលើសេចក្តីសម្រេច ឬកិច្ចរបស់តុលាការដទៃទៀត នៅក្នុងប្រព័ន្ធតុលាការកម្ពុជាឡើយ[141] ហើយក្នុងការសម្រេចថាតុលាការកម្ពុជាធម្មតា មិនមានយុត្តាធិការក្នុងការជំនុំជម្រះរឿងក្តី ទាក់ទងឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហមនោះ សហចៅក្រមស៊ើបអង្កេត បានរំលងហួសអាណត្តិការងាររបស់ខ្លួនរួចទៅហើយ។

៧៣. ទោះបីជាយ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះគឺជាអង្គជំនុំជម្រះត្រួតពិនិត្យបណ្តឹងឧទ្ធរណ៍ ដែលធ្វើឱ្យអង្គជំនុំជម្រះនេះចាំបាច់ ត្រូវតែពិចារណាទៅលើបញ្ហាដែលបានលើកឡើង ដែលជាបញ្ហាសំខាន់ទូទៅមួយ[142] សម្រាប់យុត្តិសាស្ត្រ និងកេរ្តិ៍ដំណែលរបស់ អ.វ.ត.ក។

### ក. **<u>រឿងក្តីដែលអ.វ.ត.ក បានទទួល</u>**

៧៤. អង្គបុរេជំនុំជម្រះសូមរម្លឹកថា ពុំមានការចែងទុកជាមុនឡើយនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក អំពីនីតិវិធីក្នុងការបញ្ជូនរឿងក្តីពាក់ព័ន្ធនឹងរឿងក្តីដែល អ.វ.ត.ក បានទទួលរួចហើយនោះ។ រឿងក្តីទាំងនោះ មិនអាចបញ្ជូនទៅតុលាការជាតិបានឡើយ [143] ។ ដោយសារតែមានការបញ្ជាក់យ៉ាងច្បាស់តាំងពីឆ្នាំ

---

[140] សំណុំរឿង ០០១ (០១អបជ )សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន របស់ជនត្រូវចោទ កាំង ហ្កេកអ៊ាវ ហៅ ឯកសារ ២០០៧ឆ្នាំ ខែធ្នូ ៣ទីថ្ងៃ "ឌុច" C5/45 ("សាលដីកាសំណុំរឿង ០០១ លើដីកាឃុំខ្លួនបណ្តោះអាសន្ន ឯកសារ)C5/45)") កថាខណ្ឌ ១៩។ សូមមើលផងដែរ សំណុំរឿង ០០២ (០១អបជ )សេចក្តីសម្រេចជាសាធារណៈ ស្តីពីបណ្តឹងឩតចិត្តជាបន្ទាន់ របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល ដោយរងចាំបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាឃុំខ្លួនបណ្តោះអាសន្ន ក្នុងសំណុំរឿង នួន ជា ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ ឯកសារ C11/29 (សំណុំរឿង ០០២ សេចក្តីសម្រេច ថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០០៨) កថាខណ្ឌ ៣០។ សំណុំរឿង ០០១ សារណារបស់សាស្ត្រាចារ្យ David SCHEFFER អ្នកជំនាញច្បាប់អន្តរជាតិ ក្នុងនាមជាអ្នកមិនមែនជាគូភាគី ដើម្បីគាំទ្រដល់សហចៅក្រមស៊ើបអង្កេត ថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៧ ឯកសារ C5/13 ("ការសង្ខេបរបស់សាស្ត្រាចារ្យ SCHEFFER ក្នុងសំណុំរឿង ០០១ (C5/13)")ទំព័រ ៥។

[141] *សូមមើល* សាលដីកាសំណុំរឿង ០០១ លើដីកាឃុំខ្លួនបណ្តោះអាសន្ន ឯកសារ)C5/45) កថាខណ្ឌ ១៧។

[142] *សូមមើលជាឧទាហរណ៍* តុលាការ Internatinal Criminal Tribubnal for the Former Yugoslavia (ICTY) រដ្ឋអាជ្ញា តទល់និង *Tadić*, IT-94-1-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ២៤៧ ,២៨១ , ។៣១៦ តុលាការ ICTY, រដ្ឋអាជ្ញា តទល់និង *Mucić និងអ្នកដទៃទៀត* IT-96-21-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ២២១។ តុលាការ ICTR រដ្ឋអាជ្ញា តទល់និង *Akayesu*, ICTR-96-4-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ១៩, ២៣ ដល់២៤។

[143] សាលដីកាសំណុំរឿង ០០១ លើដីកាឃុំខ្លួនបណ្តោះអាសន្ន ឯកសារ)C5/45) កថាខណ្ឌ ១៧។ សាលដីកានៃសំណុំរឿង ០០១ (ឯកសារ F28) កថាខណ្ឌ ៧១។



PRE-TRIAL E.C.C.C

01575471



២០០៩ មកម្ល៉េះថា ពុំមានការចោទប្រកាន់បន្ថែមទៀតឡើយបន្ទាប់ពីបញ្ចប់រឿងក្តីចំនួនបួនដែល អ.វ.ត.ក បានទទួលរួចហើយនោះ[144] បញ្ហាដែលសហចៅក្រមស៊ើបអង្កេតបានលើកឡើង គឺពាក់ព័ន្ធជាចម្បងតែទៅនឹងរឿងក្តីផ្សេងៗទៀតក្នុងសម័យខ្មែរក្រហមប៉ុណ្ណោះ។

## ខ. រឿងក្តីដែលអ.វ.ត.ក មិនបានទទួល

### ១. យុត្តាធិការឥស្សរចិត្ត

៧៥. អង្គបុរេជំនុំជម្រះយល់ឃើញថា កម្ពុជាមានយុត្តាធិការឥស្សរចិត្តទៅលើរឿងក្តីទាំងអស់ក្នុងសម័យខ្មែរក្រហមដែល អ.វ.ត.ក មិនបានទទួល។ មុនពេលបង្កើត អ.វ.ត.ក រាជរដ្ឋាភិបាលកម្ពុជា មិនត្រឹមតែមានជម្រើសដោយសេរីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានកាតព្វកិច្ចផងដែរតាមច្បាប់អន្តរជាតិ ក្នុងការចោទប្រកាន់មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ឬបុគ្គលដែលត្រូវបានចោទប្រកាន់ថាជាជនទទួលខុសត្រូវខ្ពស់បំផុតលើបទល្មើសអន្តរជាតិ ដែលជាការអនុវត្តយុត្តាធិការមូលដ្ឋានរបស់ខ្លួន។ នៅក្នុងកិច្ចព្រមព្រៀងជាមួយអង្គការសហប្រជាជាតិ រាជរដ្ឋាភិបាលកម្ពុជាគ្រាន់តែប្រគល់យុត្តាធិការជូនទៅ អ.វ.ត.ក ធ្វើការជំនុំជម្រះទៅលើប្រភេទនៃចារីមួយនេះ ជាជាងប្រើប្រាស់វចនាសម្ព័ន្ធតុលាការរបស់ខ្លួនដែលមានស្រាប់រួចហើយនោះ[145]។ តាមពិតទៅ នៅពេល អ.វ.ត.ក ចាប់បដិសន្ធិឡើងនោះ តុលាការ កម្ពុជាកំពុងដំណើរការជំនុំជម្រះបុគ្គលមួយចំនួនដែលបំពេញបាន (ឬអាចបំពេញបាន) លក្ខខណ្ឌតម្រូវសម្រាប់យុត្តាធិការបុគ្គលនៅ អ.វ.ត.ក[146]។

---

[144] សូមមើល សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី៖ ការដាក់សេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីចំនួនពីរ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៩។

[145] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ឯកសារ D427/2/15 & D427/3/15 កថាខណ្ឌ ១០៣។

[146] *សូមមើលជាឧទាហរណ៍* សំណុំរឿង ០០៤ លិខិតលើកទី១ របស់ចៅក្រម Mark HARMON ជូនចៅក្រម ន័យ ថុល ទាក់ទងទៅនឹងសំណុំរឿងតុលាការយោធារបស់ តា ម៉ុក ថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៣ ឯកសារ D246.1.1។ សំណុំរឿង ០០៤ ចម្លើយលើកទី១របស់លោកចៅក្រម ន័យ ថុល ជូនសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាក់ទងទៅនឹងសំណុំរឿងតុលាការយោធារបស់ តា ម៉ុក ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ឯកសារ D246.1.2។ សំណុំរឿង ០០៤ លិខិតលើកទី២ របស់ចៅក្រម Mark HARMON ជូនចៅក្រម ន័យ ថុល ទាក់ទងទៅនឹងសំណុំរឿងតុលាការយោធារបស់ តា ម៉ុក ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D246.1.3។ សំណុំរឿង ០០៤ ចម្លើយលើកទី២របស់លោកចៅក្រម ន័យ ថុល ជូនសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាក់ទងទៅនឹងសំណុំរឿងតុលាការយោធារបស់ តា ម៉ុក ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D246.1.4។ សំណុំរឿង ០០៤ លិខិត

## ២. ច្បាប់ជាធរមានរបស់ អ.វ.ត.ក

៧៦. សំខាន់បំផុត អង្គបុរេជំនុំជម្រះកត់សម្គាល់ថា អត្ថបទដ៏ច្បាស់លាស់នៃលិខិតុបករណ៍បង្កើត អ.វ.ត.ក មិនបានគាំទ្រដល់ការសន្និដ្ឋានដែលថា អ.វ.ត.ក ដកហូតពីតុលាការកម្ពុជាធម្មតានូវយុត្តាធិការឥស្សរចិត្តលើរឿងក្តីទាំងអស់ក្នុងសម័យខ្មែរក្រហមនោះឡើយ។ យោងតាមមាត្រា ២ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងបុព្វកថានៃកិច្ចព្រមព្រៀង ស្តីពីការបង្កើត អ.វ.ត.ក នោះ អ.វ.ត.ក គឺជាតុលាការពិសេសដែលបង្កើតឡើងនៅក្នុងប្រព័ន្ធតុលាការកម្ពុជាដែលមានស្រាប់[147]។ មាត្រា ១ និង២(១) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ដែលឆ្លុះបញ្ចាំងឡើងវិញដោយ មាត្រា ១ និង២ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានចែងយ៉ាងច្បាស់អំពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ហើយកម្រិតត្រឹមតែមេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មមួយចំនួន ដែលបានប្រព្រឹត្តនៅក្នុងរបបខ្មែរក្រហម។ នៅក្នុងច្បាប់ជាធរមានមិនបានចែងថា អ.វ.ត.ក មានយុត្តាធិការផ្តាច់មុខទៅលើរឿងក្តីផ្សេងទៀតនៅក្នុងរបបខ្មែរក្រហមឡើយ។

៧៧. សេចក្តីព្រាងនៃកំណត់ត្រាប្រវត្តិដែលមាន បានគាំទ្របន្ថែមទៀតដល់ការសន្និដ្ឋានដែលថា អ.វ.ត.ក មិនបានដកហូតចេញពីតុលាការកម្ពុជាធម្មតា នូវយុត្តាធិការទៅលើរឿងក្តីក្នុងរបបខ្មែរក្រហមនោះឡើយ។ ទោះបីជាសហចៅក្រមស៊ើបអង្កេត ពឹងផ្អែកការសម្រេចរបស់ខ្លួនយ៉ាងច្បាស់លាស់ទៅលើ "ការពិនិត្យយ៉ាងល្អិតល្អន់ទៅលើប្រវត្តិនៃការចរចាមុនពេលបង្កើត អ.វ.ត.ក"[148] យ៉ាងណាក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេត មិនបានយោងទៅរកឯកសារជាក់លាក់ណាមួយឡើយ[149] ហើយតាមពិតទៅសហចៅក្រមស៊ើបអង្កេត ត្រូវបានអង្គការសហប្រជាជាតិបដិសេធ មិនបង្ហាញនូវកំណត់ត្រាភាគច្រើននៃការចរចា[150]។

---

របស់ចៅក្រម Michael BOHLANDER ជូនលោកចៅក្រម ន័យ ធុល ទាក់ទងសំណើសុំជំនួយបន្ថែម (ទាក់ទងនឹង តា ម៉ុក) ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D326.1។ សំណុំរឿង 004 លិខិតរបស់ចៅក្រម ន័យ ធុល ជូនចៅក្រម Michael BOHLANDER ទាក់ទងសំណើសុំជំនួយបន្ថែម (ទាក់ទងនឹង តា ម៉ុក) ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ ឯកសារ D326.2។

[147] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២ ថ្មី (ចែងថា អ.វ.ត.ក "ត្រូវបង្កើតឡើងនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់[របស់កម្ពុជា]")។ កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក បុព្វកថា កថាខណ្ឌ ៤។

[148] ដីកាដំណោះស្រាយ (ហេតុសំអាង) កថាខណ្ឌ ១២។

[149] *សូមមើល* ដីកាដំណោះស្រាយ (ហេតុសំអាង), កថាខណ្ឌ ១២ និងកថាខណ្ឌបន្តបន្ទាប់ទៀត ដែលយោងទៅរកសាលដីកា សំណុំរឿង ០០១ (ឯកសារ F28) កថាខណ្ឌ ៤៦ ដល់៥៦ (ប្រវត្តិនៃការចរចា ដូចបានបញ្ជាក់ដោយអង្គជំនុំជម្រះតុលាការកំពូល

01575473



៧៨. ការពិនិត្យយ៉ាងល្អិតល្អន់ទៅលើកំណត់ត្រាដែលមានស្រាប់ អំពីប្រវត្តិនៃការចរចា បានបង្ហាញថា រាជរដ្ឋាភិបាលកម្ពុជាបានពិចារណាថា វេទិកាដ៏សមស្របសម្រាប់ការជំនុំជម្រះទៅលើប្រភេទនៃចារីកម្រិតខ្ពស់ ដែលមានចំនួនកំណត់នោះ គឺតុលាការពិសេសមួយ ដែលមានការជួយគាំទ្រពីសហគមន៍អន្តរជាតិ ដោយមានសមាធាតុអន្តរជាតិ និងមានអណត្តិការងារមានកំណត់ ដោយសារពាក់ព័ន្ធនឹងសមត្ថភាព ភាពស្របច្បាប់ និងកេរ្តិ៍ដំណែល[151]។ មិនមានអ្វីដែលគាំទ្រដល់ការសម្រេចដែលថា ការកម្រិត

---

ទាក់ទងបញ្ហាជាក់លាក់)។

[150] ដីកាដំណោះស្រាយ (ហេតុសំអាង) កថាខណ្ឌ ១៩ យោងទៅរកសំណុំរឿង ០០៣ ការជូនដំណឹងស្តីពីការដាក់ចូលក្នុងសំណុំរឿង នូវកំណត់ដែលមានស្រាប់ ទាក់ទងការបង្កើត អ.វ.ត.ក ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ D181/2។

[151] *សូមមើលជាឧទាហរណ៍* កិច្ចប្រជុំលើកទីមួយ និតិកាលទីបីរបស់សភាជាតិកម្ពុជា ការពិភាក្សាដេញដោល និងការអនុម័តលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា និងការពិភាក្សាដេញដោល និងការអនុម័តលើ វិសោធនកម្មច្បាប់ស្តីពីការ ជំនុំជម្រះលើមេដឹកនាំខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជា ថ្ងៃទី ០៤ ដល់០៥ ខែ តុលា ឆ្នាំ ២០០៤ ("ការពិភាក្សាដេញដោលរបស់សភាជាតិកម្ពុជា ("ទំព័រ ២៨ ដល់៣០ ")ប្រសិនបើយើងអនុញ្ញាតិឲ្យ[អ្នកដែលសម្លាប់ប្រជាជនរាប់លាននាក់] រួចផុតពីឧក្រិដ្ឋកម្មដែលពួកគេប្រព្រឹត្ត ការនេះនឹងបង្កើតជាឧទាហរណ៍សម្រាប់មេដឹកនាំបន្ទាប់។ [...] ដូច្នេះយើងត្រូវតែបញ្ចប់ ការអនុវត្តដ៏អាក្រក់បែបនេះ ហើយដើម្បីបញ្ចប់ការអនុវត្តបែបនេះ យើងចាំបាច់ត្រូវបង្កើតតុលាការមួយ ជាតុលាការពិសេស [ដើម្បីជំនុំជម្រះមេដឹកនាំខ្មែរក្រហម] ដោយមានការចូលរួមពីអង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិ ដើម្បីធានានូវឯករាជ្យភាព ("ទំព័រ ៣១ ដល់ ៣៤") ឥឡូវនេះជាពេលនាំមកជំនុំជម្រះ អ្នកដែលរៀបចំផែនការ និងបញ្ជាឲ្យមានអំពើសាហាវយង់ឃ្នង។ [...] ជាការសមហេតុផលដែលត្រូវមានព្រះរាជអាជ្ញា អ្នកជំនាញច្បាប់ និងចៅក្រមកម្ពុជា និងចៅក្រមអន្តរជាតិ ដែលត្រូវធ្វើការរួមគ្នា ក្នុងការជំនុំជម្រះអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត។ ការនេះនឹងនាំទៅដល់ការបង្កើតនូវវប្បធម៌មួយ ដែលទប់ស្កាត់ការកើតឡើងវិញ នូវអំពើសាហាវយង់ឃ្នងបែបនេះ នៅក្នុងផ្នែកដទៃទៀតលើពិភពលោក ("ទំព័រ ៤៥ ដល់ ៤៦ ")អង្គជំនុំជម្រះវិសាមញ្ញ នឹងនាំមកនូវយុត្តិធម៌។ ជនរងគ្រោះក្នុងរបបអាចដឹងបន្ថែមទៀត អំពីគោលការណ៍យុត្តិធម៌។ គោលការណ៍យុត្តិធម៌គឺជាប្រភពនៃ កំណែទម្រង់វិស័យតុលាការនៅកម្ពុជា ហើយនឹងដើរតួនាទីជាសារព្រមានមួយ ចំពោះជនផ្តាច់ការទាំងអស់នៅលើពិភពលោក។ ប្រជាជនកម្ពុជា និងប្រជាជននៅលើពិភពលោក នឹងដឹងអំពីការពិតថាហេតុអ្វីទើប មេដឹកនាំសម្លាប់ប្រជាជនខ្លួនឯង ("ទំព័រ ៤៨ ")អ្នកជំនាញដែលរៀបចំតុលាការអន្តរជាតិ បានទទួលស្គាល់ថា ការជំនុំជម្រះជនសង្ស័យរាប់សិបនាក់ ឬរាប់ពាន់នាក់ គឺមិនមែនជាកាតព្វកិច្ច ដែលនាំឲ្យមាននូវលទ្ធផលដែលល្អនោះទេ")។ សូមមើលផងដែរ សេចក្តីប្រកាសស្តីពីកត្តាជម្រុញ សម្រាប់សេចក្តីព្រាងច្បាប់ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជាដែលមានស្រាប់ សម្រាប់ជំនុំជម្រះទៅលើឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (សេចក្តីប្រកាសលេខ ០១ SCN.KBC) ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០០ ")សេចក្តីប្រកាសស្តីពីកត្តាជម្រុញ សម្រាប់ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក") ទំព័រ ៣។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៤០/០០២/២០០១ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១ ទំព័រ ៣។សេចក្តីប្រកាសស្តីពីការជម្រុញ លើសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តលើ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងការជំនុំជម្រះតាមច្បាប់កម្ពុជា ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (សេចក្តីប្រកាសលេខ

យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក អាចត្រូវបានបកស្រាយថាជាការផ្ទុះបញ្ចាំង នូវចេតនារបស់អ្នកព្រាងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងកិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.វ.ត.ក ដែលថាចារីដទៃទៀត អាចគេចផុតចេញពីសំណាញ់យុត្តិធម៌នោះឡើយ[152]។

## ៣. សេចក្ដីសន្និដ្ឋាន

៧៩. ដូចបានបញ្ជាក់ជូនខាងលើ អ.វ.ត.ក មិនមានយុត្តាធិការក្នុងការកាត់សេចក្ដីលើសកម្មភាពរបស់ស្ថាប័នដទៃទៀតឡើយ [153] ហើយសហចៅក្រមស៊ើបអង្កេតបានសម្រេចដោយពុំបានពឹងផ្អែកលើបញ្ញត្តិច្បាប់ជាក់លាក់ណាមួយថាតុលាការកម្ពុជាធម្មតា មិនមានយុត្តាធិការក្នុងការជំនុំជម្រះរឿងក្ដីទាក់ទងនឹងឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហមនោះ។ ទោះបីនៅក្នុងច្បាប់ជាធរមានរបស់ អ.វ.ត.ក មិនបានហាមឃាត់មិនឱ្យមានការបញ្ជូនប្រភេទនៃរឿងក្ដីដែលស្ថិតក្រោមយុត្តាធិការមានកម្រិតរបស់ខ្លួន ត្រឡប់ទៅឱ្យស្ថិតក្រោមយុត្តាធិការរបស់តុលាការកម្ពុជាធម្មតា នៅពេលដែល អ.វ.ត.ក លែងមានអត្ថិភាពក៏ដោយ ក៏ការ

---

38.SCN.KBT) ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៣ ទំព័រ ១។ សូមមើលផងដែរ សេចក្ដីថ្លែងការណ៍របស់ សាស្ត្រាចារ្យ SCHEFFER (ឯកសារ D308/3/1/9.2) កថាខណ្ឌ ៨ ដល់៩។ David SCHEFFER "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" *in* Cherif BASSIOUNI (ed.), *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* Vol. III, Koninklijke Brill NV: 2008 (3rd ed.) ទំព័រ ២៤០។

[152] *សូមមើលជាឧទាហរណ៍* ឯកអគ្គរដ្ឋទូត Thomas HAMMARBERG គ្នាឯកភាពការដល់ក្រហមឈានខ្មែរតុលាការតើ" រកស្វែងកម្ពុជា ឯកសារមជ្ឈមណ្ឌលក្នុងនៅ "ប្រជាជាតិសហអង្គការកម្ពុជា និងរដ្ឋាភិបាលរវាងពិភាក្សាណា៖ ការរបៀបដោយ ២០០១កញ្ញា ឆ្នាំខែ ២១ពិត លេខ ការ ទំព័រ ៣៧ (មាន ស្វែងការក្នុងចាំបាច់ភាព"រករូបមន្តផ្លូវច្បាប់ [នៃយុត្តាធិការបុគ្គលរបស់ អក.ត.វ.] ដែលនឹងកម្រិតកំណត់ទៅលើចំនួននៃការជំនុំជម្រះ ដោយមិនផ្ដល់នូវការលើកលែងដោយប្រយោល ចំពោះជនទាំងឡាយណាដែលស្ថិតក្រៅក្រុមកំណត់ជាក់លាក់នោះ" )។ កិច្ចពិភាក្សាដេញដោលនៅចំពោះមុខសភាជាតិកម្ពុជាបង្ហាញថា ភាគីចរចាមានចេតនាចង់ឱ្យរឿងក្ដីពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មសម័យខ្មែរក្រហមដែលប្រព្រឹត្តឡើងដោយជនទាំងឡាយដែលមិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះ នៅតែស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការកម្ពុជាធម្មតា។ *សូមមើលជាឧទាហរណ៍* កិច្ចពិភាក្សាដេញដោលសភាជាតិកម្ពុជា ទំព័រ ៣៧ ("ការជំនុំជម្រះចំពោះអ្នកដែលមានតួនាទីធម្មតា គឺមិនមែនជាបញ្ហាលំបាកឡើយ ដោយសាអ្នកទាំងនោះអាចត្រូវផ្ដន្ទាទោស ចំពោះមុខតុលាការកម្ពុជា")។

[153] សាលដីកាសំណុំរឿង ០០១ លើដីកាឃុំខ្លួនបណ្ដោះអាសន្ន ឯកសារ)C5/45)") កថាខណ្ឌ ១៩។ សូមមើលផងដែរ សំណុំរឿង ០០២ (០១អបជ )សេចក្ដីសម្រេចជាសាធារណៈ ស្ដីពីបណ្ដឹងជិតចិត្តជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល ដោយរងចាំបណ្ដឹងឧទ្ធរណ៍ ប្រឆាំងដីកាឃុំខ្លួនបណ្ដោះអាសន្ន ក្នុងសំណុំរឿង នួន ជា ថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ ២០០៨ ឯកសារ C11/29 កថាខណ្ឌ ៣០។ សំណុំរឿង ០០១ សារណារបស់សាស្ត្រាចារ្យ David SCHEFFER អ្នកជំនាញច្បាប់អន្តរជាតិ ក្នុងនាមជាអ្នកមិនមែនជាគូភាគី ដើម្បីគាំទ្រដល់សហចៅក្រមស៊ើបអង្កេត ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៧ ឯកសារ C5/13 ទំព័រ ៥។

សម្រេចថាតើ ច្បាប់ជាតិហាមឃាត់ការចោទប្រកាន់បន្ថែមទៀត ឬក៏អត់នោះ មិនមែនជាបន្ទុករបស់ អ.វ.ត.ក ឡើយ។ បញ្ហាពាក់ព័ន្ធតែមួយគត់នៅចំពោះមុខតុលាការនេះគឺថាតើ ច្បាប់ជាធរមានរបស់ អ.វ.ត.ក រារាំង ឬមិនរារាំងចំពោះយុត្តាធិការជាតិ។ ច្បាប់ជាធរមានរបស់ អ.វ.ត.ក មិនបានរារាំងនោះឡើយ។

៨០. ដោយពិចារណាទៅលើអំណះអំណាងដែលបានបញ្ជាក់ជូនខាងលើនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេត បានប្រព្រឹត្តនូវកំហុសអង្គច្បាប់ តាមរយៈការបកស្រាយច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដោយដកហូតពីតុលាការកម្ពុជាធម្មតានូវយុត្តាធិការរបស់ពួកគេទៅលើឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម។ តុលាការកម្ពុជាធម្មតា មានយុត្តាធិការពេញលេញជាមូលដ្ឋានទៅលើបញ្ហាយុត្តិធម៌ព្រហ្មទណ្ឌនានា។

## V. ការពិចារណាលើអង្គសេចក្តី

៨១. អង្គបុរេជំនុំជម្រះ មិនអាចស្វែងរកសម្លេងគាំទ្រមតិភាគច្រើនចំនួន៤ ដើម្បីធ្វើសេចក្តីសម្រេចដោយផ្អែកលើសំអាងហេតុរួមមួយ។ អនុលោមតាមវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង យោបល់ដាច់ដោយឡែករបស់ចៅក្រមនានានៃអង្គបុរេជំនុំជម្រះ នឹងភ្ជាប់ជាមួយនឹងសេចក្តីពិចារណានេះ។

## VI. សេចក្តីសម្រេច

**ដោយផ្អែកលើហេតុផលទាំងនេះ អង្គបុរេជំនុំជម្រះយោងតាមសំឡេងឯកច្ឆន្ទ៖**

- យល់ឃើញថាពាក្យសុំនេះអាចទទួលយកបាន

- ប្រកាស ថាការពន្យាពេលក្នុងការចេញដីកាដំណោះស្រាយ (សំអាងហេតុ) បន្ទាប់ពីការបញ្ចប់កិច្ចស៊ើបសួរប្រឆាំងលើអ៊ឹម ចែម ជាការមិនត្រឹមត្រូវ

- ប្រកាស ថាសហចៅក្រមស៊ើបអង្កេត មានកំហុសឆ្គងក្នុងការវាយតម្លៃទៅលើភាពអាចជឿជាក់បាន និងតម្លៃជាភស្តុតាងនៃភស្តុតាងទាំងនោះ

- ប្រកាស ថា ស្របតាមយុត្តាធិកានៃអ.វ.ត.ក តុលាការកម្ពុជាធម្មតាមានយុត្តាធិការពេញលេញជាមូលដ្ឋានទៅលើបញ្ហាយុត្តិធម៌ព្រហ្មទណ្ឌនានា

01575476



- ប្រកាស ថាអង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្រពីចៅក្រម៤(បួន)រូប យ៉ាងតិច ដើម្បីចេញសេចក្ដីសម្រេចមួយទៅលើអង្គសេចក្ដី ដោយផ្អែកលើសំអាងហេតុរួមមួយ។

- ប្រកាស ថាដីកាដំណោះស្រាយ (សំអាងហេតុ) លើកលែងចោទប្រកាន់លើអ៊ឹម ចែម ត្រូវបានតម្កល់ទុក។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្ដីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨**

**អង្គបុរេជំនុំជម្រះ**

**ប្រធាន**

**PRAK Kimsan Olivier BEAUVALLET NEY Thol Kang Jin BAIK HUOT Vuthy**

ចៅក្រមប្រាក់ គឹមសាន ចៅក្រមន៍យ ថុល និងចៅក្រមហួត វុទ្ធី សូមលើកឡើងនូវមតិយោបល់របស់ខ្លួន ទាក់ទិននឹងអង្គសេចក្ដីនៃបណ្ដឹងឧទ្ធរណ៍។ ចៅក្រម Olivier BEAUVALLET និងចៅក្រម Kang Jin BAIK សូមលើកឡើងនូវមតិយោបល់របស់ខ្លួន ទាក់ទិននឹងអង្គសេចក្ដីនៃបណ្ដឹងឧទ្ធរណ៍។

01575477



## VII. យោបល់របស់ចៅក្រម ប្រាក់ គីមសាន, ចៅក្រម ន័យ ចុល និងចៅក្រម ហួត វុទ្ធី

៨២. ក្នុងសេចក្ដីសម្រេចនៃដីកាដំណោះស្រាយ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ សហចៅក្រមស៊ើបសួរសម្រេចថាអ.វ.ត.ក មិនមានយុត្តាធិកាលើអ៊ឹម ចែម ឡើយ និងបានលើកលែងចោទប្រកាន់ប្រឆាំងអ៊ឹម ចែម ដោយអាងហេតុថា អ៊ឹម ចែម មិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬក៏ជាជនម្នាក់ក្នុងចំណោមមន្ត្រី ដែលទទួលខុសត្រូវជាន់ខ្ពស់បំផុតក្នុងរបបខ្មែរក្រហម[154]។

៨៣. សហព្រះរាជអាជ្ញាអន្តរជាតិ បានយល់ឃើញផ្សេងអំពីសហចៅក្រមស៊ើបអង្កេត ដោយបានលើកឡើងនូវចំនុចមួយចំនួនដែលអាចបញ្ជាក់ថាអ៊ឹម ចែម ស្ថិតក្នុងយុត្តាធិការបុគ្គលនៃអ.វ.ត.ក ហើយស្នើសុំឱ្យអបជ បញ្ជូនសំណុំរឿងទៅ សចស ដើម្បីវាយតម្លៃឡើងវិញថាតើ អ៊ឹម ចែម ស្ថិតក្នុងយុត្តាធិការបុគ្គលនៃអ.វ.ត.ក ឬជម្រើសម្យ៉ាងទៀតស្នើសុំឱ្យ អ.ប.ជ ធ្វើការវាយតម្លៃដោយខ្លួនឯងផ្ទាល់តែម្ដង[155]។

៨៤. សហព្រះរាជអាជ្ញាជាតិ បានរក្សានូវជំហររបស់ខ្លួនដដែលថា ជនសង្ស័យនៅក្នុងសំណុំរឿង០០៣ និង០០៤ មិនមែនជាមេដឹកនាំជាន់ខ្ពស់ និងមិនមែនជា ជនដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរ ទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋកម្មការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ប្រព្រឹត្តក្នុងអំឡុង ពីថ្ងៃទី១៧ មេសា ១៩៧៥ ដល់ថ្ងៃទី៦ មករា ១៩៧៩ ពោលគឺមិនស្ថិតក្នុងយុត្តាធិការរបស់អ.វ.ត.កទេ។[156]

៨៥. ក្នុងសំណុំរឿង ០០១ និង សំណុំរឿង ០០២ សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ បានឯកភាព និងយល់ព្រម ចោទប្រកាន់ជនសង្ស័យតែចំនួនប្រាំរូប ដើម្បីដាក់ជូនសហចៅក្រមស៊ើបអង្កេត ដោយមូលហេតុថា ជនសង្ស័យទាំងនេះជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជា អ្នកទទួលខុសត្រូវខ្ពស់

---

[154] ដីកាដំណោះស្រាយ (ផ្នែកសេចក្ដីសម្រេច) កថាខណ្ឌ១០ ។

[155] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ៨២។

[156] ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ កថាខណ្ឌ២៧ ឯកសារលេខ D304/1។

បំផុត ចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតក្នុងយុត្តាធិការរបស់អ.វ.ត.ក។[157] ជនសង្ស័យទាំង៥រូប រួមមាន នួន ជា, អៀង សារី, ខៀវ សំផន, អៀង ធីរិទ្ធ, និងកាំង ហ្គេកអ៊ាវ ហៅឌុច។[158]

៨៦. ក្នុងបណ្តឹងឧទ្ធរណ៍ចំពោះមុខអង្គបុរេជំនុំជម្រះក្នុងសំណុំរឿងបច្ចុប្បន្ន សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងនូវមូលដ្ឋានចំនួន៦ ថាជាកំហុសរបស់សហចៅក្រមស៊ើបសួរ ហើយតាមរយៈ មូលដ្ឋានទាំង ៦ នេះ អ៊ឹម ចែម គប្បីត្រូវបានបញ្ជូនទៅជំនុំជម្រះ។

៨៧. កន្លងមកអង្គបុរេជំនុំជំរះ នៃអ.វ.ត.ក បានទទួលយកនូវការខ្វែងយោបល់គ្នាមួយ រវាងសហព្រះរាជអាជ្ញាជាតិ និង អន្តរជាតិ នៃអ.វ.ត.ក ដោយយោងតាមវិធានផ្ទៃក្នុង ៧១(២) ដែលសហព្រះរាជអាជ្ញាអន្តរជាតិស្នើរសុំថា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរចំនួនពីរ បង្កើតបានជាសំណុំរឿង ០០៣/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស និង ០០៤/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស (ដីកាបញ្ជូនរឿងឲ្យស៊ើបសួរថ្មី) ដែលត្រូវបញ្ជូនទៅសហចៅក្រមស៊ើបអង្កេត សម្រាប់បើកការស៊ើបសួរ តែមិនត្រូវបានឯកភាពពីសហព្រះរាជអាជ្ញាជាតិ (ការខ្វែងយោបល់គ្នា)។

៨៨. នៅក្នុងសេចក្តីពិចារណា ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នា រវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះបានប្រកាសថា មិនទទួលបាននូវសម្លេង គាំទ្រពីចៅក្រម បួនរូបយ៉ាងតិច ដើម្បីធ្វើសេចក្តីសម្រេចលើការខ្វែងយោបល់គ្នានេះទេ។ ចៅក្រមជាតិនៃអង្គបុរេជំនុំជំរះយល់ឃើញថាអំណះអំណាងដែលលើកឡើងដោយព្រះរាជអាជ្ញាជាតិ មានលក្ខណៈគ្រប់គ្រាន់ដើម្បីទប់ស្កាត់ការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ទី២ និង ទី៣។

៨៩. អនុលោកតាមវិធានផ្ទៃក្នុង ៧១ (៤) កិច្ចរបស់សហព្រះរាជអាជ្ញាអន្តរជាតិត្រូវតែយកទៅអនុវត្ត។ នៅក្នុងករណីនេះមានន័យថា សហព្រះរាជអាជ្ញាអន្តរជាតិត្រូវបញ្ជូនដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មី ដើម្បីបើកកិច្ចស៊ើបសួរ ស្របតាមវិធាន ៥៣ (១) នៃវិធានផ្ទៃក្នុង។

៩០. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាតុលាការពិសេសមួយដែលអនុវត្តនីតិវិធីនៃការចោទប្រកាន់ និងការស៊ើបសួរ ខុសពីតុលាការថ្នាក់ជាតិ។ ការចោទប្រកាន់ និងការ ស៊ើបសួររបស់តុលាការថ្នាក់ជាតិ គឺធ្វើឡើងតែលើអង្គហេតុទេ មានន័យថា ចៅក្រមស៊ើបសួរទទួលបណ្តឹងអំពីអង្គហេតុ ដែលមាននៅ

---

[157] ដូចខាងលើ កថាខណ្ឌ២៨។

[158] ដូចខាងលើ កថាខណ្ឌ៣១។

ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា[159] ។ ផ្ទុយមកវិញនៅអង្គជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជា ការចោទប្រកាន់ អាចធ្វើទៅបានលុះត្រា តែបំពេញលក្ខខណ្ឌពីរគឺ ទី១.អង្គហេតុ "ឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុង ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ និងទី២. បុគ្គល "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម"[160]។

៩១. កន្លងមកក្នុងសេចក្តីប្រកាសព័ត៌មានចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ជាក់ថាសហព្រះរាជអាជ្ញាអន្តរជាតិនឹងមិនធ្វើការស៊ើបអង្កេតលើជនសង្ស័យបន្ថែមទៀតទេ។ ការប្រកាសនេះបង្ហាញថា សហព្រះរាជអាជ្ញាអន្តរជាតិមិនមានគោលការណ៍ណាមួយច្បាស់លាស់ក្នុងការកំណត់ ជ្រើសរើសជនសង្ស័យមកធ្វើការវិនិច្ឆ័យទោសទេ។ ប្រសិនបើអនុញ្ញាតិឱ្យមានការកាត់ទោសជនសង្ស័យដែលបានមកអំពីការជ្រើសរើស ដោយចិត្តឯង ដោយពុំមានគោលការណ៍ច្បាស់លាស់នោះ គឺពិតជាមិនអាចផ្តល់យុត្តិធម៌បានឡើយ។

៩២. ចៅក្រមជាតិនៃអ.ប.ជ នៅតែយល់ឃើញថា អ៊ឹម ចែម មិនស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឡើយ ហើយចៅក្រមជាតិនៃអ.ប.ជ ឯកភាពដីកាដំណោះស្រាយរបស់ស.ច.ស ត្រង់ចំណុចថា អ.វ.ត.ក មិនមានយុត្តាធិកាលើអ៊ឹម ចែម និងសម្រេចលើកលែងចោទប្រកាន់ប្រឆាំងអ៊ឹម ចែម។

ភ្នំពេញ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨

ប្រាក់ គឹមសាន | ន័យ ថុល | ហួត វុទ្ធី

[159] មាត្រា ៤៤ និង១២៥ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[160] មាត្រា ១ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ១មាត្រា នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុ ជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និងវិធាន ៥៣ នៃវិធានផ្ទៃក្នុង។

## VIII. យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET

៩៣. ចៅក្រមដែលទទួលបន្ទុក នឹងធ្វើការអធិប្បាយអំពីការពិចារណានូវមូលដ្ឋានចំនួន ប្រាំមួយដែលបានប្តឹងឧទ្ធរណ៍ដោយសហព្រះរាជអាជ្ញាអន្តរជាតិ និងកំណត់អំពីផលប៉ះពាល់នៃកំហុសលើការសន្និដ្ឋានអំពីយុត្តាធិការបុគ្គលរបស់អ.វ.ត.ក លើ អ៊ឹម ចែម ដូចខាងក្រោម។

### ក. <u>មូលដ្ឋានទី ១ ៖ ការចោទប្រកាន់អំពីការខកខានក្នុងការពិចារណាទៅលើបទចោទដែលពុំត្រូវបានចោទជាផ្លូវការ</u>

#### ១. សារណា

៩៤. សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតខកខានមិនបានពិចារណាទៅលើបទចោទទាំងអស់ដែលសហចៅក្រមបានទទួលនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ហើយខកខានក្នុងការពិចារណាទៅលើទឡ្ហីករណ៍នៅក្នុងដីកាសន្និដ្ឋានស្តាពរអំពីរបៀបដែលភស្តុតាងគាំទ្រការទទួលខុសត្រូវរបស់ អ៊ឹម ចែម លើបទឧក្រិដ្ឋមួយចំនួន [161] ។ សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់ជាក់លាក់ចំពោះការសម្រេចថា ច្បាប់ពុំអនុញ្ញាតឲ្យស្នើសុំការចោទប្រកាន់បញ្ជូន អ៊ឹម ចែម ទៅជំនុំជម្រះ ចំពោះបទឧក្រិដ្ឋច្រើនលើសពីបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់មកលើរូបគាត់នោះ [162]។ មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍មួយនេះត្រូវបានគាំទ្រដោយទឡ្ហីករណ៍ចំនួនបួន។

៩៥. ទឡ្ហីករណ៍ទីមួយ អ៊ឹម ចែម ត្រូវបានជូនដំណឹងត្រឹមត្រូវអំពីបទចោទទាំងអស់តាមរយៈការផ្តល់លទ្ធភាពឲ្យពិនិត្យមើលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ហើយបានយល់ថា បើទោះជាពុំត្រូវបានចោទប្រកាន់ជាផ្លូវការក៏ដោយ បទចោទទាំងនេះអាចត្រូវបានស៊ើបសួរ ហើយចុងក្រោយឈានដល់ការចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ។[163] សហព្រះរាជអាជ្ញាអន្តរជាតិគូសបញ្ជាក់ថា អ៊ឹម ចែម បានធ្វើសំណើសុំបំពេញកិច្ចស៊ើបសួរជាក់លាក់ ពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្ម ដែល

---

[161] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១១-១២។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤០-៤១។

[162] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១២ ។

[163] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៣-១៤។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤៦-៤៨។

គាត់ពុំត្រូវបានចោទប្រកាន់ ឧទាហរណ៍ ទំនប់ត្រពាំងថ្ម ដោយបង្ហាញថា គាត់យល់ថា អង្គហេតុទាំងនោះមិនស្ថិតនៅក្នុងវិសាលភាពដែលច្បាប់អនុញ្ញាតឱ្យធ្វើការចោទប្រកាន់បញ្ជូនទៅជំនុំជម្រះបានឡើយ។[164]

៩៦. ទទ្បីករណ៍ទីពីរ សិទ្ធិរបស់សហព្រះរាជអាជ្ញាក្នុងការធ្វើសេចក្ដីសន្និដ្ឋានអំពីភ័ស្តុតាងពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះបទឧក្រិដ្ឋ ដែលពុំត្រូវបានចោទប្រកាន់ជាផ្លូវការ ត្រូវបានបដិសេធ[165] ។ សហព្រះរាជអាជ្ញាអន្តរជាតិបញ្ជាក់ថា សហព្រះរាជអាជ្ញាពុំទទួលបានឱកាសធ្វើសេចក្ដីសន្និដ្ឋានអនុលោមតាមវិធានផ្ទៃក្នុង ឬ តាមរយៈការអញ្ជើញរបស់សហចៅក្រមស៊ើបអង្កេត អំពីបទឧក្រិដ្ឋណាខ្លះដែលត្រូវដាក់បញ្ចូលទៅក្នុងសេចក្ដីជូនដំណឹងអំពីបទចោទផ្សេងៗ អនុលោមតាមវិធាន ៥៧ នៃវិធានផ្ទៃក្នុង [166] ។ សហចៅក្រមស៊ើបអង្កេតមិនអាចគ្រាន់តែទម្លាក់ការស៊ើបសួរលើអង្គហេតុដែលខ្លួនទទួលបានដោយពុំស្ដាប់សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ហើយដោយមិនចេញសេចក្ដីសម្រេចដែលមានសំអាងហេតុនោះទេ បើមិនដូច្នេះ វាគ្មានប្រយោជន៍អ្វីចាំបាច់ចែងប្បញ្ញត្តិនៃវិធាន ៦៦ *ស្ទួន* នៃវិធានផ្ទៃក្នុងដែលអនុញ្ញាតឱ្យបន្ថយវិសាលភាពនៃការស៊ើបសួរក្រោយពីស្ដាប់ភាគីនោះទេ[167]។

៩៧. ទទ្បីករណ៍ទីបី សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សិទ្ធិរបស់គាត់ក្នុងការប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីភ័ស្តុតាងនៃការចោទប្រកាន់ដែលពុំបានចោទជាផ្លូវការក៏ត្រូវបានច្រានចោលផងដែរ ដោយសារតែគ្មាន "សេចក្ដីសម្រេច" សម្រាប់ឱ្យសហព្រះរាជអាជ្ញាប្ដឹងឧទ្ធរណ៍នៅក្នុងអំឡុងពេលណាមួយក្នុងពេលស៊ើបសួរនោះឡើយ[168]។ ប្រសិនបើដីកាដំណោះស្រាយពុំលើកឡើងពីការចោទប្រកាន់ដែលពុំត្រូវបានចោទប្រកាន់ផ្លូវការ ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតបានទទួលរួច

---

[164] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៤។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤៧។

[165] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៥។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤៤-៤៥។

[166] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៥។

[167] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៧។

[168] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៦។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤៥-៤៦។

01575482



ហើយនោះ វាជាការបដិសេធសិទ្ធិរបស់សហព្រះរាជអាជ្ញាក្នុងការប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសំអាងហេតុនៅក្នុងសេចក្ដីសម្រេច ដែលពុំចោទប្រកាន់បទឧក្រិដ្ឋ ឬ ទម្រង់នៃការទទួលខុសត្រូវជាក់លាក់[169]។

៩៨. ទទ្បីករណ៍ទីបួន សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចធ្វើការសម្រេចឱ្យបានច្បាស់លាស់នៅក្នុងដីកាដំណោះស្រាយលើគ្រប់បទចោទដែលពួកគេទទួលបាន ដោយកាតព្វកិច្ចនេះនឹងរលត់ ប្រសិនបើពួកគេអាចចោទប្រកាន់បញ្ជូនទៅជំនុំជម្រះដោយផ្អែកតែទៅលើអង្គហេតុដែលពួកគេចោទប្រកាន់ [170] ។ ជាពិសេស សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់ទៅនឹងការសំអាងរបស់សហចៅក្រមស៊ើបអង្កេតលើដីកាសម្រេចមុនមួយនៅក្នុងសំណុំរឿង ០០២ ("ដីកាបញ្ជាក់បំភ្លឺអំពីបទចោទនៅក្នុងសំណុំរឿង ០០២") យោងតាមដីកាសម្រេចនេះ សហចៅក្រមស៊ើបអង្កេត "មិនអាចចោទប្រកាន់បញ្ជូនជនណាម្នាក់ទៅជំនុំជម្រះលើអង្គហេតុពាក់ព័ន្ធដែលបុគ្គលនោះពុំត្រូវបានចោទប្រកាន់ពីដំបូងនោះឡើយ" ហើយអះអាងថា ការសម្រេចនេះមិនត្រូវមិនពិចារណានោះទេ [171] ។ តាមការយល់ឃើញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដីកាបញ្ជាក់បំភ្លឺនៅក្នុងសំណុំរឿង ០០២ នេះ នៅពេលពិនិត្យទាំងស្រុងទៅ គ្រាន់តែបញ្ជាក់អំពីការអនុវត្តនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡូ គឺថា បុគ្គលម្នាក់មិនអាចត្រូវចោទប្រកាន់បញ្ជូនទៅជំនុំជម្រះចំពោះបទចោទនោះទេ លើកលែងតែចៅក្រមស៊ើបសួរបានទទួលអង្គហេតុទាំងនោះត្រឹមត្រូវទៅតាមដីកាសន្និដ្ឋានរបស់ស្ថាប័នអយ្យការ[172]។

៩៩. សហមេធាវីការពារក្ដីឆ្លើយតបថា ការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងច្បាប់ដែលមានអានុភាពអនុវត្តគឺជាការយល់ខុសលើអង្គច្បាប់ និងអង្គហេតុ[173]។ ជាពិសេស កាតព្វកិច្ចក្នុងការឆ្លើយតបទៅនឹងបទចោទនីមួយៗកើតមាន តែក្នុងករណីដែលមានការសម្រេចលើយុត្តាធិការរួចហើយតែប៉ុណ្ណោះ ដែលនេះជាលក្ខខណ្ឌមិនអាចខ្វះបានក្នុងការធ្វើសេចក្ដីសម្រេចលើអង្គសេចក្ដីនៃរឿងក្ដី[174]។ សហមេធាវីបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេតបានពិចារណាត្រឹមត្រូវលើបទចោទទាំងអស់ដែលសហ

---

[169] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៦។

[170] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៩។

[171] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៨-២២។ *សូមមើលផងដែរ* សំណុំរឿង ០០២ ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យបំភ្លឺអំពីបទចោទ ("ដីកាសម្រេចលើការបញ្ជាក់បំភ្លឺអំពីបទចោទក្នុងសំណុំរឿង ០០២ (ឯកសារ D198/1)") ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D198/1 កថាខណ្ឌ ១០។

[172] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២២។

[173] ចម្លើយតប កថាខណ្ឌ ២៦-២៧។

[174] ចម្លើយតប កថាខណ្ឌ ២៩-៣០។

ចៅក្រមស៊ើបអង្កេតបានទទួលនៅក្នុងដីកាដំណោះស្រាយ [175] ហើយ អ៊ឹម ចែម នៅតែស្ថិតនៅក្រៅវង្វង់យុត្តាធិការនៃ អ.វ.ត.ក ដដែល បើទោះជាគាត់ត្រូវបានចោទប្រកាន់លើបទចោទពីអង្គហេតុដែលពុំត្រូវចោទប្រកាន់ជាផ្លូវការទាំងនោះក្តី[176]។

១០០. សហមេធាវីការពារក្តីអះអាងបន្ថែមទៀតថា ការជូនដំណឹងពីបទចោទ មិនមែនដីកាសន្និដ្ឋានរបស់ស្ថាប័នអយ្យការទេ មានបំណងជូនដំណឹងអំពីបទចោទឱ្យបានល្អិតអំពីលក្ខណៈ និងមូលហេតុនៃការចោទប្រកាន់ ដូចដែលបានសម្រេចយ៉ាងជាក់លាក់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅពេលដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការត្រួតពិនិត្យ*ដោយកំបាំងមុខ* នោះ [177] ។ សហមេធាវីការពារក្តីបញ្ជាក់ថា ការជូនដំណឹងអំពីបទចោទគឺជាសេចក្តីសម្រេចរបស់តុលាការដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតក្រោយរកឃើញភ័ស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់អំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌលើជនសង្ស័យរួច [178] ។ ទោះបីជា អ៊ឹម ចែម អាចត្រូវបានចោទប្រកាន់លើបទឧក្រិដ្ឋបន្ថែមនៅក្នុងអំឡុងពេលស៊ើបអង្កេត ហើយនៅក្នុងបរិបទនេះ បានដាក់សំណើសុំនានា រួមទាំង សំណើសុំពាក់ព័ន្ធនឹងទំនប់ត្រពាំងថ្មក៏ដោយ មានតែសេចក្តីជូនដំណឹងអំពីបទចោទប៉ុណ្ណោះដែលបានផ្តល់ព័ត៌មានស្តាពរអំពីការកំណត់ពីវិសាលភាពនៃការចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះដែលអាចមាន ក្រោយការបញ្ចប់កិច្ចស៊ើបសួរ [179] ។ ការចោទប្រកាន់បទឧក្រិដ្ឋនៅក្រៅបទចោទទាំងនោះ លែងមានភាពពាក់ព័ន្ធទៀតហើយ ឬ ពុំមែនជាកម្មវត្ថុនៃការត្រៀមរៀបចំក្នុងការការពារក្តីឡើយ[180]។

១០១. សហមេធាវីក៏អះអាងផងដែរថា ទឡ្ហីករណ៍ពាក់ព័ន្ធនឹងសិទ្ធិក្នុងការធ្វើសេចក្តីសន្និដ្ឋាន និងសិទ្ធិប្តឹងឧទ្ធរណ៍ គ្មានភាពសមស្របឡើយ [181] ។ សហចៅក្រមស៊ើបអង្កេតមានអំណាចក្នុងការកំណត់ថាតើអង្គ

---

[175] ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/2.1) ទំព័រ ៣៥-៣៧ *ដែលយោងលើ* ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៤៤-២៤៦។

[176] ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/2.1) ទំព័រ ៣៥-៣៦ *ដែលយោងលើ* ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៤៦-២៤៧។

[177] ចម្លើយតប កថាខណ្ឌ ២៧-២៨ *ដែលយោងលើ* សេចក្តីសម្រេចចោទប្រកាន់*កំបាំងមុខ* (ឯកសារ D239) កថាខណ្ឌ ៧៥។

[178] ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/2.1) ទំព័រ ៣៩-៤០ *ដែលយោងលើ* ដីកាសម្រេចបដិសេធសំណើសុំដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យបន្ថែម ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ D298/2 កថាខណ្ឌ ១៣។

[179] ចម្លើយតប កថាខណ្ឌ ៣១-៣៣។

[180] ចម្លើយតប កថាខណ្ឌ ៣៣។

[181] ចម្លើយតប កថាខណ្ឌ ៣៤, ៣៧។

ហេតុណាមួយអាចជាមូលដ្ឋាននៃបទចោទ ហើយទាំងសហព្រះរាជអាជ្ញា ឬ មេធាវីការពារក្តីពុំមានសិទ្ធិក្នុងការធ្វើសេចក្តីសន្និដ្ឋាននៅមុនពេលសម្រេចសេចក្តីលើករណីនេះទេ[182]។ ដូច្នេះ ការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិថា គាត់ពុំត្រូវបានអញ្ជើញឱ្យធ្វើសេចក្តីសន្និដ្ឋាន មិនសមហេតុផលនោះទេ ដោយសារវិធាន ៥៧ នៃវិធានផ្ទៃក្នុង ពុំផ្តល់សិទ្ធិមានវត្តមានរបស់គាត់ នៅក្នុងអំឡុងពេលនៃសវនាការបង្ហាញខ្លួនលើកដំបូងនិងដោយសារ អ៊ឹម ចែម ត្រូវបានជូនដំណឹងអំពីបទចោទតាមរយៈសេចក្តីសម្រេចតុលាការ[183]។ ចំណាត់ការសមហេតុផលគឺការដាក់សេចក្តីសន្និដ្ឋានដោយខ្លួនឯងដាច់ដោយឡែកស្នើសុំឱ្យកែប្រែបទចោទតែប៉ុណ្ណោះ[184]។ សហមេធាវីការពារក្តីបញ្ជាក់ទៀតថា សហព្រះរាជអាជ្ញាមានសិទ្ធិប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ*ដោយកំបាំងមុខ* បាន និងមានសិទ្ធិលើកឡើងការជំទាស់អំពីសំអាងហេតុនៃសេចក្តីសម្រេចមិនចោទប្រកាន់អង្គហេតុជាក់លាក់បាន ក៏ប៉ុន្តែ សហព្រះរាជអាជ្ញាមិនបានធ្វើដូច្នេះឡើយ[185]។ ចុងក្រោយ ការយោងទៅវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង មិនសមហេតុផលនោះទេ ដោយសារសហចៅក្រមស៊ើបអង្កេតពុំបានបន្ថយវិសាលភាពនៃការស៊ើបអង្កេត ដោយគ្រាន់តែសម្រេចមិនចោទប្រកាន់អង្គហេតុមួយចំនួន ពីព្រោះលក្ខខណ្ឌអប្បបរមាពុំត្រូវបានបំពេញប៉ុណ្ណោះ[186]។

១០២. សហព្រះរាជអាជ្ញាអន្តរជាតិឆ្លើយតបថា ការអះអាងរបស់សហមេធាវីការពារក្តីពុំមានមូលដ្ឋានគាំទ្រ ហើយផ្ទុយពីយុត្តិសាស្ត្ររបស់ អ.វ.ត.ក[187]។ ជាពិសេស សហព្រះរាជអាជ្ញាអន្តរជាតិយោងទៅសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០១ ដែលនៅក្នុងសាលដីកានោះអង្គបុរេជំនុំជម្រះលើកឡើងអំពីការកំណត់បទចោទឡើងវិញ ហើយបានយល់ឃើញថា ឧក្រិដ្ឋកម្មដែលពុំត្រូវបានចោទប្រកាន់ជាផ្លូវការ អាចត្រូវដាក់បន្ថែមនៅក្នុងដីកាដំណោះស្រាយបាន ប្រសិនបើបទឧក្រិដ្ឋជាមូលដ្ឋានទាំងនោះត្រូវបានបញ្ចូលនៅក្នុងដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា[188]។ សហព្រះរាជអាជ្ញាអន្តរជាតិបញ្ជាក់ថា អង្គបុរេជំនុំជម្រះបានសម្រេចដោយគ្មានចំណុចស្រពិចស្រពិលថា សហចៅក្រមស៊ើបអង្កេត

---

[182] ចម្លើយតប កថាខណ្ឌ ៣៤។

[183] ចម្លើយតប កថាខណ្ឌ ៣៥។

[184] ចម្លើយតប កថាខណ្ឌ ៣៦។

[185] ចម្លើយតប កថាខណ្ឌ ៣៨។

[186] ចម្លើយតប កថាខណ្ឌ ៣៩។

[187] ការឆ្លើយតប កថាខណ្ឌ ១២-១៣។

[188] ការឆ្លើយតប កថាខណ្ឌ ១៣-១៤ *ដែលយោងលើ* កថាខណ្ឌ ១០៤-១០៥, ១០៧។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤២-៤៣។

ត្រូវសម្រេចនៅក្នុងដីកាដំណោះស្រាយអំពីអង្គហេតុទាំងអស់ដែលជាផ្នែកនៃកិច្ចស៊ើបសួរ ដោយពុំបានយោងលើដំណើរការនៃការចោទប្រកាន់ផ្លូវការនោះឡើយ[189]។ យើងក៏មិនឃើញមានការបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងអនុលោមតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុងថា បទចោទដែលដីកាដំណោះស្រាយនឹងយកមកធ្វើជាមូលដ្ឋាន នឹងកម្រិតត្រឹមបទចោទទាំងឡាយដែលត្រូវបានចោទប្រកាន់នោះឡើយ[190]។

១០៣. សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់ទៅនឹងការអះអាងថា កាតព្វកិច្ចក្នុងការឆ្លើយតបទៅនឹងបទចោទនីមួយៗកើតឡើងតែនៅពេលមានការសម្រេចលើយុត្តាធិការរួចហើយទេ ដោយសារតែការវាយតម្លៃសមហេតុផលលើយុត្តាធិការអាចធ្វើឡើងតែនៅពេលអង្គហេតុពាក់ព័ន្ធទាំងអស់ត្រូវបានពិនិត្យរួចរាល់ប៉ុណ្ណោះ[191]។ សេចក្តីសន្និដ្ឋានស្តីពីការគ្មានយុត្តាធិការបុគ្គលពុំអាចឱ្យសហចៅក្រមស៊ើបអង្កេតរួចផុតកាតព្វកិច្ចក្នុងការធ្វើការសម្រេចលើអង្គហេតុលើបទចោទទាំងអស់ ហើយពុំរារាំងការសម្រេចលើលទ្ធភាពនៃការទទួលខុសត្រូវរបស់ អ៊ឹម ចែម លើបទឧក្រិដ្ឋនោះទេ[192]។ គាត់បន្ថែមថា សហមេធាវីការពារក្តីពុំបានព្យាយាមផ្តល់យុត្តិកម្មចំពោះការខកខានរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចោទប្រកាន់បទឧក្រិដ្ឋមួយចំនួន ដែលវាមិនអាចឱ្យសម្រេចថាតើការវាយតម្លៃលើយុត្តាធិការបុគ្គលអាចនឹងមានការផ្លាស់ប្តូរយ៉ាងដូចម្តេច ប្រសិនបើបទចោទទាំងអស់ត្រូវបានពិចារណារួចហើយនោះ[193]។

១០៤. សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានបន្ថែមថា សេចក្តីសន្និដ្ឋានរបស់សហមេធាវីការពារក្តីមានលក្ខណៈផ្ទុយគ្នានឹងការយល់ដឹងរបស់ពួកគាត់ថា បើទោះអង្គហេតុបាន ឬ មិនបានចោទប្រកាន់ក៏ដោយ វាអាចនាំឱ្យមានដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ ហើយបញ្ជាក់ថា សហមេធាវីការពារក្តីពិតជាបានស្នើសុំមោឃភាពផ្នែកផ្សេងៗនៃកិច្ចស៊ើបអង្កេតពាក់ព័ន្ធនឹងទំនប់ត្រពាំងថ្ម និងចំការខ្នុរ ក្រោយពេលជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ[194]។ ចុងក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សហមេធាវីការ

---

[189] ការឆ្លើយតប កថាខណ្ឌ ១៥-១៧ *ដែលយោងលើ* សាលដីកាលើដីកាដំណោះស្រាយក្នុងសំណុំរឿង ០០១ (ឯកសារ D99/3/42) កថាខណ្ឌ ២៩, ៣២-២៩។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤៦។

[190] ការឆ្លើយតប កថាខណ្ឌ ១៨-១៩។

[191] ការឆ្លើយតប កថាខណ្ឌ ២១។

[192] ការឆ្លើយតប កថាខណ្ឌ ២២។

[193] ការឆ្លើយតប កថាខណ្ឌ ២៤។

[194] ការឆ្លើយតប កថាខណ្ឌ ២៥-២៨។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤៧។

ពារក្តី បានបកស្រាយខុសលើសិទ្ធិរបស់សហព្រះរាជអាជ្ញាក្នុងការធ្វើសេចក្តីសន្និដ្ឋាន[195] និងសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍[196]។

## ២. កិច្ចពិភាក្សា

១០៥. ចៅក្រមទទួលបន្ទុក នឹងពិចារណាជាបន្តបន្ទាប់អំពី (ក) តើសេចក្តីជូនដំណឹងអំពីបទចោទកម្រិតវិសាលភាពដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះដែរឬទេ (ខ) តើសិទ្ធិរបស់សហព្រះរាជអាជ្ញានៅក្នុងការអន្តរាគមន៍នៅក្នុងកិច្ចដំណើរការនីតិវិធីត្រូវបានរំលោភបំពានដែរឬទេ និង (គ) តើសហចៅក្រមស៊ើបអង្កេតមានភារកិច្ចចេញសេចក្តីសម្រេចលើអង្គហេតុទាំងអស់ដែលពួកគេបានទទួលត្រឹមត្រូវដែរឬទេ។

### ក. សេចក្តីជូនដំណឹងអំពីបទចោទ និងវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ

១០៦. វិធាន ៦៧ នៃវិធានផ្ទៃក្នុង ចែងត្រង់ផ្នែកពាក់ព័ន្ធថា៖

១. សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរដោយចេញដីកាដំណោះស្រាយថាត្រូវចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់។ ដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាមិនចងសហចៅក្រមស៊ើបអង្កេតឡើយ។

២. ដីកបញ្ជូនរឿងទៅជំនុំជម្រះនេះត្រូវបញ្ជាក់អំពីអត្តសញ្ញាណនៃជនជាប់ចោទ ការបង្ហាញអំពីអង្គហេតុ និងការកំណត់បទល្មើសដោយសហចៅក្រមស៊ើបអង្កេត ក្នុងនោះមានទាំងបទប្បញ្ញត្តិនៃបទឧក្រិដ្ឋដែលពាក់ព័ន្ធ និងប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ បើពុំនោះសោត ដីកានេះត្រូវចាត់ទុកជាមោឃៈដោយមានកំហុសនីតិវិធី។

៣. សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាលើកលែងចោទប្រកាន់ក្នុងករណីដូចខាងក្រោម៖

ក.អំពើដែលចោទប្រកាន់មិនរាប់ចូលជាបទឧក្រិដ្ឋ ដែលស្ថិតនៅក្រោមយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ។

ខ. ជនប្រព្រឹត្តបទឧក្រិដ្ឋនោះមិនទាន់កំណត់អត្តសញ្ញាណនៅឡើយ ឬ

---

[195] ការឆ្លើយតប កថាខណ្ឌ ២៩-៣០។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤៤-៤៥។

[196] ការឆ្លើយតប កថាខណ្ឌ ៣១-៣២។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤៥។

គ. ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនត្រូវចោទ។

១០៧. វិធាន ៥៧(១) នៃវិធានផ្ទៃក្នុង ដែលដូចគ្នានឹងមាត្រ ១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែង អំពីដំណើរការនៃការចោទប្រកាន់៖

"នៅពេលជនត្រូវចោទចូលបង្ហាញខ្លួន ចំពោះមុខសហចៅក្រមស៊ើបអង្កេតជាលើកដំបូង សហចៅក្រមស៊ើបអង្កេតត្រូវកត់ត្រាទុកនូវអត្តសញ្ញាណរបស់ជននោះ និងប្រាប់ជននោះអំពីបទចោទប្រកាន់ និងអំពីសិទ្ធិមាន មេធាវី និងសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយនឹងសំណួរ។ ជនត្រូវចោទមានសិទ្ធិពិគ្រោះជាមួយមេធាវីមុនពេលដែលខ្លួនត្រូវបានសួរចម្លើយ និងមានមេធាវីអមជាមួយនៅក្នុងពេលសួរចម្លើយ។ ប្រសិនបើជនត្រូវចោទយល់ព្រម ឆ្លើយនោះសហចៅក្រមស៊ើបអង្កេត ត្រូវធ្វើការសួរចម្លើយនោះភ្លាម។ កំណត់ហេតុសួរចម្លើយត្រូវដាក់ចូលក្នុងសំណុំរឿង"។

១០៨. វិធាន ៥៥(៤) នៃវិធានផ្ទៃក្នុងចែងបំភ្លឺសំអាងហេតុដែលសហចៅក្រមស៊ើបអង្កេតអាចសម្រេចចោទប្រកាន់ចំពោះការប្រព្រឹត្តបទឧក្រិដ្ឋ៖

"សហចៅក្រមស៊ើបអង្កេតមានអំណាចបើកការស៊ើបសួរប្រឆាំងនឹងជនទាំងឡាយណា ដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេត អាចបើកកិច្ចស៊ើបសួរផងដែរ ចំពោះបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា បុគ្គលនោះអាចជាអ្នកទទួលខុសត្រូវក្នុងការប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទោះបីជាបុគ្គលទាំងនោះមិនមានឈ្មោះក្នុងដីកាក៏ដោយ"។

១០៩. ការជូនដំណឹងអំពីបទចោទជាលទ្ធផលនឹងទុកលទ្ធភាពជូនសហចៅក្រមស៊ើបអង្កេតលើកឡើង ដោយអាចចោទប្រកាន់បុគ្គល ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានរបស់ស្ថាប័នអយ្យការ ឬ ដោយគ្មានឈ្មោះបុគ្គល។ លក្ខណវិនិច្ឆ័យតែមួយគត់លើការចោទប្រកាន់គឺថាតើ បើតាមការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេត "មាន*តម្រុយច្បាស់លាស់ និងស៊ីសង្វាក់* បញ្ជាក់ថា បុគ្គលនោះអាចជាអ្នកទទួលខុសត្រូវក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ" ដែរឬទេ[197]។ ហេតុដូច្នេះ នៅក្នុងប្រព័ន្ធនីតិវិធីដឹកនាំដោយចៅក្រម ដំណើរការចោទប្រកាន់គឺជាសេចក្តីសម្រេចរបស់តុលាការដែលតាមរយៈសេចក្តីសម្រេចនេះ ជនសង្ស័យ ពុំមែនត្រឹមតែត្រូវបានចោទប្រកាន់ជាផ្លូវការអំពីបទឧក្រិដ្ឋដែលខ្លួនស្ថិតក្រោមការស៊ើបអង្កេតប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវបានជូនដំណឹងថា មានភស្តុតាងក្នុងកម្រិតមួយត្រូវបានប្រមូលដាក់បន្ទុកលើខ្លួនផងដែរ។ ម្យ៉ាងវិញ

[197] វិធាន ៥៥(៤) នៃវិធានផ្ទៃក្នុង (គូសបញ្ជាក់បន្ថែម)។

ទៀត តាមរយៈសេចក្តីជូនដំណឹងអំពីបទចោទនេះ ជនសង្ស័យត្រូវបានផ្តល់ឱកាសឱ្យឆ្លើយតបទៅនឹងបទចោទ និងត្រៀមរៀបចំការការពារក្តីក្នុងកម្រិតមួយអាចឱ្យជនសង្ស័យមានលទ្ធភាពដើរតួនាទីសកម្មនៅក្នុងកិច្ចដំណើរការនីតិវិធី និងក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន [198] ។ តាមការយល់ឃើញរបស់ស្ថាប័នអយ្យការ ដំណើរការចោទប្រកាន់ក៏បង្ហាញច្បាស់អំពីបទចោទណា ក្នុងចំណោមបទចោទជាបឋម ដែលត្រូវរក្សាទុក។

១១០. យោងតាមសំអាងហេតុដូចបានរៀបរាប់ខាងលើ អង្គបុរេជំនុំជម្រះនាពេលថ្មីៗនេះបានបញ្ជាក់ថា "នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡូ មានតែអង្គហេតុដែលត្រូវបានចោទប្រកាន់ជាមុនតែប៉ុណ្ណោះទើបអាចយកមកពិចារណាចោទប្រកាន់បញ្ជូនទៅជំនុំជម្រះបាន"[199] ហើយ "ដំណើរការចោទប្រកាន់ជាលក្ខខណ្ឌតម្រូវសម្រាប់ការចោទប្រកាន់បញ្ជូនទៅជំនុំជម្រះនាពេលបន្តបន្ទាប់"[200] ។ នៅក្នុងដីកាសម្រេចស្តីពីការបញ្ជាក់បំភ្លឺអំពីបទចោទនៅក្នុងសំណុំរឿង ០០២ [201] សហចៅក្រមស៊ើបអង្កេតក៏បានបញ្ជាក់យ៉ាងច្បាស់តែម្តងផងដែរថា សហចៅក្រមស៊ើបអង្កេត "មិនអាចនឹងធ្វើការបញ្ជូនបុគ្គលណាមួយទៅជំនុំជម្រះចំពោះអង្គហេតុណាដែលបុគ្គលនោះមិនត្រូវបានដាក់ឱ្យឋិតក្រោមការត្រួតពិនិត្យជាមុននោះទេ" [202] ហើយសហចៅក្រមស៊ើបអង្កេតនឹងធ្វើសេចក្តីសម្រេចនៅក្នុងដីកាដំណោះស្រាយពាក់ព័ន្ធនឹងអង្គហេតុទាំងអស់ដែលពួកគេបានទទួលយ៉ាងត្រឹមត្រូវ "តាមរយៈការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ដីកាលើកលែងការចោទប្រកាន់"[203]។

---

[198] សំណុំរឿង ០០៤ (អបជ៥២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរទាក់ទងនឹងអំពើហិង្សាផ្លូវភេទនៅគុកលេខ ៨ និងស្រុកបាកាន ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកសារ D365/3/1/5 ("សាលដីកាលើកិច្ចស៊ើបសួរទាក់ទងនឹងអំពើហិង្សាផ្លូវភេទ (ឯកសារ D365/3/1/5)") កថាខណ្ឌ ៣៦ (សំណុំរឿង ០០១ សាដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ) *ដែលយោងលើ*សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយបញ្ជូន ឌុច ទៅជំនុំជម្រះ កថាខណ្ឌ ១៣៨។ សំណុំរឿង ០០២ (អបជ៣២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចពន្យារពេលឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ ឯកសារ C22/9/14 កថាខណ្ឌ ២៦។

[199] សាលដីកាលើកិច្ចស៊ើបសួរទាក់ទងនឹងអំពើហិង្សាផ្លូវភេទ (ឯកសារ D365/3/1/5)") កថាខណ្ឌ ៣៥។

[200] សាលដីកាលើកិច្ចស៊ើបសួរទាក់ទងនឹងអំពើហិង្សាផ្លូវភេទ (ឯកសារ D365/3/1/5)") កថាខណ្ឌ ៣៦។

[201] សូមមើល បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៨-២២។

[202] ដីកាសម្រេចលើការបញ្ជាក់បំភ្លឺអំពីបទចោទក្នុងសំណុំរឿង ០០២ (ឯកសារ D198/1) កថាខណ្ឌ ១០ (ការគូសបញ្ជាក់បន្ថែម)។

[203] ដីកាសម្រេចលើការបញ្ជាក់បំភ្លឺអំពីបទចោទក្នុងសំណុំរឿង ០០២ (ឯកសារ D198/1) ផ្នែកសេចក្តីសម្រេច ទំព័រ ៦(ការគូស

01575489



១១១. ការសម្រេចទាំងនេះផ្ទុះបញ្ចាំងពីពាក្យពេចន៍នៃវិធាន ៦៧(១) នៃវិធានផ្ទៃក្នុង អនុលោមតាមវិធាននេះ ដីកាដំណោះស្រាយអាចចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ "*ជនត្រូវចោទ*" ហើយដូចគ្នានឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាជាធរមាន និងក្រមនីតិវិធីព្រហ្មទណ្ឌបារាំងផងដែរ។ ចៅក្រមទទួលបន្ទុកបញ្ជាក់ឲ្យបានជាក់លាក់លើប្បញ្ញត្តិនៃមាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងមាត្រា ១៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ដែលយោងតាមក្រមនេះ សហចៅក្រមស៊ើបសួរត្រូវសម្រេច ប្រសិនបើខ្លួនពិចារណាឃើញថា "*បទចោទ* ដែលទទួលបានប្រឆាំងនឹងបុគ្គល *ក្រោមការត្រួតពិនិត្យរបស់តុលាការ*"[204] គឺជាបទឧក្រិដ្ឋ "ដើម្បីចោទប្រកាន់បញ្ជូន*ជនត្រូវចោទ* ទៅជំនុំជម្រះនៅចំពោះមុខសាលាដំបូង"[205] ។ ស្រដៀងគ្នានេះដែរ សភាស៊ើបសួរត្រូវចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ "ប្រសិនបើ *បទចោទ* ប្ដឹងប្រឆាំងនឹងបុគ្គលដែលដាក់ឲ្យស្ថិតនៅ*ក្រោមការត្រួតពិនិត្យរបស់តុលាការ* គឺជាបទល្មើសដែលត្រូវបានចាត់ថ្នាក់ជាបទឧក្រិដ្ឋតាមច្បាប់"[206] ។ យុត្តិសាស្ត្ររបស់តុលាការកំពូលនៃប្រទេសបារាំងក៏បានបញ្ជាក់ច្បាស់ដែលថា នៅពេលចេញដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរសម្រេចថាតើបទចោទដែលបានទទួលប្រឆាំងនឹងបុគ្គលដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការគឺជាបទឧក្រិដ្ឋដែរឬទេ [207] ដែលវាបង្កប់ន័យថា មានតែជនដែលត្រូវបានចោទប្រកាន់ជាមុនប៉ុណ្ណោះទើបអាចចោទប្រកាន់បញ្ជូនទៅជំនុំជម្រះបាន [208] ។ សាលាដំបូងដែលប្រឈមនឹងស្ថានភាពបុគ្គលត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះពុំត្រូវបានចោទប្រកាន់ជាមុននោះ ត្រូវបញ្ជូនសំណុំរឿងត្រឡប់មកឲ្យរដ្ឋអាជ្ញាវិញ ដើម្បីផ្ដល់លទ្ធភាពឲ្យគាត់ទទួលសាជាថ្មីនូវសិទ្ធិស៊ើបអង្កេតតាមផ្លូវតុលាការម្ដងទៀត ក្នុងគោលដៅធ្វើនីយ័តកម្មកិច្ចដំណើរការនីតិវិធី[209]។

---

បញ្ជាក់បន្ថែម)។

[204] ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ១៨១ (ការបកប្រែក្រៅផ្លូវការ) (ការគូសបញ្ជាក់បន្ថែម)។

[205] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៤៧ (ការបកប្រែក្រៅផ្លូវការ) (ការគូសបញ្ជាក់បន្ថែម)។

[206] ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ២១៤ (ការបកប្រែក្រៅផ្លូវការ) (ការគូសបញ្ជាក់បន្ថែម) ។ មាត្រា ២៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា បទប្បញ្ញត្តិនៃមាត្រា ២៤៧ ទាក់ទងនឹងដីកាដំណោះស្រាយដែលចេញដោយចៅក្រមស៊ើបសួរ ត្រូវអនុវត្តលើដីកាដំណោះស្រាយដែលចេញដោយសភាស៊ើបសួរ ក្នុងអានុភាពដូចគ្នាដែរ។

[207] *សូមមើល ឧទា.* តុលាការកំពូលព្រហ្មទណ្ឌបារាំង ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៧ សំណុំរឿងលេខ 17-84473។ តុលាការកំពូលព្រហ្មទណ្ឌបារាំង ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣ សំណុំរឿងលេខ 12-87137។ តុលាការកំពូលព្រហ្មទណ្ឌបារាំង ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៨ សំណុំរឿងលេខ 17-88314 & 07-88315។

[208] *សូមមើល ឧទា.* តុលាការកំពូលព្រហ្មទណ្ឌបារាំង ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៤ សំណុំរឿងលេខ 17-84187។

[209] *សូមមើល ឧទា.* តុលាការកំពូលព្រហ្មទណ្ឌបារាំង ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៤ សំណុំរឿងលេខ 04-83670។ *សូមមើល ឧទា.* តុលាការកំពូលព្រហ្មទណ្ឌបារាំង មាត្រា ៣៨៥។

១១២. អាស្រ័យហេតុនេះ ចៅក្រមទទួលបន្ទុក យល់ឃើញថា ជនសង្ស័យដំបូងត្រូវតែទទួលការចោទប្រកាន់ជាមុននៅមុនពេលបញ្ជូនទៅជំនុំជម្រះ។ ករណីដែលថា សហមេធាវីការពារក្ដីបានលើកទឡ្ហីករណ៍ផ្លូវច្បាប់ពាក់ព័ន្ធនឹងការចោទប្រកាន់នៅទីតាំងឧក្រិដ្ឋកម្ម ក្រៅពី បទចោទដែលបានចោទប្រកាន់ជាផ្លូវការពុំបានបន្ថយលក្ខខណ្ឌនីតិវិធីនេះទេ ជាពិសេស ដោយសារតែ អ៊ឹម ចែម អាចត្រូវបានចោទប្រកាន់លើបទឧក្រិដ្ឋផ្សេងៗទៀតនៅក្នុងពេលស៊ើបអង្កេតនាពេលណាមួយរហូតដល់ពេលចេញដីកាដំណោះស្រាយ។ លើសពីនេះទៀត ចៅក្រមទទួលបន្ទុកច្រានចោលសេចក្ដីសន្និដ្ឋានពាក់ព័ន្ធនឹងវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុងថាមិនពាក់ព័ន្ធ ដោយវិធាននេះពុំអាចអនុវត្តនៅក្នុងរឿងក្ដីបច្ចុប្បន្ននេះបានទេ។

### ខ. <u>សិទ្ធិរបស់សហព្រះរាជអាជ្ញាក្នុងការអន្តរាគមន៍នៅក្នុងកិច្ចដំណើរការនីតិវិធី</u>

១១៣. ទោះបីជាសេចក្ដីសម្រេចចោទប្រកាន់ជនសង្ស័យត្រូវបានធ្វើឡើងដោយភាគីតែម្ខាង សហព្រះរាជអាជ្ញាមានសិទ្ធិចូលរួមក្នុងការស៊ើបអង្កេតបាន[210]។ វិធានផ្ទៃក្នុងផ្ដល់មធ្យោបាយនានាឱ្យសហព្រះរាជអាជ្ញាអន្តរាគមន៍នៅក្នុងកិច្ចដំណើរការនីតិវិធី រួមទាំង តាមរយៈការធ្វើសំណើសុំឱ្យសហចៅក្រមស៊ើបអង្កេត "ចេញដីកា ឬ ធ្វើការបំពេញកិច្ចស៊ើបសួរទាំងនោះដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថាមានសារប្រយោជន៍ក្នុងការដឹកនាំការស៊ើបអង្កេត" អនុលោមតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង។

១១៤. ដូច្នេះ វាបើកឱកាសឱ្យសហព្រះរាជអាជ្ញាស្នើសុំបន្ថែមបទចោទក្នុងទម្រង់ជាសំណើសុំបំពេញកិច្ចស៊ើបសួរនៅពេលណាក៏ដោយក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ហើយលើកបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបដិសេធបាន មិនថា ដោយជាក់លាក់ ឬ ដោយតណ្ហីភាពឡើយ ដោយផ្អែកលើការបដិសេធតាមការសន្មត អនុលោមតាមវិធាន ៥៥(១០) និងវិធាន ៧៤(២) នៃវិធានផ្ទៃក្នុង[211]។ ជាការពិត អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាបានប្រើប្រាស់នីតិវិធីនេះនៅពេលសហព្រះរាជអាជ្ញាបានស្នើសុំការចោទប្រកាន់បន្ថែមនៅក្នុងសំណុំរឿង ០០២[212] ដោយបានទទួលស្គាល់ច្បាស់លាស់នៅពេលនោះ

---

[210] សាលដីកាលើកិច្ចស៊ើបសួរទាក់ទងនឹងអំពើហិង្សាផ្លូវភេទ (ឯកសារ D365/3/1/5)") កថាខណ្ឌ ៣៨ *ដែលយោងលើ* សំណុំរឿង ០០៤ (អបជ១៩) សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យកំបាំងមុខ មតិយោបល់ចៅក្រម BEAUVALLET និង BWANA ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០១៦ ឯកសារ D239/1/8 កថាខណ្ឌ ១៩, ២១។

[211] សាលដីកាលើកិច្ចស៊ើបសួរទាក់ទងនឹងអំពើហិង្សាផ្លូវភេទ (ឯកសារ D365/3/1/5)") កថាខណ្ឌ ៣៨។

[212] សំណុំរឿង ០០២ សំណើរបស់សហព្រះរាជអាជ្ញាសុំធ្វើសេចក្ដីជូនដំណឹងអំពីបទចោទប្រកាន់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ ឯកសារ D334 ("សំណើរបស់សហព្រះរាជអាជ្ញាសុំដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យបន្ថែម

ថា សហចៅក្រមស៊ើបអង្កេតមិនអាចចោទប្រកាន់បញ្ជូនជនណាម្នាក់ទៅជំនុំជម្រះបាននោះទេចំពោះអង្គហេតុពាក់ព័ន្ធដែលជននោះពុំត្រូវបានចោទប្រកាន់ជាមុននោះ[213]។ ដូច្នេះ វាគ្មានអ្វីគួរសង្ស័យឡើយថា សហព្រះរាជអាជ្ញាបានដឹងថា ពួកគេត្រូវបំផុសសេចក្តីសម្រេចពីសហចៅក្រមស៊ើបអង្កេតអំពីបទចោទបន្ថែម ហើយនៅចុងក្រោយអាចធ្វើការប្តឹងឧទ្ធរណ៍បាន ប្រសិនបើសេចក្តីសម្រេចមិនឆ្លើយតបទៅនឹងការពេញចិត្តរបស់ពួកគេ។

១១៥. នៅក្នុងករណីបច្ចុប្បន្ន អង្គបុរេជំនុំជម្រះសន្និដ្ឋានថា សហព្រះរាជអាជ្ញាខកខានមិនបានប្រើប្រាស់សិទ្ធិរបស់ពួកគេក្នុងការអន្តរាគមន៍ឱ្យបានសមស្របទៅតាមពេលវេលាត្រឹមត្រូវ ហើយសហព្រះរាជអាជ្ញាអន្តរជាតិ មិនអាចគ្រាន់តែផ្តល់ទឡ្ហីករណ៍នៅក្នុងដំណាក់កាលនេះថា បទចោទពុំបានឆ្លុះបញ្ចាំងការរំពឹងទុករបស់ខ្លួនបាននោះទេ។ អាស្រ័យហេតុនេះ មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ត្រង់ផ្នែកនេះត្រូវបានច្រានចោល។

### គ. <u>ភារកិច្ចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញសេចក្តីសម្រេចលើអង្គហេតុទាំងអស់</u>

១១៦. ចៅក្រមទទួលបន្ទុកសូមរម្លឹកថា អនុលោមតាមវិធាន ៥៥(២) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតមានភារកិច្ចស៊ើបអង្កេត*ដោយផ្ទាល់* លើអង្គហេតុសំខាន់ៗទាំងអស់ដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានរបស់ស្ថាប័នអយ្យការ [214] ។ សហចៅក្រមស៊ើបអង្កេតមានភារកិច្ចបន្ថែមទៀតត្រូវធ្វើសេចក្តីសម្រេចនៅពេលចេញដីកាដំណោះស្រាយ ពាក់ព័ន្ធនឹងអង្គហេតុនីមួយៗដែលពួកគេបានទទួលត្រឹមត្រូវ[215]។

---

(ឯកសារ D334)")។ សូមមើលផងដែរ សំណុំរឿង ០០២ ដីកាសម្រេចបដិសេធសំណើសុំដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យបន្ថែម ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ D298/2។

[213] សំណើរបស់សហព្រះរាជអាជ្ញាសុំដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យបន្ថែម (ឯកសារ D334)") កថាខណ្ឌ ១។

[214] សាលដីកាលើកិច្ចស៊ើបសួរទាក់ទងនឹងអំពើហិង្សាផ្លូវភេទ (ឯកសារ D365/3/1/5) កថាខណ្ឌ ៣៩ *ដែលយោងលើ ក្នុងនោះ* សំណុំរឿង ០០៣ (អបជ២០) សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចលើពាក្យសុំរបស់ មាស មុត ស្នើឱ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និងចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D134/1/10 មតិយោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BWANA កថាខណ្ឌ ១៣។

[215] តុលាការកំពូលព្រហ្មទណ្ឌបារាំង ថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៧៧ សំណុំរឿងលេខ 76-91442។ *សូមមើលផងដែរ* ដីកាសម្រេចលើការបញ្ជាក់បំភ្លឺអំពីបទចោទក្នុងសំណុំរឿង ០០២ (ឯកសារ D198/1) កថាខណ្ឌ ១០។

១១៧. ការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិថា សហចៅក្រមស៊ើបអង្កេតខកខានមិនបានចេញសេចក្តីសម្រេចមានសំអាងហេតុនៅក្នុងដីកាដំណោះស្រាយពាក់ព័ន្ធនឹងបទចោទ ដែលត្រូវបានចោទប្រកាន់ជាផ្លូវការ ហើយខកខានមិនបានធ្វើសេចក្តីសន្និដ្ឋានត្រឹមត្រូវអំពីយុត្តាធិការដោយផ្អែកលើអង្គហេតុពាក់ព័ន្ធទាំងអស់ មានការជាប់ពាក់ព័ន្ធជិតស្និទ្ធនឹងទឡ្ហីករណ៍ដែលបានលើកឡើងនៅក្នុងមូលដ្ឋានទីពីរ ហើយនឹងត្រូវឆ្លើយតបខាងក្រោម។

១១៨. យោងតាមសំអាងហេតុដូចបានលើកឡើងខាងលើ ចៅក្រមទទួលបន្ទុកច្រានចោលមូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍នេះ។

**ខ. មូលដ្ឋានទី ២ ៖ ការចោទប្រកាន់អំពីការខកខានក្នុងការឆ្លើយតបអង្គហេតុក្នុងដីកាដំណោះស្រាយ (សំអាងហេតុ)**

**១. សារណា**

១១៩. សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតខកខានមិនបានឆ្លើយតបទៅនឹងការចោទប្រកាន់ប្រាំប្រភេទ ដែលខ្លួនបានទទួលនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ប៉ុន្តែពុំត្រូវបានចោទប្រកាន់ នៅពេលវាយតម្លៃការទទួលខុសត្រូវរបស់ អ៊ឹម ចែម សម្រាប់គោលបំណងសម្រេចលើយុត្តាធិការបុគ្គល៖ (i) ការបោសសម្អាតភូមិភាគពាយ័ព្យ (ii) អាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងតំបន់ ៥ និង តំបន់ ១៣ (iii) ការធ្វើទុក្ខបុកម្នេញលើជនជាតិវៀតណាមនៅក្នុងតំបន់ ៥ (iv) ឧក្រិដ្ឋកម្មប្រឆាំងខ្មែរក្រោមនៅតំបន់ ១៣ និង (v) ការធ្វើទុក្ខបុកម្នេញ ទារុណកម្ម ការបាត់ខ្លួនដោយបង្ខំ និងអំពើអមនុស្សធម៌ផ្សេងទៀតនៅតាមទីតាំងជាក់លាក់[216]។

១២០. ចំណុចដំបូង សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ទោះបីជាបានទទួលស្គាល់តួនាទីសំខាន់របស់ អ៊ឹម ចែម នៅក្នុងការបោសសម្អាតភូមិភាគពាយ័ព្យក៏ដោយ សហចៅក្រមស៊ើបអង្កេតខកខានមិនបានពិចារណាលើការកាប់សម្លាប់ និងឧក្រិដ្ឋកម្មពាក់ព័ន្ធ ដែលបានបណ្តាលមកពីការបោសសម្អាតនៅក្នុងការបង្ហាញការទទួលខុសត្រូវរបស់គាត់នោះដែរ[217]។ ភស្តុតាងពាក់ព័ន្ធនឹងចំនួនមនុស្សដែលត្រូវបានគេសម្លាប់

---

216 បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៣។

217 បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៤ ដល់ កថាខណ្ឌ ២៦។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៥២។

ឬ ស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម ពុំត្រូវបានពិភាក្សានៅក្នុងការវាយតម្លៃថាតើ អ៊ឹម ចែម គឺជាបុគ្គលម្នាក់ក្នុងចំណោមបុគ្គល ដែល "ទទួលខុសត្រូវខ្ពស់បំផុត"[218]។ ចំណុចទីពីរ សហចៅក្រមស៊ើបអង្កេតខកខានមិនបានវាយតម្លៃការទទួលខុសត្រូវរបស់ អ៊ឹម ចែម លើអាពាហ៍ពិពាហ៍ដោយបង្ខំ ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងន័យ អំពើអមនុស្សធម៌ផ្សេងទៀត បើទោះជាសហព្រះរាជអាជ្ញាអន្តរជាតិបានបង្ហាញភស្តុតាងក៏ដោយ[219]។

១២១. ចំណុចទីបី សហចៅក្រមស៊ើបអង្កេតខកខានមិនបានពិចារណាលើការចោទប្រកាន់ភាគច្រើនពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិវៀតណាម[220] បើទោះជាមាន ភស្តុតាងបង្ហាញអំពីការចូលរួមពាក់ព័ន្ធរបស់ អ៊ឹម ចែម នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មបែបនេះនៅតាមទីតាំងមួយចំនួនក៏ដោយ[221] ហើយនឹងការចេញបញ្ជាដោយផ្ទាល់ឱ្យកាប់សម្លាប់ស្ត្រីជនជាតិវៀតណាមចំនួនពីរនាក់[222]។ ចំណុចទីបួន សហចៅក្រមស៊ើបអង្កេតខកខានមិនបានពិចារណាលើការចោទប្រកាន់ និងពិនិត្យលើ ភស្តុតាងបង្ហាញអំពីការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងខ្មែរក្រោមនៅតំបន់១៣ រួមទាំង ស្រុកកោះអណ្តែត ដែល តាមរបាយការណ៍ អ៊ឹម ចែម ធ្លាប់ជាលេខាស្រុក[223]។

១២២. ចំណុចទីប្រាំ សហចៅក្រមស៊ើបអង្កេតខកខានមិនបានពិចារណាភស្តុតាងដែលបង្ហាញអំពីការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មផ្សេងទៀត ដែលសហចៅក្រមស៊ើបអង្កេតទទួលបាន រួមទាំង ការធ្វើទុក្ខបុកម្នេញកម្មាភិបាលភូមិភាគពាយ័ព្យ អតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងសាច់ញាតិរបស់ពួកគេ និងជនជាតិពិន្ទុ រួមទាំង ជនជាតិចាម ចិន ឡាវ និងខ្មែរលើ ព្រមទាំង ឧក្រិដ្ឋកម្មនៃទារុណកម្មដែលបានប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងមន្ទីរសន្តិសុខវត្តអង្គសិរីមាលី និងលក្ខខណ្ឌរស់នៅអមនុស្សធម៌ផ្សេងទៀតនៅមន្ទីរសន្តិសុខភូមិចក្រី[224]។ សហចៅក្រមស៊ើបអង្កេតគ្រាន់តែ

---

[218] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៦។

[219] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៧ ដល់ កថាខណ្ឌ ២៨។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៥៧។

[220] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៩ ដល់ កថាខណ្ឌ ៣២។

[221] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣១ (រួមទាំង នៅការដ្ឋានការងារ និងមន្ទីរសន្តិសុខភ្នំទ្រយោង ការដ្ឋានប្រឡាយស្ពានស្រែង មន្ទីរសន្តិសុខចំការខ្នុរ វាលពិឃាតព្រៃតារ៉ុត ការដ្ឋានទំនប់ត្រពាំងថ្ម មន្ទីរសន្តិសុខភូមិចក្រី និងវត្តព្រះនេត្រព្រះ)។

[222] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣១។

[223] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៣ ដល់ កថាខណ្ឌ ៣៤។

[224] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៥ ដល់ កថាខណ្ឌ ៣៧។



PRE-TRIAL C... E.C.C.C

បានរកឃើញច្បោលៗថា ការធ្វើទុក្ខបុកម្នេញកើតឡើងនៅទីតាំងឧក្រិដ្ឋកម្មពុំត្រូវបានចោទប្រកាន់ ដោយពុំបានបង្ហាញថា នរណាជាជនរងគ្រោះ ហើយស្ថានទម្ងន់នៃឧក្រិដ្ឋកម្មគឺមានលក្ខណៈយ៉ាងដូចម្តេចទៅ[225]។

១២៣. សហមេធាវីឆ្លើយតបថា សហព្រះរាជអាជ្ញាខកខានមិនបានលើកឡើងបទដ្ឋានបណ្តឹងឧទ្ធរណ៍ត្រឹមត្រូវដែលអនុវត្តជាធរមានលើការកំណត់យុត្តាធិការបុគ្គល ហើយខកខានមិនបានកំណត់អត្តសញ្ញាណថាតើកំហុសអង្គច្បាប់ និងអង្គហេតុដូចបានចោទប្រកាន់នោះ គឺជាការបំពានឆន្ទានុសិទ្ធិដែរឬទេ[226]។ ជាពិសេស សហចៅក្រមស៊ើបអង្កេតបានវាយតម្លៃ និងពិចារណាត្រឹមត្រូវលើអង្គហេតុទាំងអស់ដែលសហចៅក្រមស៊ើបអង្កេតបានទទួល [227]។ សហចៅក្រមស៊ើបអង្កេតពុំមានកាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញានោះទេ ហើយក៏ពុំតម្រូវឱ្យធ្វើការសម្រេចជាក់លាក់ពាក់ព័ន្ធនឹងភស្តុតាងនីមួយៗ ឬ ការចោទប្រកាន់នីមួយៗដែលដាក់បន្ទុកលើ អ៊ឹម ចែម នោះទេ ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតពិតជាបានពិចារណាលើអង្គហេតុដែលពុំត្រូវបានចោទប្រកាន់ ហើយនៅតែសន្និដ្ឋានថា អង្គហេតុទាំងនេះនឹងពុំប៉ះពាល់ជាក់ស្តែងលើដីកាដំណោះស្រាយ[228]។

១២៤. សហមេធាវីអះអាងបន្ថែមទៀតថា សហចៅក្រមស៊ើបអង្កេតបានពិចារណាសមស្របលើអង្គហេតុពាក់ព័ន្ធទាំងអស់នៅក្នុងការសម្រេចលើយុត្តាធិការបុគ្គល រួមទាំង ការចោទប្រកាន់ពាក់ព័ន្ធនឹងភូមិភាគនិរតី[229] និងភូមិភាគពាយ័ព្យ[230] ហើយសហព្រះរាជអាជ្ញាអន្តរជាតិពុំបានបង្ហាញថាតើការចោទប្រកាន់អំពីការខកខានលើកឡើងអង្គហេតុទាំងនេះ បានបណ្តាលឱ្យមានការបំពានឆន្ទានុសិទ្ធិយ៉ាងដូចម្តេច [231]។ ពាក់ព័ន្ធនឹងការចោទប្រកាន់លើភូមិភាគនិរតី សហចៅក្រមស៊ើបអង្កេតបានសម្រេចថា អ៊ឹម ចែម ពុំបានចូលរួមពាក់ព័ន្ធនឹងការធ្វើសេចក្តីសម្រេចដែលបានប៉ះពាល់លើតំបន់ ១៣ និងស្រុកកោះអណ្តែត ដូច្នេះ សហចៅក្រមស៊ើបអង្កេតពុំតម្រូវឱ្យវាយតម្លៃលម្អិតលើភស្តុតាងពាក់ព័ន្ធនឹងការចោទប្រកាន់ឧក្រិដ្ឋកម្មនៅ

---

[225] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៦ *ដែលយោងលើ* ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៩៥ កថាខណ្ឌ ៣០៥។

[226] ចម្លើយតប កថាខណ្ឌ ៤១។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/2.1) ទំព័រ ៤៣។

[227] ចម្លើយតប កថាខណ្ឌ ៤២ ដល់ កថាខណ្ឌ ៤៤។

[228] ចម្លើយតប កថាខណ្ឌ ៤២ ដល់ កថាខណ្ឌ ៤៣។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/2.1) ទំព័រ ៤៣។

[229] ចម្លើយតប កថាខណ្ឌ ៤៦ ដល់ កថាខណ្ឌ ៥៣។

[230] ចម្លើយតប កថាខណ្ឌ ៥៤ ដល់ កថាខណ្ឌ ៧២។

[231] ចម្លើយតប កថាខណ្ឌ ៧៣។

ក្នុងទីតាំងនោះ [232] ។ ក្នុងករណីណាក៏ដោយ ភស្តុតាងពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងតំបន់ ១៣[233] និងឧក្រិដ្ឋកម្មប្រឆាំងខ្មែរក្រោម[234] ពុំមានភាពពាក់ព័ន្ធ ឬ ពុំមានតម្លៃជាភស្តុតាងនោះឡើយ។

១២៥. ចំពោះការចោទប្រកាន់ពាក់ព័ន្ធនឹងភូមិភាគពាយ័ព្យ សហមេធាវីអះអាងថា សហព្រះរាជអាជ្ញាអន្តរជាតិខកខានមិនបានបង្ហាញកំហុស ឬ ការបំពានឆន្ទានុសិទ្ធិពាក់ព័ន្ធនឹងការបោសសម្អាត[235] អាពាហ៍ពិពាហ៍ដោយបង្ខំ [236] និងការធ្វើទុក្ខបុកម្នេញលើជនជាតិវៀតណាម[237] នៅក្នុងតំបន់ ៥ ហើយឧក្រិដ្ឋកម្មផ្សេងទៀតដែលសហចៅក្រមស៊ើបអង្កេតបានទទួលនោះទេ [238] ។ ជាពិសេស សហចៅក្រមស៊ើបអង្កេតបានពិនិត្យភស្តុតាងពាក់ព័ន្ធនឹងការចូលរួមរបស់ អ៊ឹម ចែម នៅក្នុងការបោសសម្អាតជាហូរហែមក ហើយយ៉ាងច្រើនបំផុត បានរកឃើញថា គាត់បានដឹកនាំការផ្ទេរកម្មាភិបាល ដែលមានភាពពាក់ព័ន្ធតិចតួចនៅក្នុងការសម្រេចលើយុត្តាធិការបុគ្គល [239] ។ សហមេធាវីអះអាងបន្ថែមទៀតថា ការចូលរួម និងសិទ្ធិអំណាចរបស់ អ៊ឹម ចែម លើការដ្ឋានទំនប់ត្រពាំងថ្ម មន្ទីរសន្តិសុខវត្តចំការខ្នុរ និងវត្តព្រះនេត្រព្រះ ពុំបានរកភស្តុតាងឃើញ ហេតុដូច្នេះ ករណីនេះពុំពាក់ព័ន្ធនឹងបញ្ហាចោទនៃយុត្តាធិការបុគ្គលនោះឡើយ [240] ។ គ្មានភស្តុតាងជាក់ស្តែងអំពីការចូលរួមរបស់ អ៊ឹម ចែម នៅតាមទីតាំងឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងការចោទប្រកាន់អំពីការធ្វើទុក្ខបុកម្នេញនោះឡើយ[241]។ ចំណុចចុងក្រោយ ទោះបីជាមានការទទួលស្គាល់ថា គ្មានសំអាងហេតុជាក់លាក់ បានលើកឡើងពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញលើជនជាតិវៀតណាមនៅវាលពិឃាតព្រៃតារ៉ុត មន្ទីរ

---

[232] ចម្លើយតប កថាខណ្ឌ ៤៧ ដល់ កថាខណ្ឌ ៤៨។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/2.1) ទំព័រ ៤៥។

[233] ចម្លើយតប កថាខណ្ឌ ៤៩ ដល់ កថាខណ្ឌ ៥១។

[234] ចម្លើយតប កថាខណ្ឌ ៥២ ដល់ កថាខណ្ឌ ៥៣។

[235] ចម្លើយតប កថាខណ្ឌ ៥៥ ដល់ កថាខណ្ឌ ៥៦។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/2.1) ទំព័រ ៤៦ ដល់ ទំព័រ ៤៨។

[236] ចម្លើយតប កថាខណ្ឌ ៥៨ ដល់ កថាខណ្ឌ ៦១។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/2.1) ទំព័រ ៤៨ ដល់ ទំព័រ ៥១។

[237] ចម្លើយតប កថាខណ្ឌ ៦២ ដល់ កថាខណ្ឌ ៦៩។

[238] ចម្លើយតប កថាខណ្ឌ ៧០ ដល់ កថាខណ្ឌ ៧២។

[239] ចម្លើយតប កថាខណ្ឌ ៥៥ ដល់ កថាខណ្ឌ ៥៦។

[240] ចម្លើយតប កថាខណ្ឌ ៥៩ កថាខណ្ឌ ៦៣ ដល់ កថាខណ្ឌ ៦៤។

[241] ចម្លើយតប កថាខណ្ឌ ៧១។

សន្តិសុខភូមិចក្រី និងការកាប់សម្លាប់ស្ត្រីវៀតណាមពីរនាក់ក៏ដោយ[242] ក៏សហមេធាវីសន្និដ្ឋានថា ភស្តុតាងទាំងនេះមិនអាចជឿទុកចិត្តបាន ឬ មិនគ្រប់គ្រាន់នៅឡើយ[243]។

១២៦. សហព្រះរាជអាជ្ញាអន្តរជាតិឆ្លើយតបថា សហចៅក្រមស៊ើបអង្កេតមិនបានពិចារណាលើភស្តុតាងជាក់លាក់ ទៅតាមច្បាប់កំណត់ ថែមទាំងការចោទប្រកាន់ទាំងអស់ និងភស្តុតាងដែលអមមកជាមួយ[244]។ ទឡ្ហីករណ៍របស់សហមេធាវី មិនព្រមលើកឡើងអំពីករណីថាតើការវាយតម្លៃយុត្តាធិការបុគ្គល បានធ្វើឡើងជាក់ស្តែងយ៉ាងដូចម្តេច ហើយវាគឺពុំតម្រូវឱ្យបង្ហាញសំអាងហេតុ ឬ លើកឡើងអំពីឧក្រិដ្ឋដូចបានចោទប្រកាន់[245]។ សហមេធាវីបង្ហាញមិនត្រឹមត្រូវលើសំអាងហេតុ និងភស្តុតាងពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែល អ៊ឹម ចែម ពុំត្រូវបានចោទប្រកាន់ ជាពិសេស ពាក់ព័ន្ធនឹងការបោសសម្អាតភូមិភាគពាយ័ព្យ[246]។ ការខកខានមិនបានពិចារណាលើការកាប់សម្លាប់ប្រជាជនយ៉ាងហោចណាស់ ១.២០០ នាក់ ពុំមានការពាក់ព័ន្ធតិចតួចនឹងការវាយតម្លៃលើការទទួលខុសត្រូវរបស់ អ៊ឹម ចែម នោះទេ[247]។ សហមេធាវីក៏កំណត់មិនត្រឹមត្រូវលើ ភស្តុតាងដាក់បន្ទុកពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ[248] ការប្រព្រឹត្តលើជនជាតិវៀតណាម[249] និងការចោទប្រកាន់ផ្សេងទៀត[250]។ សហព្រះរាជអាជ្ញាអន្តរជាតិគូសបញ្ជាក់ថា ភស្តុតាងរបស់សាក្សីឃើញហេតុការណ៍ផ្ទាល់ភ្នែក និងជនរងគ្រោះ បើទោះជាគ្មានភស្តុតាងស៊ីសង្វាក់ អាចបំពេញបទដ្ឋាននៃភវនីយភាព ដែលអាចអនុវត្តបាននៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងដំណាក់កាលនេះ[251]។ ជារួមមក ការវាយតម្លៃ

---

[242] ចម្លើយតប កថាខណ្ឌ ៦៥។

[243] ចម្លើយតប កថាខណ្ឌ ៦០ ដល់ កថាខណ្ឌ ៦៨។

[244] ការឆ្លើយតប កថាខណ្ឌ ៣៣។

[245] ការឆ្លើយតប កថាខណ្ឌ ៣៤។

[246] ការឆ្លើយតប កថាខណ្ឌ ៤១ ដល់ កថាខណ្ឌ ៤២។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៥៦ ដល់ ទំព័រ ៥៧។

[247] ការឆ្លើយតប កថាខណ្ឌ ៤២។

[248] ការឆ្លើយតប កថាខណ្ឌ ៣៥ ដល់ កថាខណ្ឌ ៣៨។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៥៧ ដល់ ទំព័រ ៦២។

[249] ការឆ្លើយតប កថាខណ្ឌ ៣៩ ដល់ កថាខណ្ឌ ៤០។

[250] ការឆ្លើយតប កថាខណ្ឌ ៤៣។

[251] ការឆ្លើយតប កថាខណ្ឌ ៣៨។

លើការចូលរួមរបស់ អ៊ឹម ចែម នៅក្នុងឧក្រិដ្ឋកម្មទាំងនោះ គឺជានីតិវិធីចាំបាច់ក្នុងការកំណត់ថាតើ អ៊ឹម ចែម គឺជាបុគ្គលម្នាក់ក្នុងចំណោមបុគ្គលផ្សេងទៀតដែលទទួលខុសត្រូវខ្ពស់បំផុតដែរឬទេ[252]។

### ២. ការពិភាក្សា

១២៧. ទឡ្ហីករណ៍ទី ២ នៃបណ្ដឹងឧទ្ធរណ៍ ចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយខកខានមិនបានសម្រេចលើអង្គហេតុ ដែលខ្លួនបានទទួលបណ្ដឹង ហើយហេតុដូច្នេះ ខកខានមិនបានពិចារណាលើអង្គហេតុទាំងនេះ ក្នុងពេលវាយតម្លៃលើយុត្តាធិការបុគ្គល[253]។

១២៨. តាំងពីដំបូង ចៅក្រមទទួលបន្ទុកលើរឿងក្ដីរម្លឹកថា យោងតាមវិធាន ៥៥(២) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតត្រូវស៊ើបអង្កេតទាំងអស់ ប៉ុន្តែ តែលើអង្គហេតុដែលខ្លួនបានទទួលបណ្ដឹងប៉ុណ្ណោះ គឺអង្គហេតុដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[254] ។ តើការចោទប្រកាន់ជាក់លាក់ស្ថិតនៅក្នុងវិសាលភាពនៃបញ្ហាដែលបានដាក់ចំពោះមុខសហចៅក្រមស៊ើបអង្កេតដែរឬយ៉ាងណានោះ អាចត្រូវបានកំណត់តែតាមរយៈការពិចារណាទៅលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ព្រមទាំងឧបសម្ព័ន្ធ[255]

---

[252] ការឆ្លើយតប កថាខណ្ឌ ៤២ ដល់ កថាខណ្ឌ ៤៣។

[253] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២៣-៣៧។

[254] ឧទាហរណ៍ សូមមើល សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៃសំណុំរឿង ០០១ (ឯកសារ D99/3/42) កថាខណ្ឌ ៣៥-៣៧។ សំណុំរឿង ០០៣ សេចក្ដីសម្រេចលើពាក្យសុំមោឃភាពចំនួន២ ឯកសារ D134/1/10 យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BWANA កថាខណ្ឌ ១៣។ សំណុំរឿង ០០៣ (អបជ ២៨) សាលដីកា ១) លើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងសំណើចំនួនប្រាំបួនរបស់ មាស មុត សុំប្ដឹងទៅអង្គបុរេជំនុំជម្រះឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ និង ២) លើសំណើសុំចំនួនពីរដែលត្រូវបានបញ្ជូនដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ D165/2/26 កថាខណ្ឌ ១៧៥។ សំណុំរឿង ០០៤ (អបជ ៣៩) សេចក្ដីពិចារណាលើសំណើរបស់ យឹម ទិត្យ សុំធ្វើមោឃភាពកិច្ចស៊ើបសួរ និងដីកាទាក់ទងនឹងទំនប់កង្កួត ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D345/1/6 កថាខណ្ឌ ២៤-២៦។ សំណុំរឿង ០០៤ សេចក្ដីសម្រេចលើការស៊ើបសួរអំពីអំពើហិង្សាផ្លូវភេទ D365/3/1/5 កថាខណ្ឌ ៣៩ ។ សូមមើលផងដែរ មាត្រា ១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

[255] ឧទាហរណ៍ សូមមើល សំណុំរឿង ០០៣ ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D134/1/10 , យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BWANA កថាខណ្ឌ ៤, សំណុំរឿង ០០៤ សេចក្ដីពិចារណាលើសំណើរបស់ យឹម ទិត្យ សុំធ្វើមោឃភាពកិច្ចស៊ើបសួរ និងដីកាទាក់ទងនឹងទំនប់កង្កួត ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D345/1/6 កថាខណ្ឌ ២៦។ ។

ជាមួយនឹងសេចក្តីណែនាំអំពីការកំណត់ប្រភេទបទល្មើសតាមផ្លូវច្បាប់ ដែលសហព្រះរាជអាជ្ញាស្នើឡើង[256] ។ ម្យ៉ាងវិញទៀត សហចៅក្រមស៊ើបអង្កេតអាចមិនចោទប្រកាន់ជនសង្ស័យណាម្នាក់ ពីឧក្រិដ្ឋកម្មនៅក្រៅវិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ ហើយសហចៅក្រមស៊ើបអង្កេតមិនអាចត្រូវបានស្នើសុំឱ្យពង្រីកបទចោទបានទេ ពេលចេញដីកាដំណោះស្រាយ តាមរយៈដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា។ ដូចគ្នានេះដែរ អង្គបុរេជំនុំជម្រះមិនអាចពង្រីកវិសាលភាពនៃបទចោទ ដោយផ្អែកលើការចោទប្រកាន់ដែលបានលើកឡើងដោយយឺតយ៉ាវនៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយឡើយ។

១២៩. ភារកិច្ចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការស៊ើបអង្កេតលើរាល់ការចោទប្រកាន់ទាំងអស់ ដែលខ្លួនបានទទួលបណ្តឹង អនុលោមតាមវិធាន ៦៧(១) នៃវិធានផ្ទៃក្នុង ក៏បង្កើតបានជាភារកិច្ចក្នុងការផ្តល់ការកំណត់តាមផ្លូវច្បាប់ត្រឹមត្រូវ លើអង្គហេតុនីមួយៗ នៅពេលចេញដីកាដំណោះស្រាយ ហើយសហចៅក្រមស៊ើបអង្កេតនៅតែទទួលបានបណ្តឹងអំពីអង្គហេតុដែលខ្លួនខកខានមិនបានបំពេញភារកិច្ច [257] ។ សេចក្តីសម្រេចបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់ មិនពាក់ព័ន្ធនឹងការអនុវត្តអំណាចឆន្ទានុសិទ្ធិឡើយ[258]។ លើសពីនេះទៅទៀត ចៅក្រមទទួលបន្ទុកលើរឿងក្តីរម្លឹកថា វិធាន ៦៧(៤) នៃវិធានផ្ទៃក្នុង តម្រូវឱ្យដីកាដំណោះស្រាយត្រូវមានសំអាងហេតុ[259]។

១៣០. ចៅក្រមទទួលបន្ទុកលើរឿងក្តីកត់សម្គាល់ថា អ៊ឹម ចែម ត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំត្រយ៉ូង និងការដ្ឋានទំនប់ស្ពានស្រែង[260]។ ការចោទប្រកាន់ព្រហ្មទណ្ឌផ្សេងទៀតដែលបានលើកឡើង នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

---

[256] ឧទាហរណ៍ សូមមើល សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៃសំណុំរឿង ០០១ (ឯកសារ D99/3/42) កថាខណ្ឌ ៣៥។

[257] ឧទាហរណ៍ សូមមើល សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៃសំណុំរឿង ០០១ (ឯកសារ D99/3/42) កថាខណ្ឌ ៣៧។ សូមមើលផងដែរ តុលាការកំពូលបារាំង សំណុំរឿងព្រហ្មទណ្ឌ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ១៩៧៧ សំណុំរឿងលេខ ៧៦-៩១៤៤១។ តុលាការកំពូលបារាំង សំណុំរឿងព្រហ្មទណ្ឌ ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៤ សំណុំរឿងលេខ ០៣-៨៥៩៨៣។

[258] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៃសំណុំរឿង ០០១ (ឯកសារ D99/3/42) កថាខណ្ឌ ៣៧។

[259] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៃសំណុំរឿង ០០១ (ឯកសារ D99/3/42) កថាខណ្ឌ ៣៨។ សូមមើលផងដែរ មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

[260] សូមមើលការជូនដំណឹងអំពីបទចោទ (ឯកសារ D239.1)។

បន្ថែម មិនត្រូវបានចោទប្រកាន់ប្រឆាំងនឹងគាត់ទេ។ ក្នុងករណីនេះ សហចៅក្រមស៊ើបអង្កេតបានធ្វើការ "ពិនិត្យឡើងវិញសង្ខេប" លើភ័ស្តុតាងទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មដែលមិនបានចោទប្រកាន់[261] ដោយបានកត់សម្គាល់ជាទូទៅថា វិសាលភាព និងវង្វង់សិទ្ធិអំណាចរបស់ អ៊ឹម ចែម លើទីតាំងទាំងនេះ[262] ក៏ដូចជាចំនួនជនរងគ្រោះ[263] មិនត្រូវបានបង្ហាញច្បាស់លាស់ដោយការស៊ើបអង្កេតឡើយ។ ទោះជាយ៉ាងណានេះក្តី សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានដោយប្រញាប់ប្រញាល់ពេកថា "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការដាក់ក្នុងមន្ទីរឃុំឃាំង អំពើមនុស្សឃាត ការដាក់ឱ្យទៅជាទាសករ អំពើអមនុស្សធម៌ផ្សេងទៀត ការធ្វើទុក្ខបុកម្នេញ ព្រមទាំងឧក្រិដ្ឋកម្មជាតិនៃអំពើមនុស្សឃាត" ត្រូវបានប្រព្រឹត្តឡើងនៅតាមទីតាំងឧក្រិដ្ឋកម្មដែលមិនត្រូវបានចោទប្រកាន់[264] ប៉ុន្តែ បានយល់ឃើញថា ទោះបីជាយកមកពិចារណាក៏ដោយ ក៏ អ៊ឹម ចែម "នៅតែស្ថិតនៅក្រៅយុត្តាធិការរបស់ អ.វ.ត.ក ដែរ ចំពោះគ្រប់ទម្រង់នៃការទទួលខុសត្រូវដែលបានចោទប្រកាន់ទាំងអស់នោះ"[265]។

១៣១. ទីមួយ ចៅក្រមទទួលបន្ទុកលើរឿងក្តីនឹងពិនិត្យមើលឡើងវិញនូវអំណះអំណាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងទឡ្ហីករណ៍ទី ២ នៃបណ្តឹងឧទ្ធរណ៍ និងទីពីរ ពិនិត្យមើលដោយបញ្ញត្តិថា តើការចោទប្រកាន់ព្រហ្មទណ្ឌផ្សេងទៀត ដែលបានលើកឡើង នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដែលសហចៅក្រមស៊ើបអង្កេតបានទទួលបណ្តឹងត្រឹមត្រូវ ត្រូវបានដោះស្រាយត្រឹមត្រូវដែរឬទេ នៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ)។ ការពិនិត្យឡើងវិញបែបនេះតម្រូវឱ្យចៅក្រមទទួលបន្ទុកលើរឿងក្តីបំភ្លឺអំពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក លើ អ៊ឹម ចែម។

---

[261] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៤៨-២៥១ (មន្ទីរសន្តិសុខវត្តអង្គសិរីមាឈី និងទីតាំងសម្លាប់មនុស្សព្រៃស្វុខុន កថាខណ្ឌ ២៥២-២៥៩ (វត្តព្រះនេត្រព្រះ និងទីតាំងពាក់ព័ន្ធ) កថាខណ្ឌ ២៦០-២៦៣ (មន្ទីរសន្តិសុខភូមិចក្រី) កថាខណ្ឌ ២៦៤-២៦៧ (ទីតាំងសម្លាប់មនុស្សព្រៃតារ៉ុត) កថាខណ្ឌ ២៦៨-២៧០ (វត្តចម្ការខ្នុរ) កថាខណ្ឌ ២៧១-២៧៨ (ការដ្ឋានទំនប់ត្រពាំងថ្ម) កថាខណ្ឌ ២៧៩-២៨០ (ការរំលោភសេពសន្ថវៈ និងការធ្វើមនុស្សឃាតស្ត្រីវៀតណាមពីរនាក់ នៅព្រះនេត្រព្រះ)។

[262] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៤៧។ សូមមើលផងដែរ ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៥១, ២៥៩។

[263] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៥០, ២៥៩, ២៦៣,២៦៧, ២៧០, ២៧៧-២៧៨, ៣២១។

[264] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣០៥។

[265] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣១៣។

## ក. មូលដ្ឋានទី២(១)៖ ការបោសសម្អាតនៅភូមិភាគពាយ័ព្យ

១៣២. ទឡ្ហីករណ៍ទី២(១) ចោទប្រកាន់ថា ទោះបីមានការទទួលស្គាល់នូវតួនាទីចម្បងរបស់ អ៊ឹម ចែម នៅក្នុងការបោសសម្អាតនៅភូមិភាគនិរតីក៏ដោយ តែសហចៅក្រមស៊ើបអង្កេតពុំបានយកមកពិចារណានូវស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលកើតចេញពីការបោសសម្អាតនេះទេ រួមទាំងចំនួននៃការសម្លាប់ ការប្រើប្រាស់អំពើទារុណកម្ម និងភាពទន់ខ្សោយនៃជនរងគ្រោះ នៅក្នុងការវាយតម្លៃពាក់ព័ន្ធថា តើ អ៊ឹម ចែម ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[266]។

១៣៣. តាមរយៈកថាខណ្ឌ ៥៤ ដល់ កថាខណ្ឌ ៥៩ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ សហចៅក្រមស៊ើបអង្កេតបានយកមកពិនិត្យទាន់ពេលវេលានូវការចោទប្រកាន់នានាដែលពាក់ព័ន្ធនឹងការបោសសម្អាតនៅភូមិភាគពាយ័ព្យ ដែលដឹកនាំដោយ អ៊ឹម ចែម និងកម្មាភិបាលភូមិភាគនិរតីផ្សេងទៀត និងដែលរួមមានការចាប់ខ្លួន និង ការសម្លាប់ "កម្មាភិបាលគ្រប់ជាន់ថ្នាក់ទាំងអស់ដែលមានស្រាប់នៅភូមិភាគពាយ័ព្យ" និងបណ្តាលឱ្យមាន "ការចាប់ខ្លួន ការសម្លាប់ និងការបាត់ខ្លួនមានការកើនឡើងគួរឱ្យកត់សម្គាល់ក្នុងចំណោមប្រជាជនទូទៅ" បន្ថែមទៀត៖

> ៥៤. ចាប់ផ្តើមពីខែ មិថុនា ឆ្នាំ ១៩៧៧ កម្មាភិបាលភូមិភាគពាយ័ព្យត្រូវបានបោសសម្អាតចាប់តាំងពីថ្នាក់ភូមិ រហូតដល់ថ្នាក់ភូមិភាគ ពីសំណាក់បក្សកុម្មុយនីស្តកម្ពុជាមកពីភូមិភាគនិរតីដែលដឹកនាំដោយ តាម៉ុក តាទិត្យ និង អ៊ឹម ចែម។
>
> ៥៥. ការបោសសម្អាតបានចាប់ផ្តើមនៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៧ ដោយមានការចាប់ខ្លួនគណៈភូមិភាគពាយ័ព្យ និងលេខាតំបន់១ ឈ្មោះ រស់ ម៉ៅ *ហៅ* សាយ ព្រមជាមួយនឹងការមកដល់របស់កងកម្លាំងភូមិភាគនិរតី នៅក្នុងស្រុកព្រះនេត្រព្រះ ដែលដឹកនាំដោយ អ៊ឹម ចែម។ លេខាភូមិភាគនិរតី និង សមាជិកគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ឈ្មោះ តាម៉ុក បានចាត់តាំងឱ្យ អ៊ឹម ចែម គ្រប់គ្រងនៅក្នុងស្រុកព្រះនេត្រព្រះ និង "ដោះស្រាយ" បញ្ហាប្រជាជននៅទីនោះ ព្រមទាំងបានទំនាក់ទំនងជាមួយ ចែម និង បានផ្តល់បទបញ្ជាទៅឱ្យគាត់ [ចែម] បន្ទាប់ពី គាត់ [ចែម] បានផ្លាស់ទៅកាន់ភូមិភាគពាយ័ព្យនោះ។

---

[266] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៤-២៦។ *សូមមើលផងដែរ* ប្រតិចារឹកថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៥២ ។

៥៦. បន្ទាប់ពីបានមកដល់ស្រុកព្រះនេត្រព្រះ អ៊ឹម ចែម បានជួបជាមួយអ្នកកាន់តំណែងមុន ដែលជាលេខាស្រុក ឈ្មោះ អន ម៉ោង ហើយបានទទួលបញ្ជីឈ្មោះមនុស្សចំនួន ១០០.០០០ នាក់ ដោយរាប់បញ្ចូលទាំងកម្មាភិបាលថ្នាក់ស្រុកដែលកំពុងធ្វើការនៅទីនោះផង។ មិនយូរប៉ុន្មាន អន ម៉ោង ត្រូវបានចាប់ខ្លួន ពោលគឺ នៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៧៧ ហើយរយៈពេលពីរបីថ្ងៃក្រោយមក កម្មាភិបាលជាន់ខ្ពស់ផ្សេងទៀតមកពីតំបន់ ៥ និងស្រុកព្រះនេត្រព្រះក៏ត្រូវបានចាប់ខ្លួនដែរ។ អ៊ឹម ចែម បាននាំមកជាមួយនូវកម្មាភិបាលភូមិភាគនិរតីចំនួន ៥០០នាក់ ទៅកាន់ស្រុកព្រះនេត្រព្រះ ហើយបានប្រើប្រាស់កម្លាំងទាំងអស់នោះ ដើម្បីធ្វើការដកហូតអាវុធពីកម្មាភិបាលភូមិភាគពាយ័ព្យនៅទីនោះ ព្រមទាំងបានបញ្ជូនអ្នកទាំងនោះទៅកាន់ការដ្ឋានធ្វើការងារដោយបង្ខំ ឬទៅមន្ទីរសន្តិសុខ ដូចជា (មន្ទីរ) ស-២១ និងគុកតំបន់ នៅភ្នំត្រយោង ដែលអ្នកទាំងអស់នោះត្រូវបានឃុំខ្លួន និងសម្លាប់ចោល។ កម្មាភិបាលគ្រប់ជាន់ថ្នាក់ទាំងអស់ដែលមានស្រាប់នៅភូមិភាគពាយ័ព្យត្រូវបានចាប់ខ្លួន និងសម្លាប់ចោល ដោយរាប់តាំងពីប្រធានភូមិ ប្រធានឃុំ មន្ត្រីថ្នាក់ស្រុក និងតំបន់ ព្រមទាំងសមាជិកគ្រួសាររបស់អ្នកទាំងនេះដែរ។

៥៧. ចាប់ពីប៉ុន្មានខែចុងក្រោយនៃឆ្នាំ ១៩៧៧ រហូតដល់នៅពាក់កណ្តាលឆ្នាំ ១៩៧៨ ការបោសសម្អាតត្រូវបានពង្រីកជាលក្ខណៈប្រព័ន្ធដល់ទូទាំងភូមិភាគពាយ័ព្យទាំងមូលតែម្តង។ ឧទាហរណ៍ នៅក្នុងខែ សីហា ឆ្នាំ ១៩៧៧ កម្មាភិបាលភូមិភាគនិរតី (ដែលជួនកាលត្រូវបានហៅថាជាពួកនិរតី) បានមកដល់ក្នុងស្រុកមោងឫស្សី ហើយ "មេដឹកនាំចាស់ៗទាំងអស់ ត្រូវបានសម្លាប់ចោល"។ នៅស្រុកបាត់ដំបងនៃតំបន់ ៤ កម្មាភិបាលភូមិភាគនិរតី បានមកដល់ នៅក្នុងខែ សីហា និងបានចូលរួមជាមួយកម្មាភិបាលមូលដ្ឋានស្រាប់តែបាត់ខ្លួនមួយរំពេច"។ នៅក្នុងស្រុកស៊ីសុផុន របស់តំបន់ ៥ កម្មាភិបាលមូលដ្ឋាន "ត្រូវបានបោសសម្អាតទាំងអស់ ហើយបាននាំទៅកន្លែងផ្សេងទៀតនិងជំនួសដោយពួកនិរតី" នៅអំឡុងខែ វិច្ឆិកា ឆ្នាំ ១៩៧៧។ នៅ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ កម្មាភិបាលភូមិភាគពាយ័ព្យនៅក្នុងខេត្តពោធិ៍សាត់ "ត្រូវបានបង្ខំឱ្យឡើងជិះឡាន ហ្សេ.អឹម.សេ និងបានដឹកយកតាមទិសដៅទៅស្រុកមោងឫស្សី"។ នៅកន្លែងវត្តបន្ទាយនាង របស់ស្រុកមង្គលបុរី ប្រធាននៅមូលដ្ឋាន "ត្រូវបានចាប់ខ្លួនដោយនិរតី ដែលកំពុងមកដល់ទីនោះ នៅក្នុងខែ មីនា ឆ្នាំ ១៩៧៨"។ ភស្តុតាងស្រដៀងគ្នានេះដែរ កើតមាននៅតាមកន្លែងផ្សេងៗទៀតរបស់ភូមិភាគពាយ័ព្យ។ ការបោសសម្អាតត្រូវបានដាក់ឱ្យអនុវត្តពីសំណាក់កងកម្លាំងយោធារបស់ភូមិភាគនិរតី របស់តាម៉ុក ដែល "ដកហូតអាវុធ" ពីកម្មាភិបាលមូលដ្ឋានរបស់ភូមិភាគពាយ័ព្យ។

៥៨. ការបោសសម្អាត ដែលកើតឡើងនៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៨ ដោយមានការចាប់ខ្លួនប្រធានភូមិភាគជាន់ខ្ពស់ និងប្រធានតំបន់ ដោយរាប់បញ្ចូលទាំងលេខាភូមិភាគពាយ័ព្យ ឈ្មោះ

មួល សម្បត្តិ *ហៅ* រស់ ញឹម អនុលេខាភូមិភាគពាយ័ព្យ ឈ្មោះ កឺ លេខាតំបន់ ៣ ឈ្មោះ ភោគ សារី *ហៅ* តុំ លេខាតំបន់ ១ និង សមាជិកគណៈភូមិភាគពាយ័ព្យ ឈ្មោះ ហេង ទាវ *ហៅ* ប៉ែត *ហៅ* កន្ទុល និង កូនរបស់ ញឹម ឈ្មោះ ដៀល។ នៅពេលដែលការបោសសម្អាតបានចប់សព្វគ្រប់ តាម៉ុក បានលេចឡើងធ្វើការលេខាស្តីទីរបស់ភូមិភាគពាយ័ព្យ ហើយបណ្តាញគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជាថ្នាក់តំបន់ ស្រុក និងឃុំ ត្រូវបានជំនួសដោយកម្មាភិបាលភូមិភាគនិរតី ដែលបានរាយការណ៍មកឱ្យគាត់ [តាម៉ុក]។ កម្មាភិបាលភូមិភាគពាយ័ព្យដែលត្រូវបោសសម្អាតត្រូវបាន "បាត់ខ្លួន" និងមិនដែលឃើញត្រឡប់មកវិញឡើយ ឬក៏ត្រូវបានចាប់ខ្លួនបញ្ជូនទៅកាន់មន្ទីរ ស-២១ ជាមន្ទីរដែលអ្នកទាំងអស់នោះត្រូវបានសម្លាប់ជាបន្តបន្ទាប់។ ភូមិភាគពាយ័ព្យមានចំនួនអ្នកទោសជាប់នៅមន្ទីរស-២១ ខ្ពស់ជាងគេបំផុត បើប្រៀបធៀបជាមួយភូមិភាគផ្សេងៗទៀត ដោយមានចំនួន ៥ ដងច្រើនជាងអ្នកទោសមកពីភូមិភាគដែលមានអ្នកទោសច្រើនជាងគេបន្ទាប់ទី២។

៥៩. ក្រៅពីការបោសសម្អាតកម្មាភិបាលដែលមានស្រាប់នៅទីនោះ ការចាប់ខ្លួន ការសម្លាប់ និងការបាត់ខ្លួនមានការកើនឡើងគួរឱ្យកត់សម្គាល់ ក្នុងចំណោមប្រជាជនទូទៅនៅក្នុងស្រុកព្រះនេត្រព្រះ និងទូទាំងភូមិភាគពាយ័ព្យ បន្ទាប់ពី តាម៉ុក, អ៊ឹម ចែម, តាម៉ុក និង កម្មាភិបាលភូមិភាគនិរតីចូលមកគ្រប់គ្រង។ តាមសម្តីរបស់អ្នករស់រានមានជីវិតម្នាក់មកពីខាង (ភូមិភាគ) ពាយ័ព្យ បានឱ្យដឹងថា "ឆ្នាំ ១៩៧៨ ជាឆ្នាំដែលមានការសម្លាប់យ៉ាងរង្គាល"។ ជនរងគ្រោះនៅក្នុងអំឡុងពេលនោះរួមមាន ប្រជាជនថ្មី ប្រជាជនមូលដ្ឋាន អ្នកមានជាតិពន្ធុវៀតណាម ហើយប្រជាជនទាំងឡាយៗដែលត្រូវបាននាំមកពីភូមិភាគបូព៌ាទៅកាន់ទីនោះ។ មន្ទីរសន្តិសុខ ទីតាំងសម្លាប់ និងការដ្ឋានធ្វើការដោយបង្ខំ ដែលនឹងមានរៀបរាប់នៅក្នុងកថាខណ្ឌខាងក្រោម គឺជាទីតាំងប្រព្រឹត្តបទឧក្រិដ្ឋកម្ម ដែលជនរងគ្រោះទាំងអស់នេះត្រូវបានឃុំខ្លួន និងសម្លាប់ចោលនៅក្នុងអំឡុងពេលនោះដែល តាម៉ុក, អ៊ឹម ចែម និង កម្មាភិបាលភូមិភាគនិរតី ធ្វើការគ្រប់គ្រងនៅក្នុងតំបន់ភូមិភាគពាយ័ព្យនោះ[267]។

១៣៤. សហព្រះរាជអាជ្ញាអន្តរជាតិបានចោទប្រកាន់បន្ថែមថា អ៊ឹម ចែម បានចូលរួមជាសហចារីនៅក្នុងសហឧក្រិដ្ឋកម្មរួមដើម្បីបោសសម្អាតនៅភូមិភាគពាយ័ព្យ និង បានរៀបរាប់អំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តទៅលើប្រជាជនទូទៅ បន្ទាប់ពីកម្មាភិបាលភូមិភាគនិរតីបានទៅដល់៖

១១. បន្ទាប់ពីការមកដល់របស់កម្មាភិបាលភូមិភាគនិរតីក្នុងភូមិភាគកណ្តាល និង ពាយ័ព្យ ដំណាក់កាលដ៏ឃោរឃៅមួយបានកើតឡើងភ្លាម ដែលពេលនោះ ប្រជាជនត្រូវបានបង្ខំឱ្យធ្វើការងារយ៉ាប់យ៉ឺនជាងមុន អាហារទទួលទានបានតិចតួចជាងមុន ហើយមនុស្សរាប់ពាន់នាក់ត្រូវ

---

[267] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ (ឯកសារ D1) កថាខណ្ឌ ៥៤-៥៩ (លុបចោលជើងទំព័រ)។

បានចាប់ និង សម្លាប់ ដែលរួមមានទាំងប្រជាជនថ្មី កម្មាភិបាលមូលដ្ឋាន ជនជាតិចាម ជនកម្ពុជាដែលមានដើមកំណើតវៀតណាម និងអ្នកមកពីភូមិភាគបូព៌ា ដែលត្រូវបានបញ្ជូនទៅភូមិភាគកណ្ដាល និង ពាយ័ព្យទាំងឡានៗទៅសម្លាប់។ អាចមានការស្លាប់មនុស្សច្រើនរហូតដល់ ៤០០.០០០ នាក់ នៅក្នុងភូមិភាគកណ្ដាល និង ៥៦០.០០០ នាក់ នៅក្នុងភូមិភាគពាយ័ព្យ នៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ។

១៧. ផែនការឧក្រិដ្ឋកម្មរួមមួយទៀត ឬសហឧក្រិដ្ឋកម្មរួម បានកើតឡើងយ៉ាងហោចណាស់ចាប់តាំងពីពាក់កណ្ដាលឆ្នាំ ១៩៧៧ រហូតដល់ចុងបញ្ចប់របបកម្ពុជាប្រជាធិបតេយ្យ ដែលរួមមាន តាម៉ុក, តាទិត្យ, អ៊ឹម ចែម និងសមាជិកគណៈកម្មាធិការ ព្រមទាំងអ្នកក្រោមបង្គាប់ផ្ទាល់របស់គាត់ដែលមកពីខាងភូមិភាគនិរតី។ កម្មវត្ថុរបស់សហឧក្រិដ្ឋកម្មរួមនេះ គឺត្រូវបោសសម្អាតនៅភូមិភាគពាយ័ព្យ និងសម្លាប់ខ្មាំងទាំងអស់របស់របបកម្ពុជាប្រជាធិបតេយ្យ។ ទិសដៅជាក់លាក់របស់សហឧក្រិដ្ឋកម្មរួម គឺកម្មាភិបាលមូលដ្ឋាន ក្រុមគ្រួសារ និង "ខ្សែបណ្ដាញ" របស់អ្នកទាំងនោះ ព្រមទាំងប្រជាជនដែលមានទំនាក់ទំនងជាមួយនឹង "សង្គមចាស់" ប្រជាជនថ្មី ឬ "ប្រជាជន ១៩៧៥" ជនជាតិភាគតិចចាម ដែលមានលក្ខណៈជាតិពន្ធុនិងសាសនា និងអ្នកដែលមានជាតិពន្ធុវៀតណាម។ តាទិត្យ និង អ៊ឹម ចែម បានចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមនេះ ធ្វើជាសហចារី និងចង់បានលទ្ធផលបែបនេះ[268]។

១៣៥. នៅក្នុងទិដ្ឋភាពទូទៅដោយសង្ខេបរបស់ខ្លួនចំពោះឧក្រិដ្ឋកម្មដែលមិនត្រូវបានចោទប្រកាន់ សហចៅក្រមស៊ើបអង្កេតពុំបានធ្វើការកំណត់តាមផ្លូវច្បាប់ឲ្យបានច្បាស់លាស់ ពាក់ព័ន្ធនឹងការបោសសម្អាតនៅភូមិភាគពាយ័ព្យ និងការទទួលខុសត្រូវរបស់ អ៊ឹម ចែម ពាក់ព័ន្ធនឹងការបោសសម្អាតនោះទេ[269]។ ថ្វីត្បិតតែយ៉ាងនោះក្ដី សហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្ដីសន្និដ្ឋានជាច្រើននៅក្នុងដីកាដំណោះស្រាយទាំងមូល (សំអាងហេតុ) ពាក់ព័ន្ធនឹងតួនាទីរបស់ អ៊ឹម ចែម នៅក្នុងការបោសសម្អាត នៅពេលពិភាក្សាអំពីតួនាទីរួម សិទ្ធិអំណាច និងការប្រព្រឹត្តិនៅក្នុងភូមិភាគពាយ័ព្យរបស់គាត់ [270] ព្រមទាំងនៅក្នុងការធ្វើសេចក្ដីសន្និដ្ឋានទៅលើអង្គហេតុ និងអង្គច្បាប់ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយោង និង ការដ្ឋានប្រឡាយស្ពានស្រែង[271]។

---

[268] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ (ឯកសារ D1) កថាខណ្ឌ ១១, ១៧ (លុបចោលជើងទំព័រ)។

[269] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៤៧-២៨០។

[270] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៥៦-១៨៨។

[271] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៨៩-២៤៣, ២៨៥-៣០២, ៣០៨-៣០៩។

១៣៦. ជាពិសេស សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់នូវភស្តុតាង ដោយបង្ហាញថា ក្រោយពេល អ៊ឹម ចែម និងកម្មាភិបាលភូមិភាគនិរតីបានចូលគ្រប់គ្រងតំបន់ ៥ នៅពាក់កណ្តាលឆ្នាំ ១៩៧៧ ពួកគេបាន អនុវត្តយុទ្ធនាការចាប់ខ្លួន និងសម្លាប់ជាប្រព័ន្ធដែលដាក់មុខសញ្ញាលើកម្មាភិបាលភូមិភាគពាយ័ព្យ [272] ។ ប្រតិបត្តិការណ៍ដែលដំណើរការ និងត្រួតពិនិត្យដោយ តាម៉ុក[273] មានគោលបំណងដាក់ជំនួសកម្មាភិបាល ភូមិភាគពាយ័ព្យចាប់ពីថ្នាក់សហករណ៍ ទៅថ្នាក់ភូមិភាគ[274]។ នៅខែ មីនា ឆ្នាំ ១៩៧៧ អ៊ឹម ចែម ត្រូវបាន ចាត់តាំងជាលេខាស្រុកព្រះនេត្រព្រះ ក្នុងតំបន់ ៥ ដោយជំនួស តាម៉ោង ដែលត្រូវបានចាប់ខ្លួន និងបញ្ជូន ទៅមន្ទីរ ស-២១[275]។ គាត់បានកាន់តំណែងនេះរហូតដល់កងទ័ពវៀតណាមចូលទៅដល់នៅខែ មករា ឆ្នាំ ១៩៧៩[276]។ សមាជិកគណៈកម្មាធិការតំបន់ ៥ ក៏ត្រូវបានចាប់ខ្លួនផងដែរ បន្ទាប់ពេល អ៊ឹម ចែម និង តាម៉ុក បានទៅដល់ភូមិភាគពាយ័ព្យ ដោយចាប់ផ្តើមពី តាហ៊ឹង (ឬ តាហ៊ុង) អាចថា តាវុធ និង តាវ៉ាល់ បន្ទាប់ មក តាជាល (ឬ តាជៀល) នៅដើម និងពាក់កណ្តាលឆ្នាំ ១៩៧៨ និង ចុងក្រោយ តារិន[277]។ អ៊ឹម ចែម ក្លាយជាអនុលេខាតំបន់ ៥ ក្រោយពេលដក តារិន ចេញ[278]។

១៣៧. ពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា តាមបញ្ជារបស់ អ៊ឹម ចែម កម្មាភិបាលភូមិភាគពាយ័ព្យត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរសន្តិសុខភ្នំទ្រយោង [279] ដោយសារត្រូវបានគេចាត់ទុកថាជាសមាសភាពអាក្រក់ ឬខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា [280] ហើយថា ពួកគេជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាទម្រង់នៃការធ្វើទុក្ខបុកម្នេញដោយសារ មូលហេតុនយោបាយ[281]។ សហចៅក្រមស៊ើបអង្កេតក៏បានកត់សម្គាល់ផងដែរនូវភស្តុតាងដែលថា កម្មាភិបាល ភូមិភាគពាយ័ព្យត្រូវបានបង្ខំឱ្យធ្វើការនៅការដ្ឋានប្រឡាយស្ពានស្រែង និងត្រូវបានសម្លាប់ ប្រសិនបើពួកគេ

---

[272] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៨៥។ *សូមមើលផងដែរ* កថាខណ្ឌ ១៥៣-១៥៤។

[273] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៥៥, ២៨៤។

[274] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៥២។

[275] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៥៨។ *សូមមើលផងដែរ* កថាខណ្ឌ ១៥៤។

[276] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៦០, ១៦៦។

[277] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៦២-១៦៣។

[278] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៦៣-១៦៦។

[279] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២០០, ២០២។

[280] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៨១, ២៩៥។

[281] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៩៥។

01575505



ធ្វើខុស[282] ។ សហចៅក្រមស៊ើបអង្កេតបានទទួលស្គាល់ជាទូទៅថា ក្រោយពេលកម្មាភិបាលភូមិភាគពាយ័ព្យបានទៅដល់ ប្រជាជនមួយចំនួនធំត្រូវបានចាប់ខ្លួន និងសម្លាប់ រួមទាំងប្រជាជនដែលមានទំនាក់ទំនងជាមួយវៀតណាម និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរផងដែរ ទៅតាមបញ្ជារបស់ អ៊ឹម ចែម និងកម្មាភិបាលផ្សេងៗទៀត[283]។

១៣៨. ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ អ៊ឹម ចែម សហចៅក្រមស៊ើបអង្កេតកត់សម្គាល់នូវភស្តុតាងថា គាត់បានចូលរួមនៅក្នុងចរន្តទីពីរនៃការបោសសម្អាតនៅឆ្នាំ ១៩៧៧ និងដើមឆ្នាំ ១៩៧៨ ដោយដឹកនាំកម្មាភិបាលភូមិភាគនិរតីមួយក្រុម ដែលមានចំនួនពី ៥០០ ទៅ ៦០០ គ្រួសារ និងរួមទាំងទាហានពី ៣០០ ទៅ ៥០០ នាក់ តាមរថភ្លើងពីតាកែវឆ្ពោះទៅភូមិភាគពាយ័ព្យ ដោយឈរនៅតាមផ្លូវនៅទីក្រុងភ្នំពេញ ដែលគាត់បានជួប ប៉ុល ពត នៅទីនោះ[284]។ នៅពេលគាត់ទៅដល់ភូមិភាគពាយ័ព្យ អ៊ឹម ចែម ជាអ្នកទទួលខុសត្រូវការដ្ឋាន និងមន្ទីរសន្តិសុខថ្នាក់តំបន់ និងទទួលព័ត៌មានពីអ្វីដែលបានកើតឡើងនៅមូលដ្ឋាន តាមរយៈប្រភពជាច្រើន ដូចជា របាយការណ៍ ការធ្វើទស្សនកិច្ចដោយផ្ទាល់ ការប្រជុំ និងនីរសារ[285]។ សហចៅក្រមស៊ើបអង្កេតក៏បានធ្វើការកត់សម្គាល់ផងដែរថា អ៊ឹម ចែម មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយ តាម៉ុក[286] ហើយថា គាត់អាចបានដឹងពីការបោសសម្អាតនៅដើមឆ្នាំ ១៩៧៦ នៅពេលគាត់បានចូលរួមការប្រជុំមួយនៅស្រុកកោះអណ្តែត ដែលមានការពិភាក្សាអំពីផែនការផ្លាស់ទីកន្លែងប្រជាជនភូមិភាគនិរតី[287] ។ សហចៅក្រមស៊ើបអង្កេតបានកំណត់អត្តសញ្ញាណភស្តុតាងបន្ថែមថា អ៊ឹម ចែម បាននិយាយជាសាធារណៈប្រឆាំងនឹងកម្មាភិបាលភូមិភាគពាយ័ព្យ ហើយនៅឯការប្រជុំមួយនៅភ្នំលៀប គាត់បានអំពាវនាវឱ្យអ្នកចូលរួមប្រជុំនោះធ្វើការកំណត់អត្តសញ្ញាណកម្មាភិបាលជាន់ខ្ពស់ដើម្បីយកទៅសម្លាប់[288] ។ ហេតុនេះ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា អ៊ឹម ចែម បានដឹងពីអត្ថិភាពនៃការវាយប្រហារ ហើយថា សកម្មភាពរបស់គាត់បានបង្កើតជាផ្នែកនៃការវាយប្រហារនោះ[289] ។ សហចៅក្រមស៊ើបអង្កេតក៏យល់ឃើញបន្ថែមថា គាត់គួរតែ

---

[282] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៣២។

[283] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៨៦។

[284] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៥២, ១៥៥-១៥៦, ២៨៤។

[285] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៨៤។

[286] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៥៥។

[287] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៥៦។

[288] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៨១-១៨២។

[289] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៨៤។

ទទួលខុសត្រូវក្នុងនាមជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំត្រយោង និង ការដ្ឋានប្រឡាយស្ពានស្រែង[290] ដោយសារគាត់បានចែករំលែកនូវផែនការផ្លាស់ប្តូរកម្មាភិបាល[291] និងចូលរួមក្នុងផែនការនោះ ដោយបញ្ជាឱ្យដាក់ទៅជាទាសករ ការចាប់ខ្លួន និងសម្លាប់កម្មាភិបាលភូមិភាគពាយ័ព្យ[292]។

១៣៩. ពាក់ព័ន្ធចំណុចនានាដែលបានលើកឡើងខាងលើ ចៅក្រមដែលចុះហត្ថលេខាយល់ឃើញថា ការចោទប្រកាន់នានាពាក់ព័ន្ធនឹងការបោសសម្អាតនៅភូមិភាគពាយ័ព្យ ទោះជាចំណុចស្នូលនៃការអះអាងរបស់សហព្រះរាជអន្តរជាតិក៏ដោយ តែវាគ្រាន់តែជាការលើកឡើងមួយផ្នែក និងពាក់ព័ន្ធតែទៅនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ដែលបានប្រព្រឹត្តទៅលើកម្មាភិបាលនៅភូមិភាគពាយ័ព្យនៅមន្ទីរសន្តិសុខភ្នំទ្រយោង និង ការដ្ឋានប្រឡាយស្ពានស្រែងប៉ុណ្ណោះ។ សហចៅក្រមស៊ើបអង្កេតពុំបានលើកឡើងនូវភស្តុតាងពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តទៅលើកម្មាភិបាល និងប្រជាជនទូទៅនៅក្នុងបរិបទនៃការបោសសម្អាតនៅភូមិភាគពាយ័ព្យទាំងមូលទេ ហើយជាពិសេសទៅទៀតនៅស្រុកព្រះនេត្រព្រះ និងតំបន់ ៥ ព្រមទាំងការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះតួនាទីរបស់គាត់នៅក្នុងការបោសសម្អាត[293]។ ហេតុនេះ តួនាទីចម្បងរបស់ អ៊ឹម ចែម នៅក្នុងយុទ្ធនាការការចាប់ខ្លួន និង ការសម្លាប់កម្មាភិបាលនៅភូមិភាគពាយ័ព្យជាប្រព័ន្ធ និង ដែលបណ្តាលឱ្យមានការវាយប្រហារទៅលើប្រជាជនស៊ីវិលទូទៅនៅក្នុងភូមិភាគនេះ នឹងត្រូវយកមកពិចារណាមួយផ្នែក ក្នុងការសម្រេចថា តើ គាត់បានស្ថិតនៅក្នុងចំណោមជនទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ឬយ៉ាងណា។

១៤០. ជាពិសេស ចៅក្រមចុះហត្ថលេខាកត់សម្គាល់ថា មានភស្តុតាងគ្រប់គ្រាន់ថា កម្មាភិបាលជាច្រើននាក់ផ្សេងទៀតត្រូវបានចាប់ខ្លួន និងសម្លាប់នៅតំបន់ ៥ ដូចជា សំអាត ដែល អ៊ឹម ចែម បានចោទថាជាជនក្បត់[294] តាក្រក ដែលត្រូវបានចាប់ខ្លួនក្នុងអំឡុងពេលប្រជុំមួយដែល អ៊ឹម ចែម បានរៀបចំ កម្មាភិបាល

---

[290] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣០៩។

[291] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣០៨។

[292] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣០៩។

[293] *សូមមើល* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ (ឯកសារ D1) កថាខណ្ឌ ១៧។

[294] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាច់ គិត ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៤ ឯកសារ D119/74 នៅត្រង់ ERN (ភាសាខ្មែរ) 00971128 (ឆ.១)។

ផ្សេងទៀតនៅឃុំព្រះនេត្រព្រះ[295] និង តាផាង អតីតលេខាឃុំភ្នំលៀប[296]។ ភស្តុតាងក៏បានបង្ហាញផងដែរថា ប្រជាជនចំនួន ១.២១១ នាក់មកពីភូមិភាគពាយ័ព្យត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ និងត្រូវបានសម្លាប់ ដែលភាគច្រើននៅចន្លោះពីខែ មិថុនា ឆ្នាំ ១៩៧៧ រហូតដល់ខែ ឧសភា ឆ្នាំ ១៩៧៨[297]។ ទោះសហចៅក្រមស៊ើបអង្កេតបានយកពិនិត្យទាន់ពេលក៏ដោយ តែពួកគេមិនបានលើកឡើងបន្ថែម [298] នូវវិសាលភាពនៃការកើនឡើងនូវចំនួននៃការចាប់ខ្លួន ការសម្លាប់ និងការបាត់ខ្លួនក្នុងចំណោមប្រជាជនទូទៅ ដោយសារការបោសសម្អាតនោះទេ។ ទោះបីសហចៅក្រមស៊ើបអង្កេតបានធ្វើការសន្និដ្ឋានជាទូទៅថា "កម្មាភិបាលភូមិភាគនិរតីមិនមែនដាក់មុខសញ្ញាតែលើកម្មាភិបាលភូមិភាគពាយ័ព្យប៉ុណ្ណោះទេ" ហើយថា ក្រោយពេលកម្មាភិបាលភូមិភាគនិរតីបានទៅដល់ អ៊ឹម ចែម "គឺជាអ្នកសម្រេចលើការចាប់ខ្លួនមនុស្សជាច្រើននាក់" [299] ក៏ដោយ តែសហចៅក្រមស៊ើបអង្កេតបានធ្វើការកត់សម្គាល់ដោយសង្ខេបប៉ុណ្ណោះចំពោះភស្តុតាងនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្រោមបទបញ្ជារបស់ពួកភូមិភាគនិរតី នៅវត្តព្រះនេត្រព្រះ និងទីតាំងពាក់ព័ន្ធនានា[300] មន្ទីរសន្តិសុខភូមិចក្រី[301] និងព្រៃតារ៉ុត[302] ព្រមទាំងភស្តុតាងនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តទាំងនៅ

---

[295] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុស ណារិន ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D119/38 នៅត្រង់ ERN (ភាសាខ្មែរ) 00915849 (ឆ.១២)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ D119/99 នៅត្រង់ ERN (ភាសាខ្មែរ) 00978922 (ឆ.២៦-២៧)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D119/121 នៅត្រង់ ERN (ភាសាខ្មែរ) 00985871 (ឆ.៣៥), 00985872 (ឆ.៤២) និង 00985872-00985873 (ឆ.៤៣-៤៤)។ *សូមមើលផងដែរ* ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៥៤។

[296] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វា នង់ ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D119/43 នៅត្រង់ ERN (ភាសាខ្មែរ) 00915884 (ឆ.១៨)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដួង វ័ន្តឌី ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ D119/48 នៅត្រង់ ERN (ភាសាខ្មែរ) 00933098 (ឆ.៥)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D119/121 នៅត្រង់ ERN (ភាសាខ្មែរ) 00985871 (ឆ.៣៥), 00985872 (ឆ.៤២) និង 00985872-00985873 (ឆ.៤៣-៤៤)។

[297] *សូមមើល* សំណុំរឿង ០០៤/១ បញ្ជីឈ្មោះអ្នកទោស ស-២១ ដែលមកពីភូមិភាគពាយ័ព្យ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ ឯកសារ D6.1.890។

[298] *សូមមើល* ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ (ឯកសារ D1) កថាខណ្ឌ ១១, ៥៩។

[299] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៨០។

[300] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៥២, ២៥៧។

[301] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៦០, ២៦៣។

[302] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៦៤, ២៦៦-២៦៧។

ក្រោមការដឹកនាំរបស់ភូមិភាគពាយ័ព្យ និងភូមិភាគនិរតីនៅវត្តចម្ការខ្នុរ [303] និងត្រពាំងថ្ម [304] ។ ភាគច្រើនសហចៅក្រមស៊ើបអង្កេតមិនបានធ្វើការសន្និដ្ឋានណាមួយពាក់ព័ន្ធនឹងវិសាលភាព និងស្ថានទម្ងន់នៃឧក្រិដ្ឋកម្មទាំងនោះដែលមិនត្រូវបានចោទប្រកាន់ទេ ជាពិសេស ទាក់ទិននឹងការវាយតម្លៃចំពោះចំនួនជនរងគ្រោះ និងការទទួលខុសត្រូវរបស់ អ៊ឹម ចែម។ ដោយកត់សម្គាល់ថា បញ្ហាទាំងនេះនឹងត្រូវលើកមកពិចារណាលម្អិតខាងក្រោម ចៅក្រមចុះហត្ថលេខាយល់ឃើញថា មនុស្សច្រើនពាន់នាក់មកពីភូមិភាគពាយ័ព្យអាចត្រូវបានធ្វើការបោសសម្អាតនៅតាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សជាច្រើន នៅភូមិភាគពាយ័ព្យបន្ថែមទៅលើជនរងគ្រោះដែលត្រូវបានកំណត់អត្តសញ្ញាណ និង បានរាប់ចំនួននៅក្នុងកំណត់ហេតុមន្ទីរ ស-២១។

១៤១. ចៅក្រមចុះហត្ថលេខារម្លឹកឡើងវិញថា ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបណ្តាលមកពីការបោសសម្អាតនៅភូមិភាគពាយ័ព្យ និងដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ អ៊ឹម ចែម រួមទាំងការសម្លាប់ ការចាប់ខ្លួនដោយខុសច្បាប់ និងការឃុំឃាំង ការធ្វើទុក្ខបុកម្នេញ ការបាត់ខ្លួនដោយបង្ខំ និងអំពើអមនុស្សធម៌ផ្សេងទៀត គួរតែត្រូវលើកឡើងឲ្យបានច្បាស់ និង ផ្តល់សំអាងហេតុនៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ)។ ដូចដែលសហចៅក្រមស៊ើបអង្កេតបានទទួលស្គាល់រួចមកហើយ គឺថាពិតជាមានភស្តុតាងគ្រប់គ្រាន់ដែលថា អ៊ឹម ចែម បានដឹងពីការវាយប្រហារទៅលើប្រជាជនស៊ីវិលនៅភូមិភាគពាយ័ព្យ ហើយថា សកម្មភាពរបស់គាត់ រួមទាំងការដឹកនាំការបោសសម្អាត បានបង្កើតជាផ្នែកនៃការដឹងឮនោះ[305] ព្រមទាំងភស្តុតាងគ្រប់គ្រាន់ដែលថា គាត់បានចែករំលែកផែនការក្នុងការផ្លាស់ប្តូរកម្មាភិបាលភូមិភាគពាយ័ព្យ និង បានចូលរួម ដោយបញ្ជាឲ្យដាក់ទៅជាទាសករ ការចាប់ខ្លួន និងសម្លាប់[306]។ អនុលោមទៅតាមការធ្វើសន្និដ្ឋានទាំងនេះ និង ការប្រព្រឹត្ត និងសិទ្ធិអំណាចរបស់ អ៊ឹម ចែម ទាំងនៅក្នុងតំបន់ ៥ និង ស្រុកព្រះនេត្រព្រះនោះ [307] មានភស្តុតាងគ្រប់គ្រាន់ដើម្បីបង្ហាញថា គាត់អាចទទួលខុសត្រូវក្នុងនាមជាសមាជិកសហឧក្រិដ្ឋកម្មរួម ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តមិនត្រឹមតែនៅមន្ទីរសន្តិសុខភ្នំត្រយោង និងការដ្ឋានប្រឡាយស្ពានស្រែងប៉ុណ្ណោះទេ តែក៏បានប្រព្រឹត្តយ៉ាងហោចណាស់នៅក្នុងតំបន់ ៥ ទាំងមូលនៃភូមិភាគពាយ័ព្យដែរ។

[303] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៦៩-២៧០។

[304] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៧៤, ២៧៦-២៧៨។

[305] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៨៤។

[306] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣០៨-៣០៩។

[307] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៨០-១៨៤។

១៤២. ចៅក្រមចុះហត្ថលេខាសន្និដ្ឋានថា ជារួម សហចៅក្រមស៊ើបអង្កេតពុំបានធ្វើការកំណត់តាមផ្លូវច្បាប់ឱ្យបានត្រឹមត្រូវទេ ពាក់ព័ន្ធនឹងការបោសសម្អាតនៅភូមិភាគពាយ័ព្យ ដើម្បីពិចារណាអំពីស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម និងដើម្បីវាយតម្លៃទៅលើការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មទាំងនោះ។ អាស្រ័យហេតុនេះ ចៅក្រមចុះហត្ថលេខាសូមធ្វើការតម្កល់ទឡ្ហីករណ៍ទី២(១) នៃបណ្តឹងឧទ្ធរណ៍ ហើយនឹងធ្វើការដោះស្រាយនាពេលបន្ទាប់នៅក្នុងសាលដីកានេះថា តើការខកខាននេះ ជាកត្តាសម្រេចជាមូលដ្ឋាននៃការកំណត់ទៅលើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬយ៉ាងណា។

## ខ. មូលដ្ឋានទី២(២)៖ អាពាហ៍ពិពាហ៍ដោយបង្ខំ

១៤៣. សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើង នៅក្នុងទឡ្ហីករណ៍ទី២(២) នៃបណ្តឹងឧទ្ធរណ៍ថា សហចៅក្រមស៊ើបអង្កេតខកខានមិនបានវាយតម្លៃអំពីបញ្ហាអាពាហ៍ពិពាហ៍ដោយបង្ខំថាជាអំពើអមនុស្សធម៌ផ្សេងៗទៀត នៅក្នុងតំបន់ ៥ និងតំបន់ ១៣ ដែលបញ្ហានេះគាត់បានអះអាងថាបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានស្ថាពរ[308]។

១៤៤. ចៅក្រមទទួលបន្ទុករឿងក្តីនេះយល់ស្របថា បទល្មើសអាពាហ៍ពិពាហ៍ដោយបង្ខំមិនត្រូវបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) ទេ។ ទោះបីយ៉ាងណាក៏ដោយ តាមការពិនិត្យឡើងវិញទៅលើវិសាលភាពនៃកិច្ចស៊ើបសួរបង្ហាញថា សហចៅក្រមស៊ើបអង្កេតមិនទទួលបានបណ្តឹងអំពីការចោទប្រកាន់បែបនេះទេ ហើយសហចៅក្រមស៊ើបអង្កេតមិនមានកំហុសឡើយដែលមិនបានធ្វើការកំណត់តាមផ្លូវច្បាប់ទៅលើអាពាហ៍ពិពាហ៍ដោយបង្ខំថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ។

១៤៥. ជាបឋម ចៅក្រមទទួលបន្ទុករឿងក្តីនេះកត់សម្គាល់ថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ មិនបានដាក់បញ្ចូលការចោទប្រកាន់តាមអង្គហេតុអំពីអាពាហ៍ពិពាហ៍ដោយបង្ខំថាជាអំពីអមនុស្សធម៌ផ្សេងៗទៀតឡើយ។ បន្ទាប់មកទៀត ទោះបីជាដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមជាក់លាក់ស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ បានស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចស៊ើបសួរទៅលើការចោទប្រកាន់ពាក់ព័ន្ធនឹងការពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងតំបន់១ និងតំបន់៤១ ក៏ដោយ[309] ក៏ដីកាសន្និដ្ឋាននេះបានកម្រិតយ៉ាងច្បាស់អំពីវិសាលភាពនៃកិច្ចស៊ើបសួររបស់ពួកគាត់ត្រឹមតែតំបន់ចំនួនពីរ

---

[308] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៧-២៨។

[309] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ (ឯកសារ D191) កថាខណ្ឌ ២-៦។

01575510



ប៉ុណ្ណោះ ហើយភស្តុតាងដែលមាននៅក្នុងសំណុំរឿងពាក់ព័ន្ធនឹងតំបន់ទាំងពីរនេះមិនបានបង្កើតនូវទំនាក់ទំនងជាមួយនឹង អ៊ឹម ចែម ទេ។ ចុងក្រោយ នៅក្នុងការឆ្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដោយស្នើសុំឱ្យស៊ើបសួរទៅលើការចោទប្រកាន់អំពីអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងស្រុកសំឡូតក្នុងតំបន់ ១[310] ដែលមិនមានជាប់ទាក់ទិនសម្រាប់តំបន់៥ និងតំបន់១៣ ឡើយ។

១៤៦. ហេតុនេះ ទោះបីជាការពិនិត្យដោយសង្ខេបទៅលើភស្តុតាងដែលប្រមូលបាននៅក្នុងសំណុំរឿង ០០៤/១ អាចផ្តល់នូវហេតុផលឱ្យសហព្រះរាជអាជ្ញាអន្តរជាតិជឿជាក់បានថា បទល្មើសអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានប្រព្រឹត្តឡើងនៅក្នុងតំបន់ ៥[311] និងតំបន់ ១៣[312] ក៏ដោយ បើតាមខ្លឹមសារនៃវិធាន ៥៣ (១) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតមិនអាចចាត់ទុកថាខ្លួនត្រូវបានស្នើសុំឱ្យធ្វើការស៊ើបសួរដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដែលពង្រីកវិសាលភាពនៃកិច្ចស៊ើបសួរទៅក្នុងតំបន់ទាំងនោះ ឡើយ។ អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតមិនបានខកខានក្នុងការលើកឡើងនៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) អំពីបញ្ហាអាពាហ៍ពិពាហ៍ដោយបង្ខំថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀតនោះឡើយ។ ទឡ្ហីករណ៍រងទី ៥(២) នៃបណ្តឹងឧទ្ធរណ៍ត្រូវបានបដិសេធ។

---

[310] សំណុំរឿង ០០៤/១ ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរទៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងតំបន់១ និងតំបន់៤ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ និងបានដាក់នៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ D272/1 កថាខណ្ឌ ១០-១១។

[311] *សូមមើល ឧទា.* សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ រឿង សារួន ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D5/865 នៅត្រង់ ERN (ភាសាខ្មែរ) 00957089-00957090។ សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ស៊ុន ស៊ុយ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D5/895 នៅត្រង់ ERN (ភាសាខ្មែរ) 00973710។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយ ថង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D119/131 នៅត្រង់ ERN (ភាសាខ្មែរ) 00996500 (ឆ. ៦៥)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយ សែន សុផុន ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ D219/506 នៅត្រង់ ERN (ភាសាខ្មែរ) 01148734 (ឆ. ៥១)។

[312] *សូមមើល ឧទា.* សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយ យិន តេង ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ D219/135 នៅត្រង់ ERN (ភាសាខ្មែរ) 01052735-01052745 (ឆ. ៤២១ - ឆ. ៥២៨)។

### គ. មូលដ្ឋានទី២(៣) ៖ ឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិវៀតណាម

១៤៧. ទឡ្ហីករណ៍ទី ២(៣) នៃបណ្តឹងឧទ្ធរណ៍ចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតមិនបានពិចារណាការចោទប្រកាន់ភាគច្រើនដែលទាក់ទងនឹងការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវពាក់ព័ន្ធនឹងការការប្រព្រឹត្តលើជនជាតិវៀតណាមនៅក្នុងតំបន់ ៥[313] ។ សហព្រះរាជអាជ្ញាអន្តរជាតិបានចង្អុលលើភស្តុតាងបង្ហាញពីការចូលរួមរបស់ អ៊ឹម ចែម ក្នុងការសម្លាប់ស្ត្រីជនជាតិវៀតណាម ២ នាក់ និងនៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខភ្នំត្រយោង ការដ្ឋានស្ពានស្រែង មន្ទីរសន្តិសុខចម្ការខ្នុរ វាលពិឃាតព្រៃតារុត ការដ្ឋានទំនប់ត្រពាំងថ្ម និងវត្តព្រះនេត្រព្រះ[314]។

១៤៨. ចៅក្រមទទួលបន្ទុករឿងក្តីសង្កេតឃើញថា បទចោទដែលបានស្នើឡើងប្រឆាំងនឹង អ៊ឹម ចែម នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ រួមមាន ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ពូជសាសន៍ និងសាសនា ដែលប្រព្រឹត្តទៅលើ *ក្នុងចំណោមបុគ្គលផ្សេងទៀត* ជនជាតិភាគតិចវៀតណាម ប៉ុន្តែ ពុំមែនការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវនោះទេ[315] ។ ចៅក្រមទទួលបន្ទុករឿងក្តីនេះសូមរំលឹកថា ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ អាចត្រូវបានកំណត់និយមន័យថាជាការប្រព្រឹត្តដោយចេតនានូវអំពើសកម្ម ឬអំពើអកម្ម ដែលពិតជារើសអើង និងដកហូត ឬរំលោភលើសិទ្ធិជាមូលដ្ឋានដែលមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬច្បាប់សន្ធិសញ្ញាអន្តរជាតិ (*ធាតុផ្សំសត្យានុម័ត*) ដោយមានចេតនារើសអើងដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា (*ធាតុផ្សំអត្តនោម័ត*)[316]។

១៤៩. សហចៅក្រមស៊ើបអង្កេតទទួលបានការចោទប្រកាន់អង្គហេតុយ៉ាងជាក់លាក់បន្ថែមទៀត ទាក់ទងនឹងការបោសសំអាតភូមិភាគពាយ័ព្យ ដែល អ៊ឹម ចែម ត្រូវបានចោទប្រកាន់ថាបានចូលរួមក្នុងនាមជាសហចារី។ តាមការចោទប្រកាន់ ការបោសសំអាតនេះបានកំណត់គោលដៅលើបុគ្គលនានា ក្នុងនោះ "ជនជាតិ

---

[313] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៩, ៣២។

[314] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៩-៣២។

[315] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី (ឯកសារ D1) កថាខណ្ឌ ១១៩។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ (ឯកសារ D191) កថាខណ្ឌ ១៣។

[316] សាលដីកានៃសំណុំរឿង ០០១ (ឯកសារ F28) កថាខណ្ឌ ២២៦, ២៤១។

ពិន្ទុវៀតណាម" និងបាននាំឱ្យមានការកើនឡើងចំនួននៃការចាប់ខ្លួន [និង] ការសម្លាប់យ៉ាងច្រើនសន្ធឹកសន្ធាប់"[317]។ យោងតាមកថាខណ្ឌទី ៥៩ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ជនរងគ្រោះនៃការបោសសំអាតនៅក្នុងចំណោមប្រជាជនទូទៅ រួមមាន ជនជាតិពិន្ទុវៀតណាម ដែលត្រូវបានឃុំខ្លួន និងសម្លាប់នៅតាមមន្ទីរសន្តិសុខ ទីតាំងសម្លាប់មនុស្ស និងការដ្ឋានធ្វើការដោយបង្ខំ ដូចមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី។ ការចោទប្រកាន់អង្គហេតុ ទាក់ទងនឹងវត្តចម្ការខ្នុរ ចែងបញ្ជាក់យ៉ាងច្បាស់ថា "ជនរងគ្រោះជាច្រើនគឺជាអ្នកតាំងទីលំនៅជនជាតិវៀតណាម" [318] ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ បានប្តឹងសហចៅក្រមស៊ើបអង្កេតយ៉ាងច្បាស់ អំពីការរំលោភសេពសន្ថវៈ និងការសម្លាប់ស្ត្រីជនជាតិវៀតណាមពីរនាក់នៅក្នុងស្រុកព្រះនេត្រព្រះ[319]។

១៥០. ដូច្នេះ ចៅក្រមដែលទទួលបន្ទុកលើរឿងក្តី យល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានទទួលបណ្តឹងអំពីបទល្មើសនៃការធ្វើទុក្ខបុកម្នេញចំពោះបុគ្គលដែលមានជាតិពិន្ទុវៀតណាម នៅតាមទីតាំងឧក្រិដ្ឋកម្មដូចបានរៀបរាប់ ហើយនៅតំបន់ ៥ ជារួម ក្នុងបរិបទនៃការបោសសំអាតភូមិភាគពាយ័ព្យ។ ទោះជាយ៉ាងណាក៏ដោយ ចៅក្រមមិនបានចោទប្រកាន់ អ៊ឹម ចែម ពីឧក្រិដ្ឋកម្មនេះនៅមន្ទីរសន្តិសុខភ្នំត្រយោង ការដ្ឋានស្ពានស្រែង ឬ ទីតាំងឧក្រិដ្ឋកម្មផ្សេងណាទៀតឡើយ[320]។

១៥១. ចៅក្រមដែលទទួលបន្ទុកលើរឿងក្តីនឹងពិនិត្យមើលថា តើសហចៅក្រមស៊ើបអង្កេតខកខានពិចារណាការចោទប្រកាន់ "ស្ទើរតែទាំងអស់" នៃការធ្វើទុក្ខបុកម្នេញលើជនជាតិពិន្ទុវៀតណាមដែរឬទេ។ ដោយសារចៅក្រមបានទទួលការចោទប្រកាន់ទាំងនេះយ៉ាងត្រឹមត្រូវ ចៅក្រមមានកាតព្វកិច្ចអនុលោមតាមវិធាន ៥៥(២) និង ៦៧(១) នៃវិធានផ្ទៃក្នុង ស៊ើបអង្កេត និងសម្រេចលើការចោទប្រកាន់ទាំងនេះនៅពេលចេញដីកាដំណោះស្រាយ (សំអាងហេតុ)។

១៥២. ជាដំបូង ចៅក្រមទទួលបន្ទុកលើរឿងក្តីកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេត មិនបានធ្វើការកំណត់តាមផ្លូវច្បាប់ឲ្យបានច្បាស់លាស់ ទាក់ទងនឹងការធ្វើទុក្ខបុកម្នេញលើជនជាតិពិន្ទុវៀតណាមនៅក្នុង

---

[317] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី (ឯកសារ D1) កថាខណ្ឌ ១១, ១៧, ៥៩។

[318] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី (ឯកសារ D1) កថាខណ្ឌ ៧១។

[319] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ (ឯកសារ D191) កថាខណ្ឌ ៩។

[320] *សូមមើល* សេចក្តីជូនដំណឹងអំពីបទចោទ (ឯកសារ D239.1)។

តំបន់ ៥ លើកលែងតែទាក់ទងនឹងបទល្មើសដែលត្រូវបានប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខភ្នំត្រយោង[321] និងបានធ្វើការសន្និដ្ឋានដោយសង្ខេបមួយថា "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ [...] ការធ្វើទុក្ខបុកម្នេញ ត្រូវបានប្រព្រឹត្តឡើងនៅវត្តអង្គស្រីមាលា និងទីតាំងសម្លាប់មនុស្សព្រៃសុខុន វត្តព្រះនេត្រព្រះ និងទីតាំង ដែលពាក់ព័ន្ធនានា មន្ទីរសន្តិសុខភូមិចក្រី ទីតាំងសម្លាប់មនុស្សព្រៃតារ៉ុត វត្តចំការខ្នុរ និងការដ្ឋានត្រពាំងថ្ម"[322]។

១៥៣. ទោះបីយ៉ាងណាក៏ដោយ សហចៅក្រមស៊ើបអង្កេតបានធ្វើការសន្និដ្ឋានពាក់ព័ន្ធផ្សេងៗទៀតជាច្រើន នៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) ដោយបានកត់សម្គាល់ជាក់លាក់ថា "កម្មាភិបាលភូមិភាគនិរតីបានធ្វើការវាយប្រហារទៅលើប្រជាជនស៊ីវិល [នៅក្នុងតំបន់ ៥]" ដែលក្នុងនោះរួមមាន "ការរៀនសូត្រ" ឬ ការបោសសម្អាត "សមាសធាតុមិនល្អ" ឬ "ខ្មាំង" ពិតប្រាកដ ឬ តាមការគិតរបស់ ប.ក.ក ប្រជាជនដែលគេគិតថាមានទំនាក់ទំនងជាមួយវៀតណាម"[323]។ "ប្រជាជនដែលត្រូវបានកំណត់ថាស្ថិតក្នុងក្រុមទាំងនេះត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅមន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្សផ្សេងៗ នៅក្នុងតំបន់ ៥ ដូចជា មន្ទីរសន្តិសុខភ្នំត្រយោង ដែលនៅទីនោះ ពួកគេរាប់រយនាក់ត្រូវបានសម្លាប់"[324]។ សហចៅក្រមស៊ើបអង្កេត ក៏បានពិចារណាភ័ស្តុតាងផងដែរដែលថា "នៅក្រោមការគ្រប់គ្រងរបស់ អ៊ឹម ចែម ជាលេខាស្រុកព្រះនេត្រព្រះ [...] មនុស្សដែលជាប់ទាក់ទងជាមួយនឹងវៀតណាម [...] ត្រូវបានចាប់ខ្លួន និងសម្លាប់ចោល" ហើយ "អ៊ឹម ចែម គឺជាអ្នកសម្រេចលើការចាប់ខ្លួនមនុស្សជាច្រើននាក់"[325]។ ពាក់ព័ន្ធនឹងការវាយតម្លៃទៅលើការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់គាត់ ចៅក្រមបានរកឃើញថា គាត់ និងកម្មាភិបាលភូមិភាគនិរតីផ្សេងទៀត "មានផែនការរួមគ្នាក្នុងការផ្លាស់ប្តូរកម្មាភិបាលភូមិភាគពាយ័ព្យ [...] និងអនុវត្តគោលនយោបាយរបស់ ប.ក.ក ឱ្យបានជោគជ័យ" រួមទាំង "ការឃុំខ្លួន និងសម្លាប់ពលករដែលគិតថាជាខ្មាំង និងអ្នកដែលគេចាត់ទុកថាមានទំនាក់ទំនងជាមួយវៀតណាម ឬ ជាមួយរដ្ឋាភិបាល លន់ នល់"[326]។

---

[321] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៩៥។

[322] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣០៥។

[323] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៨១។

[324] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៨១។

[325] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៨៦។

[326] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣០៨។

01575514



១៥៤. ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មជាក់លាក់នៅក្នុងតំបន់ ៥ សហចៅក្រមស៊ើបអង្កេតបានសំអាងបន្ថែមលើភស្តុតាងដែលបង្ហាញថា "អ្នកទោសនៅមន្ទីរសន្តិសុខ [ភ្នំត្រយោង] រួមមាន ជនជាតិវៀតណាម"[327] ហើយ "ហេតុផលចាប់ខ្លួននៅ [ការដ្ឋានប្រឡាយស្ពានស្រែង] រួមមាន ការជាប់ទាក់ទងជាមួយគ្រួសារ ឧទាហរណ៍ ជាមួយនឹងអ្នកដែលជាប់សាច់ឈាមវៀតណាម"[328]។ សហចៅក្រមស៊ើបអង្កេតជឿជាក់ថា ឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំត្រយោងគឺជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពីព្រោះ "មនុស្សជាច្រើនដែលត្រូវបានឃុំខ្លួន ត្រូវបានដាក់ឱ្យទៅជាទាសករ និងត្រូវបានសម្លាប់ [នៅទីនោះ] គឺ [...] ជាមនុស្សដែលគិតថាមានទំនាក់ទំនងជាមួយវៀតណាម ឬ ជាមនុស្សដែលគេចាត់ទុកថាជា "ជនក្បត់" ប.ក.ក ឬ "សមាសធាតុមិនល្អ" [ដែលត្រូវបានកំណត់គោលដៅ] ដោយសារពួកគេស្ថិតនៅក្នុងប្រភេទទាំងនេះ"[329]។ ផ្ទុយមកវិញ នៅពេលពិនិត្យមើលសង្ខេបលើភស្តុតាងទាក់ទងនឹងឧក្រិដ្ឋកម្មដែលពុំបានចោទប្រកាន់ សហចៅក្រមស៊ើបអង្កេត ពុំពិចារណាចម្លើយសាក្សីដែលពុំមានមូលដ្ឋានបញ្ជាក់ដែលបានលើកឡើងថា គ្រួសារវៀតណាមចំនួន ១០០០ គ្រួសារ បានបាត់ខ្លួនពីទំនប់ត្រពាំងថ្ម ក្នុងរយៈពេល ២៤ ម៉ោង ក្នុងឆ្នាំ១៩៧៨[330] ក៏ដូចជាភស្តុតាងពាក់ព័ន្ធនឹងការរំលោភសេពសន្ថវៈ និងការសម្លាប់ស្ត្រីជនជាតិវៀតណាមចំនួនពីរនាក់នៅស្រុកព្រះនេត្រព្រះ ដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថាពុំមានភស្តុតាងគ្រប់គ្រាន់[331]។

១៥៥. ចៅក្រមទទួលបន្ទុកលើរឿងក្តីពិចារណាឃើញថា ការយល់ឃើញទាំងនេះឆ្លើយតបបានតែមួយផ្នែកប៉ុណ្ណោះចំពោះការចោទប្រកាន់ថា ជនជាតិពិន្ទុវៀតណាមត្រូវបានគេធ្វើទុក្ខបុកម្នេញនៅភូមិភាគពាយ័ព្យ រួមទាំងនៅតាមទីតាំងឧក្រិដ្ឋកម្មផ្សេងទៀតក្រៅពីមន្ទីរសន្តិសុខភ្នំត្រយោង។ យោងតាមហេតុផលដូចគ្នាដូចខាងលើ[332] ចៅក្រមទទួលបន្ទុកលើរឿងក្តីយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមិនបានឆ្លើយតបទៅនឹងភស្តុតាងទាក់ទងនឹងបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងប្រឆាំងនឹងជនជាតិវៀតណាមក្នុងបរិបទនៃការបោសសម្អាតភូមិភាគពាយ័ព្យ ជាពិសេសនោះ ស្រុកព្រះនេត្រព្រះ និងតំបន់ ៥ ហើយខកខានមិនបានធ្វើការកំណត់តាមផ្លូវច្បាប់ឱ្យបានត្រឹមត្រូវអំពីវិសាលភាព និងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មទាំងនេះ។

---

[327] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២០២។

[328] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៣៨។

[329] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៩៥។

[330] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៧៦។

[331] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៧៩-២៨០។

[332] *សូមមើល កថាខណ្ឌ* ១៣២-១៤២ ខាងលើ។

១៥៦. តាមការពិ ក្រោយពីបានពិនិត្យមើលភ័ស្តុតាងនៅក្នុងសំណុំរឿង ចៅក្រមទទួលបន្ទុកលើរឿងក្តីយល់ឃើញថា ជារួម មានភ័ស្តុតាងគ្រប់គ្រាន់បង្ហាញទៅតាមលក្ខខណ្ឌតម្រូវនៅក្នុងដំណាក់កាលនេះថា ជនជាតិពិន្ទុវៀតណាម និងអ្នកដែលជាប់ពាក់ព័ន្ធនឹងវៀតណាម ត្រូវបានកំណត់គោលដៅ ចាប់ខ្លួន និងសម្លាប់ចោលក្រោមការគ្រប់គ្រងរបស់កម្មាភិបាលភូមិភាគនិរតីនៅក្នុងភូមិភាគពាយ័ព្យនោះ។ ទាក់ទងនឹងការដ្ឋានសាងសង់ទំនប់ត្រពាំងថ្ម ទោះបីសហចៅក្រមស៊ើបអង្កេតបានច្រានចោលភ័ស្តុតាងដែលបង្ហាញថា គ្រួសារជនជាតិវៀតណាមចំនួន ១០០០ គ្រួសារ បានបាត់ខ្លួនក្នុងរយៈពេលមួយថ្ងៃក្នុងឆ្នាំ ១៩៧៨ ក៏ដោយ[333] ក៏ប៉ុន្តែ យើងឃើញមានភ័ស្តុតាងគ្រប់គ្រាន់បង្ហាញថា ជនជាតិពិន្ទុវៀតណាម និងអ្នកដែលជាប់ពាក់ព័ន្ធនឹងវៀតណាម ត្រូវបានគេកំណត់គោលដៅជារួម[334]។ ជាពិសេស ទៅ ចាត់ បានលើកឡើងថា នៅពេល អ៊ឹម ចែម ទទួលខុសត្រូវជាគណៈស្រុក ប្រជាជនជាច្រើននាក់ត្រូវបានសម្លាប់នៅទំនប់ត្រពាំងថ្ម ហើយជនជាតិវៀតណាមត្រូវបានគេស្វែងរក ចាប់ខ្លួន និងសម្លាប់ចោល[335]។ ជៀប ឈាន បានរាយការណ៍ថា នៅឆ្នាំ ១៩៧៧ ប្រជាជននៅក្នុងកងរបស់គាត់ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ថាជាប់ពាក់ព័ន្ធនឹង

---

[333] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៧៦។ *សូមមើលផងដែរ* សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៣ ឯកសារ D119/23 ត្រង់ ERN (EN) 00935608 ( ឆ២០)។

[334] សំណុំរឿង ០០៤/០១ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ប៊ូ ម៉ៅ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D123/1/2.53 ត្រង់ ERN (EN) 00969902-00969905, 00969909។ សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៤ ឯកសារ D119/94 ត្រង់ ERN (EN) 00982761 (ឆ៣៧)។ សំណុំរឿង ០០៤/០១ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឃ ម៉ុត ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D123/1/2.57 ត្រង់ ERN (EN) 00987554។ សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក សាំ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ ឯកសារ D119/120 ត្រង់ ERN (EN) 01057753 (ឆ១៤៤)។ សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម សីលា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៤ ឯកសារ D219/35 ត្រង់ ERN (EN) 01053592 (ឆ៤៤)។ សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទៅ ចាត់ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D219/130 ត្រង់ ERN (EN) 01059955 (ឆ១៥១-ឆ១៥៣) និង 01059963 (ឆ២០៧)។ សំណុំរឿង ០០៤/០១ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ពេជ្រ ហម ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៧ ឯកសារ D123/1/1.6a ត្រង់ ERN (EN) 00982770។

[335] សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទៅ ចាត់ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D219/130 ត្រង់ ERN (EN) 01059955 (ឆ១៥១-ឆ១៥៣) និង 01059963 (ឆ២០៧)។

យួន[336]។ ពេជ្រ ហម បានបន្ថែមទៀតថា មនុស្សត្រូវបានគេតាមដានប្រវត្តិរូប ដូចបានបញ្ជាក់ដោយ ចាន់ ឌៀល[337] ហើយអ្នកដែលត្រូវបានគេរកឃើញថាជាជនជាតិវៀតណាម មិនមានសុវត្ថិភាពនោះទេ[338]។

១៥៧. ជនជាតិវៀតណាម និងអ្នកដែលជាប់ពាក់ព័ន្ធនឹងវៀតណាម ក៏ត្រូវបានគេកំណត់គោលដៅដូចគ្នា នៅកន្លែងផ្សេងទៀតក្នុងតំបន់ ៥។ ក្នុងស្រុកព្រះនេត្រព្រះ ចាន់ ឌៀល បានបញ្ជាក់ថា អ្នកដែលរាប់អាន យួន ត្រូវបានសម្លាប់ចោល រួមជាមួយក្រុមគ្រួសាររបស់ពួកគេ នៅកន្លែង តាក្រាក់[339] ខណៈដែល ឈៀន ហ្សួង បានរៀបរាប់ថា គ្រួសារវៀតណាម ២ គ្រួសារ ដែលមានសមាជិក ១២ នាក់ ត្រូវបានគេយកទៅ សម្លាប់ចោលនៅក្នុងឆ្នាំ ១៩៧៧[340]។ ម៉ក់ វន្នី បានរាយការណ៍ថា អ្នកដែលត្រូវបានគេសម្លាប់នៅព្រៃតារ៉ុត ត្រូវបានគេចោទថាជាជនជាតិវៀតណាម[341]។ ឃ ម៉ុត បានរៀបរាប់ពិពណ៌នាអំពីរបៀបដែលនៅវាល ដណ្តៅបក្តាម គាត់ និងអ្នកដទៃ ត្រូវបានចាប់ខ្លួនបញ្ជូនទៅសម្លាប់ នៅពេលដែលពួកគេត្រូវបានចោទ ប្រកាន់ថាជាយួន[342]។ ពេជ្រ រស់ ក៏បានលើកឡើងផងដែរថា អ្នកដែលត្រូវបានចោទប្រកាន់ថាមានទំនាក់ ទំនងជាមួយ យួន ត្រូវបានសម្លាប់នៅភ្នំត្រយោង ឬ ភ្នំលៀប[343]។ ភួង ប៉ៃ និង ប្រាក់ ការ ដែលរស់នៅក្នុង ស្រុកភ្នំស្រុក និងអ្នកដែលត្រូវបានចោទប្រកាន់ថាជាជនជាតិវៀតណាម បានរាយការណ៍ថា កម្មាភិបាល

---

[336] សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជៀប ឈាន ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D6.1.431 ត្រង់ ERN (EN) 00277817។

[337] សំណុំរឿង ០០៤/០១ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាមួយ ចាន់ ឌៀល ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D123/1/2.48 ត្រង់ ERN (EN) 01063444។

[338] សំណុំរឿង ០០៤/០១ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ពេជ្រ ហម ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៧ ឯកសារ D123/1/1.6a ត្រង់ ERN (EN) 00982770។

[339] សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ឌៀល ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៣ ឯកសារ D119/39 ត្រង់ ERN (EN) 00944479 (ឆ៧)។

[340] សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ឌៀល ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៣ ឯកសារ D5/929/1 ត្រង់ ERN (EN) 00979900។

[341] *សូមមើល ឧ.* សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ក់ វន្នី ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D119/125 ត្រង់ ERN (EN) 01035088 (ឆ១៤, ឆ១៨)។

[342] សំណុំរឿង ០០៤/០១ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឃ ម៉ុត ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D123/1/2.57 ត្រង់ ERN (EN) 00987556-00987557 និង ERN (FR) 01169540-01169541។

[343] សំណុំរឿង ០០៤/០១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ពេជ្រ រស់ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៣ ឯកសារ D5/1100 ត្រង់ ERN (EN) 01186136។

ភូមិភាគនិរតីបានសំរិតសំរាំងគ្រួសារវៀតណាមដែលនៅសេសសល់ ហើយបានជ្រើសរើសពួកគេយកទៅសម្លាប់ចោល[344]។ នៅស្រុកស៊ីសុផុន ស៊ាន ញៀន បានឱ្យដឹងថា ជនរងគ្រោះភាគច្រើនក្នុងចំណោមជនរងគ្រោះចំនួន ៤០០០ ទៅ ៤៥០០ នាក់ នៅចម្ការខ្នុរ ត្រូវបានទទួលស្គាល់ជាជនជាតិវៀតណាមដែលបានតាំងលំនៅយូរមកហើយ[345]។ ទិល ហោវ ក៏ត្រូវបានគេប្រាប់ផងដែរថា ជនវៀតណាមត្រូវបានចាប់ខ្លួន និងបញ្ជូនទៅចម្ការខ្នុរក្រោមការគ្រប់គ្រងរបស់កម្មាភិបាលនិរតី[346] ហើយ អឿ លឿ ត្រូវបានដាក់គុកនៅទីនោះចាប់ពីឆ្នាំ១៩៧៦ ដល់ ឆ្នាំ១៩៧៨ ពាក់ព័ន្ធនឹងការប្រកាន់ថាជាជនជាតិវៀតណាម[347]។ មានភស្តុតាងស្រដៀងគ្នាបន្ថែមទៀតបង្ហាញថា ប្រជាជនត្រូវបានសម្លាប់ចោលដោយសារតែមានទំនាក់ទំនងជាមួយវៀតណាម នៅគ្រប់តំបន់ទាំងអស់ក្នុងភូមិភាគពាយ័ព្យ[348]។

---

[344] សំណុំរឿង ០០៤/០១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ភួង ផៃ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៣ ឯកសារ D5/998 ត្រង់ ERN (EN) 01190850។ សំណុំរឿង ០០៤/០១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប្រាក់ ការ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៣ ឯកសារ D5/1000 ត្រង់ ERN (EN) 01135194។

[345] សំណុំរឿង ០០៤/០១ របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា ការកំណត់ផែនទីវាលពិឃាតនៅក្នុងប្រទេសកម្ពុជា - បន្ទាយមានជ័យ ឆ្នាំ១៩៩៨ ឯកសារ D118/38 ត្រង់ ERN (EN) 00078068។ *សូមមើលផងដែរ* សំណុំរឿង ០០៤/០១ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំង ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៣ ឯកសារ D118/38 ត្រង់ ERN (EN) 00900781។ សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុន ឃិន ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ ឯកសារ D119/206 ត្រង់ ERN (EN) 01087434 (ឆ២១)។

[346] សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទិល ហោវ ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៤ ឯកសារ D119/115 ត្រង់ ERN (EN) 00987794 (ឆ២៥-ឆ២៦)។

[347] សំណុំរឿង ០០៤/០១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អឿ លឿ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ D5/1252 ត្រង់ ERN (EN) 01144155-01144156។

[348] *សូមមើល ឧ.* សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អួង សារ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៤ ឯកសារ D118/199 ត្រង់ ERN (EN) 00985108-00985109 (ឆ៣០-ឆ៣៥)។ សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ុន ហាន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D219/516 ត្រង់ ERN (EN) 01166153-01166154 (ឆ៨-ឆ៩)។ សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ុន ហាន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D219/516 ត្រង់ ERN (EN) 01166158-01166159 (ឆ៣០, ឆ៣៣-ឆ៣៤)។ សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខៀវ ផាន់ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ឯកសារ D219/664 ត្រង់ ERN (EN) 01207571 (ឆ១១៦)។ សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខែម សុខ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ ឯកសារ D118/264 ត្រង់ ERN (EN) 01033087-01033088 (ឆ៦១-ឆ៦២)។ សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម ទឹម ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ឯកសារ D118/108 ត្រង់ ERN (EN) 00976928 (ឆ៤៧)។ សំណុំរឿង ០០៤/០១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ គីម សួរ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ ឯកសារ D5/147 ត្រង់ ERN (EN)

១៥៨. ចៅក្រមទទួលបន្ទុកលើរឿងក្តីក៏ពិចារណាឃើញផងដែរថា មានភ័ស្តុតាងជាក់ស្តែងគ្រប់គ្រាន់បង្ហាញថា ស្ត្រីជនជាតិវៀតណាមពីរនាក់ នារី សាន និង នារី នួន ត្រូវបានសម្លាប់នៅក្នុងស្រុកព្រះនេត្រព្រះ ក្រោមការគ្រប់គ្រងរបស់ អ៊ឹម ចែម [349] ។ ចារីម្នាក់ក្នុងចំណោមចារីដែលត្រូវបានចោទប្រកាន់ ដែលជាប្រធានកងចល័ត កោ ឡឹន បានបដិសេធហេតុការណ៍ដែលបានកើតឡើង[350] ប៉ុន្តែ ក្រោយមកបានទទួលស្គាល់ថា គាត់ស្គាល់ នារី សាន ហើយថា នារី សាន ប្រហែលជាត្រូវបានគេសម្លាប់ចោលនៅឆ្នាំ ១៩៧៧ នៅស្រុកព្រះនេត្រព្រះ នៅពេលដែលស្រុកនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមនិរតី និង អ៊ឹម ចែម[351] ។ លើសពីនេះទៅទៀត ទោះបីសហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ភ័ស្តុតាងផ្ទុយរបស់សាក្សីម្នាក់ក៏ដោយ យ៉ាងហោចណាស់ មានមនុស្សបីនាក់ផ្សេងទៀតបង្ហាញភ័ស្តុតាងស៊ីសង្វាក់នឹងហេតុការណ៍នេះ។ ពេជ្រ រស់ បានរៀបរាប់លម្អិតថា អ្នកក្រោមបង្គាប់របស់ កោ ឡឹន បានរំលោភសេពសន្ថវៈ វះពោះ និងសម្លាប់ស្ត្រីវៀតណាមទាំងពីរនាក់នោះនៅការដ្ឋានវាលដណ្តៀបក្តាម។ ព្រឹត្តិការណ៍នេះបានកើតឡើងក្រោមបញ្ជារបស់ក្រុមនិរតី ហើយ អ៊ឹម ចែម ប្រាកដជាបានដឹងវា[352] ។ ប៊ូ ម៉ៅ ដែលជាអនុប្រធានរបស់ កោ ឡឹន [353] និងដែលចម្លើយរបស់គាត់ត្រូវបានសំអាងនៅក្នុងផ្នែកផ្សេងទៀតនៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) [354] បានបញ្ជាក់ថា ស្ត្រីដែលពាក់ព័ន្ធនឹងជនជាតិវៀតណាម ត្រូវបានចាប់ខ្លួនដឹកជញ្ជូនទៅក្បែរការដ្ឋានទំនប់អូរលៀប ហើយបញ្ហានេះមិនត្រូវបានស៊ើបអង្កេតបន្ថែមឡើយ[355] ។ សួរ ចាន់សារ៉េត ក៏

---

00384366។

[349] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៧៩-២៨០។

[350] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៧៩។ *សូមមើល ផងដែរ* សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡឹន ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤ ឯកសារ D119/121 ត្រង់ ERN (EN) 01067919 (ឆ១-ឆ២)។

[351] សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡឹន ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤ ឯកសារ D119/121 ត្រង់ ERN (EN) 01067919-01067923 (ឆ៣-ឆ២១), 01067929 (ឆ៥០)។

[352] សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៤ ឯកសារ D119/99 ត្រង់ ERN (EN) 00985204-00985205 (ឆ៣១-ឆ៣៣)។ សំណុំរឿង ០០៤/០១ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ពេជ្រ រស់ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D123/1/2.52 ត្រង់ ERN (EN) 00969843-00969846; សំណុំរឿង ០០៤/០១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ពេជ្រ រស់ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៣ ឯកសារ D5/1100 ត្រង់ ERN (EN) 01186137។

[353] *សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ គរ លេន , ២៩ មេសា ២០១៤, ឯកសារ D119/121, ត្រង់ ERN (EN) 01067923 (ឆ២៣, ឆ២៥)*។

[354] *សូមមើល ឧ.* ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៨៦ និងលេខយោងជើងទំព័រ ៣៩៧។

[355] សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៤ ឯកសារ D119/94

បានរាយការណ៍ផងដែរថា គាត់កំពុងនិយាយជាមួយ នារី សាន នៅពេលដែលប្រធានកងចល័តវ័យក្មេងម្នាក់មកពីភូមិភាគនិរតី បានមកដល់ជាមួយបុគ្គលិកក្រោមបង្គាប់ ដើម្បីចាប់ខ្លួនគាត់ពីបទជាប់ទាក់ទងជាមួយជនជាតិវៀតណាម[356]។ ដូចគ្នាដែរ យ ម៉ុត ក៏បានរៀបរាប់ថា សាន ត្រូវបានចាប់ខ្លួន និងសម្លាប់ចោល ហើយបងប្អូនបង្កើត និងស្ត្រីជនជាតិយួនម្នាក់ទៀត ក៏ត្រូវបានចាប់ខ្លួននៅវាលដង្កៀបក្តាមផងដែរនាពេលក្រោយមក[357]។

១៥៩. សរុបមក ចៅក្រមទទួលបន្ទុកលើរឿងក្តីពិចារណាឃើញថា មានភ័ស្តុតាងគ្រប់គ្រាន់បង្ហាញអំពីអត្ថិភាពនៃគោលនយោបាយ ប.ក.ក ប្រឆាំងនឹងជនជាតិពិន្ទុវៀតណាម និងអ្នកជាប់ពាក់ព័ន្ធនឹងវៀតណាមដែលត្រូវបានអនុវត្តនៅក្នុងភូមិភាគពាយ័ព្យក្រោមការគ្រប់គ្រងរបស់កម្មាភិបាលនិរតី ជាផ្នែកមួយនៃសហឧក្រិដ្ឋកម្មរួម។ នៅពេលថ្លឹងថ្លែងវាដោយមិនលម្អៀង អ៊ឹម ចែម បានចូលរួមក្នុងនាមជាសហចារី[358]។ អ៊ឹម ចែម ខ្លួនឯងបានទទួលស្គាល់ថា មានលិខិតផ្ញើមកពីមន្ទីរស្រុក ស្នើសុំឱ្យគាត់ចាប់ខ្លួនមនុស្សប្រភេទខុសៗគ្នា ហើយពួកគេបានស្រាវជ្រាវរក និងចាប់អ្នកដែលមានទំនាក់ទំនងជាមួយគិញវៀតណាម[359]។ ភ័ស្តុតាងនេះស៊ីសង្វាក់គ្នាជាមួយនឹង កោ ឡឹន ដែលបានបញ្ជាក់ថា ការពិត មានគោលនយោបាយមួយដែល "កំណត់គោលដៅសម្លាប់ជនជាតិវៀតណាមមែននៅក្នុងរបបខ្មែរក្រហម"[360] ហើយ ប៊ូ ម៉ៅ ដែលបាននិយាយថាប្រជាជនមកពីភូមិភាគនិរតីបានព្យាយាម "កម្ចាត់យួន"[361]។ សួរ ចាន់សារ៉េត បានអះអាងបន្ថែមទៀតថា

---

ត្រង់ ERN (EN) 00982761 (ឆ៣៧)។

[356] សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួរ ចាន់សារ៉េត ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៥ ឯកសារ D219/455 ត្រង់ ERN (EN) 01151189-01151192 (ឆ៥៦-ឆ៦៤)។

[357] សំណុំរឿង ០០៤/០១ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ យ ម៉ុត ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D123/1/2.57 ត្រង់ ERN (EN) 00987562-00987563 និង ERN (FR) 01169544។

[358] *សូមមើលខាងលើ* កថាខណ្ឌ ១៣២-១៤២។

[359] សំណុំរឿង ០០៤/០១ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៧ ឯកសារ D123/1/5.1a ត្រង់ ERN (EN) 00089782។ *សូមមើល ផងដែរ* ពាក់ព័ន្ធនឹងភូមិភាគនិរតី សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធៀន ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ ឯកសារ D6.1.688 ត្រង់ ERN (EN) 00384406 ("ពេលនោះយាយចែមបាននិយាយជាមួយគ្នាគាត់អំពីការចាប់អ្នកទាំងអស់នេះ ដោយនិយាយថា អ្នកទាំងអស់នោះពាក់ព័ន្ធជាមួយយួន [...]")។

[360] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡឹន ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤ ឯកសារ D119/121 ត្រង់ ERN (EN) 01067919-01067923 (ឆ៣-ឆ២១), 01067930 (ឆ៥៥)។

[361] សំណុំរឿង០០៤/១, DC-Cam សម្ភាស ប៊ូ ម៉ៅ, ១៦ មិថុនា ២០១១ ឯកសារ D123/1/2.53 ត្រង់ ERN (EN)

បន្ទាប់ពីកម្មាភិបាលនិរតីបានមកដល់ និងសម្លាប់កម្មាភិបាលភូមិភាគពាយ័ព្យ ពួកគេបានស្វែងរកមនុស្ស គ្រប់គ្នាដែលមានទំនាក់ទំនងជាមួយវៀតណាម ហើយបានយកពួកគេទៅសម្លាប់ចោល[362]។

១៦០. យោងតាមហេតុផលខាងលើ ចៅក្រមទទួលបន្ទុកលើរឿងក្តីយល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញប្រឆាំងនឹងជនជាតិវៀតណាម ត្រូវបានប្រព្រឹត្តឡើងមិនត្រឹមតែនៅមន្ទីរសន្តិសុខភ្នំត្រយោងប៉ុណ្ណោះទេ យ៉ាងហោចណាស់ក៏នៅគ្រប់តំបន់ ៥ នៃភូមិភាគពាយ័ព្យផងដែរ ហើយ អ៊ឹម ចែម អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនេះ។ អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតខកខានមិនបានធ្វើការកំណត់តាមផ្លូវច្បាប់ឱ្យបានត្រឹមត្រូវទាក់ទងនឹងការធ្វើទុក្ខបុកម្នេញលើជនជាតិវៀតណាម យ៉ាងហោចណាស់ ក្នុងតំបន់ ៥ នៃភូមិភាគពាយ័ព្យ និងខកខានពិចារណាអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មនៅពេលវាយតម្លៃលើការទទួលខុសត្រូវរបស់ អ៊ឹម ចែម។ ដូច្នេះ ចៅក្រមទទួលបន្ទុកលើរឿងក្តីគាំទ្រទឡ្ហីករណ៍ទី ២(៣) នៃបណ្តឹងឧទ្ធរណ៍ ហើយនឹងឆ្លើយតបនៅពេលក្រោយនៅក្នុងសាលក្រមនេះ ថាតើ ការខកខាននេះជាកត្តាកំណត់យ៉ាងសំខាន់នៃការសម្រេចអំពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬយ៉ាងណា។

## ឃ. មូលដ្ឋានទី២(៤) ៖ ឧក្រិដ្ឋកម្មប្រឆាំងខ្មែរក្រោម

១៦១. ទឡ្ហីករណ៍ ២(៤) នៃបណ្តឹងសារទុក្ខបានចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតមិនបានពិចារណាទៅលើភស្តុតាងអំពី ការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការធ្វើទុក្ខបុកម្នេញ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរដទៃទៀត ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ទាក់ទងការប្រព្រឹត្តចំពោះខ្មែរក្រោម នៅក្នុងតំបន់ ១៣[363]។

១៦២. ចៅក្រមដែលបានចុះហត្ថលេខាខាងក្រោមទាំងនេះ បានកត់សម្គាល់ឃើញថា កថាខណ្ឌ ១៥ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម លើតំបន់ ១ បានលើកឡើងនូវការចោទប្រកាន់ប្រឆាំង អ៊ឹម ចែម

---

00969902។

[362] សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួរ ចាន់សារ៉េត ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៥ ឯកសារ D219/455 ត្រង់ ERN (EN) 01151189-01151187 (ផ៥៩)។

[363] បណ្តឹងសាទុក្ខ កថាខណ្ឌ ៣៣ ដល់៣៥។

ពីបទឃុំឃាំងនិងសម្លាប់រង្គាល ទៅលើខ្មែរក្រោមនៅវត្តអង្គសិរីមាលី និងព្រៃសុខុន ដែលមានទីតាំងនៅក្នុងស្រុកកោះអណ្ដែត តំបន់ ១៣[364] នៃភូមិភាគនិរតី៖

> នៅក្នុងស្រុកកោះអណ្ដែត ការសម្លាប់ពួកខ្មែរក្រោមជាទ្រង់ទ្រាយធំ ត្រូវបានធ្វើឡើងនៅកន្លែងសម្លាប់ព្រៃសុខុន (ហៅ ព្រៃណ្ដក់) ដែលស្ថិតនៅក្នុងភូមិស៊ីស្ពា ឃុំផ្កាប្រជុំ។ ជនរងគ្រោះខ្មែរក្រោមនានា ត្រូវបានគេឃុំឃាំងជាបណ្ដោះអាសន្ន នៅក្នុងវត្តអង្គសិរីមុនី និងបន្ទាប់មកទៀតត្រូវបានពួកកម្មាភិបាល បកក ប្រដាប់ដោយអាវុធ យកទៅសម្លាប់ទាំងក្រុមៗ ដែលម្ដងមានចំនួនពីរ ១០ ទៅ២០គ្រួសារ។ ដូចដែលបានលើកឡើងនៅក្នុងកថាខណ្ឌទី១០១ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ជនសង្ស័យឈ្មោះ អ៊ឹម ចែម គឺជាលេខា បកក នៃស្រុកកោះអណ្ដែត ចាប់ពីឆ្នាំ១៩៧៦ ដល់១៩៧៧[365]។

១៦៣. ការកំណត់ប្រភេទនៃបទល្មើសដែលបានស្នើឡើង ចំពោះការចោទប្រកាន់ទាំងអស់នេះរួមមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់នៃការធ្វើទុក្ខបុកម្នេញ ដោយផ្អែកលើមូលដ្ឋាននយោបាយនិងពូជសាសន៍ ព្រមទាំងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ [366] ។ ចៅក្រមដែលបានចុះហត្ថលេខាខាងក្រោម បានកត់សម្គាល់បន្ថែមថា ការចោទប្រកាន់ទាំងអស់នេះ គឺច្បាស់ណាស់កម្រិតត្រឹមតែស្រុកកោះអណ្ដែត ដែលរួមមានជាពិសេស ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត នៅមន្ទីរឃុំឃាំងវត្តអង្គសិរីមាលី និងទីតាំងសម្លាប់មនុស្សព្រៃសុខុន ហើយថាការចោទប្រកាន់នេះ មិនពង្រីកទៅដល់គ្រប់ផ្នែកនៃតំបន់១៣ឡើយ។

១៦៤. ការសម្រេចលើអង្គហេតុរបស់ សហចៅក្រមស៊ើបអង្កេត នៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) គឺកម្រិតកំណត់ត្រឹមតែការកត់សម្គាល់លើភស្តុតាងដែលថា ចាប់ពីខែមេសា ឆ្នាំ១៩៧៥ រហូតដល់យ៉ាងហោចណាស់ខែវិច្ឆិកា ឆ្នាំ១៩៧៨ "អ្នកទោសដែលជាប់ឃុំឃាំងនៅ វត្តអង្គសិរីមាលី គឺជាខ្មែរក្រោម និងប្រជាជន១៧មេសា ហើយដែលត្រូវបានគេយក ទៅសម្លាប់ចោលនៅព្រៃសុខុន" [367] ។ សហចៅក្រម

---

[364] សំណុំរឿង ០០៤/១ របាយការណ៍កំណត់អត្តសញ្ញាណទីតាំង ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២ ឯកសារ D119/9 នៅត្រង់ ERN (ភាសាខ្មែរ) 01100827 សំណុំរឿង ០០៤/១, របាយការណ៍កំណត់អត្តសញ្ញាណទីតាំង, ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១២, D119/10 នៅត្រង់ ERN (ភាសាខ្មែរ) 00981801។

[365] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម អំពីតំបន់ ១ (ឯកសារ D65) កថាខណ្ឌ ១៥ (មិនដាក់បញ្ចូលនូវជើងទំព័រ)។

[366] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម អំពីតំបន់ ១ (ឯកសារ D65) កថាខណ្ឌ ២២។

[367] ដីកាដំណោះស្រាយ (ផ្នែកសំអាងហេតុ), កថាខណ្ឌ ២៤៩ (មិនដាក់បញ្ចូលនូវជើងទំព័រ)។

ស៊ើបអង្កេតបានសម្រេចថា ភស្តុតាងមិនបានកំណត់ពី សិទ្ធិអំណាចរបស់ អ៊ឹម ចែម ទាក់ទងការដំណើរការនៅវត្តអង្គសិរីមាលី និងព្រៃសុខុន[368] ឬក៏ថា អ៊ឹម ចែម គឺជាលេខាស្រុកកោះអណ្ដែត ឬជាសមាជិកគណៈកម្មាធិការតំបន់ ១៣[369] ដែលចៅក្រមដែលបានចុះហត្ថលេខាខាងក្រោម នឹងពិភាក្សាលម្អិតទាក់ទងទឡ្ហីករណ៍ទី៥ និងទឡ្ហីករណ៍ទី៦ នៃបណ្ដឹងសារទុក្ខ[370]។

១៦៥. ទីមួយ ចៅក្រមដែលបានចុះហត្ថលេខាខាងក្រោម បានសម្រេចថាការស៊ើបអង្កេត មិនបានបង្ហាញឱ្យបានគ្រប់គ្រាន់ ពីធាតុផ្សំរើសអើងដែលបានតម្រូវ ដើម្បីកំណត់ថាការប្រព្រឹត្ត ទៅលើខ្មែរក្រោមនៅក្នុងស្រុកកោះអណ្ដែត នៅក្នុងអំឡុងពេលដែល អ៊ឹម ចែម ជាលេខាស្រុកនោះ បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់នៃការធ្វើទុក្ខបុកម្នេញ ដូចបានកំណត់ពីខាងលើ[371]។

១៦៦. ចៅក្រមដែលបានចុះហត្ថលេខាខាងក្រោម បានកត់សម្គាល់ជាទូទៅលើភស្តុតាងដែលថា ខ្មែរក្រោមគឺជាគោលដៅនៅក្នុងតំបន់ ១៣ នៃភូមិភាគនិរតី[372] ហើយពួកគេមួយចំនួនត្រូវបានឃុំខ្លួន និងសម្លាប់នៅមន្ទីរសន្តិសុខវត្តអង្គសិរីមាលី និងទីតាំងសម្លាប់មនុស្សព្រៃសុខុន។ ប៉ុន្តែនៅក្នុងចំពោះសាក្សីមួយចំនួនតូច ដែលបានផ្ដល់ភស្តុតាងជាក់លាក់ អំពីស្រុកកោះអណ្ដែតនោះ[373] ទាំង នាង អ៊ិច[374] និង មុំ ផល្លា[375]

[368] ដីកាដំណោះស្រាយ (ផ្នែកសំអាងហេតុ), កថាខណ្ឌ ២៥១។

[369] ដីកាដំណោះស្រាយ (ផ្នែកសំអាងហេតុ), កថាខណ្ឌ ១៤៤។

[370] សូមមើល ខាងក្រោម មូលដ្ឋានទី៥ និង ៦ នៃបណ្ដឹងឧទ្ធរណ៍

[371] សូមមើល ខាងលើ កថាខណ្ឌ ១៤៨ យោងទៅរក សាលដីកាសំណុំរឿង ០០១ (ឯកសារF28), កថាខណ្ឌ ២២៦, ២៤១។

[372] សូមមើលជាឧទាហរណ៍, សំណុំរឿង ០០៤/១, កំណត់ហេតុស្តាប់ចម្លើយ ហែម ឈួន ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ D118/45នៅត្រង់ ERN (ភាសាខ្មែរ) 00905856 (ចម្លើយ ២៩ ដល់៣២)។ សំណុំរឿង ០០៤/១, កំណត់ហេតុស្តាប់ចម្លើយ រី ពៅ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៣ ឯកសារ D118/130 នៅត្រង់ ERN (ភាសាខ្មែរ) 00960588-00960589 (ចម្លើយ ៥២ ដល់៥៨)។ សំណុំរឿង ០០៤/១, កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្បត្តិ ថ្ងៃទី៥ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D118/165នៅត្រង់ ERN (ភាសាខ្មែរ) 00968143 (ចម្លើយ ៩) 00968146-00968147 (ចម្លើយ ៣០ ដល់ចម្លើយ ៣១)។ សំណុំរឿង ០០៤/១, កំណត់ហេតុស្តាប់ចម្លើយ យ៉ោក ប៉ែត ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D219/525នៅត្រង់ ERN (ភាសាខ្មែរ) 01149886-01149887 (ចម្លើយ ៦១ ដល់ចម្លើយ ៦៨)។

[373] សូមមើល សំណុំរឿង ០០៤/១ របាយការណ៍កំណត់អត្តសញ្ញាណទីតាំង ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២ ឯកសារ D119/9 នៅត្រង់ ERN (ភាសាខ្មែរ) 00887254-00887255។ សំណុំរឿង ០០៤/១, របាយការណ៍កំណត់អត្តសញ្ញាណទីតាំង ថ្ងៃទី៦ ខែធ្នូ ឆ្នាំ ២០១២ ឯកសារ D119/10 នៅត្រង់ ERN (ភាសាខ្មែរ)00981803-00981804។

[374] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ នាង អ៊ិច ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ឯកសារ D119/82 នៅត្រង់ ERN (ភាសាខ្មែរ) 00971379-00971380 (ចម្លើយ ៨៦ ដល់ចម្លើយ ៨៧)។

បានបញ្ជាក់ថា ខ្មែរក្រោមនិងខ្មែរ "ធម្មតា" ទទួលបាននូវការប្រព្រឹត្តដូចគ្នា នៅក្នុងកងចល័តស្រុក។ មុំ ផល្លា បានរំឮកថាគាត់បានឃើញ ប្រហែលបួនខែ ឬជាងមួយឆ្នាំកន្លះ មុនពេលដួលរលំនៃរបបខ្មែរក្រហម ការសម្លាប់មនុស្សប្រហែល៣០នាក់នៅព្រៃសុខុន ដែលពួកគេអាចជាខ្មែរក្រោម បើទោះបីជាគាត់មិនបានដឹងឱ្យប្រាកដ ថាជនរងគ្រោះគឺជានរណានោះក្តី[376]។ វង ណុប បានរាយការណ៍ថា គ្រួសារខ្មែរក្រោមមកពីភ្នំពេញនិងតាកែវ ដែលពីដំបូងត្រូវបានបញ្ចូលជាមួយខ្មែរ "ធម្មតា" ហើយដែលទាំងអស់ត្រូវបានចាត់ទុកថាជា "ខ្មាំង" នោះ ត្រូវបានគេបំបែកចេញ ហើយសម្លាប់ចោលនៅព្រៃសុខុន តាមបញ្ជាពីថ្នាក់លើ នៅប្រហែលមួយខែកន្លះ ក្រោយពេលដួលរលំទីក្រុងភ្នំពេញ ក្នុងឆ្នាំ១៩៧៥[377]។ សាក្សីដែលត្រូវបានសម្ភាសន៍ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា បានអះអាងថា មនុស្សជាច្រើនត្រូវបានសម្លាប់នៅព្រៃសុខុន នៅក្នុងឆ្នាំ១៩៧៥ ហើយថាជនរងគ្រោះដំបូងគឺជា "មនុស្សដែលជម្លៀសមកពីទីក្រុង ជាពិសេសប្រជាជនខ្មែរក្រោម"[378]។ ជាចុងក្រោយ សំ គុណ បានឮថា បន្ទាប់ពីរបបដួលរលំ គឺនៅក្រោយពេលជម្លៀសចេញពីទីក្រុងភ្នំពេញ នៅក្នុងឆ្នាំ១៩៧៥ ប្រជាជនខ្មែរក្រោមត្រូវបានបញ្ចូលរួមជាមួយប្រជាជនដទៃទៀត ហើយត្រូវបានឃុំឃាំងនៅវត្តអង្គសិរីមាលី ហើយយកទៅសម្លាប់នៅព្រៃសុខុន [379] ។ ទោះបីជាគាត់ក៏បាននិយាយយោងផងដែរ ទៅរកអំឡុងរយៈពេលពីឆ្នាំ ១៩៧៦ ដល់ឆ្នាំ១៩៧៧[380] ចៅក្រមដែលបានចុះហត្ថលេខាខាងក្រោម សម្រេចថាភស្តុតាងរបស់សាក្សីរូបនេះ បើយោងតាមបទដ្ឋានដែលបានតម្រូវ គឺមិនគ្រប់គ្រាន់សម្រាប់កំណត់ថា ជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថា ប្រព្រឹត្តឡើងនៅក្នុងអំឡុងពេល

---

[375] សំណុំរឿង ០០៤/១, កំណត់ហេតុស្តាប់ចម្លើយ មុំ ផល្លា ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ឯកសារ D219/568 នៅត្រង់ ERN (ភាសាខ្មែរ) 001165964-01165965 (ចម្លើយ ៣២ ដល់ចម្លើយ៣៣)។

[376] សំណុំរឿង ០០៤/១, កំណត់ហេតុស្តាប់ចម្លើយ មុំ ផល្លា ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ឯកសារ D219/568 នៅត្រង់ ERN (ភាសាខ្មែរ) 001165967-001165971 (ចម្លើយ ៦១ ដល់ចម្លើយ ៩៩)។

[377] សំណុំរឿង ០០៤/១, កំណត់ហេតុស្តាប់ចម្លើយ វង ណុប ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ D219/592 នៅត្រង់ ERN (EN) 01171492-01171496 (ចម្លើយ ១២ ដល់ចម្លើយ៣៥) 01171498-01171501 (ចម្លើយ ៤៧ ដល់ចម្លើយ ៦៧)។

[378] សំណុំរឿង ០០៤/១ មជ្ឈមណ្ឌលឯកសារកម្ពុជា របាយការណ៍ផែនទីខេត្តតាកែវ ឆ្នាំ ១៩៩៨ ឯកសារ D1.3.10.14 នៅត្រង់ ERN (ភាសាខ្មែរ) 00714208។

[379] សំណុំរឿង ០០៤/១, កំណត់ហេតុស្តាប់ចម្លើយ សំ គុណ ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ ឯកសារ D119/4 នៅត្រង់ ERN (ភាសាខ្មែរ) 00872487 (ចម្លើយ ៣៦)។ សំណុំរឿង ០០៤/១, កំណត់ហេតុស្តាប់ចម្លើយ សំ គុណ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ឯកសារ D219/591 នៅត្រង់ ERN (ភាសាខ្មែរ) 01169863-01169868 (ចម្លើយ ១១ ដល់ចម្លើយ ៤៥)។

[380] សំណុំរឿង ០០៤/១, កំណត់ហេតុស្តាប់ចម្លើយ សំ គុណ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ឯកសារ D219/591 នៅត្រង់ ERN (ភាសាខ្មែរ) 01169865 (ចម្លើយ ២៥, ចម្លើយ ២៨)។

កាន់មុខតំណែងរបស់ អ៊ឹម ចែម នៅកោះអណ្តែត គឺត្រូវបានកំណត់គោលដៅ ទៅលើខ្មែរក្រោម ឬថាចារីបានប្រព្រឹត្តឡើង ដោយមានចេតនារើសអើងដែលបានតម្រូវ។

១៦៧. ទីពីរចៅក្រមដែលបានចុះហត្ថលេខាខាងក្រោម សម្រេចបដិសេធទឡ្ហីករណ៍ ទាក់ទងការចោទប្រកាន់ពីការប្រព្រឹត្តិ អំពើរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ពាក់ព័ន្ធខ្មែរក្រោមនៅស្រុកកោះអណ្តែត។ ទោះបីជាមានភស្តុតាងនៃជម្លោះប្រដាប់អាវុធ រវាងកម្ពុជាជាមួយ សាធារណរដ្ឋសង្គមនិយមវៀតណាម ពីខែឧសភា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ក្តី[381] តែភស្តុតាងដែលមានគឺមិនគ្រប់គ្រាន់ សម្រាប់កំណត់ថា ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ថាបានប្រព្រឹត្តឡើងចំពោះខ្មែរក្រោមក្នុងអំឡុងពេលកាន់មុខតំណែងរបស់ អ៊ឹម ចែម ជាលេខាស្រុកកោះអណ្តែត គឺ "ពាក់ព័ន្ធជិតស្និទ្ធ" ជាមួយអរិភាពទាំងនេះ ដើម្បីកំណត់ពីទំនាក់ទំនងដែលបានតម្រូវ[382]។ ចៅក្រមដែលបានចុះហត្ថលេខាខាងក្រោមជារួមទៅ ចាត់ទុកថាភស្តុតាងទាក់ទង ការប្រព្រឹត្តទៅលើខ្មែរក្រោម នៅស្រុកកោះអណ្តែត នៅក្នុងវិសាលភាពពេលវេលាពាក់ព័ន្ធ [383] គឺមិនគ្រប់គ្រាន់សម្រាប់បង្ហាញថា អត្ថិភាពនៃជម្លោះប្រដាប់អាវុធ ដើរតួនាទីយ៉ាងសំខាន់មួយ នៅក្នុងលទ្ធភាពរបស់ចារី ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ក្នុងការសម្រេចរបស់ពួកគេលើការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ គោលបំណងដែលពួកគេប្រព្រឹត្ត ឬលក្ខណៈដែលប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ[384]។

---

[381] សូមមើលជាឧទាហរណ៍, សំណុំរឿង ០០៤/១, Philip. SHORT, *ប៉ុល ពត ប្រវត្តិនៃសុបិន្តអាក្រក់មួយ* ឆ្នាំ ២០១៤ ឯកសារ D117/36.1.23 នៅត្រង់ ERN (EN) 00396580 *et seq.*។ សំណុំរឿង ០០៤/១ សារទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ៩៥ ពីឝុនទៅបងប៉ុល ពត ស្តីពីស្ថានភាពនៅតាមព្រំដែន ក្នុងតំបន់ ២៣ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ឯកសារ D132.1.160។ សំណុំរឿង ០០៤/១ របាយការណ៍ លេខ ៣២៧ ស្តីពីស្ថានភាពនៅតាមព្រំដែន ក្នុងតំបន់ ២០ ថ្ងៃទី១៧ ដល់២៥ ខែមិថុនា ឆ្នាំ១៩៧៧ ឯកសារ D132.1.74។

[382] សូមមើលជាឧទាហរណ៍ សំណុំរឿង ០០១ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (ឯកសារ E188), កថាខណ្ឌ ៤១៦។ តុលាការ ICTY, *រដ្ឋអាជ្ញា តទល់នឹង Tadić*, IT-94-1-A, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី សុំប្តឹងបណ្តឹងសាទុក្ខបន្ទាន់បង្អង់ ស្តីពីយុត្តាធិការ អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ ៧០។ តុលាការ ICTY, *រដ្ឋអាជ្ញា តទល់នឹង Stakić*, IT-97-24-A, សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ៣៤២។

[383] សូមមើលខាងលើ កថាខណ្ឌ១៦៦។

[384] សូមមើលជាឧទាហរណ៍ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកដទៃទៀត* IT-96-23/1-A, សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ ៥៨។ តុលាការ ICTR *រដ្ឋអាជ្ញា តទល់នឹង Setako*, International Criminal Tribunal for Rwanda ICTR-04-81-A, សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ ២៤៩។

១៦៨. យោងតាមការបកស្រាយខាងលើ ចៅក្រមដែលបានចុះហត្ថលេខាខាងក្រោមសម្រេចថា ភស្តុតាងដែលប្រមូលបាន នៅក្នុងពេលស៊ើបអង្កេត គឺមិនគ្រប់គ្រាន់យ៉ាងជាក់ស្តែង ក្នុងការកំណត់ពីការទទួលខុសត្រូវរបស់ អ៊ឹម ចែម ទៅលើការធ្វើទុក្ខបុកម្នេញប្រឆាំង ខ្មែរក្រោមនៅស្រុកកោះអណ្តែត និងទៅលើការរំលោភបំពានធ្ងន់ធ្ងរដទៃទៀត ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ។ ហេតុដូច្នេះសហចៅក្រមស៊ើបអង្កេតមិនមានកំហុសឆ្គងក្នុងការមិនពិនិត្យមើល ទៅលើចំណុចនេះដោយលម្អិតនោះឡើយ។ ហេតុដូច្នេះចៅក្រមដែលបានចុះហត្ថលេខាខាងក្រោម សម្រេចបដិសេធទាំងស្រុង ទៅលើទឡ្ហីករណ៍ ២(៤) នៃបណ្តឹងឧទ្ធរណ៍។

### ង. <u>មូលដ្ឋានទី២(៥) ៖ ការធ្វើទុក្ខបុកម្នេញទៅលើក្រុមនានា និងឧក្រិដ្ឋកម្មផ្សេងៗទៀត</u>

១៦៩. ទឡ្ហីករណ៍ទី២(៥) នៃបណ្តឹងឧទ្ធរណ៍ចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតមិនបានពិនិត្យឱ្យបានត្រឹមត្រូវទៅលើការចោទប្រកាន់ដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានស្ថាពរ អំពីការធ្វើទុក្ខបុកម្នេញទៅលើក្រុមនយោបាយ និងក្រុមជាតិពន្ធុនានា[385] ព្រមទាំងការចោទប្រកាន់លើអង្គហេតុពាក់ព័ន្ធនឹងការធ្វើទារុណកម្មដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំត្រយោង និង មន្ទីរសន្តិសុខវត្តចម្ការខ្នុរ ការដាក់ក្នុងមន្ទីរឃុំឃាំង និង ការបាត់ខ្លួនដោយបង្ខំនៅមន្ទីរឃុំឃាំងវត្តអង្គសិរីមាលី និងលក្ខខណ្ឌរស់នៅបែបអមនុស្សធម៌នៅមន្ទីរសន្តិសុខភូមិចក្រី[386]។

១៧០. តាំងពីដំបូងមក ចៅក្រមទទួលបន្ទុករឿងក្តីសូមរម្លឹកថា មានតែការពិនិត្យលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង ឧបសម្ព័ន្ធរបស់ដីកាទាំងនេះទេ ដែលអាចអនុញ្ញាតឱ្យគេធ្វើការផ្ទៀងផ្ទាត់មើលថា តើការចោទប្រកាន់ និងកិច្ចស៊ើបសួរពាក់ព័ន្ធ ស្ថិតនៅក្នុងវិសាលភាពនៃអង្គសេចក្តីដែលដាក់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬយ៉ាងណា[387]។ ហេតុនេះ ចៅក្រមទទួលបន្ទុករឿងក្តីសូមធ្វើការបដិសេធដោយមិនយកមកពិភាក្សានូវការអះអាងដែលថា សហចៅក្រមស៊ើបអង្កេតមិនបានពិចារណាទៅលើការចោទប្រកាន់នានាដែលបានលើកឡើងយ៉ាងយឺតយ៉ាវ នៅក្នុងដីកា

---

[385] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៥-៣៦។

[386] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៧។

[387] *សូមមើល ខាងលើ* កថាខណ្ឌ ១២៨ ។

01575526



សន្និដ្ឋានស្លាពរ។ ចៅក្រមចុះទទួលបន្ទុករឿងក្តីនឹងពិនិត្យទៅលើវិសាលភាពនៃកិច្ចស៊ើបសួរ ចំពោះការអះអាងនីមួយៗដែលបានលើកឡើងនៅក្នុងទឡ្ហីករណ៍ទី២(៥) នៃបណ្តឹងឧទ្ធរណ៍។

### *១. ការធ្វើទុក្ខបុកម្នេញទៅលើកម្មាភិបាលភូមិភាគពាយ័ព្យ*

១៧១. បទចោទទៅលើ អ៊ឹម ចែម ដែលបានស្នើឡើងនៅក្នុងកថាខណ្ឌ ១១៩ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ បញ្ចូលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមនទម្រង់ជា "ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុ [...] នយោបាយ" តែមិនបានលើកឡើងជាក់លាក់ចំពោះកម្មាភិបាលភូមិភាគពាយ័ព្យ នៅក្នុងចំណោមក្រុមដែលត្រូវបានកំណត់ជាគោលដៅទេ។ ក៏ប៉ុន្តែ កថាខណ្ឌ ១៧ ចោទប្រកាន់ជាក់លាក់ថា "កម្មាភិបាលមូលដ្ឋាន" គឺជាគោលដៅនៃសហឧក្រិដ្ឋកម្មរួម ដើម្បីធ្វើការបោសសម្អាតនៅភូមិភាគពាយ័ព្យ ដែល អ៊ឹម ចែម បានចូលរួមក្នុងនាមជាសហចារី។ កថាខណ្ឌ ៥៤ ដល់ ៥៨ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ បានរៀបរាប់លម្អិតបន្ថែមទៀតអំពីការបោសសម្អាតកម្មាភិបាលមូលដ្ឋាន ក្រោយពេលកម្មាភិបាលភូមិភាគនិរតីបានទៅដល់ ដោយចោទប្រកាន់ថា "កម្មាភិបាលគ្រប់ជាន់ថ្នាក់ទាំងអស់ដែលមានស្រាប់នៅភូមិភាគពាយ័ព្យត្រូវបានចាប់ខ្លួន និងសម្លាប់ចោល" ហើយថា "ការបោសសម្អាតត្រូវបានពង្រីកជាលក្ខណៈប្រព័ន្ធដល់ទូទាំងភូមិភាគពាយ័ព្យទាំងមូលតែម្តង"។

១៧២. ហេតុនេះ ចៅក្រមទទួលបន្ទុករឿងក្តីយល់ឃើញថា សហចៅក្រមស៊ើបអង្កេតទទួលបានបណ្តឹងទាន់ពេលវេលាអំពីការចោទប្រកាន់នានាស្តីពីការធ្វើទុក្ខបុកម្នេញទៅលើកម្មាភិបាលភូមិភាគពាយ័ព្យ ហើយដូចដែលបានសម្រេចខាងលើ[388] គឺថា សហចៅក្រមស៊ើបអង្កេតមិនបានធ្វើការកំណត់តាមផ្លូវច្បាប់ឱ្យបានត្រឹមត្រូវទាក់ទិននឹងការចោទប្រកាន់ដែលពាក់ព័ន្ធនឹងការបោសសម្អាត មិនបានយកមកពិចារណានូវស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម និងមិនបានវាយតម្លៃអំពីការទទួលខុសត្រូវរបស់ អ៊ឹម ចែម នៅក្នុងឧក្រិដ្ឋកម្មទាំងនោះទេ។ ចៅក្រមចុះទទួលបន្ទុករឿងក្តីក៏យល់ឃើញផងដែរថា មានភស្តុតាងគ្រប់គ្រាន់ដើម្បីបង្ហាញពីធាតុផ្សំចាំបាច់នៃការរើសអើង នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ ដូចបានកំណត់ខាងលើ [389] និងដើម្បីសន្និដ្ឋានថា ឧក្រិដ្ឋកម្មនេះត្រូវបានប្រព្រឹត្តទៅលើកម្មាភិបាលភូមិភាគពាយ័ព្យ មិនត្រឹមតែនៅមន្ទីរសន្តិសុខភ្នំត្រយោង[390] ប៉ុណ្ណោះទេ តែក៏មានយ៉ាងហោចណាស់នៅទូទាំងតំបន់ ៥ ទាំង

[388] *សូមមើល ខាងលើ* កថាខណ្ឌ ១៣២-១៤២ ។

[389] *សូមមើល ខាងលើ* កថាខណ្ឌ ១៤៨ *យោងទៅ* សាលដីកាសំណុំរឿង ០០១ (ឯកសារ F28) កថាខណ្ឌ ២២៦, ២៤១។

[390] *សូមមើល* ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៩៥។

មូលផងដែរ។ ចុងក្រោយ មានភស្តុតាងគ្រប់គ្រាន់អំពីការទទួលខុសត្រូវរបស់ អ៊ឹម ចែម[391]។ ហេតុនេះ ចៅក្រមទទួលបន្ទុករឿងក្តីគាំទ្រផ្នែកនេះនៃទឡ្ហីករណ៍ទី២(៥) នៃបណ្តឹងឧទ្ធរណ៍ ហើយនឹងធ្វើការបកស្រាយនាពេលបន្ទាប់នៅក្នុងសាលដីកានេះថា តើការខកខាននេះ ជាកត្តាកំណត់យ៉ាងសំខាន់នៃការសម្រេចអំពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬយ៉ាងណា។

## *ខ. ការធ្វើទុក្ខបុកម្នេញទៅលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ*

១៧៣. បទចោទទៅលើ អ៊ឹម ចែម ដែលបានស្នើឡើងនៅក្នុងកថាខណ្ឌ ១១៩ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ បញ្ចូលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃ "ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុ [...] នយោបាយ ទៅលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ" ហើយកថាខណ្ឌ ១៧ ចោទប្រកាន់ជាពិសេសថា "ប្រជាជនដែលមានទំនាក់ទំនងជាមួយនឹង "សង្គមចាស់"" គឺជាគោលដៅនៃសហឧក្រិដ្ឋកម្មរួម ដើម្បីធ្វើការបោសសម្អាតនៅភូមិភាគពាយ័ព្យ ដែល អ៊ឹម ចែម បានចូលរួមក្នុងនាមជាសហចារី។ មានភស្តុតាងផងដែរ ដែលបានដកស្រង់ដើម្បីគាំទ្រដល់ការចោទប្រកាន់ពាក់ព័ន្ធនឹងការបោសសម្អាតនៅភូមិភាគពាយ័ព្យ ដែលចោទប្រកាន់បន្ថែមថា ក្រោយពេលកម្មាភិបាលភូមិភាគនិរតីបានទៅដល់ ការបាត់ខ្លួន និងការសម្លាប់បានពង្រីកទៅដល់ "មនុស្សដែលមានការជាប់ពាក់ព័ន្ធជាមួយនឹងសាច់ញាតិរបស់មន្ត្រីរដ្ឋការដែលបានបម្រើការងារក្នុងរដ្ឋាភិបាលមុន"[392]។

១៧៤. ហេតុនេះ ចៅក្រមទទួលបន្ទុករឿងក្តីយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានទទួលបណ្តឹងអំពីការចោទប្រកាន់ពីការធ្វើទុក្ខបុកម្នេញទៅលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ និងសាច់ញាតិរបស់ពួកគេ នៅក្នុងបរិបទនៃការបោសសម្អាតនៅភូមិភាគពាយ័ព្យ ហើយហេតុនេះ សហចៅក្រមស៊ើបអង្កេតបានបំពេញភារកិច្ចរបស់ខ្លួនក្នុងការស៊ើបសួរ និងសម្រេចទៅលើការចោទប្រកាន់ទាំងនោះ នៅពេលចេញដីកាដំណោះស្រាយ (សំអាងហេតុ)។

១៧៥. សហចៅក្រមស៊ើបអង្កេតពិតជាបានធ្វើសេចក្តីសន្និដ្ឋានលើអង្គហេតុជាច្រើនដែលថា មន្ត្រីសាធារណរដ្ឋខ្មែរ និងសាច់ញាតិរបស់ពួកគេស្ថិតនៅក្នុងចំណោមអ្នកដែលត្រូវបានចាប់ខ្លួន និងឃុំឃាំងនៅមន្ទីរ

---

391 *សូមមើល ខាងលើ* កថាខណ្ឌ ១៣២-១៤២ ។

392 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ (ឯកសារ D1) ជើងទំព័រ ២២២, ៤៥៦, ៤៥៨ *យោងទៅ* សំណុំរឿង ០០៤/១ កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយក្រុមវត្តព្រះនេត្រព្រះ ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៨ ឯកសារ D1.3.11.40 នៅត្រង់ ERN 01084704។

សន្តិសុខភ្នំត្រយោង[393] ផ្ទះតាក្រកនៅក្បែរវត្តព្រះនេត្រព្រះ[394] និងមន្ទីរសន្តិសុខភូមិចក្រី[395]។ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានបន្ថែមថា កម្មាភិបាលភូមិភាគនិរតីបានអនុវត្តការវាយប្រហារនៅក្នុងភូមិភាគពាយ័ព្យដែល អ៊ឹម ចែម បានដឹង ហើយបានចូលរួម[396] ទៅលើប្រជាជនស៊ីវិល ជាពិសេស ""សមាសធាតុមិនល្អ" ឬ "ខ្មាំង" ពិតប្រាកដ ឬតាមការគិតរបស់ ប.ក.ក" រួមទាំង "អតីតអ្នករដ្ឋការ និងយោធារបស់របបសាធារណរដ្ឋខ្មែរ និងក្រុមគ្រួសាររបស់ពួកគេ" ដោយកំណត់ជាគោលដៅ *ក្នុងចំណោមនោះ* "ប្រជាជនដែលគេចាត់ទុកថា មិនអាចទុកចិត្តបានផ្នែកនយោបាយ [និង] អតីតមន្ត្រី និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ" [397] ។ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយទៅលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរត្រូវបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំត្រយោង [398] តែត្រឹមតែធ្វើការសន្និដ្ឋានយ៉ាងប្រញាប់ប្រញាលពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញនៅឯទីតាំងឧក្រិដ្ឋកម្មផ្សេងទៀតដែលមិនបានចោទប្រកាន់[399]។

១៧៦. ចៅក្រមទទួលបន្ទុករឿងក្តីយល់ឃើញថា សេចក្តីសន្និដ្ឋានទាំងនេះឆ្លើយតបបានតែមួយផ្នែកប៉ុណ្ណោះចំពោះការចោទប្រកាន់ដែលថា មន្ត្រីសាធារណរដ្ឋខ្មែរ និងសាច់ញាតិរបស់ពួកគេត្រូវបានធ្វើទុក្ខបុកម្នេញនៅក្នុងបរិបទនៃការបោសសម្អាតនៅភូមិភាគពាយ័ព្យ ជាពិសេសនៅស្រុកព្រះនេត្រព្រះ និង តំបន់ ៥ ហើយថា សហចៅក្រមស៊ើបអង្កេតមិនបានធ្វើការកំណត់តាមផ្លូវច្បាប់ឲ្យបានត្រឹមត្រូវអំពីវិសាលភាព និងស្ថានទម្ងន់នៃឧក្រិដ្ឋកម្មទាំងនេះ។

១៧៧. ចៅក្រមទទួលបន្ទុករឿងក្តីយល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់អំពីការចាប់ខ្លួន ការឃុំឃាំង និងការសម្លាប់អតីតអ្នករដ្ឋការ មន្ត្រីយោធា និងសាច់ញាតិរបស់ខ្លួនយ៉ាងទូលំទូលាយ និងជាប្រព័ន្ធ នៅក្នុងបរិបទនៃការបោសសម្អាតនៅភូមិភាគពាយ័ព្យ យ៉ាងហោចនៅក្នុងទូទាំងតំបន់ ៥ ទាំងមូល។ សាក្សីជាច្រើនបានលើកឡើងថា អតីតទាហាន និងមន្ត្រីសាធារណរដ្ឋខ្មែរត្រូវបានចាប់ខ្លួន និងសម្លាប់នៅស្រុក

---

[393] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២០២។

[394] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៥៥។

[395] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៦១។

[396] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៨៤។

[397] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៨១, ២៨៣។

[398] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៩៥។

[399] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣០៥។

ព្រះនេត្រព្រះ នៅពេលកម្មាភិបាលនិរតីបានទៅដល់[400] រួមទាំងនៅក្នុងបរិវេណវត្តព្រះនេត្រព្រះ[401] នៅភ្នំត្រយោង [402] និងនៅមន្ទីរសន្តិសុខភូមិចក្រី [403] ព្រមទាំងនៅតាមស្រុកជិតខាង គួរឱ្យកត់សម្គាល់គឺនៅទំនប់ត្រពាំងថ្ម[404] និងនៅមន្ទីរសន្តិសុខវត្តចម្ការខ្នុរ[405]។ ការភ័យខ្លាចពីការចាប់ខ្លួនបានរីករាលដាលក្នុងចំណោម

---

[400] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផុន ម៉ុន ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D119/19 នៅត្រង់ ERN 00894492 (ឆ.១០)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ខាន់ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ ឯកសារ D106/4 នៅត្រង់ ERN 00800988 (ឆ.៨)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ោ បណ្តែត ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D219/181 នៅត្រង់ ERN 01066318 (ឆ.១៦), 01066319 (ឆ.១៩)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ ជួង ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤ ឯកសារ D119/73 នៅត្រង់ ERN 00971121-00971122 (ឆ.១៧-ឆ.១៨)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភោគ រឿប ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ D219/255 នៅត្រង់ ERN 01085157 (ឆ.១៦)។

[401] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុង ផាភ័ត ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D119/37 នៅត្រង់ ERN 00915839 (ឆ.៤)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ឌៀ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D119/39 នៅត្រង់ ERN 00915853 (ឆ.៦-ឆ.៧)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ោ បណ្តែត ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ D219/181 នៅត្រង់ ERN 01066319 (ឆ.១៨)។

[402] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម សឿម ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឯកសារ D219/153 នៅត្រង់ ERN 01058764 (ឆ.១៤)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ហួន ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ D119/130 នៅត្រង់ ERN 009893340-00989341 (ឆ.២២-ឆ.២៤)។

[403] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យូ មុត ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ D219/1 នៅត្រង់ ERN 01024619-01024620 (ឆ.៣៧-ឆ.៣៨)។ សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ យូ មុត ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D5/965 នៅត្រង់ ERN 00989853។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឧប សុក ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D219/212 នៅត្រង់ ERN 01074065 (ឆ.២៦)។

[404] សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ខោន ព្រេក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D5/1134 នៅត្រង់ ERN 01026755, 01026758។ សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ និត លួន ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D5/1019 នៅត្រង់ ERN 00991020-00991021។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្តិ ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D119/120 នៅត្រង់ ERN 00984321 (ឆ.១៤៤)។

[405] សំណុំរឿង ០០៤/១ របាយការណ៍របស់អង្គភាពគាំពារជនរងគ្រោះស្តីពីជនរងគ្រោះ ម៉ុក ធូ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D5/983/1 នៅត្រង់ ERN (ភាសាអង់គ្លេស) 00990127។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់

អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក្រោយពេលកម្មាភិបាលនិរតីបានទៅដល់ភូមិភាគពាយ័ព្យ[406]។

១៧៨. ចៅក្រមទទួលបន្ទុករឿងក្តីយល់ឃើញទៀតថា មានភស្តុតាងគ្រប់គ្រាន់អំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលកំណត់ជាគោលដៅចំពោះអតីតមន្ត្រីសាធារណរដ្ឋខ្មែរ ដែលត្រូវបានយកមកអនុវត្តនៅភូមិភាគពាយ័ព្យ ក្រោមការគ្រប់គ្រងរបស់កម្មាភិបាលនិរតី ជាផ្នែកនៃសហឧក្រិដ្ឋកម្មរួម ហើយបើផ្អែកលើគុណភាពនៃភរនីយភាព អ៊ឹម ចែម បានចូលរួមក្នុងនាមជាសហចារី[407]។ ដោយរម្លឹកឡើងវិញនៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) ពាក់ព័ន្ធនឹងតួនាទី និងសិទ្ធិអំណាចរបស់ អ៊ឹម ចែម[408] ទទួលបន្ទុករឿងក្តីកត់សម្គាល់ថា អ៊ឹម ចែម ខ្លួនឯងបានទទួលស្គាល់ថា ធ្លាប់បានទទួលសំបុត្រដែលបញ្ជាឱ្យចាប់ខ្លួន "សមាសភាពមិនល្អ" រួមមាន អតីតមន្ត្រីសាធារណរដ្ឋខ្មែរ និងអ្នករដ្ឋការក្នុងរបប លន់ នល់[409]។ សួន មុត បានបញ្ជាក់ថា ក្បាលម៉ាស៊ីនផ្នែកសន្តិសុខនៅតំបន់ ៥ នឹងផ្តល់បញ្ជីឈ្មោះ "អ្នកដែលជាប់និន្នាការនឹងរបប លន់ នល់" ទៅប្រធានភូមិ ប្រធានឃុំ ដើម្បីចាប់ខ្លួន និងបញ្ជូនពួកគេទៅកសាងខ្លួន[410]។

១៧៩. ពាក់ព័ន្ធនឹងចំណុចនានាដែលបានលើកឡើងខាងលើ ចៅក្រមទទួលបន្ទុករឿងក្តីសន្និដ្ឋានថា មានភស្តុតាងគ្រប់គ្រាន់ដើម្បីបង្ហាញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញទៅលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ និងសាច់ញាតិរបស់ពួកគេ ត្រូវបានប្រព្រឹត្តមិនត្រឹមតែនៅមន្ទីរសន្តិសុខភ្នំត្រយោង

---

ចម្លើយសាក្សី យង់ ស៊ុន ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ D219/433 នៅត្រង់ ERN 01124143 (ឆ.១០)។ សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អឿ លឿ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ D5/1252 នៅត្រង់ ERN 01036276។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D219/206 នៅត្រង់ ERN 01072259 (ឆ.២០-ឆ.២១)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D119/118 នៅត្រង់ ERN 01224760។

[406] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម សឿន ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ D219/567 នៅត្រង់ ERN 01165946 (ឆ.៤៤-ឆ.៤៥)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អិត ហល់ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ D219/475 នៅត្រង់ ERN 01134129 (ឆ.៩)។

[407] *សូមមើល ខាងលើ* កថាខណ្ឌ ១៣២-១៤២ ។

[408] ដីកាដំណោះស្រាយ កថាខណ្ឌ (សំអាងហេតុ) ១៥៦-១៧៩។

[409] សំណុំរឿង ០០៤/១ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ ឯកសារ D123/1/5.1a នៅត្រង់ ERN 00929747។

[410] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន មុត ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ D219/37 នៅត្រង់ ERN 01032108 (ឆ.៥៨-ឆ.៦៣)។

ប៉ុណ្ណោះទេ តែយ៉ាងហោចណាស់ក៏មាននៅទូទាំងតំបន់ ៥ ទាំងមូលនៃភូមិភាគពាយ័ព្យ ព្រមទាំងមានភស្តុតាងគ្រប់គ្រាន់អំពីការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មនោះដែរ។ ហេតុនេះ សហចៅក្រមស៊ើបអង្កេតមិនបានធ្វើការកំណត់តាមផ្លូវច្បាប់ឱ្យបានត្រឹមត្រូវ និងមិនបានយកស្ថានទម្ងន់នៃឧក្រិដ្ឋកម្មមកពិចារណាទេ ក្នុងការវាយតម្លៃរបស់ខ្លួនទៅលើការទទួលខុសត្រូវរបស់ អ៊ឹម ចែម។ ហេតុនេះ ចៅក្រមទទួលបន្ទុករឿងក្តីគាំទ្រផ្នែកនេះនៃទឡ្ហីករណ៍ទី២(៥) នៃបណ្តឹងឧទ្ធរណ៍ ហើយនឹងធ្វើការបកស្រាយនាពេលបន្ទាប់នៅក្នុងសាលដីកានេះថា តើការខកខាននេះ ជាកត្តាកំណត់យ៉ាងសំខាន់នៃការសម្រេចអំពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬយ៉ាងណា។

### *៣. ការធ្វើទុក្ខបុកម្នេញទៅលើប្រជាជនចាម*

១៨០. កថាខណ្ឌ ១៧ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ចោទប្រកាន់ថា "ជនជាតិភាគតិចចាម ដែលមានលក្ខណៈជាតិពន្ធុនិងសាសនា" ក្លាយជាគោលដៅនៃសហឧក្រិដ្ឋកម្មរួមដើម្បីបោសសម្អាតនៅភូមិភាគពាយ័ព្យ ដែល អ៊ឹម ចែម បានចូលរួមក្នុងនាមជាសហចារី ហើយបទចោទដែលបានស្នើឡើងនៅក្នុងកថាខណ្ឌ ១១៩ រួមមាន ""ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុពូជសាសន៍ និងសាសនា [...] ទៅលើជនជាតិចាម"។ ហេតុនេះ ចៅក្រមចុះហត្ថលេខាយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានយកមកពិនិត្យនូវការចោទប្រកាន់នានាស្តីពីការធ្វើទុក្ខបុកម្នេញទៅលើប្រជាជនចាម នៅក្នុងបរិបទនៃការបោសសម្អាតនៅភូមិភាគពាយ័ព្យ ហើយបានបំពេញភារកិច្ចស៊ើបសួរ និងសម្រេចទៅលើការចោទប្រកាន់ទាំងនោះ។

១៨១. ចៅក្រមទទួលបន្ទុករឿងក្តីសង្កេតឃើញថា ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តទៅលើប្រជាជនចាមមិនត្រូវបានដោះស្រាយជាក់លាក់នៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) ទេ។ ចៅក្រមទទួលបន្ទុករឿងក្តីក៏យល់ឃើញផងដែរថា ភស្តុតាងដែលប្រមូលបានក្នុងអំឡុងពេលស៊ើបអង្កេត មិនបានបង្ហាញឱ្យបានពេញលេញថា ការប្រព្រឹត្តចំពោះប្រជាជនចាម ក្រោមការគ្រប់គ្រងរបស់ អ៊ឹម ចែម នៅភូមិភាគពាយ័ព្យ អាចក្លាយជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញ ដូចបានកំណត់ខាងលើ នោះទេ [411] ។ ជាពិសេស ចៅក្រមទទួលបន្ទុករឿងក្តីកត់សម្គាល់ថា សហព្រះរាជអាជ្ញាអន្តរជាតិបានចង្អុលទៅភស្តុតាងថា ប្រជាជនចាមត្រូវបានកំណត់ជាគោលដៅនៅវត្តចម្ការខ្នុរ ក្នុងស្រុកព្រះនេត្រព្រះ ផ្អែកលើចម្លើយរបស់ ឃួន

---

[411] *សូមមើល ខាងលើ* កថាខណ្ឌ ១៤៨ *យោងទៅ* សាលដីកាសំណុំរឿង ០០១ (ឯកសារ F28) កថាខណ្ឌ ២២៦, ២៤១។

សាយ និង សៀន ញាណ[412]។ សៀន ញាណ ជាអ្នកដឹកនាំការគាស់សាកសព និងបញ្ជូនអដ្ឋិធាតុទៅចម្ការខ្នុរ ក្រោយពេលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ បានរាយការណ៍ថា មានជនរងគ្រោះចម្រុះ រួមមាន "ចាម ឡាវអីក៏មាន ដូចជាស្ដើងណាស់"[413] ចំណែក ឃួន សាយ បានលើកឡើងតែថា "ចិនក៏មក"[414]។

១៨២. ចៅក្រមទទួលបន្ទុករឿងក្ដីសន្និដ្ឋាន ដោយផ្អែកលើគុណភាពនៃភស្តុតាងរួមមិនគ្រប់គ្រាន់ដើម្បីបង្ហាញពីធាតុផ្សំស្ដីពីការរើសអើងចាំបាច់ទេ និងដើម្បីសន្និដ្ឋានថា ការប្រព្រឹត្តទៅលើប្រជាជនចាមក្លាយជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញ នៅពេល អ៊ឹម ចែម ចូលគ្រប់គ្រងស្រុកព្រះនេត្រព្រះនោះឡើយ។

១៨៣. ដោយពិចារណាទៅលើចំណុចខាងលើ ចៅក្រមទទួលបន្ទុករឿងក្ដីសូមច្រានចោលផ្នែកនេះនៃទឡ្ហីករណ៍ទី២(៥) នៃបណ្ដឹងឧទ្ធរណ៍។

### ៤. *ការធ្វើទុក្ខបុកម្នេញទៅលើប្រជាជនចិន ប្រជាជនឡាវ និង ជនជាតិភាគតិចខ្មែរលើ*

១៨៤. ចៅក្រមទទួលបន្ទុករឿងក្ដីកត់សម្គាល់ថា នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ បទចោទដែលបានស្នើឡើងស្ដីពីការធ្វើទុក្ខបុកម្នេញជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានកម្រិតត្រឹមតែក្រុមមនុស្សមួយចំនួន ហើយថា ក្រុមទាំងនោះមិនបានលើកឡើងច្បាស់ថាជាប្រជាជនចិន ប្រជាជនឡាវ ឬជនជាតិភាគតិចខ្មែរលើទេ[415]។ ទោះបីការចោទប្រកាន់លើអង្គហេតុទៅលើ អ៊ឹម ចែម រួមមានយោងនៅ

[412] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៣៥ *យោងទៅ* ដីកាសន្និដ្ឋានស្ដាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D304/2) កថាខណ្ឌ ២៤០។

[413] សំណុំរឿង ០០៤/១ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សៀន ញាណ ឆ្នាំ ១៩៩៧ ឯកសារ D219/204.2.1 នៅត្រង់ ERN 01107059។ *សូមមើលផងដែរ* សំណុំរឿង ០០៤/១ របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ការធ្វើផែនទីស្ដីពីវាលពិឃាតនៅកម្ពុជា៖ បន្ទាយមានជ័យ ឆ្នាំ ១៩៩៨ ឯកសារ D1.3.27.10 នៅត្រង់ ERN (ភាសាអង់គ្លេស) 00078068។ សំណុំរឿង ០០៤/១ របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D118/38 នៅត្រង់ ERN 01223508។

[414] សំណុំរឿង ០០៤/១ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឃួន សាយ ឆ្នាំ ១៩៩៧ ឯកសារ D219/204.2.1 នៅត្រង់ ERN 01107083។

[415] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ (ឯកសារ D1) កថាខណ្ឌ ១១៩។

ក្នុងជើងទំព័រ ទៅប្រជាជនជាជាតិពន្ធុចិន ពាក់ព័ន្ធនឹងការបោសសម្អាត[416] ហើយយោងទៅជនរងគ្រោះនៃជាតិ ពន្ធុចិន និងវៀតណាម "ខ្លះ" ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខវត្តចម្ការខ្នុរក៏ដោយ[417] តែភស្តុតាងដែលបានដកស្រង់ ហាក់ដូចជាគាំទ្រដល់ការចោទប្រកាន់ពីការធ្វើទុក្ខបុកម្នេញទៅលើប្រជាជនវៀតណាមជាង ហើយមិនបានបង្ហាញឱ្យឃើញពីធាតុផ្សំនៃការរើសអើងចាំបាច់ ទៅលើជនជាតិភាគតិចនៃជាតិពន្ធុផ្សេងៗទៀតឡើយ។

១៨៥. ហេតុនេះ ចៅក្រមទទួលបន្ទុករឿងក្តីយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមិនត្រូវបានប្តឹងអំពីការចោទប្រកាន់ទៅលើ អ៊ឹម ចែម អំពីការធ្វើទុក្ខបុកម្នេញទៅលើប្រជាជនចិន ប្រជាជនឡាវ និងជនជាតិភាគតិចខ្មែរលើ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ហើយហេតុនេះសហចៅក្រមស៊ើបអង្កេតពុំមានភារកិច្ចក្នុងការស៊ើបអង្កេត និងសម្រេចទៅលើការចោទប្រកាន់ទាំងនោះ អនុលោមតាមវិធាន ៥៥(២) និង៦៧(១) នៃវិធានផ្ទៃក្នុង នៅពេលចេញដីកាដំណោះស្រាយ (សំអាងហេតុ) នោះឡើយ។

១៨៦. អាស្រ័យហេតុនេះ ចៅក្រមទទួលបន្ទុករឿងក្តី សូមច្រានចោលផ្នែកនេះនៃទឡ្ហីករណ៍ទី២(៥) នៃបណ្តឹងឧទ្ធរណ៍។

## *៥. ការធ្វើទារុណកម្មនៅមន្ទីរសន្តិសុខភ្នំទ្រយោង*

១៨៧. បទចោទដែលបានស្នើឡើងប្រឆាំង អ៊ឹម ចែម នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីរួមមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទារុណកម្ម[418] ។ ចៅក្រមទទួលបន្ទុករឿងក្តី

---

[416] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ (ឯកសារ D1) កថាខណ្ឌ ៥៩ និងជើងទំព័រ ២២៧ *យោងទៅ* សំណុំរឿង ០០៤/១ កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ លីម គីមស៊ុន ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៨ ឯកសារ D1.3.11.28 នៅត្រង់ ERN 00722318-00722319 (លើកឡើងថា ក្នុងចំណោមសមាជិក ២៤នាក់នៃក្រុមគ្រួសារកាត់ចិនវៀតណាមដែលត្រូវបានចាប់ខ្លួន មានតែពីរនាក់ប៉ុណ្ណោះដែលបានរត់រួច រួមទាំងបង/ប្អូនប្រុសរបស់សាក្សីដែលនិយាយភាសាចិន)។ សំណុំរឿង ០០៤/១ កិច្ចសម្ភាសន៍របស់ SOAS/HRW ជាមួយ ឈួន បន ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៥ ឯកសារ D1.3.11.10 នៅត្រង់ ERN 00800809 (លើកឡើងថា ប្រជាជនជាតិពន្ធុចិនដែលមិននិយាយខ្មែរត្រូវគេចោទថាវៀតណាម ហើយត្រូវបានសម្លាប់)។

[417] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ (ឯកសារ D1) កថាខណ្ឌ ៧១ និងជើងទំព័រ ២៨៧ *យោងទៅ* សំណុំរឿង ០០៤/១ របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ការធ្វើផែនទីស្តីពីវាលពិឃាតនៅកម្ពុជា៖ បន្ទាយមានជ័យ ឆ្នាំ ១៩៩៨ ឯកសារ D1.3.27.10 នៅត្រង់ ERN (ភាសាអង់គ្លេស) 00078068។

[418] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី (ឯកសារ D1) កថាខណ្ឌ ១១៩។

01575534



កត់សម្គាល់នៅត្រង់ចំណុចនេះថា កថាខណ្ឌ ៨ នៃដីកាសន្និដ្ឋាននេះបានចោទប្រកាន់ថា "ប.ក.ក បានអនុវត្តគោលនយោបាយមិនស្របច្បាប់របស់ខ្លួន តាមរយៈខ្សែបណ្ដាញមន្ទីរសន្តិសុខ នៅទូទាំងប្រទេស ដែលបានឃុំឃាំង ធ្វើបាប ធ្វើទារុណកម្ម និងសម្លាប់ខុសច្បាប់នូវប្រជាជន របស់របបកម្ពុជាប្រជាធិបតេយ្យចំនួនយ៉ាងច្រើនសន្ធឹកសន្ធាប់"។ ជាពិសេសចំពោះមន្ទីរសន្តិសុខភ្នំទ្រយោង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី បានចោទប្រកាន់ថា៖

មន្ទីរសន្តិសុខភ្នំទ្រយោង មានតួនាទីជាកន្លែងអប់រំលត់ដំ ដល់សមាសភាពក្បត់តាមការចោទប្រកាន់ ជាការដ្ឋានធ្វើការដោយបង្ខំ និងជាទីតាំងសម្លាប់មនុស្ស ដែលត្រូវបានយល់ថាជាខ្មាំងរបស់ របបកម្ពុជាប្រជាធិបតេយ្យ។ អ្នកទាំងឃុំឃាំងទាំងនេះ ដែលត្រូវចាត់ថ្នាក់ថាជាអ្នកប្រព្រឹត្តល្មើសធ្ងន់ធ្ងរ ត្រូវបង្ខំឲ្យធ្វើការនៅក្នុងការដ្ឋានបំបែកថ្ម និងត្រូវផ្ដល់របបអាហារ តែបបរមួយវែកប៉ុណ្ណោះក្នុងមួយពេល។ អ្នកដែលមិនធ្វើការឲ្យបានស្វាហាប់នោះទេត្រូវសម្លាប់ចោល ហើយអ្នកខ្លះបានស្លាប់ដោយសារការអត់ឃ្លាន ឬធ្វើការហួសកម្លាំង។ ឈ្លបឃុំនិងកម្មាភិបាលភូមិភាគនិរតី នៅក្រោមការគ្រប់គ្រងរបស់ អ៊ឹម ចែម ទទួលខុសត្រូវចំពោះការចាប់ខ្លួនប្រជាជន និងនាំយកប្រជាជនទៅសម្លាប់នៅភ្នំទ្រយោង។ ការសម្លាប់ដែលមានច្រើនរហូតដល់ទៅ ១៥នាក់ក្នុងមួយយប់ៗ ត្រូវបានធ្វើឡើងនៅភាគខាងជើងភ្នំទ្រយោង[419]។

១៨៨. ចៅក្រមទទួលបន្ទុករឿងក្ដី បានកត់សម្គាល់បន្ថែមថា មន្ទីរសន្តិសុខត្រូវបានរៀបរាប់នៅក្នុងយុត្តិសាស្ត្ររបស់ អ.វ.ត.ក ថាជាកន្លែង "ទទួលបន្ទុកក្នុងការសួរចម្លើយ និងកាប់សម្លាប់អ្នកដែលត្រូវបានសន្មតថា ប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា"[420]។ អាស្រ័យហេតុនេះចៅក្រមទាំងនេះពិចារណាថា សហចៅក្រមស៊ើបអង្កេត បានទទួលដោយត្រឹមត្រូវនូវការចោទប្រកាន់ ពីការធ្វើទារុណកម្មនៅមន្ទីរសន្តិសុខភ្នំទ្រយោង ដូច្នេះហើយសហចៅក្រមស៊ើបអង្កេត ដោយអនុលោមទៅតាមវិធាន ៥៥(២) និងវិធាន ៦៧(១) នៃវិធានផ្ទៃក្នុង មានភារកិច្ចដើម្បីស៊ើបអង្កេត និងសម្រេចទៅលើបទចោទទាំងនេះ នៅពេលចេញដីកាដំណោះស្រាយ (សំអាងហេតុ)។

១៨៩. សហចៅក្រមស៊ើបអង្កេត ទទួលស្គាល់ភស្តុតាងដែលថា "នៅចន្លោះពេលពីពាក់កណ្ដាលឆ្នាំ ១៩៧៧ ដល់ចុងឆ្នាំ ១៩៧៨ យ៉ាងហោចណាស់ មានមនុស្សរាប់រយនាក់ ប៉ុន្តែក៏អាចរាប់ពាន់នាក់ដែរ"

---

[419] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី (ឯកសារ D1) កថាខណ្ឌ ៧៥ (លុបជើងទំព័រ)។

[420] សូមមើល សំណុំរឿង ០០៣ សេចក្ដីសម្រេចលើពាក្យសុំមោឃភាពចំនួន២ ឯកសារ D134/1/10 មតិយោបល់របស់ចៅក្រម BEAUVALLET និង BWANA កថាខណ្ឌ ៥២។ សំណុំរឿង ០០១ សាលក្រម (ឯកសារ E188) កថាខណ្ឌ ១១១, ១១៥។ សំណុំរឿង ០០១ សាលដីកា (ឯកសារ F28) កថាខណ្ឌ ២។

01575535



ដែលត្រូវបានឃុំនៅមន្ទីរសន្តិសុខភ្នំទ្រយោង[421] ។ សហចៅក្រមស៊ើបអង្កេតពិចារណាបន្ថែមទៀតថា ការបង្ខំឱ្យទទួលយកស្ថានភាពរស់នៅដែលអមនុស្សធម៌បែបនេះ ដូចជាការមិនផ្តល់ឱ្យនូវអាហារនិងទឹកផឹកគ្រប់គ្រាន់ ស្ថានភាពអនាម័យដ៏អាក្រក់ និងការដាក់ខ្នោះ "អ្នកទោសធ្ងន់" បង្កើតបានជាការប៉ះពាល់ ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ ដែលមានស្ថានទម្ងន់គ្រប់គ្រាន់សម្រាប់បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់នៃអំពើអមនុស្សធម៌ផ្សេងទៀត[422] ។ ទោះជាយ៉ាងនេះក្តី សហចៅក្រមស៊ើបអង្កេតមិនបានវាយតម្លៃទៅលើភស្តុតាងជាក់លាក់នៃការធ្វើទារុណកម្មនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងមិនបានធ្វើការកំណត់តាមផ្លូវច្បាប់ទៅលើការចោទប្រកាន់ទាំងអស់នេះទេ។

១៩០. ចៅក្រមទទួលបន្ទុករឿងក្តី សូមរំឮកថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់នៃការធ្វើទារុណកម្ម ត្រូវបានកំណត់និយមន័យថាជា អំពើណាមួយដែលបណ្តាលឱ្យមានការឈឺចាប់ឬការរងទុក្ខយ៉ាងធ្ងន់ធ្ងរ ទោះបីជាផ្លូវកាយឬផ្លូវចិត្តក្តី (ធាតុផ្សំសត្យានុម័ត) ដែលប្រព្រឹត្តឡើងដោយចេតនាទៅលើបុគ្គលណាមួយ (ធាតុផ្សំអត្តនោម័ត) ដោយមន្ត្រីសាធារណៈ ឬដោយការញុះញង់ពីមន្ត្រីសាធារណៈ ក្នុងគោលបំណងដើម្បីទទួលបាននូវព័ត៌មាន ឬចម្លើយសារភាព ឬការដាក់ទណ្ឌកម្ម ឬការបំភិតបំភ័យ[423]។

១៩១. ចៅក្រមទទួលបន្ទុករឿងក្តីពិចារណាថា តាមពិតទៅ មានភស្តុតាងគ្រប់គ្រាន់ ដោយផ្អែកលើតុល្យភាពនៃភវនីយភាព ដែលថា អ្នកទោសនៅមន្ទីរសន្តិសុខភ្នំទ្រយោង ទទួលរងពីអំពើដែលបណ្តាលឱ្យមានការឈឺចាប់ផ្នែករាងកាយឬផ្លូវចិត្ត ដែលប្រព្រឹត្តឡើងទៅលើពួកគេ ដើម្បីទទួលបាននូវព័ត៌មាន។ ជាពិសេស តោ ពិនថង ដែលត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខភ្នំទ្រយោង នៅក្នុងឆ្នាំ ១៩៧៨ បានបញ្ជាក់ថា កងទ័ព "យកសោរវាយក្បាល" រាល់ពេលដែលគេសួរចម្លើយគាត់ ដើម្បីបង្ខំគាត់ឱ្យឆ្លើយសារភាពថា គាត់គឺជាទាហាន លន់ នល់[424]។ រិន ខេង បានរាយការណ៍ប្រហែលគ្នាថា គាត់ត្រូវបានឃុំឃាំងរយៈពេលពីរខែនៅក្នុងឆ្នាំ ១៩៧៨ នៅមន្ទីរសន្តិសុខភ្នំទ្រយោង ដែលនៅទីនោះគាត់ត្រូវបានគេសួរចម្លើយ ហើយវាយនឹងរំពាត់យ៉ាងធ្ងន់ធ្ងរនៅពេលយប់[425] ។ ទុក ប៊ូ ដែលត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ ១៩៧៧ ហើយត្រូវបានឃុំ

---

[421] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៩៤, ១៩៩។

[422] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២០៣, ២០៦, ២៩៣។

[423] សំណុំរឿង ០០១ សាលដីកា (ឯកសារ F28) កថាខណ្ឌ ១៩៥, ២០៥។

[424] សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ តោ ពិនថង ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D5/1075, ERN (ភាសាខ្មែរ) 01022735-01022736។

[425] សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ រិន ខេង ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ

01575536



ឃុំឃាំងរយៈពេលបីខែ[426] ត្រូវបានកងទ័ពសួរចម្លើយប្រហែលប្រាំទៅប្រាំមួយដង ហើយគាត់ភ័យខ្លាចថាគាត់ត្រូវគេវាយរហូតដល់ស្លាប់ប្រសិនបើគាត់ មិនផ្តល់ "ចម្លើយដែលត្រឹមត្រូវ" នោះទេ[427]។

១៩២. មានភស្តុតាងគ្រប់គ្រាន់ថា អ្នកទោសនៅមន្ទីរសន្តិសុខភ្នំទ្រយោង ត្រូវទទួលរងព្យសនកម្មផ្លូវកាយ និងផ្លូវចិត្ត ក្រោមទម្រង់នៃការដាក់ទណ្ឌកម្ម និងការបំភិតបំភ័យ។ ជាទូទៅ អ្នកទោសភ័យខ្លាចថា ពួកគាត់ត្រូវគេវាយឬសម្លាប់ចោល ប្រសិនបើពួកគាត់ព្យាយាមរត់គេច ឬប្រព្រឹត្តនូវកំហុសឆ្គង។ បើយោងតាម ទុក ប៊ូ និង ហែម សឿន គឺ អ៊ឹម ចែម ខ្លួនគាត់ផ្ទាល់បានដឹកនាំការប្រជុំ នៅមន្ទីរសន្តិសុខ "ដើម្បីទប់ស្កាត់អ្នកទោសកុំឱ្យលួចរត់" ដោយបញ្ជាក់ថាអ្នកប្រព្រឹត្តខុស ឬអ្នកដែលមិនអាចលត់ដំឬកែប្រែខ្លួនបាន "ត្រូវស្លាប់"[428]។ តាមពិតទៅ កងទ័ពបានសម្លាប់អ្នកទោសទាំងនោះ ហើយទុកអ្នកផ្សេងទៀតឱ្យដេកជាមួយសាកសពទាំងនោះ[429]។ ទុក ប៊ូ បានរំឭកជាពិសេសថា អ្នកទោសរួមទាំងរូបគាត់ផង ត្រូវបានគេវាយដោយសារតែព្យាយាមរត់គេចចេញពីមន្ទីរសន្តិសុខ ឬដោយសារតែចូលរោងឃឹត ហើយថាអ្នកទោសម្នាក់ដែលមិនអាចបញ្ចប់ភារកិច្ចរបស់គាត់បាន ត្រូវបានគេបង្ខំឱ្យហូបដីខ្សាច់រហូតដល់គាត់ស្លាប់[430]។ ហែម សឿន ដែលត្រូវបានចាប់ខ្លួន នៅពេលដែលពួកកម្មាភិបាលភូមិភាគនិរតីមកដល់[431] បានបញ្ជាក់ថា អ្នកទោសដែលរត់គេច ត្រូវគេវាយនឹងដំបងឈើ[432]។ អ៊ិត ហាល់ ដែលត្រូវបានឃុំឃាំង តាមការសម្រេចរបស់កម្មាភិបា

D5/988, ERN (ភាសាខ្មែរ) 00990221-00990222។

[426] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយ ប៊ូ ត្លូក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ D219/400, ERN (ភាសាខ្មែរ) 01147823 (ឆ.៤៣) 01147825 (ឆ.៥៨)។

[427] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយ ប៊ូ ត្លូក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ D219/400, ERN (ភាសាខ្មែរ) 01147833 (ឆ.១២៣-ឆ.១២៨)។

[428] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយ ប៊ូ ត្លូក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ D219/400, ERN (ភាសាខ្មែរ) 01147825 (ឆ.៦៤) 01147826 (ឆ.៦៨)។ សូមមើល សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយ ហែម សឿន ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ D219/567, ERN (ភាសាខ្មែរ) 01165954 (ឆ.១៣៩)។

[429] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយ ប៊ូ ត្លូក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ D219/400, ERN (ភាសាខ្មែរ) 01147826 (ឆ.៦៩)។

[430] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយ ប៊ូ ត្លូក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ D219/400, ERN (ភាសាខ្មែរ) 01147830 (ឆ.៩៨) 01147834 (ឆ.១៣០-ឆ.១៣២)។

[431] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយ ហែម សឿន ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ D219/567, ERN (ភាសាខ្មែរ) 01165946 (ឆ.៤២) 01165947 (ឆ.៤៨)។

[432] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយ ហែម សឿន ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ D219/567,

ល ភូមិភាគនិរតីនោះ បានរាយការណ៍ថា គាត់បានទទួលការគម្រាមកំហែងសម្លាប់ ពីខ្មែរក្រហមដែលប្រចាំការនៅក្នុងគុក ដែលតែងតែយកដំបងឈើ មកដាក់ក្បែរក្បាលអ្នកទោស ហើយនិយាយថា "មិនយូរទេនឹងក្លាយជាស្នូលដីហើយ"[433] ។ ជុំ ជិម ដែលត្រូវបានគេនាំយកមកមន្ទីរសន្តិសុខនៅក្នុងឆ្នាំ ១៩៧៨[434] បានរំឮកថា អ្នកទោសដែលដើរមិនរួច ត្រូវបានគេវាយទាត់ធាក់[435]។ ប៊ិន ណាន់ និង រិន ខេង បានអះអាងបញ្ជាក់បន្ថែមថា តាមច្បាប់របស់កម្មាភិបាលភូមិភាគនិរតី[436] អ្នកនៅក្នុំទ្រយោងត្រូវគេវាយឬសម្លាប់ចោលនៅពេលអ្នកទាំងនោះលួច[437]។

១៩៣. លើសពីនេះទៅទៀត ភស្តុតាងជារួម បានបង្ហាញយ៉ាងគ្រប់គ្រាន់ តាមបទដ្ឋានដែលបានតម្រូវ ពីអំពើនៃការធ្វើទារុណកម្មទាំងអស់នេះ ត្រូវបានធ្វើឡើងដោយឆ្មាំគុកឬកងទ័ព ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ប្រធានមន្ទីរសន្តិសុខ គឺ ទុំ សឿន ដែលជាអ្នករាយការណ៍ដោយផ្ទាល់ទៅ អ៊ឹម ចែម[438]។

---

ERN (ភាសាខ្មែរ) 01165957 (ឆ.១៦៧)។

[433] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយ អិត ហល់ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ D219/475, ERN (ភាសាខ្មែរ) 01134131 (ឆ.១៩)។

[434] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយ ជុំ ជិម ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៥ ឯកសារ D219/149, ERN (ភាសាខ្មែរ) 01058728 (ឆ.១៨)។

[435] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយ ជុំ ជិម ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៥ ឯកសារ D219/149, ERN (ភាសាខ្មែរ) 01058730 (ឆ.៣២)។

[436] សំណុំរឿង ០០៤/១ បទសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៊ិន ណាន់ និង រិន ខេង ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ D123/1/2.65, ERN (ភាសាខ្មែរ) 00927367-00927369។

[437] សំណុំរឿង ០០៤/១ បទសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៊ិន ណាន់ និង រិន ខេង ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ D123/1/2.65, ERN (ភាសាខ្មែរ) 00927369-00927370, 00927373-00927374។

[438] សូមមើលឧទាហរណ៍ ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៧៥, ១៨៩, ១៩២-១៩៥។ សូមមើលផងដែរ សំណុំរឿង ០០៤/១, កំណត់ហេតុនៃការស្តាប់ចម្លើយ ទុំ សឿន ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D119/65, ERN (ភាសាខ្មែរ) 00953041 (ឆ.១៥៨) 00953043 (ឆ.១៧៥) 00953046-00953047 (ឆ.១៩៨-ឆ.១៩៩) ។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយ ទុំ សឿន ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ D219/102, ERN (ភាសាខ្មែរ) 01043195 (ឆ.១៣)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយ មី គាល់ ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ D219/256, ERN (ភាសាខ្មែរ) 01085166 (ឆ.២៥, ឆ.២៨)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយ ធិប សំផាត់ ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២ ឯកសារ D106/8, ERN (ភាសាខ្មែរ) 00801017 (ឆ.៣៥)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយ ធិប សំផាត់ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ D119/49, ERN (ភាសាខ្មែរ) 00933111 (ឆ.៧៥)។ សំណុំរឿង ០០៤/១, កំណត់ហេតុនៃការស្តាប់ចម្លើយ ជុំ កាន់ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ

01575538



១៩៤. ផ្អែកលើការបកស្រាយខាងលើនេះ ចៅក្រមទទួលបន្ទុករឿងក្ដីសន្និដ្ឋានថា មានភស្តុតាងគ្រប់គ្រាន់ដែលថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទារុណកម្ម ត្រូវបានប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខភ្នំទ្រយោង ហើយថា អ៊ឹម ចែម អាចត្រូវទទួលខុសត្រូវចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មនេះ។ បន្ថែមលើនេះ ចៅក្រមទទួលបន្ទុករឿងក្ដីពិចារណាទៅលើចំនួនអ្នកទោស ដែលត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខភ្នំទ្រយោង ក្រោមការគ្រប់គ្រងរបស់ អ៊ឹម ចែម ដែលមានយ៉ាងហោចណាស់រាប់ពាន់នាក់[439] គឺមានភាពពាក់ព័ន្ធទៅនឹងការវាយតម្លៃទៅលើចំនួននៃជនរងគ្រោះដោយសារធ្វើទារុណកម្ម និងស្ថានទម្ងន់នៃឧក្រិដ្ឋកម្មនោះ។ ហេតុដូច្នេះ ចៅក្រមទទួលបន្ទុករឿងក្ដី គាំទ្រផ្នែកនេះនៃមូលដ្ឋានទី ២(៥) នៃបណ្ដឹងឧទ្ធរណ៍ ហើយនឹងបកស្រាយនៅពេលក្រោយក្នុងសាលដីកានេះ ថាតើ ការមិនបានពិចារណា អំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងវាយតម្លៃទៅលើការទទួលខុសត្រូវរបស់ អ៊ឹម ចែម គឺជាកត្តាកំណត់ជាមូលដ្ឋាននៃការសម្រេចទៅលើយុត្តាធិការបុគ្គលរបស់អ.វ.ត.ក ដែរឬទេ។

### *៦. ការធ្វើទារុណកម្មនៅមន្ទីរសន្តិសុខវត្តចំការខ្នុរ និងទីតាំងសម្លាប់មនុស្សវត្តចំការខ្នុរ*

១៩៥. បទចោទដែលបានលើកឡើងប្រឆាំង អ៊ឹម ចែម នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី រួមមាននូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់នៃការធ្វើទារុណកម្ម[440]។ ដូចពីផ្នែកខាងលើដែរ ចៅក្រមដែលបានចុះហត្ថលេខាខាងក្រោម បានកត់សម្គាល់ថា កថាខណ្ឌ ៨ នៃដីកាសន្និដ្ឋាន បានចោទប្រកាន់ថា "ប.ក.ក បានអនុវត្តគោលនយោបាយមិនស្របច្បាប់របស់ខ្លួន តាមរយៈខ្សែបណ្ដាញមន្ទីរសន្តិសុខ នៅទូទាំងប្រទេស ដែលបានឃុំឃាំង ធ្វើបាប ធ្វើទារុណកម្ម និងសម្លាប់ខុសច្បាប់នូវប្រជាជន របស់របបកម្ពុជាប្រជាធិបតេយ្យ ចំនួនយ៉ាងច្រើនសន្ធឹកសន្ធាប់"។ ការចោទប្រកាន់ពីអង្គហេតុ ទាក់ទងវត្តចំការខ្នុរ ពឹងផ្អែកទៅលើភស្តុតាងសម្ភារៈដែលថា ទីតាំងនេះមានទាំងមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស[441] ហើយបានលើកឡើងដូចតទៅ៖

---

D119/110, ERN (ភាសាខ្មែរ) 00980395 (ទ.៨៩)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្ដាប់ចម្លើយ CHUM Chim, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៥ ឯកសារ D219/149, ERN (ភាសាខ្មែរ) 01058731 (ទ.៣៦)។

[439] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៩៤, ១៩៩។

[440] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី (ឯកសារ D1) កថាខណ្ឌ ១១៩។

[441] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី (ឯកសារ D1) ជើងទំព័រ ២៨៤ និង២៨៧ យោងទៅរកសំណុំរឿង ០០៤/១ មជ្ឈមណ្ឌលឯកសារកម្ពុជា របាយការណ៍ផែនទីខេត្ត បន្ទាយមានជ័យ ឆ្នាំ ១៩៩៧ ឯកសារ D1.3.10.10 នៅត្រង់ ERN (ភាសា

01575539



ទីតាំងសម្លាប់នៅវត្តចំការខ្នុរ មានទីតាំងនៅឃុំអូរអំបិល ស្រុកស៊ីសុផុន ខេត្តបន្ទាយមានជ័យ។ វត្ត ដែលនៅក្បែរទីតាំងសម្លាប់នេះ ត្រូវបានប្រើជាមន្ទីររបស់កម្មាភិបាលមូលដ្ឋាន។ លលាដ៍ក្បាលជាង ៩,០០០ ត្រូវបានរកឃើញនៅទីតាំងនេះ និងត្រូវបានដាក់នៅក្នុងបូជនីយដ្ឋាន វត្តសុភមង្គល។ ជនរងគ្រោះ ភាគច្រើនជាអ្នកតាំងទីលំនៅជនជាតិវៀតណាម។ ជាពិសេសការសម្លាប់កាន់តែមាន លក្ខណៈធ្ងន់ធ្ងរនៅ ចុងឆ្នាំ ១៩៧៨ នៅពេលនោះជួនកាល "ឡានមានមនុស្សពេញៗចំនួន៥ឬ៦" បានមកដល់។ អ្នករស់ជីវិត ម្នាក់បានឃើញផ្ទាល់ភ្នែក ប្រជាជន "រាប់ពាន់នាក់" "ត្រូវបានចងដាក់ខ្នោះជាប់ និងសែងចេញពីឡានធំៗ ចំនួន២០" នៅក្នុងយប់មួយ។ ឡានទាំងអស់នោះបានត្រឡប់ទៅវិញក្នុងល្ងាចនោះ "ដោយដឹកតែសម្លៀកបំពាក់របស់ប្រជាជនប៉ុណ្ណោះ"[442]។

១៩៦. ដោយរំឭកថាមន្ទីរសន្តិសុខ ត្រូវបានរៀបរាប់ថាជាទីកន្លែង "ទទួលបន្ទុកក្នុងការសួរចម្លើយ និង កាប់សម្លាប់អ្នកដែលត្រូវបានសន្មតថា ប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា" [443] ចៅក្រមដែលបានចុះហត្ថលេខាខាងក្រោម បានពិចារណាថា សហចៅក្រមស៊ើបអង្កេត បានទទួលដោយត្រឹមត្រូវនូវការចោទប្រកាន់ពីការធ្វើទារុណកម្មដែលបានប្រព្រឹត្ត នៅវត្តចំការខ្នុរ ហើយសហចៅក្រមស៊ើបអង្កេត មានភារកិច្ចដើម្បីស៊ើបអង្កេត និងសម្រេចទៅលើបទចោទទាំងនេះ និងសម្រេចទៅលើបទចោទទាំងនោះ នៅពេលចេញដីកាដំណោះស្រាយ (សំអាងហេតុ)។

១៩៧. សហចៅក្រមស៊ើបអង្កេតបានសម្រេចថា "ក្រោយការដឹកនាំរបស់ភូមិភាគពាយ័ព្យ និងភូមិភាគនិរតី ប្រជាជនត្រូវបានគេឃុំឃាំង និងកាប់សម្លាប់" នៅវត្តចំការខ្នុរ[444]។ សហចៅក្រមស៊ើបអង្កេតក៏បានកត់សម្គាល់ផងដែរពីភស្តុតាងរបស់ ទឹម រតនៈ ដែលនៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ បានឃើញនៅទីតាំងនោះនូវបន្ទប់មានស្នាមប្រឡាក់ឈាម និងសាកសពមនុស្សជាប់ខ្នោះដៃ និងខ្នោះជើងដែលត្រូវមានស្នាមជាំ និងរបួសមុខកាំបិត ដែលធ្វើឲ្យគាត់សន្និដ្ឋានថា ពួកគេទាំងនោះត្រូវបានធ្វើទារុណកម្ម នៅមុនពេលគេសម្លាប់[445]។

ខ្មែរ) 00750668-00750669។ សំណុំរឿង ០០៤/១ មជ្ឈមណ្ឌលឯកសារកម្ពុជា របាយការណ៍ផែនទីខេត្តបន្ទាយមានជ័យ ឆ្នាំ ១៩៩៨ ឯកសារ D1.3.27.10, នៅត្រង់ ERN (ភាសាអង់គ្លេស) 0078068-0078069។

[442] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ឯកសារ D1 កថាខណ្ឌ ៧១ (ដោយដកចេញនូវជើងទំព័រ)។

[443] សូមមើលសំណុំរឿង ០០៣ ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D134/1/10, យោបល់របស់ចៅក្រមអន្តរជាតិ ចៅក្រម BEAUVALLET និងចៅក្រម BWANA កថាខណ្ឌ ៥២។ សំណុំរឿង ០០១ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (ឯកសារ E188) កថាខណ្ឌ ១១១ និង១១៥។សំណុំរឿង ០០១ សាលដីកាអង្គជំនុំជម្រះតុលាការកំពូល (ឯកសារF28), កថាខណ្ឌ ២។

[444] ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ២៦៩។

[445] ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ២៦៩ យោងទៅរក សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ទឹម រតនៈ

01575540



ប៉ុន្តែសហចៅក្រមស៊ើបអង្កេត មិនបានធ្វើការសម្រេចច្បាស់លាស់ និងការសម្រេចលើអង្គច្បាប់ អំពីការប្រព្រឹត្តអំពើធ្វើទារុណកម្ម ដូចបានកំណត់និយមន័យនៅផ្នែកខាងលើឡើយ[446]។

១៩៨. ចៅក្រមដែលបានចុះហត្ថលេខាខាងក្រោម បានពិចារណាថា មានភស្តុតាងគ្រប់គ្រាន់ដែលថា អ្នកទោសនៅវត្តចំការខ្នុរ ត្រូវបានបង្កឲ្យមានការឈឺចាប់ផ្លូវកាយ និងផ្លូវចិត្ត ដើម្បីទទួលបាននូវព័ត៌មាន ឬជាទម្រង់នៃការដាក់ទណ្ឌកម្ម និងការបំភិតបំភ័យ។ ឡែម ពេញ ដែលត្រូវបានឃុំឃាំងនៅពេលដែល កម្មាភិបាលភូមិភាគនិរតីមកដល់[447] បានបញ្ជាក់ថាកម្មាភិបាលនារី មកពីភូមិភាគពាយ័ព្យ បានយកខ្សែភ្លើងមកឆក់គាត់នៅត្រង់ជើង ដៃ ក និងដងខ្លួន នៅពេលដែលគេសួរចម្លើយគាត់នៅក្នុងឆ្នាំ ១៩៧៨[448]។ ប៊ុន គឹមអេង ដែលត្រូវបានឃុំឃាំងនៅចុងឆ្នាំ ១៩៧៨ បានបញ្ជាក់ថា គាត់ភ័យខ្លាចនៅពេលឃើញពួកឈ្លប យកមនុស្សទៅសម្លាប់ជារៀងរាល់ថ្ងៃ ហើយគាត់បានឃើញខ្មែរក្រហមវាយនារីម្នាក់ និងជាន់ទន្ទ្រាំលើពោះនារីនោះ ដើម្បីជាការដាក់ទណ្ឌកម្ម ដែលនារីនោះប្រព្រឹត្តខុសសីលធម៌[449]។ ឌៀប ពឹងឡាង បានរាយការណ៍ថាគាត់ភ័យខ្លាច "ត្រូវគេជេរប្រទិច ដោយពាក្យខ្លាំងៗ" នៅគុកក្នុងឆ្នាំ ១៩៧៨[450]។ ប៉ោ ងឿត ដែលធ្វើការនៅ វត្តចំការខ្នុររហូតដល់ឆ្នាំ ១៩៧៨ បានបញ្ជាក់ជាទូទៅថា អតីតទាហានលន់ នល់ ត្រូវបានពួកឈ្លបវាយនៅពេលសួរចម្លើយ មុននឹងយកទៅសម្លាប់ចោល[451]។ ដូចគ្នានេះ ឃួន សាយ បានអះអាងថា គាត់ត្រូវបានគេសួរចម្លើយ និងធ្វើទារុណកម្មនៅវត្តចំការខ្នុរ[452] ហើយគាត់បានរៀបរាប់ថា អ្នកទោសត្រូវបានពួកខ្មែរក្រហម

---

ថ្ងៃទី២ ខែមេសា ឆ្នាំ២០១៤ ឯកសារ D119/113 នៅត្រង់ ERN (ភាសាខ្មែរ) 00982246-00982247 (ចម្លើយ ១៨ ដល់ចម្លើយ ២១)។

[446] សូមមើលខាងលើ កថាខណ្ឌ ១៩០ ។

[447] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ឡែម ពេញ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ D219/174, នៅត្រង់ ERN (ភាសាខ្មែរ) 01065986 (ចម្លើយ ១៣), 01065987 (ចម្លើយ ២០), 01065989 (ចម្លើយ ៣៧)។

[448] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ឡែម ពេញ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ D219/174, នៅត្រង់ ERN (ភាសាខ្មែរ) 01065990 (ចម្លើយ ៤៥ ដល់ចម្លើយ៤៧)។

[449] សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៊ុន គឹមអេង ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៣ ឯកសារ D5/923 នៅត្រង់ ERN (ភាសាខ្មែរ) 00979800។

[450] សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឌៀប ពឹងឡាង ថ្ងៃទី២ ខែតុលា ឆ្នាំ២០០៩ ឯកសារ D5/1459, នៅត្រង់ ERN (ភាសាខ្មែរ) 01043688-01043689។

[451] សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៉ោ ងឿត ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៣ ឯកសារ D5/995, នៅត្រង់ ERN (ភាសាខ្មែរ) 00989559-00989560។

[452] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ តាន់ សាយ ហៅ ឃួន សាយ ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ



PRE-TRIAL E.C.

វាយនឹងរំពាត់ បណ្ដើរទៅដោយច្រកស្បោងប្លាស្ទីក[453] បើទោះបីជាគាត់ជាប់ឃុំឃាំងនៅទីនោះ ត្រឹមតែខែមករា ឬពាក់កណ្ដាលឆ្នាំ ១៩៧៧ ក្ដី[454]។ គាត់អះអាងបន្តថា ប្រជាជនត្រូវបានគេចាប់ខ្លួន និងសម្លាប់នៅទីនោះរហូតដល់ឆ្នាំ ១៩៧៩ ហើយមានស្នាមឈាមនៅជាប់យ៉ាងច្បាស់ នៅលើជញ្ជាំងវត្ត គឺជាឈាមដែលខ្ទាតពីមនុស្ស ដែលត្រូវគេវាយរហូតដល់ស្លាប់[455]។ អ្នកស៊ើបអង្កេតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ស៊ិន ឃិន ហាក់ដូចជាបានដឹងពីសាក្សីថា អ្នកទោសត្រូវបានគេសួរចម្លើយ និងធ្វើទារុណកម្មនៅវត្តចំការខ្នុរ តាមរយៈវិធីបែបនេះដូចជាការវាយ ការឲ្យក្អែបទិច និងការដកក្រចក[456]។ ជាចុងក្រោយអ្នកស៊ើបអង្កេត នៃការិយាល័យសហចៅក្រមស៊ើបអង្កេត បានសន្និដ្ឋានបន្ថែមដោយផ្អែកលើភស្ដុតាងប្រមូលបានថា វត្តចំការខ្នុរគឺជាមន្ទីរឃុំឃាំង ដែលត្រូវបានប្រើប្រាស់នៅក្នុងអំឡុងពេលគ្រប់គ្រង ដោយកម្មាភិបាលភូមិភាគពាយ័ព្យ និងកម្មាភិបាលភូមិភាគនិរតី "ដែលអ្នកទោសត្រូវបានឃុំខ្លួន និងធ្វើទារុណកម្ម មុនពេលគេយកទៅសម្លាប់"[457]។

---

D118/25, នៅត្រង់ ERN (ភាសាខ្មែរ) 00892221-00892222 (ចម្លើយ ១១ ដល់ចម្លើយ ១៣)។

[453] សំណុំរឿង ០០៤/១, កំណត់ហេតុនៃកិច្ចស៊ើបសួរ ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ ឯកសារ D119/119, នៅត្រង់ ERN (ភាសាខ្មែរ) 01224963-01224964។

[454] សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ តាន់ សាយ ហៅ ឃួន សាយ ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ D118/25, នៅត្រង់ ERN (ភាសាខ្មែរ) 00892220-00892221 (ចម្លើយ ៩), 00892222 (ចម្លើយ ១៥)។ សំណុំរឿង ០០៤/០១ ការសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឃួន សាយ ឆ្នាំ ១៩៩៧ ឯកសារ D219/204.2.1, នៅត្រង់ ERN (ភាសាខ្មែរ) 01107083-01107087។ សំណុំរឿង ០០៤/១, កំណត់ហេតុនៃកិច្ចស៊ើបសួរ ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ ឯកសារ D119/119, នៅត្រង់ ERN (ភាសាខ្មែរ) 01224963-01224964។

[455] សំណុំរឿង ០០៤/០១ ការសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឃួន សាយ ឆ្នាំ ១៩៩៧ ឯកសារ D219/204.2.1, នៅត្រង់ ERN (ភាសាខ្មែរ) 01107083-01107084។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ការសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ សិត ផ្កា ឆ្នាំ ១៩៩៧ ឯកសារ D219/204.2.1នៅត្រង់ ERN (ភាសាខ្មែរ) 01107087-01107088។

[456] សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ ស៊ិន ឃិន ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ D219/206 នៅត្រង់ ERN (ភាសាខ្មែរ) 01072259 (ចម្លើយ ១៤ ដល់ចម្លើយ១៧)។

[457] សំណុំរឿង ០០៤/១, កំណត់ហេតុនៃកិច្ចស៊ើបសួរ ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៤ ឯកសារ D119/118 នៅត្រង់ ERN (ភាសាខ្មែរ) 01224759-01224761។

១៩៩. ពាក់ព័ន្ធនឹងភស្តុតាងខាងលើ បើតាមបទដ្ឋានដែលបានតម្រូវ គេអាចបង្ហាញយ៉ាងពេញលេញបានថា អំពើទារុណកម្មទាំងនេះនៅវត្តចម្ការខ្នុរ ត្រូវបានប្រព្រឹត្តដោយពួកឈ្លប កម្មាភិបាល ឬទាហាន ដែលស្ថិតក្រោមការគ្រប់គ្រងរបស់កម្មាភិបាលភូមិភាគពាយ័ព្យ និងកម្មាភិបាលភូមិភាគនិរតី។

២០០. ចំពោះសិទ្ធិអំណាចរបស់ អ៊ឹម ចែម ទាក់ទិននឹងទីតាំងនេះ ចៅក្រមទទួលបន្ទុករឿងក្តីកត់សម្គាល់ថា វត្តចម្ការខ្នុរស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការស្រុកស៊ីសុផុន ព្រមទាំងគណៈកម្មាធិការតំបន់ ៥[458] ដែល អ៊ឹម ចែម ក្លាយជាសមាជិកគណៈកម្មាធិការតំបន់ ៥ នៅដើម ឬពាក់កណ្តាលឆ្នាំ ១៩៧៨[459]។ ភស្តុតាងបានបង្ហាញគ្រប់គ្រាន់បន្ថែមទៀតថា ក្រោមការគ្រប់គ្រងរបស់កម្មាភិបាលភូមិភាគពាយ័ព្យ និងកម្មាភិបាលភូមិភាគនិរតី វត្តចម្ការខ្នុរត្រូវបានប្រើប្រាស់ជាមន្ទីរសន្តិសុខសម្រាប់ដាក់អ្នកទោសនៅស្រុកព្រះនេត្រព្រះ[460] ដែល អ៊ឹម ចែម ទទួលខុសត្រូវក្នុងនាមជាលេខាស្រុកពីខែ មីនា ឆ្នាំ ១៩៧៧[461] ហើយមានសិទ្ធិអំណាចក្នុងការចេញបញ្ជាឱ្យចាប់មនុស្ស[462]។ មានភស្តុតាងជារួមថា អ្នកជាប់ឃុំនៅវត្តចម្ការខ្នុរត្រូវបានបញ្ជូនទៅ ឬមកពីទីតាំងជាច្រើនក្នុងតំបន់ ៥ រួមទាំងមន្ទីរសន្តិសុខភ្នំត្រយោង[463]។ ជាង

---

[458] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាន ឈួង ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D119/136 នៅត្រង់ ERN 01003845 (ឆ.២៨)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តាន់ សាយ *ហៅ* ឃួន សាយ ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D118/25 នៅត្រង់ ERN 00892221-00892222 (ឆ.១០, ឆ.១៦)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ សាមុត ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ D219/477 នៅត្រង់ ERN 01134148 (ឆ.២៧)។

[459] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៦៦។

[460] *សូមមើល ឧទាហរណ៍* សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡែម ពេញ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D219/174 នៅត្រង់ ERN 01065986 (ឆ.១៣), 01065987 (ឆ.២០), 01065988-01065989 (ឆ.៣៥, ឆ.៣៧) (ក្រោមការគ្រប់គ្រងរបស់កម្មាភិបាលភូមិភាគនិរតី ត្រូវបានបញ្ជូនចេញពីស្រុកព្រះនេត្រព្រះទៅកាន់វត្តចម្ការខ្នុរ)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តាន់ សាយ *ហៅ* ឃួន សាយ ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D118/25 នៅត្រង់ ERN 00892220-00892221 (ឆ.៩) (ត្រូវបានបញ្ជូននៅឆ្នាំ ១៩៧៦ ចេញពីព្រះនេត្រព្រះ ទៅមន្ទីរសន្តិសុខវត្តចម្ការខ្នុរ)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃកិច្ចសម្ភាសន៍ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D119/119 នៅត្រង់ ERN 01224763-01224764។

[461] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៥៨, ១៦៦។

[462] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៨៦, ១៨៧។

[463] *សូមមើល ឧទាហរណ៍* សំណុំរឿង ០០៤១/ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អឿ លឿ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ D5/1252 នៅត្រង់ ERN 01036276-01036277 (ត្រូវបានបញ្ជូនចេញពីវត្តចម្ការខ្នុរ "ដោយមេគុកមិត្តឈួ" "ដែលមកពីភូមិភាគនិរតី" ទៅមន្ទីរសន្តិសុខភ្នំត្រយោងនៅឆ្នាំ ១៩៧៨ ដែលគេរាយការណ៍ថា អ៊ឹម ចែម ជាអ្នកបញ្ជាឱ្យសម្លាប់)

នេះទៀត ភស្តុតាងបង្ហាញថា សិទ្ធិអំណាចរបស់ អ៊ឹម ចែម បានពង្រីកទៅខាងក្រៅព្រំប្រទល់ស្រុកព្រះនេត្រព្រះទៅទៀត [464] ហើយជាពិសេសនៅក្នុងស្រុកស៊ីសុផុន ដែលប្តីគាត់ឈ្មោះ តាញ៉ែន ត្រូវបានតែងតាំងជាគណៈកម្មាធិការស្រុក [465] ហើយជាកន្លែងដែលប្តីគាត់ និងបងប្អូនបង្កើតគាត់បានរស់នៅទីនោះ[466]។ ពាក់ព័ន្ធនឹងចំណុចនេះ សហចៅក្រមស៊ើបអង្កេតបានទទួលស្គាល់ភស្តុតាងថា អ៊ឹម ចែម បានធ្វើការ និងមានមន្ទីរមួយនៅស៊ីសុផុន គាត់បានធ្វើដំណើរ និងទៅធ្វើទស្សនកិច្ចនៅតាមការដ្ឋាននានានៅទូទាំងតំបន់ ៥ ទាំងមូល ហើយ គាត់បានចូលរួមការប្រជុំ និងរៀបចំការប្រជុំនៅថ្នាក់តំបន់[467]។ អ៊ឹម ចែម ខ្លួនឯងក៏បានលើកឡើងថា បានចូលរួមការប្រជុំមួយនៅស្វាយស៊ីសុផុន "ទទួលផែនការ"[468] ចំណែក សួន មុត ដែលជាប្រធានភូមិនៅឃុំភ្នៀត ស្រុកស៊ីសុផុន បានបញ្ជាក់ថា គាត់បានឃើញ អ៊ឹម ចែម "ចេញចូល និង

---

។ *សូមមើលជាទូទៅផងដែរ* សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គាន់ សាយ *ហៅ* ឃួន សាយ ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D118/25 នៅត្រង់ ERN 00892221 (ឆ.១០)។ សំណុំរឿង ០០៤១/ កិច្ចសម្ភាសន៍របស់ SOAS/HRW ជាមួយ ទឹល ហេវ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៥ ឯកសារ D6.1.634 នៅត្រង់ ERN 00831512។

[464] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៦៥។

[465] កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម នៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ (ឯកសារ D123/1/5.1a) នៅត្រង់ ERN 00929747។ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម នៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c) នៅត្រង់ ERN 00929892។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន មុត ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ D219/37 នៅត្រង់ ERN 01032106 (ឆ.៤៥)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/94 នៅត្រង់ ERN 00976183 (ឆ.៥២)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នឹង ជឿន ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ D119/156 នៅត្រង់ ERN 01024774 (ឆ.២៧)។

[466] កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម នៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ ឯកសារ) D123/1/5.1c) នៅត្រង់ ERN 00929891-00929892។

[467] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៦៥។ *សូមមើលផងដែរ ឧទាហរណ៍* សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀម សារ៉េម ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៤ ឯកសារ D119/76 នៅត្រង់ ERN 00971144 (ឆ.១៩-ឆ.២៣)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន ហ៊ីយ ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D119/66 នៅត្រង់ ERN 00969016 (ឆ.១៣)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន មុត ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ D219/37 នៅត្រង់ ERN 01032106 .ឆ)៤២-៤៤), 01032107 (ឆ.៥២-ឆ.៥៥)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ D119/110 នៅត្រង់ ERN 00980395 (ឆ.៨៥-ឆ.៨៦)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ សាមុត ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ D219/477 នៅត្រង់ ERN 01134150 (ឆ.៣៥)។

[468] កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ (ឯកសារ D123/1/5.1b) នៅត្រង់ ERN 00929777។

ប្រជុំនៅមន្ទីរស្វាយស៊ីសុផុន នៅពេលដែលខ្ញុំចូលប្រជុំនៅទីនោះ។ មន្ទីរស្វាយស៊ីសុផុននោះ គឺជាមន្ទីរតំបន់ ៥"[469]។

២០១. ផ្អែកលើការពិភាក្សាខាងលើ ចៅក្រមដែលបានចុះហត្ថលេខាខាងក្រោមសម្រេចថា មានភស្តុតាងគ្រប់គ្រាន់ដែលថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់នៃការធ្វើទារុណកម្ម ត្រូវបានប្រព្រឹត្តឡើងនៅ វត្តចំការខ្នុរ ហើយថា អ៊ឹម ចែម អាចត្រូវទទួលខុសត្រូវចំពោះ ការប្រព្រឹត្តឧក្រិដ្ឋកម្មនេះ។ ហេតុដូច្នេះចៅក្រមដែលបានចុះហត្ថលេខាខាងក្រោម សម្រេចតម្កល់ទុកផ្នែកនេះ នៃទឡ្ហីករណ៍ ២(៥) នៃបណ្តឹងឧទ្ធរណ៍ ហើយនិងពិភាក្សានៅពេលក្រោយ ក្នុងសាលដីកានេះ ថាតើការសន្និដ្ឋានបែបនេះ គឺជាកត្តាកំណត់ជាមូលដ្ឋាន នៃការសម្រេចទៅលើ យុត្តាធិការលើបុគ្គល របស់អ.វ.ត.ក ដែរឬទេ។

### *៧. លក្ខខណ្ឌរស់នៅអមនុស្សធម៌នៅមន្ទីរសន្តិសុខភូមិចក្រី*

២០២. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ចោទប្រកាន់ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភូមិចក្រីដូចខាងក្រោម៖

មន្ទីរសន្តិសុខភូមិចក្រី និងទីកន្លែងសម្លាប់នៅក្បែរភូមិតាវ៉ូត មានទីតាំងនៅភូមិចក្រី ឃុំជ្ញប ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ របាយការណ៍ប៉ាន់ស្មានថា ប្រជាជនច្រើនរហូតដល់ ៦.០០០ នាក់ ត្រូវបានឃុំខ្លួន និងសម្លាប់នៅកន្លែងនោះ។ ក្នុងអំឡុងពេលមួយសប្តាហ៍ នៅចុងខែមិថុនា ឆ្នាំ១៩៧៨ "មន្ត្រីនារីរបស់ភូមិភាគនិរតី" បាននាំមនុស្សពី ២០ ទៅ ៣០ នាក់ ជារៀងរាល់យប់ទីកាន់គុកនោះ និងបានសម្លាប់អ្នកទាំងនោះចោល។ ក្រៅពីនេះ ប្រជាជននៅភូមិចក្រីស្ទើរតែទាំងអស់ ដែលមានចំនួន ៤០០ នាក់ ត្រូវបានសម្លាប់ក្នុងពេលបោសសម្អាត ដែលធ្វើឡើងនៅទូទាំងស្រុកព្រះនេត្រព្រះ រហូតដល់ ចុងខែសីហា ឆ្នាំ១៩៧៨។ ទាំងមន្ទីរសន្តិសុខ និងទីតាំងសម្លាប់ មានទីតាំងនៅជិតមន្ទីរស្រុកព្រះនេត្រព្រះ ហើយហាក់ដូចជាថា មន្ទីរសន្តិសុខនេះជាគុកថ្នាក់ស្រុកសម្រាប់ស្រុកព្រះនេត្រព្រះ[470]

២០៣. បទចោទដែលបានស្នើឡើងប្រឆាំងនឹង អ៊ឹម ចែម នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី រួមមាន ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងទៀត[471] ដែលយុត្តិសាស្ត្រនៃ អ.វ.

[469] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន មុត ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ D219/37 នៅត្រង់ ERN 01032105-01032106 (ឆ.៤១-៤២)។

[470] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី (ឯកសារ D1) កថាខណ្ឌ ៧៦ (លេខយោងជើងទំព័រត្រូវបានលុបចោល)។

[471] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី (ឯកសារ D1) កថាខណ្ឌ ១១៩។

ត.ក បានកំណត់ថាជាបទល្មើសដែលនៅសេសសល់ក្នុងគោលបំណងដើម្បីកំណត់បទល្មើសព្រហ្មទណ្ឌ ចំពោះអំពើ "ដែលមានស្ថានទម្ងន់ស្រដៀងគ្នា" នឹងឧក្រិដ្ឋកម្មដូចមានចែងផ្សេងទៀត រួមទាំង "ការឃុំខ្លួនក្នុងស្ថានភាពរស់នៅដែលមិនអាចទទួលយកបាន និងព្រៃផ្សៃ" [472] ។ ចៅក្រមដែលទទួលបន្ទុកលើរឿងក្តីពិចារណាការពិនិត្យមើលលក្ខខណ្ឌរស់នៅនៅក្នុងមន្ទីរឃុំឃាំង ថាជាទិដ្ឋភាពជាមូលដ្ឋានមួយនៃការស៊ើបអង្កេតលើការចោទប្រកាន់អំពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងមន្ទីរសន្តិសុខ។ អាស្រ័យហេតុនេះ ចៅក្រមយល់ឃើញថា សហចៅក្រមស៊ើបអង្កេតទទួលបានយ៉ាងត្រឹមត្រូវនូវការចោទប្រកាន់អំពីលក្ខខណ្ឌនៃការរស់នៅអមនុស្សធម៌ ដែលជាអំពើអមនុស្សធម៌ផ្សេងទៀត ប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខភ្នំចក្រី ហេតុដូច្នេះ ចៅក្រមមានភារកិច្ចស៊ើបអង្កេត និងសម្រេចលើការចោទប្រកាន់នៅពេលចេញដីកាដំណោះស្រាយ (សំអាងហេតុ)។

២០៤. ចៅក្រមដែលទទួលបន្ទុកលើរឿងក្តី សង្កេតឃើញថា ការចោទប្រកាន់អំពីបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខភ្នំចក្រី និងទីតាំងជាប់ៗគ្នានៅទីនោះ មិនត្រូវបានបញ្ចូលក្នុងបទចោទទាំងនោះទេ[473] ។ លើសពីនេះ សហចៅក្រមស៊ើបអង្កេតមិនបានបញ្ជាក់ច្បាស់លាស់នៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) អំពីការចោទប្រកាន់លើស្ថានភាពរស់នៅអមនុស្សធម៌នៅមន្ទីរសន្តិសុខភ្នំចក្រី [474] ឬ ធ្វើការកំណត់ជាក់លាក់តាមផ្លូវច្បាប់ ប៉ុន្តែគ្រាន់តែបានសម្រេចឡើងៗថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាទូទៅ បានកើតឡើងនៅទីតាំងឧក្រិដ្ឋកម្មដែលពុំត្រូវបានចោទប្រកាន់ [475] ។ ទោះបីជាយ៉ាងនេះក៏ដោយ សហចៅក្រមស៊ើបអង្កេតកត់សម្គាល់លើភស្តុតាងដែលបានបង្ហាញថា អ្នកដែលត្រូវបានចាប់ខ្លួនត្រូវបាន "គេឃុំឃាំង" មួយរយៈពេលខ្លី មុននឹងត្រូវបានសម្លាប់ចោលនៅមន្ទីរសន្តិសុខភ្នំចក្រីរយៈពេលប្រហែលមួយឆ្នាំរហូតដល់ចុងឆ្នាំ១៩៧៨ ឬ ដើមឆ្នាំ ១៩៧៩[476] នៅពេលដែល អ៊ឹម ចែម កាន់កាប់អំណាចនៅក្នុងស្រុកព្រះនេត្រព្រះ[477]។ សហចៅក្រមស៊ើបអង្កេតបានរកឃើញយ៉ាងច្បាស់ផងដែរថា កម្មាភិបាលភូមិភាគ

[472] សាលក្រមសំណុំរឿង ០០១ (ឯកសារ E188) កថាខណ្ឌ ៣៦៧-៣៧១។ *សូមមើលផងដែរ* តុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Krnojelac*, IT-97-25-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ ("*Krnojelac Trial Judgement*") កថាខណ្ឌ ១៣៣-១៤៤។

[473] *សូមមើល* សេចក្តីជូនដំណឹងស្តីពីបទចោទ (ឯកសារ D239.1)។

[474] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៦០-២៦៣។

[475] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៦ *ដែលយោងលើ* ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣០៥។

[476] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៦០-២៦១។

[477] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៦៦។

និរតី ដែលទទួលខុសត្រូវក្នុងការប្រតិបត្តិការ និងបញ្ជូនអ្នកត្រូវបានចាប់ខ្លួនទៅមន្ទីរសន្តិសុខភូមិចក្រី បាន រាយការណ៍ទៅ អ៊ឹម ចែម[478] ដែលក្នុងនាមជាលេខាស្រុកព្រះនេត្រព្រះ មានសិទ្ធិអំណាចមើលការខុសត្រូវ លើមន្ទីរសន្តិសុខ ការកាប់សម្លាប់ និងការចាប់ខ្លួនដែលធ្វើឡើងដោយកងឈ្លបនៅក្នុងស្រុក[479]។

២០៥. ទោះបីយ៉ាងណាក៏ដោយ ចៅក្រមដែលទទួលបន្ទុកលើរឿងក្តី សង្កេតឃើញថា ភស្តុតាងដែល ប្រមូលបាននៅក្នុងអំឡុងពេលស៊ើបសួរ មានតិចតួច ហើយភស្តុតាងទាំងនេះបង្ហាញថា អ្នកដែលត្រូវបាន ចាប់ខ្លួន ត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខភូមិចក្រី មួយរយៈពេលខ្លី មុនពេលត្រូវបានយកទៅសម្លាប់ ចោល ពោលគឺ ចាប់ពី រយៈពេលមួយយប់[480]រហូតដល់ ពីរ ឬ បីថ្ងៃ[481]។ ភស្តុតាងបង្ហាញបន្ថែមទៀតថា អ្នកដែលត្រូវបានចាប់ខ្លួនប្រហែល ១៥ ទៅ ២០ នាក់ ត្រូវបាននាំទៅកាន់ទីនោះម្តងមួយៗ[482] ហើយគុក នោះអាចឃុំអ្នកទោសពី ២០ ទៅ ៣០ នាក់ ក្នុងពេលម្តងៗ[483]។ ចៅក្រមដែលទទួលបន្ទុកលើរឿងក្តី ពិចារណាឃើញថា ភស្តុតាងដែលមានតិចតួច និងការឃុំខ្លួនមួយរយៈពេលខ្លី នាំឱ្យមានការលំបាកក្នុងការ សម្រេចលើស្ថានភាពរស់នៅអមនុស្សធម៌។ ភស្តុតាងរបស់ យូ មុត និង ច្រាច់ គិត ជាការពិតទៅ ពុំបានផ្ត ល់នូវព័ត៌មានស៊ីសង្វាក់គ្នាស្តីពីលក្ខខណ្ឌនៃការឃុំខ្លួននោះទេ ជាពិសេស ថាតើអ្នកជាប់ឃុំទាំងនោះត្រូវបាន គេចងដៃជើងឬទេ[484] ប៉ុន្តែវាបង្ហាញគាំទ្រថា ពួកគេមិនត្រូវបានគេដាក់ឃ្នោះ ឬ វាយដំនោះទេ ប៉ុន្តែ ពួកគេ បានទទួលបាយហូប[485]។

---

[478] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៦១-២៦២។

[479] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៧៣-១៧៥។

[480] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ច្រាច់ គិត ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D106/2, ERN (ភាសាខ្មែរ) 00780968 (ឆ.២០)។

[481] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ មុត ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ D219/1, ERN (ភាសាខ្មែរ) 01024621 (ឆ.៤៣-៤៤)។

[482] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ច្រាច់ គិត ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D106/2, ERN (ភាសាខ្មែរ) 00780969 (ឆ.២១)។

[483] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ មុត ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ D219/1, ERN (ភាសាខ្មែរ) 01024620 (ឆ.៣៨)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន សុខ ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ D219/397, ERN (ភាសាខ្មែរ) 01114729 (ឆ.២៥)។

[484] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ មុត ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ D219/1, ERN (ភាសាខ្មែរ) 01024620 (ឆ.៣៨) 01024623 (ឆ.៦០)។ សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ យូ មុត ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ ឯកសារ D5/965, ERN (ភាសាខ្មែរ) 00989853។ សំណុំរឿង ០០៤/១

២០៦. សរុបមក ចៅក្រមដែលទទួលបន្ទុកលើរឿងក្តីយល់ឃើញថា ពុំមានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីបង្ហាញថា ឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ដទៃទៀតនៅក្នុងទម្រង់នៃការដាក់លក្ខខណ្ឌលើការរស់នៅដោយអមនុស្សធម៌ ត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងអ្នកដែលត្រូវបានឃុំខ្លួននៅមន្ទីរសន្តិសុខភូមិចក្រី។ ដូច្នេះ សហចៅក្រមស៊ើបអង្កេត ពុំមានកំហុស ដោយសារមិនបានទទួលយកការចោទប្រកាន់ទាំងនេះ មកពិចារណានៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួន ស្តីពីយុត្តាធិការបុគ្គល នោះទេ។ អាស្រ័យហេតុនេះ ទឡ្ហីករណ៍ទី ២(៥) ត្រង់ផ្នែកមួយនេះ ត្រូវបានច្រានចោល។

### *៨. ការដាក់ក្នុងមន្ទីរឃុំឃាំង និង ការបាត់ខ្លួនដោយបង្ខំនៅវត្តអង្គសិរីមាលី*

២០៧. កថាខណ្ឌ ១៥ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមស្តីពីតំបន់ ១ ចោទប្រកាន់ថា "នៅក្នុងស្រុកកោះអណ្តែត ការសម្លាប់ពួកខ្មែរក្រោមជាទ្រង់ទ្រាយធំ ត្រូវបានធ្វើឡើងនៅកន្លែងសម្លាប់ព្រៃសុខុន" ហើយថា "ជនរងគ្រោះខ្មែរក្រោមនានាត្រូវបានគេឃុំឃាំងជាបណ្តោះអាសន្ននៅវត្តអង្គសិរីមុនី [*sic*] ហើយបន្ទាប់មកទៀតត្រូវបានពួកកម្មាភិបាល ប.ក.ក ប្រដាប់ដោយអាវុធយកទៅសម្លាប់"[486]។ បើតាមយោបល់របស់ចៅក្រមទទួលបន្ទុករឿងក្តី *ក្នុងចំណោមការចោទប្រកាន់ផ្សេងៗទៀត* ចំណុចនេះកំណត់ជាការចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្នុងទម្រង់ជាការបាត់ខ្លួនដោយបង្ខំ[487] ចំពោះប្រជាជនខ្មែរក្រោមនៅវត្តអង្គសិរីមាលី។ ហេតុនេះ សហចៅក្រមស៊ើបអង្កេតបានទទួលយកមកពិនិត្យទាន់ពេលវេលា និងមានកាតព្វកិច្ចក្នុងការស៊ើបសួរ និងសម្រេចទៅលើការចោទប្រកាន់ទាំងនេះ នៅពេលចេញដីកាដំណោះស្រាយ (សំអាងហេតុ)។

២០៨. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា វត្តអង្គសិរីមាលីដំណើរការពីខែ មេសា ឆ្នាំ ១៩៧៥ ដល់យ៉ាងហោចណាស់ខែ វិច្ឆិកា ឆ្នាំ ១៩៨ ហើយបានទទួលស្គាល់ភស្តុតាងថា ឧក្រិដ្ឋកម្មមួយចំនួនត្រូវបានប្រព្រឹត្តនៅទីតាំងនេះ[488]។ ជាពិសេស សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ថា ប្រជាជនខ្មែរក្រោម

---

កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាច់ គិត ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D106/2, ERN (ភាសាខ្មែរ) 00780968 (ឆ.២០)។

[485] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ មុត ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ D219/1, ERN (ភាសាខ្មែរ) 01024620 (ឆ.៣៨) 01024623 (ឆ.៦១)។

[486] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមស្តីពីតំបន់ ១ (ឯកសារ D65) កថាខណ្ឌ ១៥។

[487] *សូមមើលខាងក្រោម មូលដ្ឋានទី៤ នៃបណ្តឹងឧទ្ធរណ៍* ។

[488] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៤៩។

និង "ប្រជាជន ១៧ មេសា" ត្រូវបានឃុំឃាំងនៅវត្តអង្គសិរីមាលី និងត្រូវបានយកទៅសម្លាប់នៅទីតាំងសម្លាប់ព្រៃសុខុនជាប្រចាំ ក្នុងអំឡុងសម័យខ្មែរក្រហម[489] ទោះបីសហចៅក្រមស៊ើបអង្កេតយល់ថា ភស្តុតាងមិនអាចបង្ហាញពីចំនួនជនរងគ្រោះ ឬសិទ្ធិអំណាចរបស់ អ៊ឹម ចែម ពាក់ព័ន្ធនឹងទីតាំងទាំងនេះក៏ដោយ[490]។ ជាចុងក្រោយ សហចៅក្រមស៊ើបអង្កេតពុំបានធ្វើការកំណត់តាមផ្លូវច្បាប់ឱ្យបានច្បាស់លាស់ទៅលើការចោទប្រកាន់ទាំងនេះទេ លើកលែងតែការសន្និដ្ឋានដោយប្រញាប់ប្រញាល់នៅត្រង់កថាខណ្ឌ ៣០៥ នៃដីកាដំណោះស្រាយ (សំអាងហេតុ) ថា ជាទូទៅ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានកើតឡើងនៅទីតាំងឧក្រិដ្ឋកម្មដែលមិនត្រូវបានចោទប្រកាន់។

២០៩. ចៅក្រមទទួលបន្ទុករឿងក្ដីយល់ឃើញថា ភស្តុតាងដែលបានយកមកពិនិត្យខាងលើ[491] បង្ហាញយ៉ាងពេញលេញថា ប្រជាជនខ្មែរក្រោមត្រូវបានឃុំឃាំង ក្នុងចំណោមប្រជាជនផ្សេងៗទៀត ហើយចុងក្រោយបានបាត់ខ្លួននៅវត្តអង្គសិរីមាលី រួមទាំងនៅពេល អ៊ឹម ចែម ទទួលបន្ទុកជាលេខាស្រុកកោះអណ្ដែត និងជាសមាជិកគណៈកម្មាធិការតំបន់ ១៣[492]។ ភស្តុតាងបង្ហាញយ៉ាងពេញលេញបន្ថែមថា វត្តអង្គសិរីមាលីត្រូវបានប្រើប្រាស់ជាមន្ទីរស្រុក ឬដោយយោធាស្រុក[493] ហើយថា សមាជិកកងឈ្លប នគរបាល និងទាហានបានយកប្រជាជនទៅសម្លាប់នៅព្រៃសុខុន[494]។ មានការរាយការណ៍ថា អ៊ឹម ចែម ជាអ្នកគ្រប់គ្រង

---

[489] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៤៩។

[490] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៥០-២៥១។

[491] *សូមមើល ខាងលើ* កថាខណ្ឌ ១៦៦ ។

[492] *សូមមើល ខាងក្រោម* មូលដ្ឋានទី៥ និងទី៦ នៃបណ្ដឹងឧទ្ធរណ៍ ។

[493] *សូមមើល* សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារ D119/2 នៅត្រង់ ERN 00866857 (ឆ.១១)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ D219/591 នៅត្រង់ ERN 01169863 (ឆ.១៣), 01169867 (ឆ.៤០), 01169868 (ឆ.៤៧)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារ D119/4 នៅត្រង់ ERN 00872485 (ឆ.១៨-ឆ.១៩)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កៅ ឆេង ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D119/16 នៅត្រង់ ERN 00893283 (ឆ.២០)។ សំណុំរឿង ០០៤/១ របាយការណ៍អនុវត្តដីកាចាត់ឱ្យសួរជំនួស ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D119/18 នៅត្រង់ ERN 00901572។

[494] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារ D119/2 នៅត្រង់ ERN 00866858 (ឆ.១៨), 00866859 (ឆ.២៥-ឆ.២៦)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ D219/592 នៅត្រង់ ERN 01171499-01171500 (ឆ.៥៣-ឆ.៥៩), 01171502 (ឆ.៧២-ឆ.៧៣)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ

ទៅលើយោធា និងកងឈ្លបនៅស្រុកកោះអណ្តែត ក្នុងតំបន់ ១៣[495] ហើយបានបញ្ជា តាសឿន ឱ្យចាប់មនុស្ស[496] ដែលគាត់ជាប្រធានសន្តិសុខស្រុក ឬតំបន់នៅវត្តអង្គសិរីមាលី[497]។ ហើយក៏មានភស្តុតាងផងដែរថា ម៉ោង ដែលជាប្រធាននគរបាលនៅថ្នាក់ស្រុកធ្វើការនៅវត្តអង្គសិរីមាលី និងបានចូលរួមក្នុងការសម្លាប់នៅព្រៃសុខុន នៅដើមរបបខ្មែរក្រហម ជាអ្នកទទួលបញ្ជាពីថ្នាក់លើ និងរាយការណ៍ទៅថ្នាក់លើ[498]។

២១០. ចៅក្រមទទួលបន្ទុករឿងក្តីយល់ឃើញបន្ថែមថា ការពិនិត្យដោយប្រញាប់ប្រញាល់ទៅលើភស្តុតាងដែលប្រមូលបាននៅក្នុងសំណុំរឿង ០០៤/១ អាចធ្វើឱ្យសហព្រះរាជអាជ្ញាអន្តរជាតិមានហេតុផលជឿថា បើតាមអត្ថន័យនៃវិធាន ៥៣(១) នៃវិធានផ្ទៃក្នុង ប្រជាជនផ្សេងៗទៀតក្រៅពីប្រជាជនខ្មែរក្រោមត្រូវបានឃុំឃាំងក្នុងចំនួនដ៏ច្រើន និងបានបាត់ខ្លួនដោយបង្ខំនៅវត្តអង្គសិរីមាលី ហើយចុងក្រោយត្រូវបានយកទៅសម្លាប់នៅទីតាំងសម្លាប់ព្រៃសុខុន[499]។ ទោះជាយ៉ាងណាក្តី សហចៅក្រមស៊ើបអង្កេតពុំយកចំណុចនេះទៅ

---

២០១២ ឯកសារ D119/4 នៅត្រង់ ERN 00872485 (ឆ.១៨)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ផល្លា ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ D219/568 នៅត្រង់ ERN 01165969 (ឆ.៧៨-ឆ.៨១)។

[495] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កៅ ឆេង ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D119/16 នៅត្រង់ ERN 00893283 (ឆ.១៩-ឆ.២១), 00893284 (ឆ.២៤, ឆ.៣១)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ D219/294 នៅត្រង់ ERN 01095263 (ឆ.១៨៦-ឆ.១៨៧)។

[496] សំណុំរឿង ០០៤កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ១/ អ៊ុល ហឿន ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ D219/34 នៅត្រង់ ERN 01032071 (ឆ.៣៣)។

[497] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារ D119/4 នៅត្រង់ ERN 00872485 (ឆ.២០)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុល ហឿន ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ D118/209 នៅត្រង់ ERN 00980100 (ឆ.២១-ឆ.២២)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុល ហឿន ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ D219/34 នៅត្រង់ ERN 01032071 (ឆ.៣៣)។

[498] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ D219/592 នៅត្រង់ ERN 01171496-01171497 (ឆ.៣៥-ឆ.៤៤), 01171501 (ឆ.៦៧)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារ D119/2 នៅត្រង់ ERN 00866859 (ឆ.២៦, ឆ.២៨)។

[499] *សូមមើលឧទាហរណ៍* សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារ D119/2 នៅត្រង់ ERN 00866856-00866861 (ឆ.៩-ឆ.៣៦)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ D219/592 នៅត្រង់ ERN 01171493-01171502 (ឆ.១៦-ឆ.៧២)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ

ពិនិត្យទេ ដោយសារពុំមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមមួយ ដែលពង្រីកវិសាលភាពកិច្ចស៊ើបសួរទៅដល់ទីតាំងទាំងនេះ ចំពោះជនរងគ្រោះណាផ្សេងក្រៅពីប្រជាជនខ្មែរក្រោមឡើយ។

២១១. ពាក់ព័ន្ធនឹងចំណុចនានាដែលបានលើកឡើងខាងលើ ចៅក្រមទទួលបន្ទុករឿងក្តីសន្និដ្ឋានថា មានភស្តុតាងគ្រប់គ្រាន់បង្ហាញថា អ៊ឹម ចែម អាចមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៃការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំមកលើប្រជាជនខ្មែរក្រោមត្រូវបានប្រព្រឹត្តនៅវត្តអង្គសិរីមាលើ។ ហេតុនេះ ចៅក្រមទទួលបន្ទុករឿងក្តីសូមតម្កល់ផ្នែកនេះនៃទឡ្ហីករណ៍ទី២(៥) នៃបណ្តឹងឧទ្ធរណ៍ ហើយនឹងធ្វើការបកស្រាយនាពេលបន្ទាប់នៅក្នុងសេចក្តីសម្រេចនេះថា តើការសន្និដ្ឋាននេះប៉ះពាល់ដល់ការសម្រេចជាមូលដ្ឋាននៃការកំណត់ទៅលើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬយ៉ាងណា។

## ច. ការពិចារណាបន្ថែម

២១២. ចៅក្រមទទួលបន្ទុកលើរឿងក្តីយល់ថា សហចៅក្រមស៊ើបអង្កេតបានទទួលយកការចោទប្រកាន់បន្ថែមនៅតាមទីតាំងឧក្រិដ្ឋកម្មផ្សេងៗដែលមិនត្រូវបានចោទប្រកាន់លើ អ៊ឹម ចែម ឬលើកឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន ដូចជា នៅការដ្ឋានទំនប់ត្រពាំងថ្ម វត្តព្រះនេត្រព្រះ និងទីតាំងពាក់ព័ន្ធ មន្ទីរសន្តិសុខភ្នំចិត្រី និងទីតាំងសម្លាប់ព្រៃតារ៉ុត និងមន្ទីរសន្តិសុខ និងទីតាំងសម្លាប់វត្តចំការខ្នុរ[500]។

២១៣. ទោះបីជាសហចៅក្រមស៊ើបអង្កេតបានពិនិត្យឡើងវិញដោយសង្ខេបលើភស្តុតាង[501] និងបានធ្វើការសង្កេតដោយប្រញាប់ប្រញាល់ថា ឧក្រិដ្ឋកម្មនានាត្រូវបានប្រព្រឹត្តនៅទីតាំងឧក្រិដ្ឋកម្មទាំងនេះក្តី[502] ក៏សហចៅក្រមស៊ើបអង្កេតមិនបានចោទប្រកាន់ឧក្រិដ្ឋកម្មទាំងនេះលើ អ៊ឹម ចែម និងមិនបានរៀបចំការកំណត់ផ្លូវ

---

D219/591 នៅត្រង់ ERN 01169866-01169867 (ឆ.២៩-ឆ.៣៧)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ទូច ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ D219/604 នៅត្រង់ ERN 01173499 (ឆ.៦៩-ឆ.៧៤)។ សំណុំរឿង ០០៤/១ របាយការណ៍អនុវត្តដីកាចាត់ឲ្យសួរជំនួស ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D119/18 នៅត្រង់ ERN 00901572-00901574។

[500] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា (D1) កថាខណ្ឌ ៧១ កថាខណ្ឌ ៧៦-៧៨។ *មើលផងដែរ* ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង អ៊ឹម ចែម (D239.1)។

[501] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៤៨-២៧៨។

[502] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣០៥។

ច្បាប់សមហេតុផល និងជាក់លាក់ណាមួយឡើយ។ សហចៅក្រមស៊ើបអង្កេតមានភារកិច្ចស៊ើបអង្កេត និងចេញសេចក្តីសម្រេចលើរាល់ការចោទប្រកាន់ដែលខ្លួនត្រូវទទួលបន្ទុកសមស្រប ដោយយោងតាមវិធាន ៥៥(២) និង ៦៧(១) នៃវិធានផ្ទៃក្នុង[503] ហើយការខកខាននេះនឹងបង្កជាការភ័ន្តច្រឡំលើអង្គច្បាប់។

២១៤. ក្រៅពីនេះ ចៅក្រមទទួលបន្ទុកលើរឿងក្តីកត់សម្គាល់ថា ផ្អែកតាមការពិនិត្យឡើងវិញលើភស្តុតាងនេះ សហចៅក្រមស៊ើបអង្កេតបានខិតខំកំណត់ចំនួនជនរងគ្រោះឱ្យបានត្រឹមត្រូវ និងច្បាស់លាស់សម្រាប់ទីតាំងឧក្រិដ្ឋកម្មនីមួយៗដែលមិនត្រូវបានចោទប្រកាន់[504]។ ចៅក្រមទទួលបន្ទុកលើរឿងក្តីយល់ថា លក្ខខណ្ឌតម្រូវនេះគ្មានយុត្តិកម្មឡើយ ជាពិសេសពាក់ព័ន្ធនឹងស្តង់ដារភស្តុតាងដែលអាចអនុវត្តបាននៅដំណាក់កាលមុនពេលជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធី[505]។ ចៅក្រមទទួលបន្ទុកលើរឿងក្តីរម្លឹកឡើងវិញថា វាមិនសមហេតុផលទាល់តែសោះក្នុងការផ្តោតតែលើភាពជាក់លាក់កម្រិតខ្ពស់ក្នុងករណីឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ និងមិនចាំបាច់ដឹងច្បាស់ពីចំនួនជនរងគ្រោះជាក់លាក់នោះទេ[506]។ ភាពមិនច្បាស់លាស់ពាក់ព័ន្ធនឹងចំនួនជនរងគ្រោះជាក់លាក់ មិនបានទាត់ចោលសេចក្តីសន្និដ្ឋានថា ឧក្រិដ្ឋកម្មនានាត្រូវបានប្រព្រឹត្តនៅទីកន្លែង និងពេលវេលាជាក់លាក់ឡើយ[507]។

---

[503] សំណុំរឿង ០០៣ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D134/1/10 ទស្សនៈរបស់ចៅក្រម BEAUVALLET និង ចៅក្រម BWANA កថាខណ្ឌ ១៣។

[504] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៥០, ២៥៩, ២៦៣, ២៦៧, ២៧០, ២៧៧-២៧៨, ៣២១។

[505] *សូមមើល កថាខណ្ឌ ៦១-៦២ ខាងលើ* ។

[506] តុលាការឧក្រិដ្ឋកម្មអន្តរជាតិ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Bemba Gombo* ICC-01/05-01/08-424 សាលដីកាសម្រេចយោងតាមមាត្រា ៦១(៧) (ក) និង (ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីការចោទប្រកាន់របស់ព្រះរាជអាជ្ញាលើ Jean-Pierre Bemba Gombo អង្គបុរេជំនុំជម្រះ II ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩ កថាខណ្ឌ ១៣៤។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Mbarushimana* ICC-01/04-01/10-465-Red សាលដីកាសម្រេចលើការបញ្ជាក់បទចោទប្រកាន់ អង្គបុរេជំនុំជម្រះ I ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១ កថាខណ្ឌ ១១២។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Stakic* IT-97-24-T សាលដីកា អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៣ កថាខណ្ឌ ២០១។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kvocka និងអ្នកផ្សេងទៀត* IT-98-30/1-A សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ កថាខណ្ឌ ៣០។ *មើល* សំណុំរឿង ០០២ ដីកាដំណោះស្រាយ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D427 កថាខណ្ឌ ១៣៨២។

[507] តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Stakic* IT-97-24-T សាលដីកាអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៣ កថាខណ្ឌ ២០១។

២១៥. ផ្អែកតាមការភ័ន្តច្រឡំទាំងនេះ ចៅក្រមទទួលបន្ទុកលើរឿងក្ដីយល់ថា ចាំបាច់ត្រូវមានការពិនិត្យ *ពេញច្បាប់*ថាតើការចោទប្រកាន់លើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅការដ្ឋានទំនប់ត្រពាំងថ្ម វត្តព្រះនេត្រព្រះ និងទីតាំងពាក់ព័ន្ធ មន្ទីរសន្តិសុខភូមិចក្រី ទីតាំងសម្លាប់ព្រៃតារ៉ុត និងមន្ទីរសន្តិសុខវត្តចំការខ្នុរ ត្រូវបានលើកឡើងសមស្រប ទៅតាមស្តង់ដារចាំបាច់សម្រាប់ការវាយតម្លៃភស្តុតាងក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) ឬទេ។

## *១. ការដ្ឋានទំនប់ត្រពាំងថ្ម*

២១៦. សហចៅក្រមស៊ើបអង្កេតបានទទួលយកការចោទប្រកាន់ ពាក់ព័ន្ធនឹងការដ្ឋានទំនប់ត្រពាំងថ្មក្នុងកថាខណ្ឌ ៧៨ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ ៖

> ទំនប់ត្រពាំងថ្មមានទីតាំងនៅក្នុងភូមិត្រពាំងថ្មខាងជើង ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។ អង្គហេតុមួយចំនួនដែលទាក់ទងទៅនឹងទីតាំងធ្វើការដោយបង្ខំនៅទំនប់ត្រពាំងថ្ម មានចែងនៅក្នុងកថាខណ្ឌទី ៤៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូង ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧។ ក្នុងតួនាទីជាលេខាស្រុក អ៊ឹម ចែម ទទួលស្គាល់ថា គាត់បានមើលការខុសត្រូវលើមនុស្សរាប់រយនាក់មកពីស្រុកព្រះនេត្រព្រះ ដែលពួកគេត្រូវបានបង្ខំឱ្យធ្វើការនៅតាមវាលស្រែ ក្បែរទំនប់ត្រពាំងថ្មនោះ។ ការងារនៅពេលថ្ងៃ មានរយៈពេលវែងយ៉ាងខ្លាំង ហើយកម្មករធ្វើការដោយបង្ខំទាំងអស់នោះ មានពេលសម្រាកតិចតួចណាស់។ របបអាហារគឺបបរមួយចាន់ក្នុងមួយថ្ងៃ[508]។

២១៧. ផ្អែកតាមការយល់ឃើញរបស់ចៅក្រមទទួលបន្ទុកលើរឿងក្ដី ការចោទប្រកាន់ទាំងនេះអាចស្មើនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់ជា *ក្នុងចំណោមបញ្ហាផ្សេងទៀត* ការធ្វើឱ្យទៅជាទាសករ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងទៀត[509]។ សហចៅក្រមស៊ើបអង្កេតបានទាញសេចក្ដីសន្និដ្ឋានតាមអង្គហេតុដោយទទួលស្គាល់ថា មនុស្សរាប់ពាន់នាក់ត្រូវបានបង្ខំឱ្យធ្វើការសាងសង់ទំនប់ និងបានស្លាប់ដោយសារជំងឺ ការអត់អាហារ ការហេវហត់ និងការកាប់សម្លាប់[510]។ ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតពិចារណាថា គេមិនអាចកំណត់បានត្រឹមត្រូវនូវចំនួនមនុស្សដែលបានធ្វើការ និងស្លាប់នៅទីនោះក្នុងវិសាលភាពពេលវេលាពាក់ព័ន្ធ[511] យល់ឃើញថា "មុខតំណែងជាក់លាក់របស់ អ៊ឹម ចែម ពុំ

[508] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ (D1) កថាខណ្ឌ ៧៨ (ជើងទំព័រត្រូវបានលុបចោល)។

[509] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ (D1) កថាខណ្ឌ ១១៩។

[510] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៧៤, ២៧៧។

[511] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៧៧-២៧៨។

បង្ហាញច្បាស់លាស់”[512] និងចុងបញ្ចប់ មិនបានធ្វើការកំណត់ផ្លូវច្បាប់លើការចោទប្រកាន់ពាក់ព័ន្ធនឹងការដ្ឋានទំនប់ត្រពាំងថ្មឡើយ។

២១៨. ដូចការលើកឡើងខាងលើ[513] ចៅក្រមទទួលបន្ទុកលើរឿងក្តី យល់ឃើញថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំក្នុងការតម្រូវឱ្យមានការកំណត់ចំនួនជនរងគ្រោះច្បាស់លាស់។ មានភស្តុតាងគ្រប់គ្រាន់ក្នុងការកំណត់ការប៉ាន់ស្មានសមហេតុផលអំពីចំនួនមនុស្សដែលត្រូវបានបង្ខំឱ្យធ្វើការ និងចុងបញ្ចប់បានស្លាប់នៅការដ្ឋាននោះក្រោមការគ្រប់គ្រងរបស់ អ៊ឹម ចែម និងកម្មាភិបាលភូមិភាគនិរតី ដូចជា នៅចន្លោះខែ មីនា ឆ្នាំ ១៩៧៧ និងខែ មករា ឆ្នាំ ១៩៧៩។

២១៩. ដំបូង ចៅក្រមទទួលបន្ទុកលើរឿងក្តីកត់សម្គាល់ថា ទំនប់ត្រពាំងថ្មត្រូវបានសាងសង់ឡើងទាំងស្រុងដោយការងារហត្ថកម្ម[514] ហើយការសាងសង់បានចាប់ផ្តើមនៅអំឡុងឆ្នាំ ១៩៧៦ ឬ ១៩៧៧ និងបានបន្តក្រោយការមកដល់របស់កម្មាភិបាលភូមិភាគនិរតី[515] នៅខែ មីនា ឆ្នាំ ១៩៧៧[516]។ ទោះបីជាមានភស្តុតាងបញ្ជាក់ថាផ្នែកដ៏សំខាន់មួយនៃទំនប់នេះអាចត្រូវបានបញ្ចប់ការសាងសង់នៅឆ្នាំ ១៩៧៧[517] ក្តី ក៏ការងារភាគច្រើន ដូចជា ការសាងសង់ស្ពាន[518] ប្រឡាយ និងទ្វារទឹក[519] និងការបញ្ចប់ការសាងសង់អាង

---

[512] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៧២-២៧៣។

[513] *សូមមើល កថាខណ្ឌ ២១៤ ខាងលើ* ។

[514] *សូមមើល ឧ.* សំណុំរឿង ០០៤/១ ឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពី អ៊ឹម ចែម ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧ ឯកសារ D123/1/5.1a, ERN (ភាសាខ្មែរ) 00929730។ *មើលផងដែរ* ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៧៤។ សំណុំរឿង ០០៤/១ របាយការណ៍លិខិតចាត់ឱ្យស៊ើបសួរជំនួស ៖ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ថ្ងៃទី ៦ ខែ មករា ឆ្នាំ ២០១០ ឯកសារ D6.1.710, ERN (ភាសាខ្មែរ) 00464719-00464720។

[515] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៧១។ *មើលផងដែរ* កថាខណ្ឌ ១៥២ កថាខណ្ឌ ១៥៤។

[516] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៥៦។

[517] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៧១។ *មើលផងដែរ* សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាន ចុល ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨ ឯកសារ D6.1.430, ERN (ភាសាខ្មែរ) 00267754។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម ផាន់ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ ឯកសារ D6.1.450, ERN (ភាសាខ្មែរ) 00279105។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ D119/98, ERN (ភាសាខ្មែរ) 00978910 (ឆ.១៩)។

[518] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប ណម ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D219/209 ERN (ភាសាខ្មែរ) 01074042 (ឆ.៣៨)។ សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឌិប ផល្លា ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ D5/1065, ERN (ភាសាខ្មែរ) 00993275។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយ

ស្តុកទឹក[520] បន្តរហូតដល់កងទ័ពវៀតណាមចូលមកដល់។ បច្ចុប្បន្ន អាងស្តុកទឹកនេះមានទំហំប្រហែល ៩ គីឡូម៉ែត្រ x ១៣ គីឡូម៉ែត្រ[521]។

២២០. ទោះក្រោមទទួលបន្ទុកលើរឿងក្តីបានគូសបញ្ជាក់បន្ថែមទៀតថា ចំនួនកម្មករទាំងនេះពាក់ព័ន្ធនឹងការប៉ាន់ប្រមាណចំនួនជនរងគ្រោះដោយសារឧក្រិដ្ឋកម្មផ្សេងៗនៅការដ្ឋានទំនប់ត្រពាំងថ្ម។ តា ញឹម ដែលជាកម្មាភិបាល ប.ក.ក បានអួតអាងនៅអំឡុងខែ កុម្ភៈ-ធ្នូ ឆ្នាំ ១៩៧៧ ថា កម្លាំងពលកម្មសរុប ១៥.០០០-២០.០០០ នាក់ត្រូវបាន "ប្រើប្រាស់" ក្នុងការសាងសង់គម្រោងនេះ[522]។ ភស្តុតាងផ្សេងទៀតបានបញ្ជាក់ថា មនុស្សរាប់ពាន់នាក់[523] ឬរាប់ម៉ឺននាក់[524] បានធ្វើការនៅការដ្ឋានត្រពាំងថ្ម បន្ទាប់ពីការមកដល់របស់ អ៊ឹម ចែម

---

សាក្សី កោ ឡឹន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ D119/98, ERN (ភាសាខ្មែរ) 0978910 (ឆ.១៩)។

[519] សំណុំរឿង ០០៤/១ ឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពី អ៊ឹម ចែម ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧ ឯកសារ D123/1/5.1a, ERN (ភាសាខ្មែរ) 00929735-00929736។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភី ភួន ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D119/68, ERN (ភាសាខ្មែរ)00969022-00969023 (ឆ.៦)។

[520] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D119/14, ERN (ភាសាខ្មែរ) 00893271 (ឆ.២៧)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភី ភួន ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D119/68, ERN (ភាសាខ្មែរ) 00969022-00969023 (ឆ.៦)។

[521] សំណុំរឿង ០០៤/១ របាយការណ៍លិខិតចាត់ឱ្យស៊ើបសួរជំនួស ៖ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ថ្ងៃទី ៦ ខែ មករា ឆ្នាំ ២០១០ ឯកសារ D6.1.710, ERN (ភាសាខ្មែរ) 00464720, 00464723។

[522] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាន ធុល ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨ ឯកសារ D6.1.430, ERN (ភាសាខ្មែរ) 00267753-00267754។ សំណុំរឿង ០០៤/១ សេចក្តីរាយការណ៍របស់ទីភ្នាក់ងារសារព័ត៌មានចិនអំពីដំណើរទស្សនកិច្ចរបស់លោកឧបនាយករដ្ឋមន្ត្រី Chen YUNG-KUEI មកកាន់ប្រទេសកម្ពុជា ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៧៧ ឯកសារ D6.1.992, KH ERN 00659260។

[523] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉េង ឆាន ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D119/132, ERN (ភាសាខ្មែរ) 00997307 (ឆ.៧៨ ឆ.៨០)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លើយ តើស ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ D219/361, ERN (ភាសាខ្មែរ) 01105587 (ឆ.៥០)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួរ ចាន់សារ៉េត ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ D219/455, ERN (ភាសាខ្មែរ) 01129809។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាច គា ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១១ ឯកសារ D59, ERN (ភាសាខ្មែរ) 00727218។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លីវ សាលាង ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ ឯកសារ D6.1.426, ERN (ភាសាខ្មែរ) 00267765។ សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី តាំង ហ៊ីវ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ D5/1250, ERN (ភាសាខ្មែរ) 01036240។

[524] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដាន់ ស ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩ ឯកសារ D6.1.449, ERN (ភាសាខ្មែរ) 00279083។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម ផាន់ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩

ម និងកម្មាភិបាលភូមិភាគនីរតី។ ប៉ាន ឈ្លួង បានលើកឡើងថា មានមនុស្សប្រហែល ៧.៨០០-៩.០០០ នាក់មកពីកងចល័តតំបន់ ៥ សុទ្ធសាធ ធ្វើការនៅទំនប់នេះតាំងពីដើមឆ្នាំ ១៩៧៧ និងរហូតដល់ការគ្រប់គ្រងដោយកម្មាភិបាលភូមិភាគនីរតី បូករួមនឹងមនុស្សរាប់ពាន់នាក់បន្ថែមទៀតមកពីកងចល័តនៅស្រុកផ្សេងទៀត[525]។ អ៊ឹម ចែម និងសាក្សីជាច្រើន រាយការណ៍ថាមានកម្មករមកពីស្រុកផ្សេងៗក្នុងតំបន់ ៥ រួមទាំង ស្រុកព្រះនេត្រព្រះ[526]។

---

ឯកសារ D6.1.450, ERN (ភាសាខ្មែរ) 00279105។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុត សួយ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ D119/144, ERN (ភាសាខ្មែរ) 01009206 (ឆ.៣៣)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ D219/130, ERN (ភាសាខ្មែរ) 01049237 (ឆ.១០៧), ERN (ភាសាខ្មែរ) 01049242 (ឆ.១៥៦)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យី ឡៃស្រូវ ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០០៩ ឯកសារ D6.1.343, ERN (ភាសាខ្មែរ) 00279133។ សំណុំរឿង ០០៤/១ បទសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ពេជ្រ ហម ថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០០៧ ឯកសារ D123/1/1.6a, ERN (ភាសាខ្មែរ) 00057724។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លិវ ពៅ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៨ ឯកសារ D6.1.427, ERN (ភាសាខ្មែរ) 00267760។

[525] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាន ឈ្លួង ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D119/29, ERN (ភាសាខ្មែរ) 00895157 (ឆ.២), ERN (ភាសាខ្មែរ) 00895160 (ឆ.៩)។ *មើលផងដែរ* សំណុំរឿង ០០៤/១ របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីដំណើរចុះកម្មសិក្សាទៅស្រុកព្រះនេត្រព្រះ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ D119/148.1, ERN (ភាសាខ្មែរ) 01477766។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម ហុង ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ D119/47, ERN (ភាសាខ្មែរ) 00933093 (ឆ.៩)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សម ស័ក្ក ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D119/120, ERN (ភាសាខ្មែរ) 00984311 (ឆ.៥៩), ERN (ភាសាខ្មែរ) 00984319 (ឆ.១២៥)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាន ឈ្លួង ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១១ ឯកសារ D61, ERN (ភាសាខ្មែរ) 00727221-00727222។ សំណុំរឿង ០០៤/១ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាន ឈ្លួង ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ D67.6, ERN (ភាសាខ្មែរ)00734069-00734071។

[526] សំណុំរឿង ០០៤/១ ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពី អ៊ឹម ចែម ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧ ឯកសារ D123/1/5.1a, ERN (ភាសាខ្មែរ) 00929729-00929731។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សម ស័ក្ក ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D119/120, ERN (ភាសាខ្មែរ) 00984219 (ឆ.១២២)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការ ស្តាប់ចម្លើយសាក្សី ប៉ាន ឈ្លួង ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D119/29, ERN (ភាសាខ្មែរ) 00895157 (ឆ.២), ERN (ភាសាខ្មែរ) 00895159-00895160 (ឆ.៨)។ សំណុំរឿង ០០៤/១ របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីដំណើរចុះកម្មសិក្សាទៅស្រុកព្រះនេត្រព្រះ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ D119/148.1, ERN (ភាសាខ្មែរ) 01477766។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គន់ ថាន ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ ឯកសារ D6.1.425, ERN (ភាសាខ្មែរ) 00267782។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ ជួង ថ្ងៃទី ២០

២២១. លើសពីនេះទៀត ចៅក្រមទទួលបន្ទុករឿងក្តី កត់សម្គាល់ចំពោះភស្តុតាងថា ពលកម្មដោយបង្ខំ ព្រមទាំងលក្ខខណ្ឌរស់នៅនិងធ្វើការអមនុស្សធម៌ មានសភាកាន់តែធ្ងន់ធ្ងរឡើង បន្ទាប់ពីការមកដល់របស់ អ៊ឹម ចែម និងកម្មាភិបាលភូមិភាគនិរតី[527]។ ផង ធឿយ ដែលបានឃើញ អ៊ឹម ចែម កំពុងពិនិត្យការដ្ឋានជាមួយសន្តិសុខដែលប្រដាប់ដោយអាវុធម្តងក្នុងមួយសប្តាហ៍នោះ [528] បានប៉ាន់ប្រមាណថា មនុស្សជិត ១០០ នាក់បានស្លាប់ដោយសារការអត់អាហារ[529]។ សាក្សីផ្សេងទៀតជាទូទៅបានបញ្ជាក់ថា "មនុស្សជាច្រើន" បានស្លាប់ដោយសារមូលហេតុនានាដូចជា អត់អាហារ ជំងឺ និងបាក់កម្លាំង[530]។

---

ខែ មករា ឆ្នាំ ២០១៤ ឯកសារ D119/73, ERN (ភាសាខ្មែរ) 00971120 (ឆ.៥)។

[527] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លើយ តើស ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ D219/361, ERN (ភាសាខ្មែរ) 01105586 (ឆ.៤៤) និង, ERN (ភាសាខ្មែរ) 01105591 (ឆ.៩០)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម សីលា ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ D219/35, ERN (ភាសាខ្មែរ) 01032084 (ឆ.៤៣)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហង់ ហោន ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D219/175, ERN (ភាសាខ្មែរ) 01066001 (ឆ.២៧)។ សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អៀម វុយ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D5/962, ERN (ភាសាខ្មែរ) 00989804-00989806។ *សូមមើលផងដែរ* សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថូយ ចៀម ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D5/1089, ERN (ភាសាខ្មែរ) 01024379។

[528] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D119/131, ERN (ភាសាខ្មែរ) 00996503 (ឆ.៩៥-ឆ.៩៦) និង 00996504 (ឆ.១០០)។

[529] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D119/131, ERN (ភាសាខ្មែរ) 00996505-00996506 (ឆ.១១៤-ឆ.១១៥)។ *សូមមើលផងដែរ* សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រីក ធួង ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D5/1033, ERN (ភាសាខ្មែរ) 00991263។

[530] *សូមមើល* សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សម ស័ក្ក ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D119/120, ERN (ភាសាខ្មែរ) 00984321 (ឆ.១៤៥-ឆ.១៤៦)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ីម លាង ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០០៩ ឯកសារ D6.1.344, ERN (ភាសាខ្មែរ) 00279111។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លីវ សាលាង ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ ឯកសារ D6.1.426, ERN (ភាសាខ្មែរ) 00267765។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លិវ ពៅ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៨ ឯកសារ D6.1.427, ERN (ភាសាខ្មែរ) 00267761។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ D219/130, ERN (ភាសាខ្មែរ) 01049238 (ឆ.១២៤-ឆ.១២៥)។

01575557



២២២. បន្ថែមលើនេះទៀត មានភស្តុតាងដែលបង្ហាញថា ការចាប់ខ្លួន ការបាត់ខ្លួន និងការសម្លាប់ កើតមានសាមញ្ញនៅការដ្ឋានទំនប់ត្រពាំងថ្ម[531] និងបានកើនឡើងបន្ទាប់ពីកម្មាភិបាលភូមិភាគនិរតីបានមកដល់[532]។ លីវ សាលាង, នៅ ចាត់ និង គក់ ប៊ុយ បានពិពណ៌នាអំពីរបៀបដែលមនុស្សពីពីរ ទៅ ១៥ នាក់បានបាត់ខ្លួនរៀងរាល់យប់ ឬរៀងរាល់ពីរបីយប់ម្តង [533] ដែលទំនងជាស្ថិតក្រោមការគ្រប់គ្រងរបស់កម្មាភិបាលភូមិភាគនិរតី។ លិវ ពៅ បានរាយការណ៍ជាក់លាក់ថា មនុស្ស ១៥ នាក់បានបាត់ខ្លួនពីកងរបស់គាត់ក្នុងយប់

---

[531] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ D219/130, ERN (ភាសាខ្មែរ) 01049240 (ឆ.១៤១ ឆ.១៤៣) 01049241 (ឆ.១៥៤)។ សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ៅ វង់ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D5/897, ERN (ភាសាខ្មែរ) 00974335។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាំង ញ៉ម ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ ឯកសារ D6.1.451, ERN (ភាសាខ្មែរ) 00279122- 00279123។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ៃ កើត ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៩ ឯកសារ D6.1.452, ERN (ភាសាខ្មែរ) 00279098។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គន់ ថាន ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ ឯកសារ D6.1.425, ERN (ភាសាខ្មែរ) 00267783-00267784។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម ផាន់ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ ឯកសារ D6.1.450, ERN (ភាសាខ្មែរ) 00279104-00279105 ។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ភាព ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/90, ERN (ភាសាខ្មែរ) 00976140-00976141 (ឆ.១១)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លើយ តើស ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ D219/361, ERN (ភាសាខ្មែរ) 01105587 (ឆ.៥១) និង, ERN (ភាសាខ្មែរ) 01105587 (ឆ.៥៣)។ សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គាំ បុប្ផា ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D5/1045, ERN (ភាសាខ្មែរ) 00991793។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ ជួង ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤ ឯកសារ D119/73, ERN (ភាសាខ្មែរ) 00971121 (ឆ.១២-ឆ.១៣) និង, ERN (ភាសាខ្មែរ) 00971122 (ឆ.១៨)។

[532] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៧៦។ *សូមមើលផងដែរ* សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លើយ តើស ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ D219/361, ERN (ភាសាខ្មែរ) 01105588 (ឆ.៦៣) និង 01105590 (ឆ.៨៥)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ D219/130, ERN (ភាសាខ្មែរ) 01049241 (ឆ.១៥៣)។ សំណុំរឿង ០០៤/១ បទសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ពេជ្រ ហម ថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០០៧ ឯកសារ D123/1/1.6a, ERN (ភាសាខ្មែរ) 00057719។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហង់ ហោន ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D219/175, ERN (ភាសាខ្មែរ) 01066001 (ឆ.២៨)។

[533] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លីវ សាលាង ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ ឯកសារ D6.1.426, ERN (ភាសាខ្មែរ) 00267766។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ D219/130, ERN (ភាសាខ្មែរ) 01049241 (ឆ.១៥៥)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គក់ ប៊ុយ ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១២ ឯកសារ D106/9, ERN (ភាសាខ្មែរ) 00801010 (ឆ.២៦)។

មួយក្នុងអំឡុងពេលពាក់ព័ន្ធ[534]។ យី ឡៃសួរ ក៏បានមើលឃើញផងដែរនូវមនុស្សពី ១៥ ទៅ ២០ នាក់ត្រូវបានគេចាប់យកចេញទៅក្នុងពេលបីផ្សេងគ្នា[535] ខណៈដែល ស៊ឹម លាង និង កាន ផុល បានឃើញមនុស្សកំពុងត្រូវបានគេយកចេញក្នុងពេលដែលពួកគេត្រូវបានគេចងស្លាបសេក[536]។ លើសពីនេះទៀត គាំ បុប្ផា បានពិពណ៌នាអំពីកិច្ចប្រជុំមួយនៅចុងឆ្នាំ ១៩៧៧ ឬដើមឆ្នាំ ១៩៧៨ ក្នុងអំឡុងពេលដែល អ៊ឹម ចែម បានបញ្ជូនមនុស្សប្រាំមួយឡានពីការដ្ឋានយកទៅសម្លាប់នៅភ្នំត្រយ៉ូង[537] ខណៈដែល ប៊ិន ហឿយ បានរម្លឹកពីកិច្ចប្រជុំមួយដែលដឹកនាំដោយ អ៊ឹម ចែម និង តា ម៉ុក ក្នុងឆ្នាំ ១៩៧៨ ក្នុងអំឡុងពេលដែល មនុស្សពី ៨០ ទៅ ៩០ នាក់ត្រូវបានដឹកយកទៅសម្លាប់ និងកប់នៅត្រើះទំនប់[538]។ ក៏មានភស្តុតាងផងដែរថា ស្ត្រីមានផ្ទៃពោះយ៉ាងហោចណាស់ ៥ នាក់ត្រូវបានសម្លាប់ និងកប់នៅស្ពានរបស់ទំនប់នេះក្នុងឆ្នាំ ១៩៧៧ ដែលធ្វើឡើងទៅតាមបញ្ជារបស់ អ៊ឹម ចែម[539]។ យ៉េង ឆាន បានរម្លឹកពីសាកសពចំនួនពីរដែលត្រូវបានកប់នៅពីមុខទ្វារទឹករបស់ទំនប់[540] ខណៈដែល ប៉ៅ វង់ បានឃើញគេសម្លាប់មនុស្សនៅស្ពានទីមួយជាច្រើនដងក្នុងឆ្នាំ ១៩៧៨

---

[534] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លិវ ពៅ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៨ ឯកសារ D6.1.427, ERN (ភាសាខ្មែរ) 00267761-00267762។

[535] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យី ឡៃសួរ ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០០៩ ឯកសារ D6.1.343, ERN (ភាសាខ្មែរ) 00279134។

[536] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម លាង ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០០៩ ឯកសារ D6.1.344, ERN (ភាសាខ្មែរ) 00279110។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាន ផុល ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨ ឯកសារ D6.1.430, ERN (ភាសាខ្មែរ) 00267754។

[537] សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គាំ បុប្ផា ថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ២០១៣ ឯកសារ D5/1045, ERN (ភាសាខ្មែរ) 00991793-00991794។

[538] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន ហឿយ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D119/66, ERN (ភាសាខ្មែរ) 00969016-00969017 (ឆ.១៥)។

[539] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D119/131, ERN (ភាសាខ្មែរ) 00996502-00996503 (ឆ.៨៣-ឆ.៩០)។ *សូមមើលផងដែរ* សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យី ឡៃសួរ ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០០៩ ឯកសារ D6.1.343, ERN (ភាសាខ្មែរ) 00279134។ សំណុំរឿង ០០៤/១ ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០២ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ D219/494.1.11 ទំព័រ ៤២, ៤៤, ៦១។ សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នុន ឌុល ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D5/1032, ERN (ភាសាខ្មែរ) 00991243។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ D219/130, ERN (ភាសាខ្មែរ) 01049242 (ឆ.១៦១)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លីវ សាលាង ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ ឯកសារ D6.1.426, ERN (ភាសាខ្មែរ) 00267766។

[540] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉េង ឆាន ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D119/132,

រួមទាំងការសម្លាប់ម្តងរហូតដល់ដប់នាក់ក៏មាន[541]។ ជាចុងក្រោយ ថង ធឿយ បានរម្លឹកថា មនុស្សដែលដួលដោយសារអស់កម្លាំង ត្រូវបានវាយធ្វើបាប និងយកទៅសម្លាប់ ទៅតាមបញ្ជារបស់ អ៊ឹម ចែម នៅខាងជើងទំនប់[542]។

២២៣. ទាក់ទងនឹងរឿងរ៉ាវខាងលើ ចៅក្រមទទួលបន្ទុករឿងក្តីយល់ឃើញថា តាមស្តង់ដារចាំបាច់ មានការយល់ឃើញគ្រប់គ្រាន់ថា យ៉ាងហោចណាស់ មនុស្សរាប់ពាន់នាក់ និងរហូតដល់រាប់ម៉ឺននាក់ គឺជាជនរងគ្រោះនៃពលកម្មដោយបង្ខំ និងអំពើអមនុស្សធម៌ផ្សេងទៀត រួមទាំងលក្ខខណ្ឌរស់នៅ និងធ្វើការអមនុស្សធម៌ នៅការដ្ឋានទំនប់ត្រពាំងថ្មចាប់ពីប្រហែលខែ មីនា ឆ្នាំ ១៩៧៧ រហូតដល់ដើមឆ្នាំ ១៩៧៩ *ពោលគឺ* ក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់ អ៊ឹម ចែម ក្នុងឋានៈជាលេខាស្រុកព្រះនេត្រព្រះ និងសមាជិកគណៈតំបន់ ៥[543]។ ដោយការថ្លឹងថ្លែងពីភាពដែលអាចទៅរួច ភ័ស្តុតាងក៏បង្ហាញគ្រប់គ្រាន់ផងដែរថា មនុស្សត្រូវបានចាប់ខ្លួន បាត់ខ្លួនដោយបង្ខំ និងសម្លាប់នៅការដ្ឋានទំនប់ត្រពាំងថ្មក្នុងអំឡុងពេលពាក់ព័ន្ធ ដោយជនរងគ្រោះមានចំនួនរហូតដល់រាប់រយ ឬរាប់ពាន់នាក់។

២២៤. ពាក់ព័ន្ធនឹងតួនាទីរបស់ អ៊ឹម ចែម ចៅក្រមទទួលបន្ទុករឿងក្តី រម្លឹកឡើងវិញថា អ៊ឹម ចែម បានក្លាយជាលេខាស្រុកព្រះនេត្រព្រះនៅក្នុងខែ មីនា ឆ្នាំ ១៩៧៧ និងសមាជិកគណៈកម្មាធិការតំបន់ ៥ នៅដើម ឬពាក់កណ្តាលឆ្នាំ ១៩៧៨[544]។ អ៊ឹម ចែម ខ្លួនគាត់បានទទួលស្គាល់ថា គាត់បានបញ្ជូនកម្មករទៅការដ្ឋានទំនប់ត្រពាំងថ្ម និងបន្តគ្រប់គ្រងពួកគេនៅទីនោះ[545] ដូចដែលត្រូវបានបញ្ជាក់ដោយសាក្សីមួយចំនួន[546]

ERN (ភាសាខ្មែរ) 00997304 (ឆ.៥៦)។

[541] សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ៅ វង់ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D5/897, ERN (ភាសាខ្មែរ) 00974336។

[542] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D119/131, ERN (ភាសាខ្មែរ) 00996506-00996507 (ឆ.១២០-ឆ.១២៤)។

[543] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៦៦។

[544] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៥៨ កថាខណ្ឌ ១៦៦។

[545] សំណុំរឿង ០០៤/១ ឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពី អ៊ឹម ចែម ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧ ឯកសារ D123/1/5.1a, ERN (ភាសាខ្មែរ) 00929731-00929732 និង 00929737-00929738។ សំណុំរឿង ០០៤/១ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ជាមួយផលិតកម្ម Smiling Toad Productionsថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ ឯកសារ D1.3.12.1, ERN (ភាសាខ្មែរ) 00234198 ។

[546] សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រីក ធួង ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D5/1033,

ដែលបានរាយការណ៍ថា គាត់បានធ្វើអធិការកិច្ចនៅការដ្ឋានម្តងក្នុងមួយសប្តាហ៍[547] ។ អ៊ឹម ចែម ក៏បានរៀបចំ និងធ្វើជាអធិបតីក្នុងកិច្ចប្រជុំនានានៅការដ្ឋាន[548] ដាក់កូតា[549] និងមានវត្តមាននៅពេលដែល ប៉ុល ពត និង ខៀវ សំផន បានធ្វើដំណើរទស្សនកិច្ចទៅកាន់ទំនប់[550] ។ លើសពីនេះទៀត ដូចដែលបានកត់សម្គាល់ខាងលើ អ៊ឹម ចែម បានចេញបញ្ជាទៅកាន់ឃោធាតំបន់ ៥ ដែលបានដើរល្បាតការដ្ឋាន[551] ឱ្យវាយធ្វើបាប និងចាប់មនុស្សដែលបានដួលដោយសារអស់ខ្លាំងខ្លាំង[552] ។ ដោយការថ្លឹងថ្លែងពីភាពដែលអាចទៅ

---

ERN (ភាសាខ្មែរ) 00991263-00991263។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/94, ERN (ភាសាខ្មែរ) 00976178-00976179 (ឆ. ២៩-ឆ.៣១)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម អេន ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ D119/124, ERN (ភាសាខ្មែរ) 00987268 (ឆ. ១៦-ឆ. ១៩)។

[547] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ D219/130, ERN (ភាសាខ្មែរ) 01049237 (ឆ.១០៩) 01049242 (ឆ. ១៥៦)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ភាព ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/90, ERN (ភាសាខ្មែរ) 00976141 (ឆ.១២-ឆ.១៣)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លើយ តើស ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ D219/361, ERN (ភាសាខ្មែរ) 01105589 (ឆ.៧៣-ឆ.៧៤) ។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D119/131, ERN (ភាសាខ្មែរ) 00996503 (ឆ.៩៥-ឆ.៩៦)។

[548] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លើយ តើស ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ D219/361, ERN (ភាសាខ្មែរ) 01105589 (ឆ.៧៥-ឆ.៧៨) ។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាច គា ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១១ ឯកសារ D59, ERN (ភាសាខ្មែរ) 00727218។

[549] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លើយ តើស ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ D219/361, ERN (ភាសាខ្មែរ) 01105589 (ឆ.៧៦) និង 01105590-01105591 (ឆ.៨៧-៨៩)។ *សូមមើលផងដែរ* ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៧៣។

[550] សំណុំរឿង ០០៤/១ ឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពី អ៊ឹម ចែម ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧ ឯកសារ D123/1/5.1a, ERN (ភាសាខ្មែរ) 00929741។

[551] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថង ធឿយ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D119/131, ERN (ភាសាខ្មែរ) 00996506 (ឆ.១១៦-ឆ.១១៨) និង 00996506 (ឆ.១២១)។

[552] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៧៣។ *សូមមើលផងដែរ* សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថង ធឿយ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D119/131, ERN (ភាសាខ្មែរ) 00996506-00996507 (ឆ .១១៨-ឆ.១២៤)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លើយ តើស ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ D219/361, ERN (ភាសាខ្មែរ) 01105591 (ឆ.៩១-ឆ.៩២)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ D219/130, ERN (ភាសាខ្មែរ) 01049239 (ឆ.១២៨-ឆ.១៣១) 01049241 (ឆ. ១៥២-ឆ.១៥៣)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ

រួច ភស្តុតាងជារួមបង្ហាញយ៉ាងគ្រប់គ្រាន់ថា អ៊ឹម ចែម មានអំណាចលើបុគ្គលិកយោធាដែលបានឈរជើងប្រចាំការនៅទំនប់នេះ [553] និងថា យ៉ាងហោចណាស់ គាត់គឺជាកម្មាភិបាលម្នាក់ក្នុងចំណោមកម្មាភិបាលដែលទទួលបន្ទុកលើការដ្ឋានទំនប់ត្រពាំងថ្ម[554]។

២២៥. ហេតុដូចនេះ ចៅក្រមទទួលបន្ទុកលើរឿងក្តីយល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់ដែលថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ និងអំពើអមនុស្សធម៌ផ្សេងទៀត ត្រូវបានប្រព្រឹត្តនៅការដ្ឋានទំនប់ត្រពាំងថ្មក្នុងអំឡុងពេលពាក់ព័ន្ធ ដែលមានជនរងគ្រោះរាប់រយ ឬរាប់ពាន់នាក់ ហើយថា អ៊ឹម ចែម អាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ។ ចៅក្រមទទួលបន្ទុករឿងក្តីចាត់ទុកថា ការចោទប្រកាន់ទាំងនេះគួរត្រូវបានបញ្ចូលក្នុងបទចោទប្រកាន់ និងគួរត្រូវបានពិចារណាឱ្យបានត្រឹមត្រូវក្នុងការវាយតម្លៃយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក លើ អ៊ឹម ចែម។ ការបកស្រាយថាតើកំហុសទាំងនេះគឺ ជាកត្តាកំណត់ជាមូលដ្ឋាននៃការសម្រេចបែបនោះ នឹងត្រូវបានបង្ហាញដូចខាងក្រោម។

### ២. វត្តព្រះនេត្រព្រះ និងទីតាំងពាក់ព័ន្ធ

២២៦. នៅក្នុងកថាខណ្ឌ ៧៧ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ សហចៅក្រមស៊ើបអង្កេតបានទទួលការចោទប្រកាន់ទាក់ទងនឹងវត្តព្រះនេត្រព្រះ រួមទាំងមន្ទីរពេទ្យនៅជាប់គ្នានឹងទីតាំងសម្លាប់ចំការតាឡឹង ៖

---

D119/94, ERN (ភាសាខ្មែរ) 00976178 (ឆ.២៩)។

[553] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ D119/130, ERN (ភាសាខ្មែរ) 00989348 (ឆ.៨៧)។

[554] សំណុំរឿង ០០៤/១ ឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពី អ៊ឹម ចែម ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧ ឯកសារ D123/1/5.1a, ERN (ភាសាខ្មែរ) 00929730-00929731។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លើយ គើស ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ D219/361, ERN (ភាសាខ្មែរ) 01105593 (ឆ.១០៤)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង វុន ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D118/153, ERN (ភាសាខ្មែរ) 00968038 (ឆ.៥៩)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាច គា ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១១ ឯកសារ D59, ERN (ភាសាខ្មែរ) 00727218-00727218។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈួន ចាន់រីន ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ D219/474, ERN (ភាសាខ្មែរ) 01134118-01134119 (ឆ. ១៩)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម អេន ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ D119/124, ERN (ភាសាខ្មែរ) 00987268 (ឆ. ១៨)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ឈួក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ D119/52, ERN (ភាសាខ្មែរ) 00933130 (ឆ. ១២)។



PRE-TRIAL CH... E.C.C.C

01575562



ដោយមានមន្ទីរពេទ្យមួយ និងទីតាំងសម្លាប់ជាប់គ្នានោះនៅចំការតាឡឹង វត្តព្រះនេត្រព្រះ រួមមានទីតាំងរណ្ដៅសាកសពចំនួន ៦ ដែលត្រូវបានគាស់រួច។ ការប៉ាន់ស្មានដំបូងៗពីរណ្ដៅសាកសពបានឲ្យដឹងថា មានប្រជាជនប្រមាណជា ៧០០ នាក់ ត្រូវបានសម្លាប់នៅទីនេះ ទោះជាសាកសពខ្លះ អាចត្រូវបានដុតនៅក្នុងទីតាំងទាំងពីរនេះក៏ដោយ។ សាក្សីម្នាក់បានបញ្ជាក់ថា "គណៈឃុំរបស់ ប៉ុល ពត" បានប្រើប្រាស់ផ្ទះមួយនៅក្បែរវត្តព្រះនេត្រព្រះ និងថា អ្នកទោសត្រូវបានគេឃុំនៅក្នុងផ្ទះនោះ មុនពេលត្រូវបាននាំយកទៅសម្លាប់ចោលនៅចំការតាឡឹង។ មានរបាយការណ៍មួយបានកំណត់អត្តសញ្ញាណនៃអដ្ឋិធាតុទាំងនោះថាភាគច្រើនជាអដ្ឋិធាតុរបស់មនុស្សប្រុសពេញវ័យ មានអាយុក្រោម ៤៥ ឆ្នាំ ដែលតាមទំនងបំផុតនោះ គឺជាអ្នកជម្លៀសមកពីភ្នំពេញ[555]។

២២៧. ចៅក្រមទទួលបន្ទុកលើរឿងក្ដីយល់ឃើញថា ការចោទប្រកាន់ទាំងនេះអាចស្មើនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់ជា *ក្នុងចំណោមបញ្ហាផ្សេងទៀត* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ និងអំពើអមនុស្សធម៌ផ្សេងទៀត[556] ។ ចៅក្រមទទួលបន្ទុកលើរឿងក្ដីក៏រកឃើញផងដែរថា ផ្ទះរបស់ តា ក្រក និងកន្លែងសម្លាប់នៅចម្ការដូង និងចម្ការ ដែលជិតនឹងផ្ទះនោះ អាចត្រូវបានចាត់ទុកថាជាកន្លែងដែលមានព្រឹត្តិការណ៍ឧក្រិដ្ឋកម្មពាក់ព័ន្ធបានកើតឡើង [557] ។ តាមរយៈការពិនិត្យមើលឡើងវិញដោយសង្ខេបលើភស្តុតាង សហចៅក្រមស៊ើបអង្កេតបានទទួលស្គាល់ថា មនុស្សត្រូវបានឃុំខ្លួន និងសម្លាប់ ឬស្លាប់ដោយការអត់អាហារ ឬជំងឺនៅវត្តព្រះនេត្រព្រះ និងកន្លែងពាក់ព័ន្ធនានារបស់វត្តនេះ ក្រោមការគ្រប់គ្រងរបស់កម្មាភិបាលភូមិភាគនិរតី ដោយមានការសម្លាប់ស្ទើរតែរាល់យប់ក្នុងអំឡុងខែចុងក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យ[558] ។ ទោះបីជាយ៉ាងណាក៏ដោយ សហចៅក្រមស៊ើបអង្កេតមិនបានកំណត់តាមផ្លូវច្បាប់ឲ្យបានត្រឹមត្រូវចំពោះការចោទប្រកាន់ទាំងនេះ ដោយកត់សម្គាល់ថា "ពុំឃើញមានភស្តុតាងបង្ហាញច្បាស់លាស់ថាតើ មានមនុស្សប៉ុន្មាននាក់ដែលបានស្លាប់នៅទីនោះ" និង "ពុំឃើញមានភស្តុតាងផ្ទាល់បង្ហាញការចូលរួមពាក់ព័ន្ធរបស់ អ៊ឹម ចែម ជាមួយនឹងការស្លាប់ និងការចាប់ខ្លួននៅទីតាំងនេះ" [559]។

---

[555] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី ៣ (D1) កថាខណ្ឌ ៧៧ (ជើងទំព័រត្រូវបានលុបចោល)។

[556] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី ៣ (D1) កថាខណ្ឌ ១១៩។

[557] *មើល* សំណុំរឿង ០០៤/១ របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D119/46, ERN (ភាសាខ្មែរ) 00945877-00945878។ សំណុំរឿង ០០៤/១ របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D106/12, ERN (ភាសាខ្មែរ) 00788227។ *មើលផងដែរ* ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៥៥-២៥៨។

[558] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៥២-២៥៩។

[559] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៥៩។

២២៨. ចៅក្រមទទួលបន្ទុកលើរឿងក្តីបញ្ជាក់សាជាថ្មីថា សហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្តកំហុស ដោយបានទាមទារឲ្យបង្ហាញចំនួនមនុស្សស្លាប់ជាក់លាក់[560]។ ចៅក្រមទទួលបន្ទុកលើរឿងក្តីកត់សម្គាល់ថា មានភស្តុតាងគ្រប់គ្រាន់ ដែលប្រមូលបានក្នុងអំឡុងកិច្ចស៊ើបសួរ ដែលបង្ហាញថា មនុស្សត្រូវគេសម្លាប់ក្នុង បរិវេណវត្តព្រះនេត្រព្រះ។ ថ្វីត្បិតតែរបាយការណ៍ ឆ្នាំ ១៩៩៧ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទុកនូវ តួលេខចម្រូងចម្រាសអំពីចំនួនមនុស្សស្លាប់នៅទីតាំងនោះក៏ដោយ ក៏ចៅក្រមទទួលបន្ទុកលើរឿងក្តីយល់ ឃើញថា ការប៉ាន់ប្រមាណអំពីចំនួន ៦៦០-៧២០ ដោយផ្អែកលើចម្លើយរបស់ ទុំ សឺន មានភាពគ្រប់គ្រាន់ ដើម្បីបង្ហាញឲ្យហួសពីវិមតិសង្ស័យថា យ៉ាងហោចណាស់ ជនរងគ្រោះរាប់រយនាក់ត្រូវបានកប់នៅចម្ការ តាឡឹង[561]។ សុស ណារិន អនុប្រធានភូមិប៉ោយក្អៀង បានរៀបរាប់ថា គាត់បានឃើញគេសម្លាប់មនុស្ស ៤ នាក់នៅវត្តព្រះនេត្រព្រះ[562]។ សាក្សីជាច្រើននៅតែចងចាំជានិច្ចនូវការសម្លាប់ សឿន និង ពៅ ជាសាធារ ណៈនៅមុខវត្ត ដោយសារតែបានប្រព្រឹត្ត "ខុសសីលធម៌" ក្នុងឆ្នាំ ១៩៧៧ ឬឆ្នាំ ១៩៧៨[563]។

---

[560] *សូមមើលខាងលើ* កថាខណ្ឌ ២១៣ ។

[561] សំណុំរឿង ០០៤/១ មជ្ឈមណ្ឌលឯកសារកម្ពុជា៖ ការចុះកំណត់ទីតាំងរណ្តៅឃាតកម្មក្នុងប្រទេសកម្ពុជានៅលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ ឯកសារ D1.3.10.10, ERN (ភាសាខ្មែរ) 00750665, 00750677-00750678។ សូមមើលផង ដែរ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ស៊ិន ឃិន ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D219/205, ERN (ភាសាខ្មែរ) 01072293 (ឆ.២៨-ឆ.២៩)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D106/11, ERN (ភាសាខ្មែរ) 00787415-00787416។ សំណុំរឿង ០០៤/១ ស្រុកព្រះនេត្រព្រះ ស្ថិតិប្រាសាទបុរាណ-ស្តូបអដ្ឋិធាតុ និងសិល្បៈមហាជនរបស់គណៈកម្មការមន្ទីរឃោសនាការ វប្បធម៌-ព័ត៌មានខេត្តបាត់ដំបង លេខ ៧១១ ឃវពខ ចុះ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៨៤ ឯកសារ D119/50.2, ERN (ភាសាខ្មែរ) 00933219។

[562] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ សុស ណារិន ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D119/38, ERN (ភាសាខ្មែរ) 00915848 (ឆ.៤)។

[563] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ គ្រិត រិត ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D119/42, ERN (ភាសាខ្មែរ) 00915872 (ឆ.៩)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ មុំ ឈួក ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ D119/52, ERN (ភាសាខ្មែរ) 00933132 (ឆ.២១)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ រស់ ចុះថ្ងៃ ទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ D119/99, ERN (ភាសាខ្មែរ) 00978921 (ឆ.២០-ឆ.២១)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ឈឹម ផន ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ D219/347, ERN (ភាសាខ្មែរ) 01103341 (ឆ.៤)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ទារ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ D119/152, ERN (ភាសាខ្មែរ) 01024726 (ឆ.១៥)។ សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណីរបស់ ថង ធឿយ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D5/853, ERN (ភាសាខ្មែរ) 00956904។ សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមប ណ្តឹងរដ្ឋប្បវេណីរបស់ ធិម សុវណ្ណី ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D5/969, ERN (ភាសាខ្មែរ) 00989915។

២២៩. មានភស្តុតាងផងដែរអំពីឧក្រិដ្ឋកម្ម ប្រព្រឹត្តនៅផ្ទះតាក្រក ដែលត្រូវគេប្រើជាមន្ទីឃុំឃាំង[564]។ អ្នកទោសអាចត្រូវគេសម្លាប់នៅទីធ្លាខាងមុខ ឬនៅកន្លែងសម្លាប់មនុស្សជិតៗនោះ[565] ។ ក្រិត រិត បាននឹកឃើញថា គាត់បានឃើញកម្មាភិបាលនារីភូមិភាគនិរតីបណ្តើរអ្នកដែលគេចាប់បានទាំងខ្សែៗយកទៅសម្លាប់[566] រីឯ ណារ ឯក បានឃើញកម្មាភិបាលនារីសម្លាប់មនុស្សជាច្រើននៅទីនោះ នៅថ្ងៃមួយជិតដល់ទីបញ្ចប់នៃរបបនោះ[567]។ ប៉ោ បណ្តែត បានចងចាំថា គេយកមនុស្សទៅសម្លាប់ រៀងរាល់យប់ នៅចុងឆ្នាំ ១៩៧៧[568] ហើយ សុង ផារ៉ាត់ បានអះអាងដូចគ្នានេះដែរថា មនុស្សកាន់តែច្រើនឡើងៗត្រូវគេយកទៅ

---

សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៉ាក់ ស៊ីលឿត ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D5/984, ERN (ភាសាខ្មែរ) 00990158-00990159។ សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឡាំ ប៊ុនសួយ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D5/986, ERN (ភាសាខ្មែរ) 00990189-00990190។ សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឡាំ បុផ្ផា ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D5/989, ERN (ភាសាខ្មែរ) 00990238។ សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ កេតុ សាវ៉ន ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ D5/1254, ERN (ភាសាខ្មែរ) 01036312-01036313។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ សុស ណារិន ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D119/38, ERN (ភាសាខ្មែរ) 00915847 (ឆ.៣)។ សំណុំរឿង ០០៤/១ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឈឹម ផន ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១ ឯកសារ D123/1/2.68, ERN (ភាសាខ្មែរ) 00927526-00927527។

[564] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ក្រិត រិត ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D119/42, ERN (ភាសាខ្មែរ) 00915872 (ឆ.១០)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ប៉ោ បណ្តែត ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D219/181, ERN (ភាសាខ្មែរ) 01066319 (ឆ.២១)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ឈឹម ផន ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ D119/32, ERN (ភាសាខ្មែរ) 00907515 (ឆ.២៥)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ រស់ ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ D119/99, ERN (ភាសាខ្មែរ) 00978919 (ឆ.៩) និងសំណុំរឿង ០០៤/១ មជ្ឈមណ្ឌលឯកសារកម្ពុជា៖ ការចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជានៅលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ ឯកសារ D1.3.10.10, ERN (ភាសាខ្មែរ) 00750677-00750678។

[565] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ក្រិត រិត ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D119/42, ERN (ភាសាខ្មែរ) 00915872 (ឆ.៦-ឆ.៨)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D106/11, ERN (ភាសាខ្មែរ) 00787416-00787417។

[566] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ក្រិត រិត ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D119/42, ERN (ភាសាខ្មែរ) 00915872 (ឆ.៧)។

[567] សំណុំរឿង ០០៤/១ កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D219/177, ERN (ភាសាខ្មែរ) 01364013-01364014។

[568] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ប៉ោ បណ្តែត ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D219/181, ERN

សម្លាប់ នៅខាងក្រោយផ្ទះតាក្រក មុនពេលកងទ័ពវៀតណាមចូលមកដល់ ប្រហែលក្នុងអំឡុងខែ សីហា ឆ្នាំ ១៩៧៨[569]។ វ៉ាន់ ទាវ បានឃើញ មនុស្សប្រហែល ១២ នាក់ ត្រូវគេយកទៅសម្លាប់ នៅជិតផ្ទះតាក្រក ហើយបានឮមនុស្សស្រែក ស្ទើររៀងរាល់យប់ នៅខែចុងក្រោយនៃរបបនោះ[570]។ ណាវ វៀម បានឃើញរណ្ដៅជាច្រើន និងជើងមនុស្សមួយលេចចេញពីដីនៅក្រោយផ្ទះតាក្រក ក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់ពួកនិរតី[571]។ បើតាម ចាន់ ឌៀ ក្រោយពីរបបខ្មែរក្រហមដួលរលំ តំបន់ជុំវិញផ្ទះតាក្រកមានសុទ្ធតែលលាដ៍ក្បាល និងឆ្អឹងមនុស្ស ហើយគាត់បានប៉ាន់ប្រមាណថា មនុស្សរាប់រយនាក់ត្រូវបានកប់នៅទីនោះ[572]។ សុស ណារិន បានវាយតម្លៃថា មនុស្សប្រមាណ ២០០ ត្រូវបានសម្លាប់ នៅចម្ការដូង និងចម្ការយាយនឹង[573]។

២៣០. មានភស្តុតាងបន្ថែមទៀតថា មានអ្នកជំងឺរាប់រយនាក់នៅមន្ទីរពេទ្យ ក្នុងបរិវេណវត្ត[574] ដោយមានយោធាយាម ប្រហែលពី ៨ ទៅ ១០ នាក់ [575] ហើយអ្នកជំងឺរហូតទៅដល់មួយពាន់នាក់បានស្លាប់ដោយសារជំងឺ ពេលសម្រាកពេទ្យ ដោយសារតែខ្វះការព្យាបាល និងថ្នាំសង្កូវ[576]។ សាកសពត្រូវបានកប់ក្នុង

---

(ភាសាខ្មែរ) 01066319-01066320 (ឆ.១៨-ឆ.២៣)។

[569] សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ សុង ផាវ៉ាត់ ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D119/37, ERN (ភាសាខ្មែរ) 00915839 (ឆ.៤)។

[570] សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ វ៉ាន់ ទាវ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ D119/152, ERN (ភាសាខ្មែរ) 01024727-01024728 (ឆ.១៩-ឆ.២៥)។

[571] សំណុំរឿង ០០៤/១ កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D219/177, ERN (ភាសាខ្មែរ) 01364013-01364014។

[572] សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ ចាន់ ឌៀ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D119/39, ERN (ភាសាខ្មែរ) 00915853, 00915854 (ឆ.៥, ឆ.៨)។

[573] សំណុំរឿង ០០៤/១ កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D106/11, ERN (ភាសាខ្មែរ) 00787416-00787417។

[574] សំណុំរឿង ០០៤/១ បទសម្ភាសន៍របស់ ក.ស.ព ជាមួយ ប៉ោ បណ្ដែត ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៨ ឯកសារ D1.3.11.40, ERN (ភាសាខ្មែរ) 01084703-01084704។

[575] សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ មុំ ឈុក ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ D119/52, ERN (ភាសាខ្មែរ) 00933133 (ឆ.២៧)។

[576] សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ មុំ ឈុក ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ D119/52, ERN (ភាសាខ្មែរ) 00933133 (ឆ.២៦)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D119/24, ERN (ភាសាខ្មែរ) 00894523។ សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ សុង ផាវ៉ាត់ ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D119/37, ERN (ភាសាខ្មែរ) 00915842 (ឆ.២១-ឆ.២២)។



PRE-TRIAL ... E.C.C.C

បរិវេណវត្ត ឬនៅចម្ការដូង និងចម្ការយាយនឹង [577] រួមជាមួយសាកសពរបស់អ្នកស្លាប់ដោយសារអត់អាហារ ហើយ ធិម សុវណ្ណី បានឃើញដោយផ្ទាល់ភ្នែក នៅឆ្នាំ ១៩៧៨[578]។

២៣១. ចំពោះការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចៅក្រមទទួលបន្ទុកលើរឿងក្តីកត់សម្គាល់ឃើញថា ដីកាដំណោះស្រាយ (សំអាងហេតុ) បានបង្ហាញថា អ៊ឹម ចែម ក្នុងឋានៈជាលេខាស្រុកព្រះនេត្រព្រះ មានសិទ្ធិអំណាចលើស្រុក រួមទាំងអំណាចក្នុងការបញ្ជាឱ្យចាប់ និងសម្លាប់មនុស្ស[579]។ ជាពិសេស ឈ្លបដែលចាប់មនុស្សនៅតាមឃុំនានា ស្ថិតក្រោមការគ្រប់គ្រងរបស់គណៈស្រុក ហើយ អ៊ឹម ចែម បានសម្រេចអំពីការចាប់មនុស្សជាច្រើន[580]។ លើសពីនេះទៅទៀត ដូចសហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ អ៊ឹម ចែម បានរៀបចំកិច្ចប្រជុំជាច្រើន ហើយកិច្ចប្រជុំខ្លះមានមនុស្សចូលរួមរាប់ពាន់នាក់នៅឃុំព្រះនេត្រព្រះ និងជាពិសេស ក្នុងបរិវេណវត្ត[581]។ យ៉ាងហោចណាស់ សាក្សីម្នាក់បានរាយការណ៍ថា គាត់មានវត្តមាន ក្នុងពេលគេសម្លាប់ សឿន និង ពៅ ជាសាធារណៈ[582] ចំណែកឯសាក្សីម្នាក់ទៀត បានឃើញ អ៊ឹម ចែម បញ្ជាឱ្យ

---

[577] សំណុំរឿង ០០៤/១ កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D119/24, ERN (ភាសាខ្មែរ) 00894523។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ សុស ណារិន ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D119/38, ERN (ភាសាខ្មែរ) 00915848 (ឆ.៨)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ សុង ផាភ័ត ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D119/37, ERN (ភាសាខ្មែរ) 00915840-00915841 (ឆ.១២)។

[578] សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ធិម សុវណ្ណី ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D5/969, ERN (ភាសាខ្មែរ) 00989914-00989915។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ធិម សុវណ្ណី ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D219/60, ERN (ភាសាខ្មែរ) 01037118-01037119 (ឆ.៤៣, ឆ.៤៧-ឆ.៥២)។ សូមមើលផងដែរ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ប៉ោ បណ្តែត ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D219/181, ERN (ភាសាខ្មែរ) 01066321 (ឆ.២៨)។

[579] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៧៣-១៨៨។

[580] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៨៦។

[581] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៥៣។ សូមមើលផងដែរ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ សុង ផាភ័ត ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D119/37, ERN (ភាសាខ្មែរ) 00915842 (ឆ.១៩-ឆ.២០)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D219/177, ERN (ភាសាខ្មែរ) 01364013-01364014។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ប៉ោ បណ្តែត ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ D101/1.1, ERN (ភាសាខ្មែរ) 00743545-00743546។

[582] សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៉ាក់ ស៊ីឈឿត ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D5/984, ERN (ភាសាខ្មែរ) 00990158-00990159។

សម្លាប់អ្នកទាំងពីរនេះ [583] ។ សាក្សីជាច្រើនក៏បានឃើញ អ៊ឹម ចែម ចុះមើលតាមភូមិនានានៃឃុំព្រះនេត្រព្រះ[584] ជូនកាល ជិះឡានយោធា[585]។ ក្រោយពី អ៊ឹម ចែម បញ្ជាឲ្យសម្លាប់លេខាឃុំឈ្មោះ តាក្រក[586] កម្មាភិបាល ដែលមកជំនួសតាក្រក រាយការណ៍ទៅគាត់ផ្ទាល់[587]។ ដូច្នេះ ចៅក្រមទទួលបន្ទុកលើរឿងក្តីយល់ឃើញថា តាមស្តង់ដារចាំបាច់ អ៊ឹម ចែម មានសិទ្ធិអំណាចលើវត្តព្រះនេត្រព្រះ និងទីតាំងពាក់ព័ន្ធ ហើយបានចូលរួមពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត នៅទីនោះ។

២៣២. អាស្រ័យហេតុនេះ ចៅក្រមទទួលបន្ទុកលើរឿងក្តីរកឃើញថា មានភស្តុតាងគ្រប់គ្រាន់ថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការដាក់ក្នុងមន្ទីរឃុំឃាំង មនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងទៀត ត្រូវបានប្រព្រឹត្ត ក្នុងបរិវេណវត្តព្រះនេត្រព្រះ និងនៅតំបន់ពាក់ព័ន្ធ ក្នុងអំឡុងរយៈកាលពាក់ព័ន្ធប្រឆាំងនឹងមនុស្សរាប់រយនាក់យ៉ាងហោចណាស់ ហើយ អ៊ឹម ចែម អាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ។ ចៅក្រមទទួលបន្ទុកលើរឿងក្តីយល់ឃើញថា ការចោទប្រកាន់ទាំងនេះគួរត្រូវបានដាក់បញ្ចូលក្នុងបទចោទ និងគួរត្រូវបានពិចារណាឲ្យបានត្រឹមត្រូវ ពេលវាយតម្លៃអំពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក លើ អ៊ឹម ចែម។ ការបកស្រាយថាតើកំហុសទាំងនេះគឺ ជាកត្តាកំណត់ជាមូលដ្ឋាននៃការសម្រេចបែបនោះ នឹងត្រូវបានបង្ហាញដូចខាងក្រោម។

### ៣. មន្ទីរសន្តិសុខភូមិចក្រី និងទីតាំងសម្លាប់មនុស្សព្រៃតាវ៉ែត

២៣៣. កថាខណ្ឌ ៧៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ចោទប្រកាន់ថា មនុស្សត្រូវបានឃុំ និងសម្លាប់នៅមន្ទីរសន្តិសុខភូមិចក្រី ដែលជា "គុកថ្នាក់ស្រុកសម្រាប់ស្រុកព្រះនេត្រព្រះ" និងនៅទីតាំង

---

[583] សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ថង ធឿយ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D5/853, ERN (ភាសាខ្មែរ) 00956904។

[584] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ សុង ផារ៉ាត់ ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D119/37, ERN (ភាសាខ្មែរ) 00925841 (ឆ.១៨)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D219/177, ERN (ភាសាខ្មែរ) 01364013-01364014។ សំណុំរឿង ០០៤/១ បទសម្ភាសន៍របស់ ក.ស.ព ជាមួយ ប៉ោ បណ្តែត ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៨ ឯកសារ D1.3.11.40, ERN (ភាសាខ្មែរ) 01084704-01084705។

[585] សំណុំរឿង ០០៤/១ កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D219/177, ERN (ភាសាខ្មែរ) 01364013-01364014។

[586] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ រស់ ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ D119/99, ERN (ភាសាខ្មែរ) 00978921 (ឆ.២២)។

[587] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៥៤។



PRE-TRIAL CH... E.C.C.C

សម្លាប់មនុស្សព្រៃតារ៉ុតជិតនោះ ហើយ "ប្រជាជននៅភូមិចក្រីស្ទើរតែទាំងអស់ ដែលមានចំនួន ៤០០ នាក់ ត្រូវបានសម្លាប់ ក្នុងពេលបោសសម្អាត ដែលធ្វើឡើងនៅទូទាំងស្រុកព្រះនេត្រព្រះ រហូតដល់ចុងខែ សីហា ឆ្នាំ ១៩៧៨"។

២៣៤. ចៅក្រមទទួលបន្ទុកលើរឿងក្ដីយល់ឃើញថា ការចោទប្រកាន់ទាំងនេះអាចមានទំហំស្មើនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងទម្រង់ជាអំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម[588] និងដូចបានកត់សម្គាល់ខាងលើ លក្ខខណ្ឌរស់នៅគួរឱ្យអាណោចអាធ័ម ជាអំពើអមនុស្សធម៌ផ្សេងទៀត[589]។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតបានទទួលបណ្ដឹងអំពីការចោទប្រកាន់ទាំងនេះ ហើយមានភារកិច្ចស៊ើបអង្កេត និងចេញសេចក្ដីសម្រេចពាក់ព័ន្ធនឹងបញ្ហានេះ នៅពេលចេញដីកាដំណោះស្រាយ (សំអាងហេតុ)។

២៣៥. ក្នុងពេលពិនិត្យឡើងវិញគ្រួសៗលើភស្ដុតាង សហចៅក្រមស៊ើបអង្កេតពិតជាបានទទួលស្គាល់ថា ប្រជាជនត្រូវបានឃុំ និងសម្លាប់ នៅមន្ទីរសន្តិសុខភូមិចក្រី ក្នុងអំឡុងពេលប្រហែលមួយឆ្នាំ រហូតដល់ចុងឆ្នាំ ១៩៧៨ ឬដើមឆ្នាំ ១៩៧៩[590] ហើយព្រៃតារ៉ុត ត្រូវបានកម្មាភិបាលភូមិភាគនិរតីប្រើជាទីតាំងសម្លាប់មនុស្ស ចាប់ពីចុងឆ្នាំ ១៩៧៧ ឬដើមឆ្នាំ ១៩៧៨ រហូតដល់ចប់របបកម្ពុជាប្រជាធិបតេយ្យ[591]។ សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់អំពីការប៉ាន់ប្រមាណចំនួនមនុស្ស ចន្លោះពី ២០០ ទៅ ៧.៣០០ នាក់ ដែលត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខភូមិចក្រី [592] និងជនរងគ្រោះ យ៉ាងហោចណាស់ ១០០ នាក់ ត្រូវបានសម្លាប់នៅព្រៃតារ៉ុត ប៉ុន្តែ រកឃើញថាចំនួនចុងក្រោយនេះមានភាព "មិនជាក់លាក់" និង "មិនច្បាស់លាស់" [593] ។ សហចៅក្រមស៊ើបអង្កេតខកខានមិនបានដាក់បញ្ចូលការចោទប្រកាន់ទាំងនេះទៅក្នុងបទចោទ និងខកខានមិនបានធ្វើការកំណត់តាមផ្លូវច្បាប់ឱ្យបានត្រឹមត្រូវ នៅពេលចេញដីកាដំណោះស្រាយ (សំអាងហេតុ) លើកលែងតែចំពោះការរកឃើញយ៉ាងប្រញាប់ប្រញាល់ នៅកថាខណ្ឌ ៣០៥។

---

[588] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ (ឯកសារ D1) កថាខណ្ឌ ១១៩។

[589] *សូមមើលខាងលើ* កថាខណ្ឌ ២០២-២០៦ ។

[590] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៦០-២៦១។

[591] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៦៤-២៦៦។

[592] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៦៣-៣២១។

[593] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៦៧, ៣២១។

២៣៦. ចៅក្រមទទួលបន្ទុកលើរឿងក្ដីកត់សម្គាល់ឃើញមានភស្តុតាងថា មន្ទីរសន្តិសុខភូមិចក្រី (ហៅគុកជប់ ឬជប់វារី) ត្រូវបានប្រើជាគុក [594] និងទីតាំងសម្លាប់មនុស្ស [595] ក្នុងពេល អ៊ឹម ចែម គ្រប់គ្រងស្រុកនោះ[596]។ ទីតាំងកប់សពត្រូវបានជីកគាស់ ក្រោយខ្មែរក្រហមដួលរលំ[597] ហើយមានមនុស្សត្រូវបានសម្លាប់

---

[594] សំណុំរឿង ០០៤/១ របាយការណ៍ស្ដីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស៖ របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D106/15, ERN (ភាសាខ្មែរ) 00792064-00792065។ សូមមើលផងដែរ សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ យូ មុត ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D5/965, ERN (ភាសាខ្មែរ) 00989853។ សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ យូ មុត ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ D219/1, ERN (ភាសាខ្មែរ) 01024619-01024621 (ឆ.៣៨-ឆ.៤៣)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ ខុប សុក ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D219/212, ERN (ភាសាខ្មែរ) 01074063-01074064 (ឆ.២៤)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ ឌឹក គុយ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ D219/384, ERN (ភាសាខ្មែរ) 01113233-01113234 (ឆ.១៨)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ ប៊ិន សុខ ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ D219/397, ERN (ភាសាខ្មែរ) 01114729 (ឆ.២២-ឆ.២៥)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ D219/387, ERN (ភាសាខ្មែរ) 01366499-01366502។ សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ សួរ គិន ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ D219/437, ERN (ភាសាខ្មែរ) 01124199 (ឆ.២៥)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ និត ស៊ិត ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D119/133, ERN (ភាសាខ្មែរ) 00998150 (ឆ.១០២)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ ធិប គីមលន់ ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ D119/145, ERN (ភាសាខ្មែរ) 01022033 (ឆ.៦៣)។

[595] សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ ម៉ក់ វន្នី ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ D119/125, ERN (ភាសាខ្មែរ) 00987278 (ឆ.៩), 00987279 (ឆ.១២), (ឆ.១៤)។ សំណុំរឿង ០០៤/១កំណត់ហេតុស្ដាប់ចម្លើយ ប្រាច់ គិត ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D106/2, ERN (ភាសាខ្មែរ) 00780968-00780969 (ឆ.២០-ឆ.២២), 00784871 (ឆ.២៦)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ សុស ណារិន ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D119/38, ERN (ភាសាខ្មែរ) 00915848 (ឆ.៦)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ ប៉ាន ឈួង ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D119/29, ERN (ភាសាខ្មែរ) 00895160 (ឆ.១១)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ និត ស៊ិត ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D119/133, ERN (ភាសាខ្មែរ) 00998150 (ឆ.១០៤)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ អ៊ីវ ម៉ារ៉ា ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ D119/154, ERN (ភាសាខ្មែរ) 01024748 (ឆ.៣៥)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ ឌឹក គុយ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ D219/384, ERN (ភាសាខ្មែរ) 01113233-01113234 (ឆ.១៨)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ D219/387, ERN (ភាសាខ្មែរ) 01366499-01366502។

[596] សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ ម៉ក់ វន្នី ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ D119/125, ERN (ភាសាខ្មែរ) 00987279 (ឆ.១៤)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ ប្រាច់ គិត ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D106/2, ERN (ភាសាខ្មែរ) 00780968 (ឆ.១៩)។

និងកប់ នៅជុំវិញមន្ទីរឃុំឃាំង[598] នៅក្នុងស្រះ[599] និងនៅវាលស្រែជិតៗនោះ[600]។ ចៅក្រមទទួលបន្ទុកលើរឿងក្ដីក៏សង្កេតឃើញផងដែរថា ដំបូង ព្រៃតារ៉ុត ត្រូវបានប្រើជាទីតាំងសម្លាប់មនុស្ស នៅចុងឆ្នាំ ១៩៧៧ ឬដើមឆ្នាំ ១៩៧៨ ក្រោយការមកដល់របស់កម្មាភិបាលភូមិភាគនិរតី ហើយការសម្លាប់ត្រូវបានធ្វើឡើងជាទៀងទាត់ ចាប់ពីខែ មិថុនា ឬខែ កក្កដា ឆ្នាំ ១៩៧៨ រហូតដល់ចប់របបកម្ពុជាប្រជាធិបតេយ្យ[601]។ សាក្សីសំខាន់ៗ ដូចជា ស៊ុម តៅ ដែលរស់នៅចម្ងាយ ៣០០ ម៉ែត្រ ពីព្រៃតារ៉ុត[602] ឬម៉ក់ វន្នី ដែលមានផ្ទះនៅជិត

---

[597] សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ និត ស៊ត់ ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D119/133, ERN (ភាសាខ្មែរ) 00998150 (ទ.១០៤-ទ.១០៥)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ ឌឹក គុយ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ D219/384, ERN (ភាសាខ្មែរ) 01113233-01113234 (ទ.១៨)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ D219/387, ERN (ភាសាខ្មែរ) 01366500-01366502។ សំណុំរឿង ០០៤/១ ឧបសម្ព័ន្ធ ៥ នៃរបាយការណ៍ស្ដីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស៖ របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D106/15.5, ERN (ភាសាខ្មែរ) 00804676-00804677។

[598] សំណុំរឿង ០០៤/១ ឧបសម្ព័ន្ធ ៥ នៃរបាយការណ៍ស្ដីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស៖ របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D106/15.5, ERN (ភាសាខ្មែរ) 00804673, 00804676-00804677។ សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ ប្រាច់ គិត ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D106/2, ERN (ភាសាខ្មែរ) 00780969 (ទ.២២)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ ស៊ិន យិន ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D219/205, ERN (ភាសាខ្មែរ) 01072290 (ទ.៤)។ សំណុំរឿង ០០៤/១ របាយការណ៍ស្ដីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស៖ របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D106/15, ERN (ភាសាខ្មែរ) 00792064-00792065។

[599] សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ អ៊ីវ ម៉ារ៉ា ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ D119/154, ERN (ភាសាខ្មែរ) 01024748 (ទ.៣៥)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ សុស ណារិន ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D119/38, ERN (ភាសាខ្មែរ) 00915848 (ទ.៦)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ ម៉ក់ វន្នី ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ D119/125, ERN (ភាសាខ្មែរ) 00987278 (ទ.៩), 00987279 (ទ.១២), (ទ.១៤)។

[600] សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ ឌឹក គុយ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ D219/384, ERN (ភាសាខ្មែរ) 01113233-01113234 (ទ.១៨)។

[601] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៦៤-២៦៦។ សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ ហៀម សាខន ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D106/3, ERN (ភាសាខ្មែរ) 00780976 (ទ.២៣)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ ស៊ុម តៅ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/92, ERN (ភាសាខ្មែរ) 00976157-00976158 (ទ.២៨)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ ចាន់ ផុន ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/93, ERN (ភាសាខ្មែរ) 00976169 (ទ.៣៤)។

[602] សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ ស៊ុម តៅ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/92, ERN (ភាសាខ្មែរ) 00976157-00976158 (ទ.២៨)។

ផ្លូវទៅកាន់ទីតាំងនោះ[603] បានឮសំឡេងឡានមកដល់ និងសំឡេងស្រែក និងបានឃើញសាកសព នៅព្រៃតារ៉ុត[604]។

២៣៧. ចំពោះចំនួនជនរងគ្រោះនៅមន្ទីរសន្តិសុខភូមិចក្រី ចៅក្រមទទួលបន្ទុកលើរឿងក្តីកត់សម្គាល់ឃើញថា ការប៉ាន់ប្រមាណរបស់សហចៅក្រមស៊ើបអង្កេត មានភាពមិនត្រឹមត្រូវ និងបកស្រាយខុសលើភស្តុតាងនៅក្នុងសំណុំរឿង។ ជាពិសេស ការប៉ាន់ប្រមាណជាអប្បបរមានូវចំនួនមនុស្ស ២០០ ដែលត្រូវបានសម្លាប់ដូចបានបញ្ជាក់ក្នុងដីកាដំណោះស្រាយ (សំអាងហេតុ)[605] តាមពិត ត្រូវបានផ្តល់ជូនដោយ សុស ណារិន ពាក់ព័ន្ធនឹងទីតាំងសម្លាប់មនុស្សផ្សេងទៀត នៅជិតផ្ទះតាក្រក និងវត្តព្រះនេត្រព្រះ[606]។ ភស្តុតាងរបស់គាត់អំពីភូមិចក្រី កម្រិតត្រឹមការសង្កេតថា ពេលខ្លះ មនុស្ស ៥ ទៅ ១០ នាក់ ត្រូវបាននាំពីផ្ទះតាក្រកទៅសម្លាប់នៅទីនោះ [607] ។ ដូចគ្នានេះដែរ ការគណនារបស់សហចៅក្រមស៊ើបអង្កេតនូវចំនួនជនរងគ្រោះ ចន្លោះពី ១.៨២៥ នាក់ ទៅ ៧.៣០០ នាក់[608] ផ្អែកលើការដកស្រង់ខុសនូវភស្តុតាងរបស់ ប្រាច់ គិត ដែលតាមពិត

---

[603] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ម៉ក់ វន្ទី ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ D119/125, ERN (ភាសាខ្មែរ) 00987279-00987280 (ឆ.១៦), (ឆ.១៩)។

[604] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៦៦។ សូមមើលផងដែរ ឧទាហរណ៍ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ស៊ុម តៅ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/92, ERN (ភាសាខ្មែរ) 00976157-00976158 (ឆ.២៦,ឆ.២៨)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ម៉ក់ វន្ទី ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ D119/125, ERN (ភាសាខ្មែរ) 00987279-00987280 (ឆ.១៦, ឆ.១៨)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ចាន់ ផុន ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/93, ERN (ភាសាខ្មែរ) 00976169 (ឆ.៣៤-ឆ.៣៥)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ លៀស ស្តើង ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D219/173, ERN (ភាសាខ្មែរ) 01065978 (ឆ.៤២)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ នួន ហឿក ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ D219/385, ERN (ភាសាខ្មែរ) 01113241-01113242 (ឆ.២០-ឆ.២៨)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ឌឹក គុយ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ D219/384, ERN (ភាសាខ្មែរ) 01113234 (ឆ.២១-ឆ.២៤)។

[605] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៦៣ យោងទៅ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ សុស ណារិន ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D119/38, ERN (ភាសាខ្មែរ) 00915848 (ឆ.៦)។

[606] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ សុស ណារិន ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D119/38, ERN (ភាសាខ្មែរ) 00915848 (ឆ.៦)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D106/11, ERN (ភាសាខ្មែរ) 00787416-00787417។

[607] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ សុស ណារិន ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D119/38, ERN (ភាសាខ្មែរ) 00915848 (ឆ.៦)។

[608] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៦៣ យោងទៅ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ប្រាច់ គិត ចុះ

បានប៉ាន់ប្រមាណថា មនុស្សពី ១៥ នាក់ (ជាជាង ៥ នាក់) ទៅ ២០ នាក់ ត្រូវគេនាំយកទៅសម្លាប់ជារៀងរាល់ថ្ងៃ[609]។ ការគណនាសមហេតុផល ដោយផ្អែកលើភស្តុតាងរបស់គាត់ អាចឲ្យមានការប៉ាន់ប្រមាណទាបថា ជនរងគ្រោះ ចន្លោះពី ៥.៤៧៥ នាក់ (ជាជាង ១.៨២៥ នាក់) ដល់ ៧.៣០០ នាក់ ត្រូវបានចាប់ខ្លួន និងសម្លាប់។ ភស្តុតាងផ្សេងទៀតនៅក្នុងសំណុំរឿងពិតជាគាំទ្រដល់ការប៉ាន់ប្រមាណនេះ ដែលបង្ហាញថា គុកអាចដាក់អ្នកទោសបានពី ២០ ទៅ ៣០ នាក់ ក្នុងមួយពេល[610] ហើយមនុស្សដែលគេយកចូលទៅ បានបាត់ខ្លួន នៅព្រឹកបន្ទាប់[611]។

២៣៨. ចំពោះចំនួនជនរងគ្រោះនៅទីតាំងសម្លាប់មនុស្សព្រៃតាវ៉ុត ភស្តុតាងបង្ហាញថា ផ្នូរ ឬរណ្តៅចំនួនប្រាំ ត្រូវបានរកឃើញ ក្នុងអំឡុងកិច្ចស៊ើបសួរ[612]។ បួនត្រូវបានរកឃើញនៅជិតច្រកចូល និងមានទំហំ ៩ ម៉ែត្រក្រឡា និងជម្រៅប្រហែល ១,៨ ម៉ែត្រ[613] ហើយទីប្រាំត្រូវបានរកឃើញនៅចម្ងាយ ១.០០០ ម៉ែត្រនៅខាងជើង និងមានទំហំ ១៦ ម៉ែត្រក្រឡា និងជម្រៅ ២ ម៉ែត្រ[614]។ ស៊ុម តៅ អតីតមេភូមិក្រសាំងថ្មី នៅ

---

ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D106/2, ERN (ភាសាខ្មែរ) 00780968-00780969 (ឆ.២០-ឆ.២១, ឆ.២៣)។

[609] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ប្រាច់ គិត ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D106/2, ERN (ភាសាខ្មែរ) 00780968-00780969 (ឆ.២១), (ឆ.២៦)។

[610] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ យូ មុត ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ D219/1, ERN (ភាសាខ្មែរ) 01024619 (ឆ.៣៨)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ប៊ិន សុខ ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ D219/397, ERN (ភាសាខ្មែរ) 01114729 (ឆ.២៥)។

[611] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ប្រាច់ គិត ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D106/2, ERN (ភាសាខ្មែរ) 00780968 (ឆ.២០)។

[612] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៦៧។ សំណុំរឿង ០០៤/១ របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស៖ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D106/15, ERN (ភាសាខ្មែរ) 00792064-00792067។

[613] សំណុំរឿង ០០៤/១ របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស៖ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D106/15, ERN (ភាសាខ្មែរ) 00792064-00792067។ សំណុំរឿង ០០៤/១ ឧបសម្ព័ន្ធ ៥ នៃរបាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស៖ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D106/15.5, ERN (ភាសាខ្មែរ) 00804681, 00804684។

[614] សំណុំរឿង ០០៤/១ របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស៖ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D106/15, ERN (ភាសាខ្មែរ) 00792066-00792067។ សំណុំរឿង ០០៤/១ ឧបសម្ព័ន្ធ ៥ នៃរបាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស៖ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D106/15.5, ERN (ភាសាខ្មែរ) 00804683, 00804685។



PRE-TRIAL CHAMBER E.C.C.C.

ពេលសម្ភាស[615] បានរៀបរាប់ថា គាត់បានឃើញរណ្តៅចំនួនបី ដែលមានសាកសពមិនដល់ ១០០ ទេ មានទទឹង ២ ម៉ែត្រកន្លះ បណ្តោយ ៣ ម៉ែត្រ និងជម្រៅមិនដល់ ១ ម៉ែត្រ[616]។ ដូចគ្នានេះដែរ ហៀម សាខន ត្រូវគេប្រាប់ថា មនុស្សជាច្រើនត្រូវបានសម្លាប់ នៅព្រៃតារ៉ុត ហើយរណ្តៅប្រហែលពី ៣ ទៅ ៤ ទំហំប៉ុនៗគ្នា ត្រូវបានរកឃើញ នៅតំបន់នោះ[617]។ ចាន់ ផុន បានឃើញរណ្តៅពីរកប់សាកសពរាប់រយ ដែលគាត់ប៉ាន់ស្មានថា មានទទឹង ៤ ម៉ែត្រ បណ្តោយ ៥ ម៉ែត្រ និងជម្រៅប្រហែល ២ ម៉ែត្រ[618]។

២៣៩. ចម្លើយទាំងនេះត្រូវបានគាំទ្រដោយភស្តុតាងនៃភាពញឹកញាប់ ដែលអ្នកទោសបានមកដល់ទីតាំងសម្លាប់មនុស្ស។ ក្នុងអំឡុងរយៈពេលពីរខែ នៅដើមឆ្នាំ ១៩៧៨ ម៉ក់ វន្នី បានឃើញឡានទ្រុងប្រហែលបីគ្រឿង ដឹកអ្នកទោស បើកសំដៅទៅព្រៃតារ៉ុត បីបួនថ្ងៃជាប់គ្នា ក្នុងមួយសប្តាហ៍[619]។ នួន ហឿក ចាំបានថា ឮសំឡេងឡាន ម្តងក្នុងមួយសប្តាហ៍ ក្នុងពេលកម្មាភិបាលភូមិភាគនិរតីគ្រប់គ្រង និងនឹកឃើញថា មានម្តងនោះ គាត់បានឃើញឡានពីរគ្រឿង[620]។ ស៊ុម តៅ បានឱ្យដឹងថា ចាប់ពីខែ មិថុនា ឬខែ កក្កដា ឆ្នាំ ១៩៧៨ រហូតដល់ចប់របបខ្មែរក្រហម ឡានមកដល់ ជារៀងរាល់ថ្ងៃ ឬពីរថ្ងៃម្តង[621]។ ចាន់ ផុន បានបញ្ជាក់ថា គាត់បានឮសំឡេងឡានមួយទៅពីរគ្រឿង ក្នុងមួយថ្ងៃ មិនយូរប៉ុន្មាន ក្រោយពីរបបនោះដួលរលំ[622]។ ជារួម

[615] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ស៊ុម តៅ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/92, ERN (ភាសាខ្មែរ) 00976153។

[616] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ស៊ុម តៅ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/92, ERN (ភាសាខ្មែរ( 00976158 (ឆ.៣០)។

[617] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ហៀម សាខន ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D106/3, ERN (ភាសាខ្មែរ( 00780976 (ឆ.២០)។

[618] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ចាន់ ផុន ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/93, ERN (ភាសាខ្មែរ( 00976169 (ឆ.៣៤-ឆ.៣៥)។

[619] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ម៉ក់ វន្នី ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ D119/125, ERN (ភាសាខ្មែរ( 00987279-00987280 (ឆ.១៦-ឆ.១៧)។

[620] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ នួន ហឿក ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ D219/385, ERN (ភាសាខ្មែរ) 01113241-01113242 (ឆ.២០-ឆ.៣១)។

[621] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ស៊ុម តៅ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/92, ERN (ភាសាខ្មែរ) 00982334 (ឆ.២៨)។

[622] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ចាន់ ផុន ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/93, ERN (ភាសាខ្មែរ) 00976169 (ឆ.៣៤)។



PRE-TRIAL ... E.C.C.C.

ទោះបីជាចៅក្រមទទួលបន្ទុករឿងក្តីឯកភាពថា ចំនួនអ្នកស្លាប់ ដែលបានផ្តល់ជូននៅក្នុងរបាយការណ៍ ឆ្នាំ ១៩៩៧ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ពាក់ព័ន្ធនឹងទីតាំងនេះ មិនអាចបញ្ជាក់បានក៏ដោយ[623] ក៏ចៅក្រមទទួលបន្ទុករឿងក្តីយល់ឃើញថា យើងអាចប៉ាន់ប្រមាណយ៉ាងសមហេតុផលឱ្យហួសពីវិមតិសង្ស័យថា យ៉ាងហោចណាស់មនុស្សរាប់រយនាក់ត្រូវបានសម្លាប់ និងកប់ នៅព្រៃតារ៉ុត។

២៤០. ចុងក្រោយ ចៅក្រមទទួលបន្ទុកលើរឿងក្តីរម្លឹកថា ទីតាំងពីរស្ថិតនៅជិតមន្ទីរស្រុកព្រះនេត្រព្រះ[624] ហើយមន្ទីរសន្តិសុខភូមិចក្រីត្រូវបានប្រើជាគុកថ្នាក់ស្រុក[625]។ ទីតាំងទាំងពីរនេះដំណើរការ ក្នុងអំឡុងរយៈពេលដែលសហចៅក្រមស៊ើបអង្កេតរកឃើញថា អ៊ឹម ចែម កំពុងកាន់អំណាច ក្នុងឋានៈជាលេខាស្រុក

---

[623] សំណុំរឿង ០០៤/១ កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ D119/102, ERN (ភាសាខ្មែរ) 01224748-01224749។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ផេង ពង្សរ៉ាស៊ី ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៥ ឯកសារ D219/144, ERN (ភាសាខ្មែរ) 01056145-01056146 (ឆ.១១-ឆ.១៣)។

[624] សំណុំរឿង ០០៤/១ របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស៖ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D106/15, ERN (ភាសាខ្មែរ) 00792064-00792065។ សំណុំរឿង ០០៤/១ ឧបសម្ព័ន្ធ ២ នៃរបាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស៖ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D106/15.2, ERN (ភាសាអង់គ្លេស) 00804668។

[625] សំណុំរឿង ០០៤/១ របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស៖ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D106/15, ERN (ភាសាខ្មែរ) 00792064-00792065។ សូមមើលផងដែរ សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ យូ មុត ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ D5/965, ERN (ភាសាខ្មែរ) 00989853។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ យូ មុត ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ D219/1, ERN (ភាសាខ្មែរ) 01024619-01024621 (ឆ.៣៨-ឆ.៤៣)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ខុប សុក ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D219/212, ERN (ភាសាខ្មែរ) 01074063-01074064 (ឆ.២៤)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ឌឹក គុយ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ D219/384, ERN (ភាសាខ្មែរ) 01113233-01113234 (ឆ.១៨)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ប៊ិន សុខ ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ D219/397, ERN (ភាសាខ្មែរ) 01114729 (ឆ.២២-ឆ.២៥)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ D219/387, ERN (ភាសាខ្មែរ) 01366499-01366502។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ស្វរ គិន ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ D219/437, ERN (ភាសាខ្មែរ) 01124199 (ឆ.២៥)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ និត ស៊ិត ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D119/133, ERN (ភាសាខ្មែរ) 00998150 (ឆ.១០២)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ធិប គីមលន់ ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ D119/145, ERN (ភាសាខ្មែរ) 01022033 (ឆ.៦៣)។



PRE-TRIAL ... E.C.C.C

01575575



ព្រះនេត្រព្រះ[626] ដែលនៅទីនោះ គាត់មានសិទ្ធិអំណាចលើមន្ទីរសន្តិសុខនានា ហើយការសម្លាប់ និងការចាប់ខ្លួន ត្រូវបានធ្វើឡើងដោយឈ្លប[627]។

២៤១. អាស្រ័យហេតុនេះ ចៅក្រមទទួលបន្ទុកលើរឿងក្ដីរកឃើញថា មានភ័ស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការដាក់ក្នុងមន្ទីរឃុំឃាំង មនុស្សឃាត និងការសម្លាប់រង្គាល[628] ត្រូវបានប្រព្រឹត្ត នៅមន្ទីរសន្តិសុខភូមិចក្រី និងនៅទីតាំងសម្លាប់មនុស្សព្រៃតារ៉ុត ក្នុងអំឡុងរយៈកាលពាក់ព័ន្ធ ហើយ អ៊ឹម ចែម អាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ។ ដោយរម្លឹកថាចំនួនជាក់លាក់នៃជនរងគ្រោះមិនចាំបាច់ត្រូវបង្ហាញឡើយ[629] ចៅក្រមទទួលបន្ទុកលើរឿងក្ដីរកឃើញថែមទៀតថាភ័ស្តុតាងគ្រប់គ្រាន់ក្នុងការបង្ហាញថា ជនរងគ្រោះមានចំនួនយ៉ាងហោចណាស់ រាប់ពាន់នាក់ នៅភូមិចក្រី និងរាប់រយនាក់ នៅព្រៃតារ៉ុត។ ចៅក្រមទទួលបន្ទុកលើរឿងក្ដីយល់ឃើញថា ការចោទប្រកាន់ទាំងនេះគួរត្រូវបានដាក់បញ្ចូលក្នុងបទចោទ ហើយគួរត្រូវបានពិចារណាយ៉ាងត្រឹមត្រូវ ក្នុងការវាយតម្លៃលើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក លើ អ៊ឹម ចែម។ ការបកស្រាយថាតើកំហុសទាំងនេះគឺ ជាកត្តាកំណត់ជាមូលដ្ឋាននៃការសម្រេចបែបនោះ នឹងត្រូវបានបង្ហាញដូចខាងក្រោម។

### *៤. មន្ទីរសន្តិសុខវត្តចម្ការខ្នុរ និងវាលពិឃាត*

២៤២. កថាខណ្ឌ ៧១ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីចោទប្រកាន់ថា "ចំនួនលលាដ៍ក្បាលជាង ៩០០០ ត្រូវបានរកឃើញ" នៅវត្តចម្ការខ្នុរ ដែលត្រូវបានប្រើប្រាស់ជាមន្ទីរសន្តិសុខ និងជាកន្លែងកាប់សម្លាប់ យោងតាមភស្តុតាងគាំទ្រនានា[630] ហើយ "ជាពិសេស ការកាប់សម្លាប់បានកើតឡើងកាន់តែខ្លាំង នៅចុងឆ្នាំ១៩៧៨" ដោយ មនុស្ស "រាប់ពាន់នាក់" "ត្រូវបានចង ដាក់ឃ្នោះ យកចេញទៅ" ត្រឹមតែមួយយប់គត់។ ចៅក្រមទទួលបន្ទុកលើរឿងក្ដីយល់ឃើញថា ការចោទប្រកាន់ទាំងនេះអាចជាឧក្រិដ្ឋ

---

[626] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៦៦។

[627] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៧៣-១៧៥។

[628] ផ្ទុយទៅវិញ ចៅក្រមទទួលបន្ទុកលើរឿងក្ដីយល់ឃើញថា ពុំមានភ័ស្តុតាងគ្រប់គ្រាន់ ដូចដែលបានវិភាគកាលពីលើកមុន ដើម្បីបង្ហាញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាលក្ខខណ្ឌរស់នៅអមនុស្សធម៌ ជាអំពើអមនុស្សធម៌ផ្សេងទៀត ហើយដោយសារហេតុផលដូចគ្នា ក្រោមទម្រង់ជាការធ្វើទារុណកម្ម ត្រូវបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភូមិចក្រី។ *សូមមើលខាងលើ* កថាខណ្ឌ ២០២-២០៦ ។

[629] *សូមមើលខាងលើ* កថាខណ្ឌ ២១៤ ។

[630] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទបី (ឯកសារ D1) លេខយោងជើងទំព័រ ២៨៤ និង ២៨៧។

01575576



កម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង អំពើអមនុស្សធម៌ផ្សេងៗទៀត [631] ហើយនឹងការធ្វើទារុណកម្ម [632] យោងតាមការវាយតម្លៃមុនៗ។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតបានទទួលការចោទប្រកាន់ទាំងនេះទាន់ពេលវេលា ហើយមានភារកិច្ចស៊ើបអង្កេត និងសម្រេចនៅពេលចេញដីកាដំណោះស្រាយ (សំអាហេតុ)។

២៤៣. សហចៅក្រមស៊ើបអង្កេតបានរកឃើញភស្តុតាងដែលបង្ហាញថា ប្រជាជនត្រូវបានឃុំខ្លួន និងសម្លាប់ចោលនៅវត្តចម្ការខ្នុរ "ក្រោមការដឹកនាំរបស់ភូមិភាគពាយ័ព្យ និងភូមិភាគនិរតី" ដោយបានកត់សម្គាល់ថា "ចំនួនផ្នូររួមត្រូវបានគេរកឃើញនៅកន្លែងនេះតាំងពីពេលនោះមក" [633] ហើយសាក្សីទាំងនោះត្រូវបានរាយការណ៍ថាបានឃើញចំនួនសាកសព មានភាពខុសៗគ្នានៅក្នុងផ្នូររួមនីមួយៗ ដែលសរុបមានចំនួនជាង ១០០០ សាកសព[634]។ ទោះបីជាយ៉ាងនេះក៏ដោយ ពួកគេបានរកឃើញថា "វាមិនច្បាស់ទេថាតើជនរងគ្រោះចំនួនប៉ុន្មាននាក់ត្រូវបានសម្លាប់ដោយកម្មាភិបាលភូមិភាគនិរតី" [635] ហើយចុងបញ្ចប់មិនបានធ្វើការសម្រេចតាមផ្លូវច្បាប់ឱ្យបានត្រឹមត្រូវនៅពេលចេញដីកាដំណោះស្រាយ (សំអាងហេតុ) ហើយបានត្រឹមតែសម្រេចដោយសង្ខេបនៅត្រង់កថាខណ្ឌ ៣០៥។

២៤៤. ដោយបទដ្ឋានភ័ស្តុតាងនៅដំណាក់កាលនេះ មិនតម្រូវឱ្យមានការបង្ហាញចំនួនជនរងគ្រោះជាក់លាក់នោះ[636] ចៅក្រមទទួលបន្ទុកលើរឿងក្តីយល់ឃើញថា ការកំណត់ "ចំនួនសមាមាត្រ" ពិតប្រាកដនៃជនរងគ្រោះក្រោមការគ្រប់គ្រងរបស់កម្មាភិបាលភូមិភាគនិរតី មិនចាំបាច់នោះឡើយ។

២៤៥. ដូចបានកត់សម្គាល់ខាងលើ មន្ទីរសន្តិសុខវត្តចម្ការខ្នុរ បានយកមកធ្វើជាមន្ទីរសន្តិសុខ និងជាកន្លែងកាប់សម្លាប់ក្រោមការគ្រប់គ្រងរបស់ភូមិភាគពាយ័ព្យ និងភូមិភាគនិរតី[637]។ ទិល សេងលី ដែលបានធ្វើការនៅក្បែរនោះ តាំងពីខែ មីនា ឆ្នាំ ១៩៧៧ បានរៀបរាប់ថាបានឮសម្រែកចេញមកពីកន្លែងនោះស្ទើរតែរៀងរាល់ល្ងាច រហូតដល់របបខ្មែរក្រហមបានដួលរលំ។ គាត់បានដឹងថា យ៉ាងហោចណាស់ មានផ្នូរធំៗចំនួន

---

[631] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទបី (ឯកសារ D1) លេខយោងជើងទំព័រ ១១៩។

[632] *សូមមើល ខាងលើ* កថាខណ្ឌ ១៩៥-២០១ ។

[633] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៦៩ (លេខយោងជើងទំព័រ ដែលត្រូវបានលុបចោល)។

[634] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៧០។

[635] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៧០។

[636] *សូមមើល ខាងលើ* កថាខណ្ឌ ២១៤ ។

[637] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៦៨-២៦៩។

៤ ហើយផ្នូររួមតូចៗជាច្រើន ដោយបានប៉ាន់ស្មានថាមានមនុស្សប្រហែល ១០០០ នាក់បានស្លាប់នៅទីនោះ[638]។ សោម ឡាង[639] និងហុង ស្រី[640] បានបញ្ជាក់ថាឃើញមានផ្នូររួមធំៗជាច្រើន ហើយបានផ្ដល់ការប៉ាន់ស្មានស្រដៀងគ្នាអំពីចំនួនជនរងគ្រោះ។ ទឹម រតនៈ បានរាយការណ៍បន្ថែមទៀតថាបានឃើញសាកសពជាប់ខ្នោះដៃ និងខ្នោះជើងរាប់រយនាក់នៅក្នុងបរិវេណវត្តចម្ការខ្នុរទាំងមូលនៅខែ វិច្ឆិកា ឆ្នាំ ១៩៧៨ ទាំងនៅជុំវិញជញ្ជាំងវត្ត និងនៅខាងក្នុងបរិវេណវត្ត ជាពិសេសនៅក្នុងបន្ទប់ឈើ។ សាកសពទាំងនេះទើបបានស្លាប់ថ្មីៗនេះ ហើយមានក្លិនស្អុយ និងហើមទៀតផង[641]។ ប៊ុន គិមអេង ដែលត្រូវបានឃុំខ្លួននៅមន្ទីរសន្តិសុខចម្ការខ្នុរនៅចុងឆ្នាំ ១៩៧៨ បានឃើញកងឈ្លបយកមនុស្សទៅសម្លាប់ចោលជារៀងរាល់ថ្ងៃ[642]។ ឡែម ពេញ ដែលត្រូវបានឃុំខ្លួននៅចម្ការខ្នុរផងដែរនោះ ក្រោយពេលកម្មាភិបាលភូមិភាគនិរតីបានមកដល់ [643] បានរៀបរាប់ឡើងវិញថា គេបានយកមនុស្សចេញទៅបាត់ ហើយបានឃើញរណ្ដៅមួយកប់សាកសពទៀតផង[644]។ សាក្សីជាច្រើនផ្សេងទៀតបានរាយការណ៍អំពីការបាត់ខ្លួន និងការកាប់សម្លាប់ជាប្រចាំថ្ងៃ ដោយកងឈ្លប ឬកងទ័ពដែលកើតឡើងនៅចន្លោះឆ្នាំ ១៩៧៧ និងឆ្នាំ ១៩៧៨ ស្ថិតនៅក្នុង ឬជុំវិញវត្តចម្ការខ្នុរ

---

[638] សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្ដាប់ចម្លើយរបស់ ទិល សេងលី ចុះថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D119/112, ERN 00982231 (ឆ.៨), 00982233 (ឆ.២២), 00982233-00982234 (ឆ.២៥, ឆ.២៨)។

[639] សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្ដាប់ចម្លើយរបស់ សោម ឡាង ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ D119/111, ERN 00982222 (ឆ.៥), 00982222-00982223 (ឆ.៦-ឆ.៨) (បានរាយការណ៍ថាបានឃើញផ្នូររួមចំនួនពីរ ដែលមានផ្នូរមួយមានទទឹង ៥ ម៉ែត្រ បណ្ដោយ ២០០ ម៉ែត្រ និងជម្រៅ ១ ម៉ែត្រ ដែលតាម គាត់ ប៉ាន់ស្មាន មានប្រហែល ១០០០ សាកសព)។ *សូមមើលផងដែរ* សំណុំរឿង ០០៤/០១ របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាឆ្នាំ ១៩៩៨៖ ការកំណត់ផែនទីវាលពិឃាតនៅក្នុងប្រទេសកម្ពុជា - បន្ទាយមានជ័យ ឯកសារ D1.3.27.10, ERN (EN) 00078068។

[640] សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្ដាប់ចម្លើយរបស់ ហុង ស្រី ចុះថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D119/114, ERN 00982253-00982254 (ឆ.១-ឆ.៧) (បានរាយការណ៍អំពីអត្ថិភាពនៃផ្នូររួមចំនួន ៥ ឬ ៦ ដែលមានផ្នូររួមធំមួយ រួមមានសាកសពរាប់រយ និង/ឬ ផ្នូររួមវែងមួយបណ្ដោយ ៦០ ម៉ែត្រ និងទទឹង ៥ ម៉ែត្រ រួមមានសាកសពនៅរប៉ាត់រប៉ាយ)។

[641] សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្ដាប់ចម្លើយរបស់ ទឹម រតនៈ ចុះថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D119/113, ERN 00982244 (ឆ.១), 00982246-00982247 (ឆ.១៥, ឆ.១៨-ឆ.២៤)។

[642] សំណុំរឿង ០០៤/០១ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប៊ុន គិមសុង ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D5/923, ERN 00989800។

[643] សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្ដាប់ចម្លើយរបស់ ឡែម ពេញ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D219/174, ERN 01065986 (ឆ.១៣), 01065987 (ឆ.២០), 01065989 (ឆ.៣៧)។

[644] សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្ដាប់ចម្លើយរបស់ ឡែម ពេញ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D219/174, ERN 01065990-01065991 (ឆ.៥៤-ឆ.៥៥)។

01575578



ហើយកន្លែងនេះស្ថិតនៅលើទីតាំងមួយដែលមានផ្ទៃដីជាច្រើនហិកតា[645] រួមទាំង នៅជិតការដ្ឋានចម្ការខ្នុរ[646] និង "រូងភ្នំ" ចម្ការខ្នុរ[647] និងភ្នំចម្ការខ្នុរ[648]។

២៤៦. មានភស្តុតាងបង្ហាញថា អ្នកទោសត្រូវបានគេធ្វើទារុណកម្ម ដូចដែលបានកត់សម្គាល់ពីមុន [649] ហើយត្រូវបានគេឃុំឃាំងក្នុងស្ថានភាពអមនុស្សធម៌ក្នុងអំឡុងពេលយុត្តាធិការពេលវេលាពាក់ព័ន្ធ។ ប៊ុន គឹមអេង បានថ្លែងថាគាត់ត្រូវបានគេដកហូតអាហារ ខណៈដែលត្រូវបានឃុំខ្លួននៅវត្តចម្ការខ្នុរនៅចុងឆ្នាំ ១៩៧៨ [650]។ អឿ លឿ ដែលជាប់គុកនៅវត្តចម្ការខ្នុរពីឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៨ បានរាយការណ៍ថា អ្នកទោសនឹងត្រូវបង្អត់អាហារ ប្រសិនបើពួកគេមិនបានបំពេញតាមផែនការការងារ និងត្រូវបានអនុញ្ញាតអោយទៅបន្ទោរបង់ យ៉ាងឆ្ងាយបំផុតនោះ គឺដប់ម៉ែត្រពីគុក។ គាត់ក៏បានរៀបរាប់ឡើងវិញផងដែរថា គាត់ត្រូវបានគេបង្ខំឱ្យធ្វើការពីរ ឬ បីថ្ងៃ ក្រោយពេលសម្រាលកូន ហើយកូននោះស្លាប់[651]។ ឃួន សាយ បានពិពណ៌នាបន្ថែមអំពីបរិវេណនៃមន្ទីរឃុំឃាំង ហើយបានបញ្ជាក់ថា អ្នកទោសរាប់ពាន់នាក់អាចត្រូវបានគេឃុំខ្លួននៅទីនោះ[652]។

---

[645] សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយរបស់ ទិល សេងលី ចុះថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D119/112, ERN 00982235 (ឆ.៣៨)។ សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តាន់ សាយ ឈ្មោះហៅក្រៅ ឃួន សាយ ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D118/25, ERN 00892223 (ឆ.១៧)។ សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D119/118, ERN 01224760។

[646] សំណុំរឿង ០០៤/០១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រឿង សារៀត ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ D5/1256 នៅត្រង់ ERN 01036350-01036351។

[647] សំណុំរឿង ០០៤/០១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កិញ អាយ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D5/944, ERN 00981367។

[648] សំណុំរឿង ០០៤/០១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កិញ អាយ ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D5/1128, ERN 01026341។ សំណុំរឿង ០០៤/០១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ញ៉ក យន់ ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D5/983, ERN 00990141-00990142។

[649] *សូមមើល ខាងលើ* កថាខណ្ឌ ១៩៥-២០១ ។

[650] សំណុំរឿង ០០៤/០១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន គិមសុង ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ D5/923, ERN 00979800។

[651] សំណុំរឿង ០០៤/០១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អឿ លឿ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ D5/1252, ERN 01036276។

[652] សំណុំរឿង ០០៤/០១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តាន់ សាយ *ហៅ* ឃួន សាយ ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ

01575579



២៤៧. នៅពេលពិនិត្យរួមគ្នាទៅ ភ័ស្តុតាងគ្រប់គ្រាន់បានបង្ហាញថា ការចាប់ខ្លួន ការឃុំខ្លួន ការបាត់ខ្លួន និងការកាប់សម្លាប់ជាប្រចាំបានកើតឡើងជាប្រចាំនៅក្នុងឆ្នាំ ១៩៧៧ និងឆ្នាំ ១៩៧៨ នៅវត្តចម្ការខ្នុរ ក្រោមការគ្រប់គ្រងរបស់កម្មាភិបាលភូមិភាគនិរតី ដែលមានជនរងគ្រោះនៅទីនោះយ៉ាងហោចណាស់រាប់រយនាក់ ហើយសាកសពទាំងនោះត្រូវបានកប់ ឬ ទុកចោលខ្ចាត់ខ្ចាយនៅក្នុងបរិវេណវត្ត។

២៤៨. ដោយពិចារណាទៅលើសំអាងហេតុខាងលើ ចៅក្រមទទួលបន្ទុកលើរឿងក្តីជឿជាក់ថា យោងតាមបទដ្ឋានតម្រូវ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ដទៃទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ និងស្ថានភាពរស់នៅអមនុស្សធម៌ ត្រូវបានប្រព្រឹត្តឡើងនៅវត្តចម្ការខ្នុរ ក្នុងកំឡុងពេលនោះតែម្តង។ ចៅក្រមទទួលបន្ទុកលើរឿងក្តីបានរម្លឹកថា ចៅក្រមបានរកឃើញភ័ស្តុតាងគ្រប់គ្រាន់បង្ហាញអំពីការទទួលខុសត្រូវរបស់ អ៊ឹម ចែម នៅទីតាំងនេះ [653] ។ ចៅក្រមទទួលបន្ទុកលើរឿងក្តីយល់ឃើញថា ការចោទប្រកាន់ទាំងនេះគួរតែត្រូវបានបញ្ចូលនៅក្នុងបទចោទ និងបានពិចារណាយ៉ាងត្រឹមត្រូវក្នុងការវាយតម្លៃយុត្តាធិការបុគ្គលនៃ អ.វ.ត.ក ចំពោះករណី អ៊ឹម ចែម។ ករណីថាតើកំហុសទាំងនេះគឺជាមូលដ្ឋាននៃការវាយតម្លៃមែន ឬ មិនមែននោះ នោះនឹងត្រូវយកមកសម្រេចនៅក្នុងសេចក្តីសន្និដ្ឋានខាងក្រោម។

## គ. <u>មូលដ្ឋានទី៣៖ កំហុសដែលបានចោទប្រកាន់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមរូបភាពជាការសម្លាប់រង្គាល</u>

### ១. សារណា

២៤៩. សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សហចៅក្រមស៊ើបអង្កេតមានកំហុសអង្គច្បាប់នៅពេលសម្រេចថា ចេតនានៃបទឧក្រិដ្ឋសម្លាប់រង្គាលត្រូវតែបានបង្កើតឡើង *"ជាមុន"* និងមានកំហុសអង្គហេតុនៅពេលសម្រេចថា អ៊ឹម ចែម ពុំមានចេតនាឧក្រិដ្ឋដែលចាំបាច់សម្រាប់បទឧក្រិដ្ឋនៃការសម្លាប់រង្គាល ដែលបានចោទប្រកាន់ថាបានប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខភ្នំត្រយោង[654]។

២៥០. យោងតាមសហព្រះរាជអាជ្ញាអន្តរជាតិ គ្មានមូលដ្ឋានសមហេតុផលក្នុងការបញ្ចូលលក្ខខណ្ឌចេតនា*ជាមុន* ចំពោះការសម្លាប់រង្គាល ហើយលក្ខខណ្ឌបែបនេះមិនមាននៅក្នុងយុត្តិសាស្ត្ររបស់ អ.វ.ត.ក

---

២០១៣ ឯកសារ D118/25, ERN 00892223 (ឆ.២០-ឆ.២១)។

[653] *សូមមើល ខាងលើ* កថាខណ្ឌ ២០០ ។

[654] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៨ *យោងលើ*ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៨៤។

ឬ តុលាការអន្តរជាតិផ្សេងទៀតនោះទ[655] ។ គាត់អះអាងថា ការបង្ហាញនូវលក្ខខណ្ឌ *ជាមុន* បែបនេះ គឺ ដំឡើង*ធាតុផ្សំអត្តនោម័ត*នៃការសម្លាប់រង្គាល រហូតដូចនឹងផែនការគិតទុកជាមុន ឬ មើលឃើញជាមុនក្នុង ការកាប់សម្លាប់ទ្រង់ទ្រាយធំ[656] ។ លក្ខខណ្ឌបែបនេះនឹងកាន់តែពង្រឹងនិទណ្ឌភាព ហើយវាគ្មានសមហេតុ ផលឡើយ ឧទាហរណ៍ ក្នុងករណីដែលមេបញ្ជាការនៅក្នុងយុទ្ធនាការជាបន្តបន្ទាប់ បញ្ជាឱ្យសម្លាប់ក្រុម ប្រជាជនតូចៗ នៅរាល់ពេលដែលមានឱកាស[657] ។ ស្នូម្បីបទឧក្រិដ្ឋប្រល័យពូជសាសន៍ ដែលស្រដៀងគ្នា នឹងបទឧក្រិដ្ឋនៃការសម្លាប់រង្គាល ប៉ុន្តែមាន*ធាតុផ្សំអត្តនោម័តតឹងរឹងជាង*[658] ពុំទាមទារនូវចេតនា *ជាមុន* នោះឡើយ[659] ។

២៥១. សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានបន្ថែមទៀតថា ប្រសិនបើមិនដោយសារតែកំហុសរបស់ខ្លួន ក្នុងការសម្រេចថាភ័ស្តុតាងនៃចេតនាគិតទុកជាមុន គឺជាលក្ខខណ្ឌតម្រូវសម្រាប់ការសម្លាប់រង្គាលនោះ ការ រកឃើញអង្គហេតុរបស់សហចៅក្រមស៊ើបអង្កេតពិតជាគាំទ្រដល់ការរកឃើញថា អ៊ឹម ចែម ទទួលខុស ត្រូវចំពោះឧក្រិដ្ឋកម្មសម្លាប់រង្គាលនៅមន្ទីរសន្តិសុខភ្នំត្រយោង[660] ។ ដោយរម្លឹកឡើងវិញថា ការដឹងឮថាការ សម្លាប់ជាច្រើនកំពុងកើតឡើង ហើយការបន្តចូលរួមបង្ហាញឱ្យឃើញអំពីចេតនាសម្លាប់ក្នុងទ្រង់ទ្រាយធំ[661] គាត់ផ្តល់ទឡ្ហីករណ៍ថា លក្ខខណ្ឌតម្រូវ*ធាតុផ្សំអត្តនោម័ត*របស់ អ៊ឹម ចែម គឺពិតជាបង្ហាញយ៉ាងច្បាស់តាមរ យៈការរកឃើញពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់គាត់ចំពោះប្រតិបត្តិការនៃភ្នំត្រយោង និងការដឹងឮអំពី ការកាប់សម្លាប់ទ្រង់ទ្រាយធំ ដែលកំពុងកើតឡើងនៅទីនោះ[662] ។

២៥២. សហមេធាវីឆ្លើយតបថា សហចៅក្រមស៊ើបអង្កេតពុំមានកំហុសអង្គច្បាប់នៅក្នុងការកំណត់និយម ន័យ*ធាតុផ្សំអត្តនោម័ត*នៃការសម្លាប់រង្គាលនោះឡើយ ហើយបានអនុម័តច្បាប់យ៉ាងត្រឹមត្រូវដូចបានកំណត់

[655] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤០។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៣៩។

[656] ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៣៩៤០-។

[657] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤១។

[658] ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤០។

[659] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤២ ដល់ កថាខណ្ឌ ៤៤។

[660] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៥។ *សូមមើលផងដែរ* កថាខណ្ឌ ៣៩។

[661] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៥។ *យោងលើ* តុលាការ ICTR រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana*, ICTR-95-1-A សាលដីកា (សំអាងហេតុ) អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ១៩៤។

[662] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៥ ដល់ កថាខណ្ឌ ៤៦។

ដោយអង្គជំនុំជម្រះតុលាការកំពូល[663] ។ ពួកគេអះអាងថា សហចៅក្រមស៊ើបអង្កេតពុំមានចេតនាបង្ហាញនូវលក្ខខណ្ឌតម្រូវឱ្យមាន*ជាមុន*នោះទេ ប៉ុន្តែគ្រាន់តែចង់ដាក់នូវ "លក្ខខណ្ឌភស្តុតាងដ៏សមហេតុផល" នៅក្នុងកាលៈទេសៈនៃការចោទប្រកាន់ពាក់ព័ន្ធ ដែលវាស៊ីសង្វាក់គ្នាជាមួយនឹងបន្ទុក និងបទដ្ឋាននៃការបង្ហាញភស្តុតាង និងគោលការណ៍ពិរុទ្ធភាព[664] និងបទដ្ឋានវិធីសាស្ត្រអន្តរជាតិចំពោះបទឧក្រិដ្ឋ[665] ។ ជាការពិតសហចៅក្រមស៊ើបអង្កេត មិនអាចជឿជាក់ថា *ធាតុផ្សំអត្តនោម័ត*នៃការសម្លាប់រង្គាលត្រូវបានបង្កើតឡើងរួចហើយ ដោយគ្មានភស្តុតាងអំពីចេតនា*ជាមុន* ក្នុងការសម្លាប់ក្នុងទ្រង់ទ្រាយធំ ដែលឈានដល់កម្រិតមួយទាក់ទងនឹងភាពមិនប្រាកដប្រជានូវអត្តសញ្ញាណរបស់ចារីផ្ទាល់ និងទំនាក់ទំនងរវាងព្រឹត្តិការណ៍សម្លាប់ខុសៗគ្នានៅមន្ទីរសន្តិសុខភ្នំត្រយោង[666]។

២៩៣. លើសពីនេះ សហមេធាវីចោទប្រកាន់ថា បើទោះជាកំហុសអង្គច្បាប់ត្រូវបានបង្កើតឡើងក្តី ក៏សហព្រះរាជអាជ្ញាអន្តរជាតិខកខានមិនបានបង្ហាញឱ្យឃើញថា កំហុសនោះបានបង្កឱ្យមានការបំពានលើឆន្ទានុសិទ្ធិនោះឡើយ[667] ។ សហមេធាវីគូសបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេតបានពិចារណាថា ការកំណត់ប្រភេទបទល្មើសជាច្រើនដែលអាចមានសម្រាប់អង្គហេតុតែមួយ មិនបានបង្កើតភាពធ្ងន់ធ្ងរនៃសកម្មភាពរបស់ អ៊ឹម ចែម នោះឡើយ[668]។ ហេតុដូច្នេះ កំហុសណាមួយក៏ដោយពាក់ព័ន្ធនឹងការកំណត់បទចោទលើការកាប់សម្លាប់នៅមន្ទីរសន្តិសុខភ្នំត្រយោងថាជាការសម្លាប់រង្គាល នឹងពុំមានផលប៉ះពាល់ជាសត្យានុម័តលើការវាយតម្លៃយុត្តិធិការបុគ្គល ឬជាកត្តាកំណត់យ៉ាងសំខាន់នៃការវាយតម្លៃចុងក្រោយនោះឡើយ[669]។ វា

---

[663] ចម្លើយតប កថាខណ្ឌ ៧៧ ដល់ កថាខណ្ឌ ៧៩ *យោងលើ* ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៦៨។ សាលដីកា ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦("សំណុំរឿង ០០២/១ សាលដីកា (ឯកសារ F36)") កថាខណ្ឌ ៥២០ កថាខណ្ឌ ៥២២។

[664] ចម្លើយតប កថាខណ្ឌ ៧៩ ដល់ កថាខណ្ឌ ៨៤។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៧ (ឯកសារ D308/3/1/19/2.1) ទំព័រ ៣៧ ដល់ទំព័រ ៤៣។

[665] ចម្លើយតប កថាខណ្ឌ ៨២ និងលេខយោងជើងទំព័រ ១៦៨ ដល់ ១៦៩។ ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/2.1) ទំព័រ ៤០ ដល់ទំព័រ ៤២។

[666] ចម្លើយតប កថាខណ្ឌ ៨១ ដល់កថាខណ្ឌ ៨៤។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៧ (ឯកសារ D308/3/1/19/2.1) ទំព័រ ៣៧ ដល់ទំព័រ ៤០។

[667] ចម្លើយតប កថាខណ្ឌ ៨៥, កថាខណ្ឌ ៩០។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៧ (ឯកសារ D308/3/1/19/2.1) ទំព័រ ៤២ ដល់ទំព័រ ៤៤។

[668] ចម្លើយតប កថាខណ្ឌ ៨៦ *យោងលើ* ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣២៣។

[669] ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៧ (ឯកសារ D308/3/1/19/2.1) ទំព័រ ៤៤។

គ្រាន់តែជាការបង្ហាញនូវធាតុផ្សំផ្លូវច្បាប់ថ្មី ប៉ុន្តែពុំមែនជនរងគ្រោះថ្មីឡើយ ហើយវាមិនមានអ្វីក្រៅពីជាស្ថានទម្ងន់តិចតួចលើបទឧក្រិដ្ឋតែប៉ុណ្ណោះ[670]។

២៥៤. សហព្រះរាជអាជ្ញាអន្តរជាតិបានឆ្លើយតបថា អំណះអំណាងរបស់សហមេធាវីគឺមានលក្ខណៈមិនស៊ីសង្វាក់គ្នាយ៉ាងខ្លាំង[671] ហើយការកំណត់បទចោទលើចេតនា*មុនព្រឹត្តិការណ៍*ថាត្រឹមតែជា "ភស្តុតាងតម្រូវដ៏សមហេតុផល" គឺមានកំហុសទាំងអង្គហេតុ និងអង្គច្បាប់[672]។ ចំណុចទីមួយ គាត់គូសបញ្ជាក់ថាសហចៅក្រមស៊ើបអង្កេតបានប៉ាន់ស្មានថា អ្នកទោសជាង ២០០០ នាក់ ត្រូវបានអ្នកយាមគុកសម្លាប់ចោល ហើយ ប្រជាជនរាប់រយនាក់បានស្លាប់ដោយសារការអត់អាហារនៅភ្នំត្រយោងនៅចន្លោះពេលពីពាក់កណ្តាលឆ្នាំ ១៩៧៧ ដល់ខែ មករា ឆ្នាំ១៩៧៩ ហើយទាំងនោះមិនមែនជាហេតុការណ៍ព្រាវៗ ឬមិនមានទំនាក់ទំនងគ្នានោះឡើយ[673]។ អង្គហេតុដែលបានរកឃើញនៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) បង្ហាញយ៉ាងច្បាស់អំពីការជាប់ពាក់ព័ន្ធ និងចេតនារបស់ អ៊ឹម ចែម[674]។ ចំណុចទីពីរ ផ្ទុយនឹងការអះអាងដែលថា បទឧក្រិដ្ឋតម្រូវឱ្យបង្ហាញធាតុផ្សំចេតនា*ជាមុន*បន្ថែម ដោយផ្អែកលើកាលៈទេសៈនៃរឿងក្តី បទឧក្រិដ្ឋក្រោមច្បាប់ព្រហ្មទណ្ឌអន្តរជាតិពុំមាននិយមន័យខុសគ្នាដោយផ្អែកលើបរិបទនោះទេ[675]។ លក្ខខណ្ឌស្តីពីទ្រង់ទាយធំនៃការសម្លាប់រង្គាល អាចត្រូវបានបំពេញតាមរយៈការសម្លាប់ជាបន្តបន្ទាប់ ឬលំដាប់លំដោយនៃការប្រព្រឹត្ត[676]។

---

[670] ចម្លើយតប កថាខណ្ឌ ៨៧ ដល់ កថាខណ្ឌ ៨៩។

[671] ការឆ្លើយតប កថាខណ្ឌ ៤៦។

[672] ការឆ្លើយតប កថាខណ្ឌ ៤៧ *យោងលើ* ចម្លើយតប កថាខណ្ឌ ៨២។

[673] ការឆ្លើយតប កថាខណ្ឌ ៤៧ *យោងលើ* ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៨៩, កថាខណ្ឌ ២០៨ ដល់ កថាខណ្ឌ ២០៩, កថាខណ្ឌ ២២០។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤១ ដល់ ទំព័រ ៤២។

[674] ការឆ្លើយតប កថាខណ្ឌ ៤៧ *យោងលើ* ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៩២, កថាខណ្ឌ ១៩៥, កថាខណ្ឌ ២០០ ដល់ កថាខណ្ឌ ២០១, កថាខណ្ឌ ២១២។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤២ ដល់ ទំព័រ ៤៣។

[675] ការឆ្លើយតប កថាខណ្ឌ ៤៨។ ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤១។

[676] ការឆ្លើយតប កថាខណ្ឌ ៤៨ និងលេខយោងជើងទំព័រ ១៥១។

01575583



## ខ. ការពិភាក្សា

២៩៥. សតុផ្សំនៃការសម្លាប់រង្គាលដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសំណុំរឿង ០០២[677] ហើយត្រូវបានឆ្លុះបង្ហាញយ៉ាងត្រឹមត្រូវនៅក្នុងកថាខណ្ឌ ៦៨ នៃដីកាដំណោះស្រាយ (សំអាងហេតុ)៖

(ក) *ធាតុផ្សំសត្យានុម័ត៖* អំពើសកម្ម អំពើអកម្ម ឬ ការរួមបញ្ចូលនៃអំពើទាំងពីរនេះ ដែលនាំឱ្យមានការបាត់បង់ជីវិតមនុស្សក្នុងទ្រង់ទ្រាយធំ។ ការកំណត់ទៅលើការសម្លាប់រង្គាលមិនចាំបាច់បង្ហាញនូវចំនួននៃជនរងគ្រោះក្នុងកំរិតអប្បបរមាណាមួយនោះទេ។ លក្ខខណ្ឌតម្រូវនៃទ្រង់ទ្រាយធំត្រូវវាយតម្លៃទៅតាមករណីនីមួយៗ ដោយផ្អែកលើកត្តានៃពេលវេលា និងទីកន្លែងនៃការកាប់សម្លាប់ ការសម្រិតសម្រាំងជនរងគ្រោះ និងវិធីកំណត់គោលដៅជនរងគ្រោះ និងអំពើការសម្លាប់ដែលមានចេតនាសំដៅលើក្រុមរួមណាមួយ ជាជាងសំដៅតែទៅលើជនរងគ្រោះម្នាក់ៗ។

(ខ) *ធាតុផ្សំអត្តនោម័ត៖* ចេតនាសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ ឬ បង្ករបួសលើរូបរាងកាយធ្ងន់ធ្ងរ ឬ បង្កើតលក្ខខណ្ឌនៃការរស់នៅដែលនាំឱ្យមានការបំផ្លាញផ្នែកសំខាន់ណាមួយនៃក្រុមនោះ។ អក បាន.ត.ជ. គឺការសម្លាប់រង្គាលនៃសន្និដ្ឋានថា គោលបំណងដើម្បីលុបបំបាត់បុគ្គលដែលជាផ្នែកនៃក្រុមមួយ ដូច្នេះហើយ វាពុំសមស្របជាមួយនឹងសញ្ញាណនៃចេតនាប្រយោលទេ។ បន្ទាប់មក អង្គជំនុំជម្រះបានបញ្ជាក់ថា ទោះបីយ៉ាណាក្តី ការដឹង*អំពើពិរុទ្ធ*ខាននោះ មិនចាំបាច់ឡើយ ជាមិនជាក់ស្តាប់មនុស្សឱ្យមានការនឹងបង្ក ប៉ុន្តែអ្វីដែលច១ំបាច់នោះគឺ *"ការបង្ហាញថាការសម្លាប់សមាជិកនៃក្រុមមួយគឺជាចេតនារបស់ចារី ដោយពុំគិតពីបញ្ហាថាតើចារីបានដឹងច្បាស់ថា ការសម្លាប់នេះនឹងកើតមានឡើងជាក់ស្តែងដែរឬយ៉ាងណានោះឡើយ។ ការគ្រាន់តែដឹងថា មានការស្លាប់កើតឡើង ពុំគ្រប់គ្រាន់ឡើយ"*។[678]

---

[677] សាលដីកាសំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៥១៧ ដល់ កថាខណ្ឌ ៥២២, កថាខណ្ឌ ៥២៥ កថាខណ្ឌ ៥២៧ កថាខណ្ឌ ៥៥១។

[678] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៦៨ (លេខយោងជើងទំព័រ លុបចោល)។ *សូមមើលផងដែរ* តុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Krstić*, IT-98-33-T, សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០០១ ("សាលក្រមក្នុងរឿងក្តី *Krstič*") កថាខណ្ឌ ៤៩៥ ដល់ កថាខណ្ឌ ៥០៤។ តុលាការ ICTR រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Ntakirutimana និង Ntakirutimana* ICTR-96-17-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ៥១៦ កថាខណ្ឌ ៥២២។ តុលាការ ICTR រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Gacumbitsi*, ICTR-2001-64-A, សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៦ កថាខណ្ឌ ៨៦។ តុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត*, IT-05-88-T, សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ ("សាលក្រមក្នុងរឿងក្តី *Popovič*") កថាខណ្ឌ ៨០០ ដល់ កថាខណ្ឌ ៨០៦។ តុលាការ ICTR រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Munyakazi*, ICTR-97-36A-

២៥៦. ទោះបីជាយ៉ាងនេះក្តី សហចៅក្រមស៊ើបអង្កេតបានសម្រេចនៅក្នុងកថាខណ្ឌ ២៨៨ នៃដីកាដំណោះស្រាយ (សំអាងហេតុ) ថា៖

> ចំពោះការសម្លាប់ទាំងអស់ដែលត្រូវបានប្រព្រឹត្តឡើងជាប្រចាំនៅមន្ទីរសន្តិសុខភ្នំត្រយោងនោះ ចំនួននៃការសម្លាប់សរុបរួមបានឈានដល់លក្ខខណ្ឌនៃទ្រង់ទ្រាយធំ។ ពួកគេទាំងនោះត្រូវបានសម្លាប់ដោយសារមូលហេតុដូចគ្នា គឺអាកប្បកិរិយាដែលផ្ទុយទៅនឹងមនោគមន៍វិជ្ជា និងគោលនយោបាយរបស់ បក។ ទោះជា.ក. ដោយចារីឡើងធ្វើជារយៈពេលយូរ ហើយប្រហែលក្នុងងនេះក្តី ការសម្លាប់ទាំងអស់នេះត្រូវបានធ្វើឡើងយ៉ាធ្វើឱ្យមានភាពទាំងអស់នេះផង។ កាលៈទេសៈផ្សេងៗគ្នាផ្ទាល់មិនច្បាស់លាស់ថាតើ ការសម្លាប់ទាំងនេះត្រូវបានធ្វើឡើងដោយចេតនាសម្លាប់ជាទ្រង់ទ្រាយធំដែរឬយ៉ាងណា។ ហេតុដូច្នេះ យើងជឿថា មិនមានមូលដ្ឋានសមហេតុផលឱ្យជឿបានថា ការស្លាប់ទាំងអស់នេះបន្ថែមលើការធ្វើមនុស្សឃាត គឺជាការសម្លាប់រង្គាលនោះឡើយ[679]។

២៥៧. ចៅក្រមដែលទទួលបន្ទុករឿងក្តីនេះសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតយោងលើ "ចេតនាជា*មុន*" របស់ចារីម្តងនៅក្នុងកថាខណ្ឌ ២៨៨ នេះ ហើយពុំបានពន្យល់ថាតើវាពាក់ព័ន្ធតាមរបៀបណាទៅនឹងនិយមន័យនៃ*ធាតុផ្សំអត្តនោម័ត*នៃការសម្លាប់រង្គាលដូចបានលើកឡើងនៅក្នុងកថាខណ្ឌ ៦៨។ ទោះបីជាយ៉ាងនេះក្តី សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានយ៉ាងច្បាស់ថា ការស្លាប់ទាំងនោះពុំមែនជាការសម្លាប់រង្គាលនោះទេ ពីព្រោះវាពុំបង្ហាញច្បាស់ថាតើការសម្លាប់ក្នុងទ្រង់ទ្រាយនៅភ្នំត្រយោងត្រូវបានអនុវត្តដោយមានចេតនា*ជាមុន* ដើម្បីសម្លាប់ក្នុងទ្រង់ទ្រាយធំដែរ ឬយ៉ាងណា ក្រោយពីពិចារណាឃើញថា ការសម្លាប់ទាំងអស់នេះត្រូវបានប្រព្រឹត្តឡើងក្នុងរយៈពេលយូរ ដោយចារីផ្ទាល់ផ្សេងៗគ្នា។ ហេតុដូច្នេះ តាមរយៈការអានធម្មតាៗនូវកថាខណ្ឌ ២៨៨ នេះ ចៅក្រមដែលទទួលបន្ទុកលើរឿងក្តីនេះ ទាញការសន្និដ្ឋានបានថា សហចៅក្រមស៊ើបអង្កេតបានចាត់ទុកចេតនា*ជាមុន*ថាមិនមែនត្រឹមតែជា "លក្ខខណ្ឌតម្រូវភស្តុតាង"នោះទេ ប៉ុន្តែវាជាធាតុផ្សំផ្លូវច្បាប់នៃការសម្លាប់រង្គាល ដែលត្រូវបង្ហាញភស្តុតាង។

---

A, សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១១ ("សាលដីកាក្នុងរឿងក្តី *Munyakazi*") កថាខណ្ឌ ១៤១ ដល់ កថាខណ្ឌ ១៤២។ តុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Lukić និង Lukić*, IT-98-32/1-A, សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២ ("សាលដីកាក្នុងរឿងក្តី *Lukić និង Lukić*") កថាខណ្ឌ ៥៣៦ និង កថាខណ្ឌ ៥៣៨។ តុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Tolimir*, IT-05-88/2-A, សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៥ កថាខណ្ឌ ១៤៦។

[679] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៨៨ (ការគូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* កថាខណ្ឌ ១៨៩ ដល់ កថាខណ្ឌ ២២៣។

២៥៨. ចៅក្រមទទួលបន្ទុកលើរឿងក្ដីនេះសូមរំលឹកថា ធាតុផ្សំនៃការសម្លាប់រង្គាលពុំរួមបញ្ចូលលក្ខខណ្ឌដែលថា *ធាតុផ្សំអត្តនោម័ត*អាចត្រូវបានបង្កើតឡើងនៅមុនពេលប្រព្រឹត្តអំពើពាក់ព័ន្ធ[680] ។ ចំពោះចេតនាជាក់លាក់នៃបទប្រល័យពូជសាសន៍វិញ[681] បញ្ហាចោទមិនមែនថាតើមាន ឬមិនមានចេតនាចាំបាច់នៅមុនពេលប្រព្រឹត្តអំពើនោះទេ ប៉ុន្តែថាតើជារីមានចេតនានេះនៅក្នុងពេលប្រព្រឹត្តបទសម្លាប់រង្គាលដែរឬទេ។ យ៉ាងច្រើនបំផុត ភ័ស្តុតាងនៃការគិតទុកជាមុនអាចជាភ័ស្តុតាងនៃចេតនា ប៉ុន្តែមិនអាចជាបន្ទុកត្រូវបង្ហាញនោះឡើយ។ ហេតុដូច្នេះ នៅពេលសម្រេចថា គ្មានមូលដ្ឋានសមហេតុផលអាចជឿជាក់បានថា ការកាប់សម្លាប់នៅមន្ទីរសន្តិសុខភ្នំត្រយោងគឺជាការសម្លាប់រង្គាល ដោយសារវាពុំបង្ហាញច្បាស់ថាតើ ការកាប់សម្លាប់ទាំងនេះត្រូវបានប្រព្រឹត្តឡើងដោយមានចេតនា*ជាមុន*ដើម្បីសម្លាប់ក្នុងទ្រង់ទ្រាយធំដែរ ឬយ៉ាងណា សហចៅក្រមស៊ើបអង្កេតបានដាក់បញ្ចូលដោយមិនត្រឹមត្រូវនូវធាតុផ្សំផ្លូវច្បាប់បន្ថែមមួយថ្មីទៅក្នុង*ធាតុផ្សំអត្តនោម័ត*នៃបទឧក្រិដ្ឋ។

២៥៩. នៅពេលនេះ ចៅក្រមទទួលបន្ទុកលើរឿងក្ដីនេះនឹងពិចារណាថា តើអ្នកវិនិច្ឆ័យលើអង្គហេតុដោយមិនលម្អៀង ដែលអនុវត្តនិយមន័យត្រឹមត្រូវចំពោះ*ធាតុផ្សំអត្តនោម័ត*នៃការសម្លាប់រង្គាល អាចសន្និដ្ឋានបានថា គ្មានមូលដ្ឋានសមហេតុផលអាចជឿជាក់ថា អ៊ឹម ចែម មានចេតនាដែលច្បាប់តម្រូវក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមរូបភាពជាការសម្លាប់រង្គាលនៅមន្ទីរសន្តិសុខភ្នំត្រយោង ឬយ៉ាងណា។

២៦០. ចៅក្រមទទួលបន្ទុកលើរឿងក្ដីនេះសូមរំលឹកថា ការវាយតម្លៃលើលក្ខខណ្ឌនៃទ្រង់ទ្រាយធំ ត្រូវធ្វើឡើងទៅតាមករណីនីមួយៗ ដោយត្រូវពិចារណាកាលៈទេសៈដែលការសម្លាប់បានកើតឡើងរួមជាមួយនឹងកត្តាពាក់ព័ន្ធ *ក្នុងនោះ* រួមមាន ពេលវេលា និងទីកន្លែងសម្លាប់ ការជ្រើសរើសជនរងគ្រោះ បែបផែននៃការកំណត់គោលដៅលើជនរងគ្រោះ ហើយថាតើការកាប់សម្លាប់ទាំងនោះសំដៅលើក្រុមរួមមួយ ឬ ជនរងគ្រោះដោយឡែកណាមួយ[682] ។ ព្រឹត្តិការណ៍នៃការសម្លាប់ដាច់ដោយឡែកពីគ្នាអាចប្រមូលបញ្ចូលគ្នាក្នុង

---

[680] *សូមមើលខាងលើ* កថាខណ្ឌ ២៥៥ ។

[681] *សូមមើល ឧ.*តុលាការ ICTR រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Simba*, ICTR-01-76-A, សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ២៦៦។ សាលដីកាក្នុងរឿងក្ដី *Munyakazi* កថាខណ្ឌ ១៤២។ សាលក្រមក្នុងរឿងក្ដី *Krstić* កថាខណ្ឌ ៥៧២។

[682] សាលដីកាក្នុងសំណុំរឿង ០០២ ឯកសារ)F36) កថាខណ្ឌ ៥៥១។ *សូមមើល ឧ.*តុលាការ ICTY រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Stanišić និង Župljanin*, IT-08-91-A, សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ ("សាលដីកាក្នុងរឿងក្ដី *Stanišić* និង *Župljanin*") កថាខណ្ឌ ១០២២ កថាខណ្ឌ ១០២៧។ សាលដីកាក្នុងរឿងក្ដី *Lukić និង Lukić* កថាខណ្ឌ ៥៣៨ កថាខណ្ឌ ៥៤២ ។ សាលក្រមក្នុងរឿងក្ដី *Popović* កថាខណ្ឌ ៨០៤ ដល់ កថាខណ្ឌ ៨០៥។ តុលាការ ICTR

01575586



គោលបំណងបំពេញលក្ខខណ្ឌនៃទ្រង់ទ្រាយធំ ប្រសិនបើវាត្រូវបានចាត់ទុកថាជាផ្នែកមួយនៃប្រតិបត្តិការតែមួយ[683]។ លក្ខខណ្ឌនៃទ្រង់ទ្រាយធំនេះមានជាប់មកជាមួយនឹង*ធាតុផ្សំអត្តនោម័ត* និង*ធាតុផ្សំសត្យានុម័ត*[684] ហេតុដូច្នេះហើយ កត្តាទាំងនោះក៏ជាប់ពាក់ព័ន្ធផងដែរសម្រាប់បង្ហាញនូវចេតនាសម្លាប់ក្នុងទ្រង់ទ្រាយធំ[685]។

២៦១. ចៅក្រមទទួលបន្ទុករឿងក្ដីនេះសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតបានពិចារណាថា ធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបង្ហាញចំពោះបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងតំបន់ ៥ ហើយវាពាក់ព័ន្ធនឹងមូលដ្ឋានបណ្ដឹងឧទ្ធរណ៍មួយនេះ[686]។ ចៅក្រមទទួលបន្ទុកទាំងនេះក៏បានយល់ឃើញយ៉ាងច្បាស់ផងដែរថា ការសម្លាប់ដែលបានប្រព្រឹត្តឡើងជាទៀងទាត់នៅមន្ទីរសន្តិសុខភ្នំត្រយោង ទោះបីជាត្រូវបានធ្វើឡើងក្នុងអំឡុងពេលដ៏យូរមួយ ហើយប្រហែលជាត្រូវបានប្រព្រឹត្តដោយចារីផ្ទាល់ផ្សេងៗគ្នាក៏ដោយ បានបង្កើតជាផ្នែកនៃប្រតិបត្តិការរួមមួយ និង "បានបំពេញលក្ខខណ្ឌអប្បបរមានៃទ្រង់

---

រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង* Nyiramasuhuko *និងអ្នកផ្សេងទៀត*, ICTR-98-42-A, សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ("*សាលដីកាក្នុងរឿងក្ដី* Nyiramasuhuko") កថាខណ្ឌ ២១២៣ ដល់ កថាខណ្ឌ ២១២៦។

[683] សាលដីកាក្នុងរឿងក្ដី *Stanišić និង Župljanin* កថាខណ្ឌ ១០២២ កថាខណ្ឌ ១០២៥។ សាលដីកាក្នុងរឿងក្ដី *Nyiramasuhuko* សាលដីកា កថាខណ្ឌ ២១២៥ *យោងលើ* តុលាការ ICTR រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Bagosora* និង *Nsengiyumva*, ICTR-98-41-A, សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ កថាខណ្ឌ ២៩៦។

[684] សាលដីកាសំណុំរឿង ០០២ (ឯកសារ F36) កថាខណ្ឌ ៥២៥ ("អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការសម្លាប់រង្គាលជាទូទៅត្រូវបានកំណត់និយមន័យថា ជា "ការសម្លាប់ក្នុងទ្រង់ទ្រាយធំ"។ ដូច្នេះ ធាតុផ្សំនៃការសម្លាប់ក្នុងទ្រង់ទ្រាយធំនេះ គឺជាផ្នែកមួយនៅក្នុងសញ្ញាណនៃការសម្លាប់រង្គាល។ ធាតុផ្សំនេះមានអត្ថិភាពទាំង ធាតុអត្តនោម័ត និងធាតុសត្យានុម័ត ដែលមានន័យថា ការសម្លាប់ត្រូវតែកើតឡើងក្នុងទ្រង់ទ្រាយធំ និងចារីត្រូវតែដឹងអំពីការសម្លាប់ក្នុងទ្រង់ទ្រាយធំនេះ។ អង្គជំនុំជម្រះតុលាការកំពូលរំឭកអំពីការកំណត់ថា បទសម្លាប់រង្គាលតម្រូវឱ្យមានការបង្ហាញឱ្យឃើញនូវចេតនាផ្ទាល់ក្នុងការសម្លាប់ដែលមានន័យថា ចេតនាប្រយោល គឺមិនគ្រប់គ្រាន់នោះឡើយ")។

[685] ឧទាហរណ៍ នៅក្នុងសាលក្រមក្នុងរឿងក្ដី *Popović* ត្រង់កថាខណ្ឌ ៨០៤ ដល់ កថាខណ្ឌ ៨០៥ អង្គជំនុំជម្រះរកឃើញថា ព្រឹត្តិការណ៍សម្លាប់ត្រូវបានប្រព្រឹត្តឡើងនៅតាមទីតាំងជាច្រើននៅក្នុងតំបន់ភូមិសាស្ត្រតែមួយ និងដោយចារីផ្ទាល់ខុសៗគ្នា ប៉ុន្តែពិចារណាឃើញថា ព្រឹត្តិការណ៍សម្លាប់ដោយឡែកពីគ្នាបង្កើតបានជាផ្នែកនៃប្រតិបត្តិការណ៍តែមួយ នៅពេលពិចារណាលើ "ពេលវេលា និងទីតាំងភូមិសាស្ត្រនៃការកាប់សម្លាប់ ភាពស្រដៀងគ្នារវាងព្រឹត្តិការណ៍ទាំងនោះ និងលក្ខណៈនៃការរៀបចំ និងសម្របសម្រួលដែលកងកម្លាំងបូស្នៀ-ស៊ែប បានអនុវត្ត" ។ អង្គជំនុំជម្រះសន្និដ្ឋានថា វាបង្ហាញច្បាស់ "តាមរយៈភ័ស្តុតាងថា កងកម្លាំងបូស្នៀ-ស៊ែប មានចេតនាសម្លាប់បុរសជនជាតិមូស្លីមស៊ែបដែលពេញកម្លាំងពីទីកដីសេប្រេនីសាក្នុងទ្រង់ទ្រាយធំ"។

[686] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៨១ ដល់ កថាខណ្ឌ ២៨៤។

ទ្រាយធំ"[687]។ ចៅក្រមទាំងនេះបានប៉ាន់ស្មានថា អ្នកទោសជាង ២.០០០ នាក់ ត្រូវបានសម្លាប់នៅក្នុងឆ្នាំ ១៩៧៧-១៩៧៩ ដោយប្រភេទចារីតែមួយ ពោលគឺ អ្នកយាមគុកប្រដាប់ដោយអាវុធ[688] នៅមន្ទីរសន្តិសុខនោះ ឬ នៅក្នុងបរិវេណមន្ទីរ[689] ការកាប់សម្លាប់ទាំងនោះត្រូវបានរៀបចំ និងសម្របសម្រួល ប្រព្រឹត្តឡើងក្រោមកាលៈទេសៈស្រដៀងគ្នា [690] ហើយជនរងគ្រោះត្រូវបានកំណត់គោលដៅរួមគ្នា និងជ្រើសរើសក្នុងលក្ខណៈជាប្រព័ន្ធ[691] ដោយផ្អែកលើហេតុផលស្រដៀងគ្នា ពោលគឺ "ឥរិយាបថផ្ទុយនឹងមនោគមន៍វិជ្ជា និងគោលនយោបាយ ប.ក.ក"[692]។

២៦២. ចៅក្រមទទួលបន្ទុកលើរឿងក្តីនេះកត់សម្គាល់បន្ថែមទៀតចំពោះការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតអំពីសកម្មភាព ចម្លើយ និងតួនាទីដឹកនាំរបស់ អ៊ឹម ចែម[693]។ ជាពិសេស សហចៅក្រមស៊ើបអង្កេត បានប៉ាន់ស្មានថា មានភស្តុតាងអាចទុកចិត្តបានបង្ហាញថា អ៊ឹម ចែម មានសិទ្ធិអំណាចទូទៅលើប្រជាជនដែលជាប់ឃុំនៅភ្នំត្រយោង និងសិទ្ធិអំណាចបញ្ជាឱ្យសម្លាប់[694]។ ចៅក្រមទទួលបន្ទុកលើរឿងក្តីនេះបានពិចារណាលើភស្តុតាងដែលថា អ៊ឹម ចែម មើលការខុសត្រូវលើប្រតិបត្តិការនៃមន្ទីរសន្តិសុខ បាន

---

[687] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៨១ ដល់ កថាខណ្ឌ ២៨៨។

[688] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៨៩, កថាខណ្ឌ ១៩៦, កថាខណ្ឌ ២០៥ ដល់ កថាខណ្ឌ ២០៧, កថាខណ្ឌ ២០៩ ("អ្នកយាមអួតអាងអំពីការសម្លាប់អ្នកទោស និងអួតក្នុងចំណោមគ្នាឯងថាតើនរណាអាចសម្លាប់អ្នកទោសបានច្រើនជាងគេ"។

[689] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៨៩, កថាខណ្ឌ ២១៨, កថាខណ្ឌ ២១៩ ដល់ កថាខណ្ឌ ២២០។ អង្គបុរេជំនុំជម្រះសូមរំលឹកថា ("ពុំមានការកំណត់អំពីតួលេខអប្បបរមាទេ។ ការសម្លាប់រង្គាលត្រូវបានយល់ឃើញថា បានប្រព្រឹត្តឡើងទាក់ទងទៅនឹងការសម្លាប់រាប់ពាន់ ឬប្រហាក់ប្រហែលតិចជាង ៦០ នាក់"។ *សូមមើល* សាលដីកាសំណុំរឿង ០០២ (ឯកសារ F36) កថាខណ្ឌ ៥៥១ *យោងលើ* សាលដីកាក្នុងរឿងក្តី *Lukić និង Lukić* កថាខណ្ឌ ៥៣៧។ តុលាការ ICTR រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Ndahimana*, ICTR-01-68-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៣ កថាខណ្ឌ ២៣១។

[690] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២០៣, កថាខណ្ឌ ២០៨ ដល់ កថាខណ្ឌ ២០៩, កថាខណ្ឌ ២១១។

[691] *សូមមើល ឧ.* ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៩៧, កថាខណ្ឌ ២០០, កថាខណ្ឌ ២០២។

[692] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៨៨។

[693] *សូមមើល* ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៩៧, កថាខណ្ឌ ២០០, កថាខណ្ឌ ២១៧, កថាខណ្ឌ ២២២, កថាខណ្ឌ ៣០៦ ដល់ កថាខណ្ឌ ៣១១។ *សូមមើលផងដែរ សាលដីកាក្នុងរឿងក្តី Munyakazi កថាខណ្ឌ ១៤២ (ទាញការសន្និដ្ឋានអំពីចេតនាចេញពីការចូលរួមរបស់បុគ្គល និងតួនាទីដឹកនាំ)*។

[694] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៧៥។

ចេញបទបញ្ជា បានចេញបញ្ជាឱ្យទៅប្រធានមន្ទីរ ដែលរាយការណ៍ផ្ទាល់ទៅគាត់វិញ[695] រួមទាំង បញ្ជាឱ្យចាប់ខ្លួន[696] និងបានចុះពិនិត្យមើលមន្ទីរ ឬ បញ្ជូននិរសាឱ្យទៅមើលរៀងរាល់ ២ ឬ ៣ ថ្ងៃម្តង[697]។ ដោយរម្លឹកឡើងវិញថា ការសន្និដ្ឋានអំពី *ធាតុផ្សំអត្តនោម័ត* អាចទាញចេញពីកាលៈទេសៈនានានោះ[698] ចៅក្រមទទួលបន្ទុកលើរឿងក្តីនេះពិចារណាឃើញថា មានមូលដ្ឋានសមហេតុផលអាចជឿជាក់ថា អ៊ឹម ចែម មានចេតនាសម្លាប់ក្នុងទ្រង់ទ្រាយធំ ដែលបានបង្ហាញភស្តុតាងតាមរយៈតួនាទី និងការបន្តចូលរួមនៅក្នុងព្រឹត្តការណ៍នៃកាប់សម្លាប់ ដែលប្រការនេះ បើទោះជាប្រព្រឹត្តក្នុងរយៈពេលយូរមួយ និងដោយចារីផ្សេងៗគ្នាក៏ដោយ គឺជាផ្នែកនៃប្រតិបត្តិការតែមួយ ហើយបានបំពេញធាតុផ្សំអប្បបរមានៃទ្រង់ទ្រាយធំ។

២៦៣. យោងតាមសំអាងហេតុខាងលើ ចៅក្រមទទួលបន្ទុកលើរឿងក្តីនេះយល់ឃើញថា ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនបានកំណត់ធាតុផ្សំផ្លូវច្បាប់មិនត្រឹមត្រូវអំពីចេតនា*ជាមុន*ទនោះ ម្ល៉េះសេចក្តីសន្និដ្ឋានសមហេតុសមផលតែមួយគត់នោះគឺ មានមូលដ្ឋានសមហេតុសមផលអាចជឿជាក់ថា អ៊ឹម ចែម មាន*ធាតុផ្សំអត្តនោម័ត*ដែលច្បាប់តម្រូវសម្រាប់ការកាប់សម្លាប់។ ផលប៉ះពាល់នៃកំហុសនទៅលើការយល់ឃើញថា អ៊ឹម ចែម មិនស្ថិតនៅក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត និងពុំបានបំពេញយុត្តាធិការបុគ្គលនៅក្នុងតុលាការនេះ នឹងត្រូវបកស្រាយនាពេលក្រោយ។

### **<u>ឃ. មូលដ្ឋានទី៤៖ កំហុសដែលបានបានចោទប្រកាន់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមអំពើអមនុស្សធម៌ផ្សេងទៀតតាមរយៈការបាត់ខ្លួនដោយបង្ខំ</u>**

#### ១. សារណា

២៦៤. សហព្រះរាជអាជ្ញាអន្តរជាតិចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតមានកំហុសដោយខកខានមិនបានសម្រេចថា បទឧក្រិដ្ឋនៃការបាត់ខ្លួនដោយបង្ខំដែលជាអំពើអមនុស្សធម៌ផ្សេងទៀត បានកើតឡើងនៅការដ្ឋានប្រឡាយស្ពានស្រែង[699] ។ សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេត

[695] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៩៥។ *សូមមើលផងដែរ* កថាខណ្ឌ ២០០។

[696] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២០០។

[697] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២២២។

[698] *សូមមើល ឧ.* សាលដីកាក្នុងរឿងក្តី *Munyakazi* កថាខណ្ឌ ១៩២ )"អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ចេតនារបស់ជនជាប់ចោទក្នុងការចូលរួមនៅក្នុងបទឧក្រិដ្ឋ អាចសន្និដ្ឋានចេញពីភស្តុតាងប្រយោល រួមទាំង ការចូលរួមដ៏សកម្មរបស់គាត់នៅក្នុងការវាយប្រហារ") ("លេខយោងជើងទំព័រត្រូវបានលុបចោល" )។

[699] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៧ ដែលយោងលើ ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣០២។

01575589



អនុវត្តខុសលើនិយមន័យនៃបទឧក្រិដ្ឋថ្មីនៃការបាត់ខ្លួនដោយបង្ខំ ដែលពុំមានអត្ថិភាពនៅក្នុងឆ្នាំ១៩៧៥ មិនមែនជាគុណធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងទៀតដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ [700] ហើយ សហចៅក្រមស៊ើបអង្កេតមានកំហុសដោយសារតម្រូវឱ្យបង្ហាញភស្តុតាងថា បុគ្គលបានស្វែងរកព័ត៌មានអំពីបុគ្គលដែលបានបាត់ខ្លួនដោយបង្ខំ ដោយពុំបានពិចារណាលើតថភាពជាក់ស្តែងនៃ ប.ក.ក[701]។

២៦៥. សហព្រះរាជអាជ្ញាអន្តរជាតិផ្តល់ទឡ្ហីករណ៍តវ៉ាជាក់លាក់ថា សហចៅក្រមស៊ើបអង្កេតគួរតែអនុវត្តធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងទៀត ដែលត្រូវបានកំណត់និយមន័យដោយអង្គជំនុំជម្រះតុលាការកំពូល ថាជាអំពើដែល "រំលោភបំពានលើសិទ្ធិជាសារវន្តរបស់ជនរងគ្រោះ ហើយមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងអំពើជាក់លាក់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សមនុស្សជាតិ" [702] ។ ហេតុដូច្នេះ វាជាកំហុស ដែលពុំបានកំណត់បទចោទនៃការបាត់ខ្លួនដោយបង្ខំនៅការដ្ឋានប្រឡាយស្ពានស្រែង ថាជាអំពើអមនុស្សធម៌ផ្សេងទៀត ដោយផ្អែកលើសំអាងហេតុតែមួយគត់ថា គ្មានភស្តុតាងនៃការសាកសួរទៅកម្មាភិបាល ពីគ្រួសារអ្នកធ្វើការដែលបានបាត់ខ្លួនឡើយ[703]។ នេះជាកត្តាពុំពាក់ព័ន្ធ ហើយប្រសិនបើសហចៅក្រមស៊ើបអង្កេតបានអនុវត្តនិយមន័យត្រឹមត្រូវ អ៊ឹម ចែម ប្រហែលជាត្រូវបានពិចារណាថាទទួលខុសត្រូវលើការបាត់ខ្លួនដោយបង្ខំបាត់ទៅហើយ[704]។ សហព្រះរាជអាជ្ញាអន្តរជាតិបានសំអាងលើការរកឃើញថា ការចាប់ខ្លួន និងការបាត់ខ្លួនអ្នកធ្វើការដោយបង្ខំ គឺជាហេតុការណ៍កើតឡើងជាទូទៅទៅហើយនៅការដ្ឋានប្រឡាយស្ពានស្រែង ហើយក៏បានសំអាងលើការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១ ថា ការបាត់ខ្លួនដោយបង្ខំគឺជាអំពើអមនុស្សធម៌ផ្សេងទៀត បើពិនិត្យមើលការឈឺចាប់ធ្ងន់ធ្ងរកើតឡើងលើជនរងគ្រោះនោះ[705]។

---

[700] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៧ ដល់ កថាខណ្ឌ ៥១ ដែលយោងលើ សាលដីកាលើសំណុំរឿង ០០២ (ឯកសារ F36) កថាខណ្ឌ ៥៨៩។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤១-៤២។

[701] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៧ កថាខណ្ឌ ៥២ ដល់ កថាខណ្ឌ ៥៧។

[702] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៩។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤១-៤២។

[703] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៩។ ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤២-៤៣។

[704] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥១។ ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤៣។

[705] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥១ ដែលយោងលើ ដីកាដំណោះស្រាយ កថាខណ្ឌ ២៣៨ កថាខណ្ឌ ៣០២។ សំណុំរឿង ០០២/១ សាលក្រមលើសំណុំរឿង ០០២/០១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ("សាលក្រមសំណុំរឿង ០០២ (ឯកសារ E313)") កថាខណ្ឌ ៦៤៣។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤៣-

២៦៦.ម្យ៉ាងវិញទៀត បើទោះជាគ្មានការកំណត់បទចោទបែបនេះក៏ដោយ វាក៏ជាកំហុសផងដែរក្នុងការតម្រូវទាមទារនូវធាតុផ្សំបទល្មើសមួយថា បុគ្គលទាងនោះត្រូវស្វះរកទីតាំងជនរងគ្រោះ ដែលវាពុំសមហេតុផលនៅក្នុងបរិបទនៃកាលៈទេសៈចាប់បង្ខំយ៉ាងខ្លាំង ដូចជា កាលៈទេសៈទាំងឡាយដែលកើតឡើងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ [706] ។ កាលៈទេសៈទាំងនោះត្រូវយកមកពិចារណាដើម្បីធានាថា ច្បាប់អាចអនុវត្តបាន ដូចបានគាំទ្រដោយច្បាប់យុត្តិសាស្ត្រនៃតុលាការសិទ្ធិមនុស្សអន្តរអាមេរិកាំង (តុលាការ "IACtHR") [707] ។

២៦៧. សហមេធាវីឆ្លើយតបថា បណ្តឹងឧទ្ធរណ៍បកស្រាយខុសលើវិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតចំពោះនិយមន័យនៃការបាត់ខ្លួនដោយបង្ខំ ហើយសហព្រះរាជអាជ្ញាអន្តរជាតិខកខានមិនបានផ្តល់ទទ្បីករណ៍តវ៉ា ឬ បង្ហាញភ័ស្តុតាងអំពីការបំពានឆន្ទានុសិទ្ធិនោះឡើយ [708] ។ សហមេធាវីគូសបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តត្រឹមត្រូវនូវនិយមន័យរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពីអំពើអមនុស្សធម៌ផ្សេងទៀត ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយបានរំលឹកថា ការបាត់ខ្លួនដោយបង្ខំអាចកំណត់បទចោទដូច្នេះបាន [709] ។ នៅក្នុងបរិបទនេះ សហចៅក្រមស៊ើបអង្កេតពុំមានកំហុសនៅក្នុងការពិចារណាលើភ័ស្តុតាងនៃការសាកសួរពីបុគ្គលទាំងនោះអំពីជោគវាសនារបស់ជនរងគ្រោះ ថាវាពុំមែនជាធាតុផ្សំបន្ថែមនៃបទល្មើសនោះទេ ប៉ុន្តែ ដោយសារសហចៅក្រមបានពិចារណាវាចាំបាច់ក្នុងការញែកឱ្យដាច់រវាងការបាត់ខ្លួនដោយបង្ខំ ចេញពីអំពើអមនុស្សធម៌ផ្សេងទៀតទៅតាមករណីនីមួយៗ [710] ។

---

៥៤។

[706] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៧ កថាខណ្ឌ ៥២ ដល់ កថាខណ្ឌ ៥៤។

[707] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៣ ដល់ កថាខណ្ឌ ៥៥ ដែលយោងលើ តុលាការសិទ្ធិមនុស្សអន្តរទ្វីបអាមេរិកកាំង ("តុលាការ IACtHR" រឿងក្តី *Velásquez- Rodríguez v. Honduras, Series C, No. 4* តទល់នឹង ហុងឌូរ៉ាស់ សាលដីកា (អង្គសេចក្តី) ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៨៨ កថាខណ្ឌ ១២៦។ តុលាការ IACtHR រឿងក្តី *Godínez-Cruz v. Honduras, Series C, No. 5,* តទល់នឹង ហុងឌូរ៉ាស់ សាលដីកា (អង្គសេចក្តី) ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៨៩ កថាខណ្ឌ ៧៦។ តុលាការ IACtHR រឿងក្តី *Caballero-Delgado and Santana* តទល់នឹង កូឡុំប៊ី សាលដីកា (អង្គសេចក្តី) ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៩៥ កថាខណ្ឌ ៧២(៥)។

[708] ចម្លើយតប កថាខណ្ឌ ៩៣។

[709] ចម្លើយតប កថាខណ្ឌ ៩៤ ដែលយោងលើ ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៧៤ ដល់ កថាខណ្ឌ ៧៥។ ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/2.1) ទំព័រ ៤៣-៤៣។

[710] ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/2.1) ទំព័រ ៤៣-៤៥។ សូមមើលផងដែរ ទំព័រ ៤៦-៤៧។

២៦៨. លើសពីនេះ សហមេធាវីតវ៉ាថា ការសំអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិលើច្បាប់យុត្តិសាស្ត្ររបស់តុលាការ IACtHR ដែលមានវិធីសាស្ត្រផ្សេងមួយចំពោះបន្ទុកនៃការបង្ហាញភ័ស្តុតាង [711] ហើយអះអាងថា វាមិនមែនបើកឱ្យសហចៅក្រមស៊ើបអង្កេតត្រឹមតែសន្មតថា ហេតុការណ៍កើតឡើងនៃការចាប់ខ្លួន និងការបាត់ខ្លួន បំពេញ*ធាតុផ្សំអត្តនោម័ត* និង*ធាតុផ្សំសត្យានុម័តនៃបទឧក្រិដ្ឋនោះទេ*[712] ។ ជាពិសេស ការត្រឹមតែអះអាងថា ការឈឺចាប់កើតឡើងលើជនរងគ្រោះនៃការបាត់ខ្លួនដោយបង្ខំនៅការដ្ឋានប្រឡាយស្ពានស្រែងគ្មានអ្វីក្រៅពីការរកឃើញនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ មិនមានលក្ខណៈគ្រប់គ្រាន់។ គ្មានអ្នកវិនិច្ឆ័យអង្គហេតុដោយមិនលម្អៀងណាម្នាក់អាចអនុវត្តការប្រៀបធៀបនេះទេ [713] ។ ចំណុចចុងក្រោយ សហមេធាវីសន្និដ្ឋានថា សហព្រះរាជអាជ្ញាអន្តរជាតិ ខកខានក្នុងការតវ៉ាអំពីចំណងទាក់ទងគ្រប់គ្រាន់រវាង អ៊ឹម ចែម និងបទឧក្រិដ្ឋដូចបានចោទប្រកាន់ ហើយខកខានមិនបានបង្ហាញថាតើការកំណត់បទចោទតាមផ្លូវច្បាប់នៃការបាត់ខ្លួនដោយបង្ខំ នឹងនាំឱ្យមានការកែប្រែការវាយតម្លៃលើយុត្តាធិការបុគ្គលយ៉ាងដូចម្ដេច ដែលនាំឱ្យមោឃៈដល់ដីកាដំណោះស្រាយ (សំអាងហេតុ)[714] ។ ជាក់ស្ដែង ការកំណត់បទចោទច្រើនលើអង្គហេតុតែមួយនឹងមិនគ្រប់គ្រាន់ក្នុងការបន្ថែមទម្ងន់លើអំពើរបស់ អ៊ឹម ចែម នោះទេ[715]។

២៦៩. នៅក្នុងការឆ្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិ លើកឡើងថា សហចៅក្រមស៊ើបអង្កេតមានកំហុសនៅក្នុងការអនុវត្តវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងចំពោះបទឧក្រិដ្ឋនៃការបាត់ខ្លួនដោយបង្ខំនៅក្នុងសំណុំរឿង ០០២ "ពុំសមស្របតាមកាលកំណត់ និងពុំត្រឹមត្រូវតាមច្បាប់ឡើយ"[716] ។ ជាពិសេស

---

[711] ចម្លើយតប កថាខណ្ឌ ៩៧។

[712] ចម្លើយតប កថាខណ្ឌ ៩៤ ដែលយោងលើ បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៥១។ ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/2.1) ទំព័រ ៤៥-៤៧។

[713] ចម្លើយតប កថាខណ្ឌ ៩៨ ដែលយោងលើ បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៥១។ ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/2.1) ទំព័រ ៤៥-៤៧ ដែលយោងលើ សាលដីកាលើសំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៦៥៥ ដល់ កថាខណ្ឌ ៦៥៦។

[714] ចម្លើយតប កថាខណ្ឌ ៩៦ កថាខណ្ឌ ៩៩។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/2.1) ទំព័រ ៤៧-៤៨។

[715] ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/2.1) ទំព័រ ៤៧ ដែលយោងលើ ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣២៣។

[716] ការឆ្លើយតប កថាខណ្ឌ ៥១ យោងលើ សាលដីកាលើសំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៥៨៩។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤២។

ដោយពិចារណាលើការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលពាក់ព័ន្ធនឹងលក្ខខណ្ឌអប្បបរមានៃអំពើអមនុស្សធម៌ផ្សេងទៀត[717] ការរកឃើញនៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) បង្ហាញយ៉ាងច្បាស់អំពីលក្ខខន្ឌគួរឱ្យភ័យខ្លាច និងគៀបសង្កត់ខ្លាំងនៅការដ្ឋានប្រឡាយស្ពានស្រែង ហើយការបាត់ខ្លួនដោយគ្មានពន្យល់ហេតុផលបានបណ្តាលឱ្យមានការឈឺចាប់ផ្លូវចិត្តធ្ងន់ធ្ងរដល់ជនរងគ្រោះ[718]។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាស្នើសុំអង្គបុរេជំនុំជម្រះអន្តរាគមន៍ ដោយហេតុថា កំហុសនៅក្នុងការអនុវត្តនិយមន័យនៃការបាត់ខ្លួនដោយបង្ខំថាជាបទឧក្រិដ្ឋមួយដោយឡែក ពុំមែនជាអំពើអមនុស្សធម៌ផ្សេងទៀតនោះ បានធ្វើឱ្យការវាយតម្លៃលើការទទួលខុសត្រូវបុគ្គលរបស់ អ៊ឹម ចែម មានវិការៈ[719]។

### ២. ការពិភាក្សា

២៧០. នៅក្នុងកថាខណ្ឌ ៧៤ នៃដីកាដំណោះស្រាយ (សំអាងហេតុ) សហចៅក្រមស៊ើបអង្កេតបានបង្ហាញយ៉ាងត្រឹមត្រូវលើធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងទៀតថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាត ដូចខាងក្រោម៖

> (ក) *ធាតុផ្សំសត្យានុម័ត៖* អំពើសកម្ម ឬ អំពើអកម្មរបស់ចារី ដែលបណ្តាលឱ្យមានព្យសនកម្មធ្ងន់ធ្ងរលើរូបរាងកាយ ឬផ្លូវចិត្ត ឬជាការធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។ អំពើសកម្ម ឬ អកម្មរបស់ចារីត្រូវតែមានលក្ខណៈ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាក់លាក់ផ្សេងទៀត ដូចមានរៀបរាប់នៅក្នុងមាត្រា ៥ នៃច្បាប់ អត.វ. លើកាលៈទេសៈជាក់ស្តែងនីមួយៗ ដោយពិចារណាទៅតាមករណីធ្វើការវាយតម្លៃក ដែលត្រូវ. ផលត្រូវមានថា ការឈឺចាប់នោះតម្រូវលក្ខខណ្ឌនីមួយៗនៅក្នុងរឿងក្តីនោះ។ មិនមានដោយឡែកអំពីវាយតម្លៃបានយកមកពិចារណាយូរអង្វែងនោះឡើយ ទោះបីជាវាអាចត្រូវពេលរយៈប៉ះពាល់ភាពធ្ងន់ធ្ងរនៃអំពើនោះក៏ដោយ។
>
> (ខ) ធាតុផ្សំអត្តនោម័ត៖ ចារីត្រូវតែបានប្រព្រឹត្តអំពើសកម្ម ឬ អកម្ម ដោយមានចេតនាបង្កការឈឺចាប់យ៉ាងធ្ងន់ធ្ងរមកលើរូបរាងកាយ ឬ ផ្លូវចិត្ត ឬ ប្រព្រឹត្តអំពើហិង្សាយ៉ាងធ្ងន់ធ្ងរ មកលើជនរងគ្រោះដែលធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្សជាតិ នៅពេលដែលបានប្រព្រឹត្តអំពើសកម្ម ឬ

---

[717] ការឆ្លើយតប កថាខណ្ឌ ៥២ យោងលើ សាលដីកាលើសំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៦៥៦។

[718] ការឆ្លើយតប កថាខណ្ឌ ៥៣ យោងលើ ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៣១, កថាខណ្ឌ ២៣៤, កថាខណ្ឌ ២៣៨។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤៣-៤៤។

[719] ការឆ្លើយតប កថាខណ្ឌ ៥០ យោងលើ ចម្លើយតប កថាខណ្ឌ ៩២។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤៤។

01575593



អកម្មនោះ[720]។

២៧១. ក្រោយពេលសម្រេចថា ការបាត់ខ្លួនដោយបង្ខំអាចកំណត់បទចោទជាអំពើអមនុស្សធម៌ផ្សេងទៀតនោះ [721] សហចៅក្រមស៊ើបអង្កេតបានបន្តទៅកំណត់និយមន័យធាតុផ្សំជាក់លាក់នៃការបាត់ខ្លួនដោយបង្ខំនៅក្នុងកថាខណ្ឌ ៧៦ នៃដីកាដំណោះស្រាយ (សំអាងហេតុ) ថា៖

> ការបាត់ខ្លួនដោយបង្ខំ៖ ធាតុផ្សំនៃការបាត់ខ្លួនដោយបង្ខំ គឺ៖ (i) បុគ្គលណាម្នាក់អាចត្រូវបានដកហូតសេរីភាពរបស់ខ្លួន (ii) ការដកហូតសេរីភាពនេះត្រូវបានធ្វើឡើង តាមរយៈការបដិសេធមិនបង្ហាញព័ត៌មានទាក់ទងនឹងជោគវាសនា ឬ ទីកន្លែងដែលបុគ្គលពាក់ព័ន្ធនោះស្ថិតនៅ ឬ មិនទទួលស្គាល់ការដកហូតសេរិភាពនោះ (iii) បុគ្គលនោះត្រូវបានបដិសេធចំពោះដំណោះស្រាយតាមផ្លូវច្បាប់ និងការធានាផ្នែកនីតិវិធី និង (iv) ធាតុផ្សំទីមួយ និងទីពីរ ត្រូវបានអនុម័តដោយភ្នាក់ងាររដ្ឋ ឬ ដោយមានការអនុញ្ញាត ការគាំទ្រ ឬ ការយល់ព្រមពីរដ្ឋ ឬ អង្គការនយោបាយណាមួយ[722]។

២៧២. ចៅក្រមដែលទទួលបន្ទុករឿងក្ដីនេះយល់ស្របតាមការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលថា ការបាត់ខ្លួនដោយបង្ខំ ពុំបានចែងច្បាស់ក្រឡែតថាជាប្រភេទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយដាច់ដោយឡែកនៅក្នុងឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ នោះទេ ហើយអំពើនេះអាចចាត់ទុកជាអំពើអមនុស្សធម៌ផ្សេងទៀតអនុលោមតាមមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ប្រសិនបើវាបំពេញធាតុផ្សំនៃបទឧក្រិដ្ឋនោះ[723]។

---

[720] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៧៤ (លេខយោងជើងទំព័រ លុបចោល)។ សូមមើលផងដែរ សាលដីកាលើសំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៥៧៨ ដល់ កថាខណ្ឌ ៥៨០ កថាខណ្ឌ ៥៨៦។ សាលក្រមលើសំណុំរឿង ០០២/១ (ឯកសារ E313) កថាខណ្ឌ ៤៣៧ ដល់ កថាខណ្ឌ ៤៣៩។ សំណុំរឿង ០០១ សាលក្រម ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ E188 (សាលក្រមសំណុំរឿង ០០១ (ឯកសារ E188)") កថាខណ្ឌ ៣៦៧ ដល់ កថាខណ្ឌ ៣៧១។ តុលាការ ICTY រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Vasiljević, IT-98-32-T, សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០០២ ("សាលក្រម Vasiljević") កថាខណ្ឌ ២៣៤ ដល់ កថាខណ្ឌ ២៣៦។ តុលាការ ICTY រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Kordić និង Čerkez, IT-95-14/2-A, សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ១១៧។ តុលាការ ICTR រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana, ICTR-95-1-T, សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ កថាខណ្ឌ ១៥១ កថាខណ្ឌ ១៥៤។

[721] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៧៥ ក្នុងនោះ យោងលើ សាលក្រមលើសំណុំរឿង ០០២/១ (ឯកសារ E313) កថាខណ្ឌ ៤៤៨។

[722] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៧៦ យោងលើ សូមមើលផងដែរ សាលក្រមលើសំណុំរឿង ០០២/១ (ឯកសារ E313) កថាខណ្ឌ ៤៤៨។

[723] សាលដីកាលើសំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៥៨៩។

ចៅក្រមទទួលបន្ទុកលើរឿងក្ដីនេះក៏យល់ស្របថា "ការកំណត់ពីធាតុផ្សំនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ [...] ថាជាប្រភេទបទឧក្រិដ្ឋដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពុំសមស្របតាមកាលកំណត់ និងពុំត្រឹមត្រូវតាមច្បាប់ឡើយ" [724] ។ ដូចអង្គជំនុំជម្រះតុលាការកំពូលសម្រេចយ៉ាងច្បាស់លាស់ បញ្ហាណែនាំពាក់ព័ន្ធគឺថាតើអំពើនេះបានបំពេញនិយមន័យនៃអំពើអមនុស្សធម៌ផ្សេងទៀតដែរឬទេ នៅពេលពិចារណាកាលៈទេសៈជាក់លាក់នៃរឿងក្ដីបច្ចុប្បន្ន[725]។

២៧៣. យោងតាមសំអាងហេតុខាងលើ ចៅក្រមទទួលបន្ទុកលើរឿងក្ដីនេះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមានកំហុសនៅក្នុងការចែងបញ្ជាក់ធាតុផ្សំនៃការបាត់ខ្លួនដោយបង្ខំនៅក្នុងកថាខណ្ឌ ៧៦ នៃដីកាដំណោះស្រាយ (សំអាងហេតុ) បន្ថែមលើធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងទៀត។

២៧៤. ចៅក្រមទទួលបន្ទុកលើរឿងក្ដីនេះយល់ឃើញបន្ថែមទៀតថា សហចៅក្រមស៊ើបអង្កេតអនុវត្តមិនត្រឹមត្រូវលើនិយមន័យនៃការបាត់ខ្លួនដោយបង្ខំ តាមបែបបុរាណ ពុំមែនធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងទៀត នៅក្នុងការសម្រេចថាតើឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងនៅការដ្ឋានប្រឡាយស្ពានស្រែងដែរឬទេ។ ជាពិសេស សហចៅក្រមស៊ើបអង្កេតមានកំហុសដោយខកខានមិនបានសន្និដ្ឋានពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងទៀតក្រោមការបាត់ខ្លួនដោយបង្ខំ ក្នុងហេតុផលតែមួយគត់ថា "មិនមានភស្តុតាងបង្ហាញថា មានការសួរលើចំណុចនេះទៅអាជ្ញាធរដែលទទួលខុសត្រូវលើការដ្ឋានឡើយ" [726] ។ ចៅក្រមទទួលបន្ទុកលើរឿងក្ដីកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានសម្រេចស្រដៀងគ្នាពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងទៀត នៅមន្ទីរសន្តិសុខភ្នំត្រយ៉ូង ដោយចាត់ទុកថាជា "ធាតុផ្សំគន្លឹះនៃឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំ" ចំពោះអង្គហេតុដែលថា "អាជ្ញាធរបានបដិសេធលើសំណើសុំបង្ហាញព័ត៌មានអំពីទីតាំង និងជោគវាសនារបស់ជនរងគ្រោះ"[727]។ ទោះបីជាមិនបានប្ដឹងឧទ្ធរណ៍ក៏ដោយ ការសម្រេចនេះបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេតអនុ

[724] សាលដីកាលើសំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៥៨៩។

[725] សាលដីកាលើសំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៥៨៤ កថាខណ្ឌ ៥៨៩ កថាខណ្ឌ ៦៥១។ សូមមើលផងដែរ សាលដីកាលើដីកាដំណោះស្រាយសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (ឯកសារ D427/2/15 និងឯកសារ D427/3/15) កថាខណ្ឌ ១៥៦ កថាខណ្ឌ ១៦០ ដល់ កថាខណ្ឌ ១៦១។

[726] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣០២។

[727] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៩៤។

វត្ថុមិនត្រឹមត្រូវលើនិយមន័យតាមផ្លូវច្បាប់នៃការបាត់ខ្លួនដោយបង្ខំនៅក្នុងដីកាដំណោះស្រាយទាំងមូល (សំអាងហេតុ)។

២៧៥. សរុបមក ចៅក្រមទទួលបន្ទុកលើរឿងក្តីនេះពិចារណាឃើញថា ការសម្រេចនៅក្នុងកថាខណ្ឌ ២៩៤ និង កថាខណ្ឌ ៣០២ នៃដីកាដំណោះស្រាយ (សំអាងហេតុ) នាំឱ្យមានកំហុសអង្គច្បាប់។ លក្ខខណ្ឌដែលថា បុគ្គលទាំងឡាយត្រូវសាកសួរអំពីទីកន្លែងរបស់ជនរងគ្រោះ ហើយកម្មាភិបាលបដិសេធផ្តល់ព័ត៌មានជូន ពុំមែនជាធាតុផ្សំផ្លូវច្បាប់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមបទអំពើមនុស្សធម៌ផ្សេងទៀតនោះទេ។ ទឡ្ហីករណ៍ពាក់ព័ន្ធ ដែលសហចៅក្រមស៊ើបអង្កេតខកខានមិនបានពិចារណាលើកាលៈទេសៈចាប់បង្ខំ ដែលបានកើតឡើងនៅក្នុងសម័យកាលនោះ នៅពេលកំណត់លក្ខខណ្ឌនេះ [728] ពុំចាំបាច់យកមកសម្រេចនោះទេ។

២៧៦. នៅពេលនេះ ចៅក្រមទទួលបន្ទុកលើរឿងក្តីនេះនឹងពិចារណាថាតើមានភស្តុតាងគ្រប់គ្រាន់បង្ហាញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមបទអំពើអមនុស្សធម៌ផ្សេងទៀត ត្រូវបានបង្កើតឡើងនៅការដ្ឋានប្រឡាយស្ពានស្រែង ហើយនាំឱ្យ អ៊ឹម ចែម ទទួលខុសត្រូវ ដែរឬទេ។ ជាជាងញែកធាតុផ្សំនៃអំពើនេះ និងធ្វើតេស្តវាដាច់ដោយឡែក ថា ការបាត់ខ្លួនដោយបង្ខំគឺជាបទឧក្រិដ្ឋដោយឡែក អំពើដែលកើតឡើងនៅការដ្ឋានប្រឡាយស្ពានស្រែងគួរយកមកពិចារណាជារួម ដោយត្រូវសម្រេចថាតើលក្ខណៈ និងស្ថានទម្ងន់របស់វាស្រដៀងគ្នានឹងលក្ខណៈ និងស្ថានទម្ងន់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចបានចែងនៅក្នុងនោះដែរឬទេ[729]។

២៧៧. ចៅក្រមទទួលបន្ទុកលើរឿងក្តីនេះសូមរំលឹកថា ពីដំបូង ការវាយតម្លៃលើស្ថានទម្ងន់នៃអំពើហាមឃាត់ត្រូវជាករណីជាក់លាក់។ ទោះបីជាវាពុំចាំបាច់ចែងជាបទល្មើសព្រហ្មទណ្ឌឱ្យបានច្បាស់លាស់នៅក្រោមច្បាប់អន្តរជាតិក៏ដោយ [730] "អំពើអមនុស្សធម៌ឈានដល់ស្ថានទម្ងន់មួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត ជាធម្មតា គឺជាការរំលោភធ្ងន់ធ្ងរលើសិទ្ធិមនុស្ស"[731]។ ក្នុងចំណោមសិទ្ធិមនុស្សពាក់ព័ន្ធ រួម

---

[728] សូមមើល បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥២ ដល់ កថាខណ្ឌ ៥៧។

[729] សាលដីកាលើសំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៥៨០។

[730] សាលដីកាលើដីកាដំណោះស្រាយសំណុំរឿង ០០២ (ឯកសារ D427/2/15 និងឯកសារ D427/3/15) កថាខណ្ឌ ១៥៦។

[731] សាលដីកាលើសំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៥៨២ ដល់កថាខណ្ឌ ៥៨៤។ សូមមើលផងដែរ តុលាការ ICTY រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kupreškić និងអ្នកផ្សេងទៀត, IT-95-16-T, សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ២០០០ ("សាលក្រម Kupreškić") កថាខណ្ឌ ៥៦៦ កថាខណ្ឌ ៨១៨។

មានសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខបុគ្គល និងការហាមឃាត់ការប្រព្រឹត្ត ឬ ទណ្ឌកម្មសាហាវឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប ការចាប់ខ្លួនតាមអំពើចិត្ត ការឃុំខ្លួន ឬ ការនិរទេស និងការជ្រៀតជ្រែកតាមអំពើចិត្តលើភាពឯកជន គ្រួសារ លំនៅដ្ឋាន ឬ លិខិតឆ្លើយឆ្លង[732]។ ជាក់ស្តែង អំពើពាក់ព័ន្ធត្រូវបង្កការឈឺចាប់ធ្ងន់ធ្ងរលើរូបរាងកាយ ឬ ផ្លូវចិត្ត ឬ ត្រូវតែជាការប៉ះពាល់ធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ [733] ។ ភាពធ្ងន់ធ្ងររបស់វាត្រូវយកមកវាយតម្លៃដោយពិចារណាលើកាលៈទេសៈនានា ដូចជាលក្ខណៈនៃអំពើសកម្ម ឬ អំពើសកម្ម រយៈពេល និង/ឬ ភាពកើតឡើងដដែលៗរបស់វា កាលៈទេសៈរបស់បុគ្គល និងផលប៉ះពាល់រាងកាយ ផ្លូវចិត្ត និងសីលធម៌លើជនរងគ្រោះ[734]។

២៧៨. នៅក្នុងរឿងក្តីបច្ចុប្បន្ន សហចៅក្រមស៊ើបអង្កេតបានរកឃើញថា "មានភស្តុតាងជាច្រើនដែលបង្ហាញថា ពលករត្រូវបានចាប់ខ្លួន យកចេញទៅ ឬ បាត់ខ្លួនពីការដ្ឋានប្រឡាយស្ពានស្រែង ព្រមទាំង មានភស្តុតាងថា អ្នកដែលបានបាត់ខ្លួនពីការដ្ឋានប្រហែលជាត្រូវបានគេសម្លាប់នៅមន្ទីរសន្តិសុខភ្នំទ្រយោង" [735] ។ យ៉ាងហោចណាស់ ករណីនេះពាក់ព័ន្ធនឹងការរំលោភលើសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខបុគ្គល សេរីភាពពីការចាប់ខ្លួន និងឃុំខ្លួនតាមអំពើចិត្ត និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជាសាធារណៈ និងសិទ្ធិទទួលស្គាល់ចំពោះមុខច្បាប់។ ដីកាដំណោះស្រាយ (សំអាងហេតុ) បង្ហាញបន្ថែមទៀតថា ប្រជាជនរាប់ពាន់នាក់ត្រូវបានបង្ខំឱ្យធ្វើការនៅក្នុងស្ថានភាពយ៉ាប់យឺននៅការដ្ឋានប្រឡាយស្ពានស្រែង [736] "ការចាប់ខ្លួន និងការបាត់ខ្លួនកម្មករឃើញកើតមានជាទូទៅ" [737] ដែលត្រូវបានអនុវត្ត និងចូលរួមចំណែក

---

[732] សាលដីកាលើសំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៥៨២ ដល់ កថាខណ្ឌ ៥៨៥។

[733] សាលដីកាលើសំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៥៧៩ ដល់ កថាខណ្ឌ ៥៨០។ តុលាការ ICTY រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kordić និង Čerkez, IT-95-14/2-T, សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ២៦៩។

[734] សាលក្រមលើសំណុំរឿង ០០១ (ឯកសារ E188) កថាខណ្ឌ ៣៦៩។ សាលក្រមលើសំណុំរឿង ០០២/១ (ឯកសារ E313) កថាខណ្ឌ ៤៣៨។ សាលដីកាលើសំណុំរឿង ០០២ (ឯកសារ F36) កថាខណ្ឌ ៥៨៦។ តុលាការ ICTY រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Krnojelac, IT-97-25-T, សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ ("សាលក្រម Krnojelac") កថាខណ្ឌ ១៣១។ សាលក្រម Vasiljević កថាខណ្ឌ ២៣៥។

[735] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣០២។ សូមមើលផងដែរ កថាខណ្ឌ ២៣១ ដល់ កថាខណ្ឌ ២៣២ កថាខណ្ឌ ២៣៧ ដល់ កថាខណ្ឌ ២៤០ កថាខណ្ឌ ២៤២។

[736] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២២៤ កថាខណ្ឌ ២៣០ កថាខណ្ឌ ២៣៤ ដល់ កថាខណ្ឌ ២៣៧ កថាខណ្ឌ ២៤១។

[737] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៣៨។

បង្កឱ្យមានបរិយាកាសភិតភ័យ [738] ហើយ "ក្រុមគ្រួសារពលករដែលបានបាត់ខ្លួនពុំអាចដឹងពីជោគវាសនារបស់ពួកគេ ឬ ដឹងអំពីទីកន្លែងស្នាក់នៅរបស់ពួកគេបាន"[739]។

២៧៩. ផ្អែកលើកាលៈទេសៈទាំងនេះ ចៅក្រមទទួលបន្ទុកលើរឿងក្តីយល់ឃើញថា អំពើនៃការបាត់ខ្លួនដោយបង្ខំត្រូវយកមកពិចារណាថាមានស្ថានទម្ងន់ធ្ងន់ធ្ងរ ហើយថាបានរំលោភបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ សេចក្តីសន្និដ្ឋាននេះគាំទ្រដោយលិខិតុបករណ៍ និងយុត្តិសាស្ត្រនៅមុន និងក្រោយឆ្នាំ១៩៧៥[740] ហើយដោយអង្គហេតុដែលថា ការបាត់ខ្លួនដោយបង្ខំត្រូវបានកំណត់នាពេលថ្មីៗនេះថាជាបទល្មើសព្រហ្មទណ្ឌនាអនុលោមតាមច្បាប់អន្តរជាតិ[741]។ កាលៈទេសៈបង្ហាញនៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) ពាក់ព័ន្ធនឹងការដ្ឋានប្រឡាយស្ពានស្រែង ក៏ផ្តល់ភ័ស្តុតាងគ្រប់គ្រាន់បង្ហាញថា អំពើនេះបានបង្កការឈឺចាប់លើផ្លូវ

---

[738] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៣២ ដល់ កថាខណ្ឌ ២៣៤ កថាខណ្ឌ ២៣៩ កថាខណ្ឌ ២៤២។

[739] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣០២។

[740] សូមមើល ឧ. សាលក្រមលើសំណុំរឿង ០០២/១ (ឯកសារ E313) កថាខណ្ឌ ៤៤៤ ដល់ កថាខណ្ឌ ៤៤៧ ក្នុងនោះយោងលើ ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមធំៗនៅមុនសាលាក្តីយោធាអន្តរជាតិ នូរ៉ឺមប៊ឺក ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៤៥ ដល់ ថ្ងៃទី១ ខែតុលា ឆ្នាំ១៩៤៦ វ៉ុល ១ ទំព័រ ២៣២ ដល់ ទំព័រ ២៣៣ ទំព័រ ២៩០ ដល់ ទំព័រ ២៩១។ រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង Altstoetter និងអ្នកផ្សេងទៀត (រឿងក្តី Justice) មតិយោបល់ និងសាលក្រម ចុះថ្ងៃទី៣ ដល់ ថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៤៧ ដែលបានបោះពុម្ពផ្សាយឡើងវិញនៅក្នុងការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមធំៗនៅមុនសាលាក្តីយោធាអន្តរជាតិ នូរ៉ឺមប៊ឺក ក្រោមក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ វ៉ុល ៣ ទំព័រ ៩៥៤ ដល់ ទំព័រ ១១៧៧ ("សាលក្រមលើរឿងក្តី Justice") ត្រង់ទំព័រ ៧៥ ទំព័រ ១០៤២ ទំព័រ ១០៥៧ ដល់ ទំព័រ ១០៦៨ ទំព័រ ១០៦១។ សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ ៣៣/១៧៣ ស្តីពីបុគ្គលដែលបានបាត់ខ្លួន ឯកសារ U.N. Doc. A/RES/33/173 ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៧៨។ តុលាការ IACtHR រឿងក្តី Velasquez-Rodriguez តទល់នឹង ហុងឌូរ៉ាស់ សាលដីកា ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៨៨ (ស៊េរី គ លេខ ៤) កថាខណ្ឌ ១៥៥ ដល់ កថាខណ្ឌ ១៥៧។ គណកម្មាធិការសិទ្ធិមនុស្ស រឿងក្តី Mojica តទល់នឹង សាធារណរដ្ឋដូមីនីកាំង លិខិតឆ្លើយឆ្លងលេខ ៤៤៩/១៩៩១ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៤ កថាខណ្ឌ ៥.៧។ គណកម្មាធិការសិទ្ធិមនុស្ស រឿងក្តី Laureano Atachahua តទល់នឹង ប៉េរូ លិខិតឆ្លើយឆ្លងលេខ ៥៤០/១៩៩៣ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៦ កថាខណ្ឌ ៨.៥។ សូមមើលផងដែរ សាលក្រម Kupreškić កថាខណ្ឌ ៥៦៦ យោងលើ សេចក្តីប្រកាសស្តីពីការការពារបុគ្គលគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ ឯកសារ U.N. Doc. A/RES/47/133 ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩២។ អនុសញ្ញាអន្តរទ្វីបអាមេរិកាំងស្តីពីការបាត់ខ្លួនបុគ្គលដោយបង្ខំ អនុម័តនៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៩៤ និងចូលជាធរមាននៅថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៩៦។

[741] សាលដីកាលើសំណុំរឿង ០០២ (ឯកសារ *F36*) កថាខណ្ឌ ៥៨៥។ សូមមើលផងដែរ ឧ. សាលក្រមសំណុំរឿង ០០២/១ (ឯកសារ *E313*) កថាខណ្ឌ ៤៤៧។ លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ឯកសារ *UN Doc. A/CONF.* 183/9; 37 *ILM* 1002 (1998) (*"លក្ខន្តិកៈទីក្រុងរ៉ូម"*) មាត្រា ៧(១)(*i*)។ អនុសញ្ញាអន្តរជាតិស្តីពីការការពារគ្រប់បុគ្គលទាំងអស់ពីការបាត់ខ្លួនដោយបង្ខំ អនុម័តនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៦ និងបានចូលជាធរមាននៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១០។

ចិត្តធ្ងន់ធ្ងរ និងជាការប៉ះពាល់លើសេចក្តីថ្លៃថ្នូរបស់មនុស្ស ហេតុដូច្នេះ វាឈានដល់កម្រិតស្ថានទម្ងន់ដែលចាំបាច់ត្រូវចាត់ទុកជាអំពើអមនុស្សធម៌ផ្សេងទៀត[742] ។ ជាការពិត ចៅក្រមទទួលបន្ទុកលើរឿងក្តីសង្កេតឃើញថា អំពើបែបនេះអាចប្រដូចនឹងអំពើនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចបានចែងនៅក្នុងនោះ ដូចជាការដាក់ក្នុងមន្ទីរឃុំឃាំង និងការនិរទេស ពាក់ព័ន្ធនឹងសិទ្ធិដែលពាក់ព័ន្ធ (*ឧ.* សិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខបុគ្គល) ហើយផលប៉ះពាល់លើជនរងគ្រោះ (*ឧ.* ភាពមិនប្រាកដប្រជា ការភ័យខ្លាច ការបែកបាក់ពីគ្រួសារ និងផ្ទះសម្បែង)[743] ។

---

[742] សូមប្រៀបធៀបជាមួយ ឧ. សាលដីកាលើសំណុំរឿង ០០២ (ឯកសារ *F36*) កថាខណ្ឌ ៦៥២ កថាខណ្ឌ ៦៥៨ ដល់ កថាខណ្ឌ ៦៥៩ (ការរកឃើញថា គ្រួសារដែលត្រូវគេបំបែក និងពុំដែលបានឮអំពីជោគវាសនានៃការបាត់ខ្លួនសមាជិកគ្រួសាររបស់ពួកគេ មានការជាប់ពាក់ព័ន្ធនឹងការបង្ហាញអំពើអមនុស្សធម៌ផ្សេងទៀតដែលបានកើតឡើង) កថាខណ្ឌ ៦៥៦ (ប្រភេទ និងស្ថានទម្ងន់ស្រដៀងគ្នាអាចបង្ហាញឱ្យឃើញតាមរយៈភ័ស្តុតាងបង្ហាញថា បុគ្គលជាច្រើននាក់បានទទួលរងផលប៉ះពាល់ពីអំពើនេះ ហើយបុគ្គលខ្លះត្រូវបានគេសម្លាប់ចោល ឬ ស្លាប់ដោយសារលទ្ធផលនៃអំពើនេះ)។ សាលក្រមលើសំណុំរឿង ០០២/១ (ឯកសារ *E313*) កថាខណ្ឌ ៤៤៥ (វាជាការប្រព្រឹត្តដោយអមនុស្សធម៌ ដោយវាមិនត្រឹមតែប៉ះពាល់តែទៅលើបុគ្គលទាំងឡាយណាដែលបានបាត់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែ វាក៏ប៉ះពាល់ទៅលើក្រុមគ្រួសាររបស់អ្នកជាប់ឃុំ ដែលពួកគេត្រូវបានបដិសេធមិនផ្តល់ព័ត៌មានអំពីជោគវាសនាសាច់ញាតិរបស់ពួកគេដែលត្រូវបានជាប់ឃុំនោះ)។ សាលក្រមលើសំណុំរឿង ០០១ (ឯកសារ *E188*) កថាខណ្ឌ ៣៧៣ (អំពើទាំងនេះទុកឱ្យពួកគេរស់នៅក្នុងភាពភ័យខ្លាចជាប្រចាំ)។ សាលក្រម *Justice* ទំព័រ ១០៥៨ (ការបាត់ខ្លួនគឺជាការប្រព្រឹត្តដោយអមនុស្សធម៌ពុំមែនត្រឹមតែលើអ្នកទោសនោះទេ វាថែមទាំងលើគ្រួសារ មិត្តភ័ក្ត និងសាច់ញាតិរបស់ពួកគេទៀតផង ដែលពួកគេស្ថិតក្នុងសភាពភ័យខ្លាច និងស្មុគស្មាញជាដរាបអំពីទីកន្លែង និងជោគវាសនាអ្នកដែលបាត់ខ្លួន)។ សាលក្រម *Kupreškić* កថាខណ្ឌ ៨១៩ ដល់ កថាខណ្ឌ ៨២០ (បានឃើញមរណភាពនៃអ្នកជាទីស្រលាញ់មួយរូបអាចបង្កឱ្យមានការឈឺចប់ផ្លូវចិត្តធ្ងន់ធ្ងរ)។ តុលាការ *ICTY* រឿងក្តី រដ្ឋអាជ្ញា តទល់នឹង *Đorđević, IT-05-87/1-T,* សាលក្រមរួមជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ ១៧០៣ (ការរកឃើញភាពធ្ងន់ធ្ងរ និងស្ថានទម្ងន់ស្រដៀងគ្នា ដែលអំពើពាក់ព័ន្ធនឹងការចាកចេញដោយបង្ខំពីលំនៅដ្ឋាន និងសហគមន៍របស់ប្រជាជន ហើយជារឿយៗធ្វើឱ្យប៉ះពាល់ផ្លូវចិត្ត និងរូបកាយ ហើយពុំដឹងជាក់លាក់ថាពួកគេនឹងត្រឡប់មកវិញនៅថ្ងៃណា)។ តុលាការ *ICTY* រឿងក្តី រដ្ឋអាជ្ញា តទល់នឹង *Prlić* និងអ្នកផ្សេងទៀត *IT-04-74-T* សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ វ៉ុល ៣ កថាខណ្ឌ ១០៥៩ កថាខណ្ឌ ១២៣៦ (បរិយាកាសនៃការភ័យខ្លាច និងភាពតក់ស្លុតក្នុងចំណោមជនជាប់ឃុំ)។ សាលក្រម *Krnojelac* កថាខណ្ឌ ១៤៣ (ការរកឃើញការឈឺចាប់ផ្លូវចិត្តធ្ងន់ធ្ងរ ដែលអ្នកជាប់ឃុំបានទទួលរងដោយសារសំឡេងនៃទារុណកម្ម និងការវាយដំក្នុងរយៈពេលជាច្រើនខែ ក្លាយជាបញ្ហាភ័យញាប់ញ័រ និងតក់ស្លុត ហើយមិនអាចសម្រាលនៅពេលយប់បានដោយសារសំឡេងទាំងអស់នោះ គេមិនអាចកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើស ហើយអ្នកខ្លះបានឃើញសមាជិកគ្រួសារខ្លួនត្រូវបានគេយកចេញទៅបាត់ ហើយបានឮថា អ្នកទាំងនោះបានទទួលរកការវាយដំធ្ងន់ធ្ងរ)។

[743] សូមមើល សាលដីកាលើសំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៦៥៦ កថាខណ្ឌ ៦៥៩។

01575599



២៨០. ចំណុចចុងក្រោយ ចៅក្រមទទួលបន្ទុកលើរឿងក្តីនេះកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានសម្រេចយ៉ាងជាក់លាក់ថា អ៊ឹម ចែម ទទួលខុសត្រូវរួមលើគម្រោងនៅការដ្ឋានប្រឡាយស្ពានស្រែង[744] បានបញ្ជាឱ្យចាប់ខ្លួន[745] បានគម្រាមកំហែងការចាប់ខ្លួនកម្មករ ដើម្បីជាទណ្ឌកម្មនៃការខកខានមិនបានបំពេញតាមផែនការ[746] ហើយអាចត្រូវបានរកឃើញថាទទួលខុសត្រូវលើអំពើអមនុស្សធម៌ផ្សេងទៀតនៅការដ្ឋានប្រឡាយស្ពានស្រែង[747] ចេតនាដែលគាត់បានបង្ហាញ បានបន្តឱ្យគាត់ចូលរួមនៅក្នុងបទឧក្រិដ្ឋទាំងនោះ[748] ។ សហចៅក្រមស៊ើបអង្កេតក៏បានរកឃើញថា ធាតុផ្សំទូទៅនៃបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ត្រូវបានរកឃើញចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងតំបន់ ៥ និងពាក់ព័ន្ធនឹងមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍មួយនេះ[749]។

២៨១. ចៅក្រមទទួលបន្ទុកលើរឿងក្តី *តាមគំនិតផ្តួចផ្តើមរបស់ខ្លួន* កត់សម្គាល់បន្ថែមទៀត ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខភ្នំទ្រយោង ថា សហចៅក្រមស៊ើបអង្កេតទទួលស្គាល់ "របាយការណ៍អំពីអ្នកទោសដែលបាត់ខ្លួន ហើយមិនដែលឃើញត្រឡប់មកវិញ"[750] ។ ភស្តុតាងនៅក្នុងសំណុំរឿង[751] បានបង្ហាញយ៉ាងគ្រប់គ្រាន់អំពីការបាត់ខ្លួនបែបនេះ ព្រមទាំងសិទ្ធិអំណាចទូទៅរបស់ អ៊ឹម ចែម ទៅលើគុកនេះផងដែរ[752]។

---

[744] *សូមមើល* ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២២៩។

[745] *សូមមើល* ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣០៩ ដល់ កថាខណ្ឌ ៣១០។

[746] *សូមមើល* ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៣៨ កថាខណ្ឌ ២៤៣។

[747] *សូមមើល* ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣០៦ ដល់ កថាខណ្ឌ ៣១១។

[748] *សូមមើល* ឧ. ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៣០៩។ សូមមើលផងដែរ ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៣៨ កថាខណ្ឌ ២៤៣។

[749] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៨១ ដល់ កថាខណ្ឌ ២៨៤។

[750] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៩៥។

[751] សូមមើល ឧទា. សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម សឿន ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ D219/567 ត្រង់ ERN 01165949 (ឆ. ៧៤), 01165956 (ឆ. ១៥៧) 01165956 (ឆ. ១៦១)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មី តាល់ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ D219/256 ត្រង់ ERN 01085166 (ឆ. ២៧)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គោ ពិនថង ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១១ ត្រង់ ERN 00743550។ សំណុំរឿង ០០៤/១ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៊ិន ណាន់ និង រិន ខេង ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ D123/1/2.65 ត្រង់ ERN 00927374។

[752] សូមមើល ឧទា. ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៧៥, ១៨៩, ១៩២-១៩៥។

២៨២. យោងតាមសំអាងហេតុខាងលើ ចៅក្រមទទួលបន្ទុកលើរឿងក្តីនេះយល់ឃើញថា ប្រសិនបើសហចៅក្រមស៊ើបអង្កេតបានអនុវត្តធាតុផ្សំច្បាប់នៃអំពើអមនុស្សធម៌មែននោះ គ្មានអ្នកវិនិច្ឆ័យដោយមិនលម្អៀងណាមួយអាចរកឃើញថា ភ័ស្តុតាងពុំមានគ្រប់គ្រាន់បង្ហាញអំពីអំពើអមនុស្សធម៌ផ្សេងទៀតតាមរយៈការបាត់ខ្លួនដោយបង្ខំនៅការដ្ឋានប្រឡាយស្ពានស្រែង និងមន្ទីរសន្តិសុខភ្នំទ្រយោង និងការទទួលខុសត្រូវរបស់ អ៊ឹម ចែម។ ផលប៉ះពាល់នៃកំហុសលើការឃើញថា អ៊ឹម ចែម មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់តុលាការនឹងត្រូវកំណត់ក្នុងសេចក្តីសន្និដ្ឋាន។

## ង. ទទ្បីករណ៍ទី ៥ និងទី ៦៖ ការចោទប្រកាន់អំពីកំហុសឆ្គងទាក់ទាក់ព័ន្ធនឹងការសន្និដ្ឋានទៅលើមុខងាររបស់ អ៊ឹម ចែម ជាលេខាស្រុកកោះអណ្តែត និង សមាជិកគណៈកម្មាធិការតំបន់ ១៣

២៨៣. ចៅក្រមទទួលបន្ទុករឿងក្តីនឹងពិចារណាទៅលើទឡ្ហីករណ៍ទី ៥ និងទី ៦ នៃបណ្តឹងឧទ្ធរណ៍រួមគ្នាដែលទឡ្ហីករណ៍ទាំងពីរនេះចោទប្រកាន់ពីកំហុសឆ្គងពាក់ព័ន្ធនឹងការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអំពីតួនាទី និងសិទ្ធិអំណាចរបស់ អ៊ឹម ចែម នៅភូមិភាគនិរតី។

### ១. សារណា

២៨៤. សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សហចៅក្រមស៊ើបអង្កេតមានកំហុសឆ្គងក្នុងការសន្និដ្ឋានថា អ៊ឹម ចែម ពុំមែនជាលេខាស្រុកកោះអណ្តែត (ទឡ្ហីករណ៍ទី ៥ នៃបណ្តឹងឧទ្ធរណ៍) ឬជាសមាជិកគណៈកម្មាធិការតំបន់ ១៣ ទេ (ទឡ្ហីករណ៍ទី ៦ នៃបណ្តឹងឧទ្ធរណ៍) ហើយថា មុខតំណែងតែមួយដែលគាត់បានកាន់នៅភូមិភាគនិរតីគឺជាប្រធានសមាគមនារីតំបន់[753]។ បើតាមសហព្រះរាជអាជ្ញាអន្តរជាតិ មិនមានអ្នកវិនិច្ឆ័យអង្គហេតុដ៏សមហេតុសមផលណាអាចធ្វើការសន្និដ្ឋានបែបនេះ ដោយផ្អែកលើការពិនិត្យដ៏ត្រឹមត្រូវលើភ័ស្តុតាងយ៉ាងត្រឹមត្រូវនោះទេ[754]។

២៨៥. ទាក់ទិននឹងទឡ្ហីករណ៍ទី ៥ នៃបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាអន្តរជាតិចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតពុំបានធ្វើការវាយតម្លៃឲ្យបានត្រឹមត្រូវទៅលើសេចក្តីថ្លែងការណ៍របស់ អ៊ឹម ចែម ពាក់ព័ន្ធនឹងមុខតំណែងរបស់គាត់ជាលេខាស្រុកកោះអណ្តែត [755] និងមិនបានវាយតម្លៃទៅលើភ័ស្តុតាងបញ្ជាក់

[753] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៨-៥៩, ៧០-៧១ យោងទៅ ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៤៣-១៥០។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤៤-៤៥។

[754] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៨, ៧០។

[755] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៩-៦២។

បន្ថែមនានា[756]។ ពាក់ព័ន្ធនឹងទឡ្ហីករណ៍ទី ៦ នៃបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា សហចៅក្រមស៊ើបអង្កេតមានកំហុសឆ្គង ក្នុងការមិនយកមកពិចារណា ដោយពុំផ្តល់ការពន្យល់ ចំពោះការទទួលស្គាល់របស់ អ៊ឹម ចែម ដែលថា គាត់បានកាន់តំណែងជាសមាជិកគណៈកម្មាធិការតំបន់ ១៣ រយៈពេលមួយឆ្នាំមុនត្រូវបានបញ្ជូនទៅភូមិភាគពាយ័ព្យ [757] ហេតុនេះ មិនយកមកពិចារណានូវភស្តុតាងរបស់អ្នកដែលដឹងច្បាស់ពីមុខតំណែងដែលគាត់បានកាន់គឺៈ អ៊ឹម ចែម ខ្លួនឯង[758]។ សហចៅក្រមស៊ើបអង្កេតមិនបានពិចារណាឲ្យបានត្រឹមត្រូវបន្ថែមទៀតទៅលើភស្តុតាងជាក់លាក់ និងច្បាស់លាស់របស់សាក្សីជាច្រើននាក់ ដែលគាំទ្រថា អ៊ឹម ចែម មានតួនាទីនៅក្នុងគណៈកម្មាធិការតំបន់ ១៣ បន្ថែមទៅលើមុខតំណែងរបស់គាត់ជាប្រធានសមាគមនារី[759] និងមិនបានពន្យល់ឡើយថា តើភស្តុតាងបង្ហាញពីលំដាប់ថ្នាក់ និងកម្រិតនៃសិទ្ធិអំណាចរបស់គាត់អាចស្របទៅនឹងការសន្និដ្ឋានថា តួនាទីតែមួយគត់របស់គាត់គឺជាប្រធានសមាគមនារី ដោយរបៀបណា[760]។ ជាចុងក្រោយ សហចៅក្រមស៊ើបអង្កេតមានកំហុសឆ្គងដែលមិនពិចារណាទៅលើភស្តុតាងច្បាស់លាស់ និងពាក់ព័ន្ធដែលបង្ហាញពីមុខតំណែងរបស់ អ៊ឹម ចែម នៅក្នុងគណៈកម្មាធិការតំបន់[761] ព្រមទាំងមានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន រួមទាំងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយដែលបញ្ជាក់អំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នកដាក់ពាក្យសុំ ដោយលើកឡើងថាគាត់បានកាន់មុខតំណែងនេះមែន[762]។

---

[756] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦៣-៦៩ យោងទៅ ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៣៨, ១៤៥, ១៤៨-១៤៩។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤៥-៤៩។

[757] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៧១-៧៣ យោងទៅ ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៤៧-១៤៨, ១៥២។ សំណុំរឿង ០០៤/១ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ ឯកសារ D123/1/5.1c ("កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម នៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c)") នៅត្រង់ ERN (ភាសាខ្មែរ) 00929877។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤៩-៥១។

[758] ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤៤-៤៥។

[759] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៧៤-៧៦, ៨០។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៧ (ឯកសារ D308/3/1/19/1.2) ទំព័រ ៤៩-៥៣។

[760] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៧៧, ៨០។

[761] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៧៨។

[762] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៧៩។

២៨៦. សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ការណ៍ដែលសហចៅក្រមស៊ើបអង្កេតមិនបានសន្និដ្ឋានថា អ៊ឹម ចែម ជាលេខាស្រុកកោះអណ្តែត និងជាសមាជិកគណៈកម្មាធិការតំបន់ ១៣ តម្រូវឱ្យមានការវាយតម្លៃសាជាថ្មីទៅលើការទទួលខុសត្រូវរបស់គាត់ ក្រោមទម្រង់ជាសហឧក្រិដ្ឋកម្មរួម ចំពោះឧក្រិដ្ឋកម្មនៅក្នុងភូមិភាគនិរតី[763]។

២៨៧. សហមេធាវីឆ្លើយតបថា ទឡ្ហីករណ៍ទី ៥ និងទី ៦ នៃបណ្តឹងឧទ្ធរណ៍គួរតែត្រូវបានច្រានចោលដោយមិនចាំបាច់យកមកពិចារណាឡើយ[764]។ សហមេធាវីលើកឡើងថា វិធីសាស្ត្ររបស់សហព្រះរាជអាជ្ញាអន្តរជាតិគឺប៉ុនប៉ងបញ្ចុះបញ្ចូលអង្គបុរេជំនុំជម្រះឱ្យសើរើអង្គហេតុសាជាថ្មី និងដាក់ជំនួសទស្សនទានរបស់សហចៅក្រមស៊ើបអង្កេតជារបស់ខ្លួនវិញ ជំរុញឱ្យការអានមិនពេញលេញ និងការអានជាបំណែកៗចំពោះដីកាដំណោះស្រាយ (សំអាងហេតុ) និងបោះបង់ចោលនូវចេតនាទាំងឡាយ ដើម្បីដោះស្រាយលើបញ្ហាបទដ្ឋានពិនិត្យឡើងវិញនៃបណ្តឹង[765]។ ជាពិសេស សហព្រះរាជអាជ្ញាអន្តរជាតិមិនបានបង្ហាញថាតើសហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្តកំហុសដោយរបៀបណាទេ ក្នុងការសន្និដ្ឋានថា អ៊ឹម ចែម មិនមែនជាលេខាស្រុកកោះអណ្តែត និងជាសមាជិកគណៈកម្មាធិការតំបន់នៅក្នុងភូមិភាគនិរតី និង ថាតើការរកឃើញបែបនេះអាចនឹងមានការជាប់ទាក់ទង ឬភាពជឿជាក់បាននៃការវាយតម្លៃណាមួយលើបញ្ហាយុត្តាធិការបុគ្គល ដោយរបៀបណាទេ[766]។

២៨៨. បើតាមទស្សនទានរបស់សហមេធាវីគឺថា វិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតចំពោះភស្តុតាង គឺសមហេតុសមផល[767]។ ពាក់ព័ន្ធនឹងទឡ្ហីករណ៍ទី ៥ នៃបណ្តឹងឧទ្ធរណ៍ សហមេធាវីជំទាស់ថា ទីមួយ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ត្រូវបានសហចៅក្រមស៊ើបអង្កេតផ្តល់ការថ្លឹងថ្លែងជាភស្តុតាងតិចជាងកិច្ចសម្ភាសន៍នានាដែលបានធ្វើឡើងដោយការិយាល័យរបស់ខ្លួន ហើយថា កិច្ចសម្ភាសន៍ទាំងនោះអាចយកមកសំអាងបានតែក្នុងករណីមានការគាំទ្រដោយប្រភព

---

763 បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៨១។

764 ចម្លើយតប កថាខណ្ឌ ១០១។

765 ចម្លើយតប កថាខណ្ឌ ១០៣, ១០៥។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៧ (ឯកសារ D308/3/1/19/2.1) ទំព័រ ៥០-៥១។

766 ចម្លើយតប កថាខណ្ឌ ១០២, ១០៤ យោងទៅ ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៤៥-២៤៦។

767 ចម្លើយតប កថាខណ្ឌ ១០៦, ១១៩។

01575603



ផ្សេងទៀតប៉ុណ្ណោះ[768] ។ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានដោយសមហេតុសមផលថា សេចក្តីថ្លែងការណ៍សរុបរបស់ អ៊ឹម ចែម បានផ្តល់ត្រឹមតែភស្តុតាងមិនច្បាស់លាស់ ហើយដោយគិតតាមបទដ្ឋាន និងបន្ទុកក្នុងការបង្ហាញភស្តុតាង ដែលពិចារណាឃើញថា គាត់ក៏បានឆ្លើយផងដែរថា គាត់ពុំមែនជាលេខាស្រុក ហើយផ្ទុយទៅវិញ គាត់ត្រឹមតែទទួលខុសត្រូវផ្នែកនារីប៉ុណ្ណោះ[769] ។ ទីពីរ សហមេធាវីជំទាស់ថា សហព្រះរាជអាជ្ញាអន្តរជាតិគ្រាន់តែធ្វើការកែសម្រួលសាជាថ្មី នូវទស្សនទាននៃភស្តុតាងដែលមានលក្ខណៈចំណុះឱ្យគ្នា ដោយជ្រើសយកសេចក្តីយោងរបស់ខ្លួនតែពីសេចក្តីថ្លែងការណ៍របស់សាក្សី ៥ នាក់[770] និងមិនបានបង្ហាញថាតើ សហចៅក្រមស៊ើបអង្កេតមានកំហុសដោយរបៀបណា ដែលថ្លឹងថ្លែងលើភស្តុតាងសរុបនោះទេ[771] ។

២៨៩. នៅក្នុងចម្លើយតបទៅនឹងទឡ្ហីករណ៍ទី ៦ នៃបណ្តឹងឧទ្ធរណ៍ សហមេធាវីធ្វើការអះអាងសាជាថ្មីថា សេចក្តីថ្លែងការណ៍របស់ អ៊ឹម ចែម ដែលផ្តល់ជូនមជ្ឈមណ្ឌលឯកសារកម្ពុជា អាចយកមកសំអាងបានតែក្នុងករណីមានការគាំទ្រដោយប្រភពផ្សេងទៀតប៉ុណ្ណោះ[772] ហើយថា សហព្រះរាជអាជ្ញាអន្តរជាតិប្រកាន់យកវិធីសាស្ត្របែបជ្រើសរើស ក្នុងការវាយតម្លៃភស្តុតាង[773] ។ ជាពិសេស ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលតំណាងឱ្យ "ការរៀបរាប់ទូទៅ" ដូចជាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលសហព្រះរាជអាជ្ញាអន្តរជាតិយកមកសំអាង មិនគ្រប់គ្រាន់ដើម្បីកំណត់អំពីអង្គហេតុពាក់ព័ន្ធទេ[774] ហើយ

---

[768] ចម្លើយតប កថាខណ្ឌ ១០៧ យោងទៅ ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១០៥, ១០៨, ១៣៩។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៧ (ឯកសារ D308/3/1/19/2.1) ទំព័រ ៥១-៥៤។

[769] ចម្លើយតប កថាខណ្ឌ ១០៩ យោងទៅ ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៣៩។ សំណុំរឿង០០៤/១ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ ឯកសារ D123/1/5.1b ("កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ (ឯកសារ D123/1/5.1b)") នៅត្រង់ ERN (ភាសាខ្មែរ) 00929772។

[770] ចម្លើយតប កថាខណ្ឌ ១១១ យោងទៅ បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦៤-៦៨។

[771] ចម្លើយតប កថាខណ្ឌ ១១០។

[772] ចម្លើយតប កថាខណ្ឌ ១២០។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៧ (ឯកសារ D308/3/1/19/2.1) ទំព័រ ៥១-៥៤។

[773] ចម្លើយតប កថាខណ្ឌ ១២១។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៧ (ឯកសារ D308/3/1/19/2.1) ទំព័រ ៥៨-៥៩។

[774] ចម្លើយតប កថាខណ្ឌ ១២២-១២៣ យោងទៅ បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៧៩ ជើងទំព័រ ១៩៦។

សាក្សី ៧ នាក់បានផ្តល់ភ័ស្តុតាងប្រយោល ដែលមានលក្ខណៈស្មាន និងមិនស៊ីសង្វាក់[775]។ បើតាមទស្សនទានរបស់សហមេធាវី សាក្សីតែម្នាក់គត់ដែលសក្តិសមជា "ភ័ស្តុតាងគាំទ្រ" ចំពោះការចោទប្រកាន់ពាក់ព័ន្ធនឹងមុខតំណែងរបស់ អ៊ឹម ចែម នៅតំបន់ ១៣[776] តែបង្កើតជាមូលដ្ឋានមិនពេញលេញសម្រាប់ទាញសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងបទដ្ឋាននៃការបង្ហាញភ័ស្តុតាង [777] ។ នៅក្នុងបរិបទនៃភ័ស្តុតាងសរុប សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតគឺសមហេតុសមផល [778] ហើយពុំអាចរកឃើញថា សហចៅក្រមស៊ើបអង្កេតបានបំពានឆន្ទានុសិទ្ធិរបស់ខ្លួនទេ[779]។

២៩០. នៅក្នុងការឆ្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិរម្លឹកថា បទដ្ឋាននៃការបង្ហាញភ័ស្តុតាងចំពោះសេចក្តីសន្និដ្ឋានលើអង្គហេតុនេះ នៅដំណាក់កាលដីកាដំណោះស្រាយគឺបទដ្ឋានលក្ខខណ្ឌភវនីយភាព មិនមែនបទដ្ឋាន "លើសពីវិមតិសង្ស័យ" ទេ[780] និងបានជំទាស់ថា ការទទួលស្គាល់របស់ អ៊ឹម ចែម ពាក់ព័ន្ធនឹងមុខតំណែងរបស់គាត់ រួមជាមួយនឹងចម្លើយសាក្សីដែលបញ្ជាក់បន្ថែមនោះ ធ្វើឲ្យបទដ្ឋាននៃការបង្ហាញភ័ស្តុតាងនេះមានភាពលើសលុបរួចទៅហើយ [781] ។ ជាពិសេស ផ្ទុយពីការអះអាងរបស់សហមេធាវី ដីកាដំណោះស្រាយ (សំអាងហេតុ) មិនបានកំណត់ដោយគ្មានមន្ទិលសង្ស័យថា កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា អាចយកមកសំអាងបានតែក្នុងករណីមានការគាំទ្រដោយប្រភពផ្សេងទៀតនោះទេ[782]។ សហមេធាវីក៏មិនបានធ្វើការកត់សម្គាល់ថា កិច្ចសម្ភាសន៍ទាំងនេះត្រូវបានកត់ត្រាទុក និងមិនបានពន្យល់ថាតើហេតុអ្វីបានជាសេចក្តីថ្លែងការណ៍របស់គាត់ផ្ទាល់បែរជាមិនអាចទុកចិត្តបានទៅវិញ

---

[775] ចម្លើយតប កថាខណ្ឌ ១២៣។ សូមមើលផងដែរ កថាខណ្ឌ ១២៤-១២៧ យោងទៅ បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៧៤-៧៨។

[776] ចម្លើយតប កថាខណ្ឌ ១២៨-១៣០ យោងទៅ បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៧៥, ៧៧-៧៨។ សំណុំរឿង ០០៤/១ កំណត់ហេតុ នៃការស្តាប់ចម្លើយសាក្សី ខឹម រ៉ៃ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D219/636 នៅត្រង់ ERN (ភាសាខ្មែរ) 01184402 (ឆ.៣៨)។

[777] ចម្លើយតប កថាខណ្ឌ ១៣០។

[778] ចម្លើយតប កថាខណ្ឌ ១៣០។

[779] ចម្លើយតប កថាខណ្ឌ ១២៣, ១២៥។

[780] ការឆ្លើយតប កថាខណ្ឌ ៥៤ យោងទៅ ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២។

[781] ការឆ្លើយតប កថាខណ្ឌ ៥៤, ៦៤។

[782] ការឆ្លើយតប កថាខណ្ឌ ៥៩ យោងទៅ ចម្លើយតប កថាខណ្ឌ ១២០។ ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១០៨។



PRE-TRIAL CHAMBER E.C.C.C

នោះទេ[783]។ សហព្រះរាជអាជ្ញាអន្តរជាតិសង្កត់ធ្ងន់ថា អង្គជំនុំជម្រះតុលាការកំពូលបានគាំទ្រដល់ការប្រើប្រាស់សេចក្តីថ្លែងការណ៍របស់ នួន ជា នៅក្រៅតុលាការដែរ ក្នុងសំណុំរឿង ០០២/១[784]។

២៩១. សហព្រះរាជអាជ្ញាអន្តរជាតិឆ្លើយតបបន្ថែមថា ក្នុងករណីណាក៏ដោយ ការទទួលស្គាល់របស់ អ៊ឹម ចែម ពាក់ព័ន្ធនឹងមុខតំណែងរបស់គាត់នៅភូមិភាគនិរតី ស្របទៅនឹងកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរដែលបានបង្កើតឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត[785]។ គាត់អះអាងថា ការវាយតម្លៃរបស់សហមេធាវីទៅលើភស្តុតាងគាំទ្រដែលបានដកស្រង់នៅក្នុងទឡ្ហីករណ៍ទី ៥ នៃបណ្តឹងឧទ្ធរណ៍មានកំហុសឆ្គង និង លើសពីការមិនយល់ដឹងអង្គហេតុ និងភស្តុតាងទៅទៀត[786]។ ទាក់ទិននឹងទឡ្ហីករណ៍ទី ៦ នៃបណ្តឹងឧទ្ធរណ៍ ការអះអាងរបស់សហមេធាវីពាក់ព័ន្ធនឹងភាពជាប់ពាក់ព័ន្ធ និង តម្លៃជាភស្តុតាងនៃភស្តុតាងរបស់សាក្សីដែលបង្ហាញពីមុខតំណែងរបស់ អ៊ឹម ចែម នៅក្នុងគណៈកម្មាធិការតំបន់ ១៣ គឺជាទូទៅ មិនត្រូវបានគាំទ្រ និងមិនត្រឹមត្រូវនោះទេ[787]។ ជាពិសេស ការចោទប្រកាន់របស់ពួកគេពាក់ព័ន្ធនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជារឿងមិនសមរម្យ ដោយសារពាក្យសុំទាំងនោះត្រូវបានយោង ដើម្បីគាំទ្រដល់ភស្តុតាងផ្សេងទៀតប៉ុណ្ណោះ[788]។

## ២. ការពិភាក្សា

២៩២. ចៅក្រមទទួលបន្ទុករឿងក្តីនឹងពិនិត្យ (ក) ថាតើ សហចៅក្រមស៊ើបអង្កេតមានកំហុសឆ្គង ដោយមិនពិចារណាទៅលើសេចក្តីប្រកាសរបស់ អ៊ឹម ចែម ដែលបានផ្តល់នៅខាងក្រៅដំណើរការតាមផ្លូវតុលាការស្តីពីមុខតំណែងរបស់គាត់នៅភូមិភាគនិរតី ឬយ៉ាងណា និង (ខ) បន្ទាប់ពីបានរៀបរាប់ដោយសង្ខេបអំពីសាវតារផ្ទាល់ខ្លួនរបស់គាត់នៅមុនឆ្នាំ ១៩៧៥ (គ) ថាតើ សហចៅក្រមស៊ើបអង្កេតមានកំហុសឆ្គងក្នុងការសន្និដ្ឋានថា មុខតំណែងតែមួយគត់របស់គាត់នៅភូមិភាគនិរតីគឺជាប្រធានសមាគមនារីនៅតំបន់ ១៣ ឬយ៉ាងណា។ បន្ទាប់មកចៅក្រមទទួលបន្ទុករឿងក្តីនឹងសម្រេចថាតើ មានភស្តុតាងគ្រប់គ្រាន់ ដោយផ្អែកលើ

---

[783] ការឆ្លើយតប កថាខណ្ឌ ៥៩។

[784] ការឆ្លើយតប កថាខណ្ឌ ៥៥ យោងទៅ សាលដីកាសំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៣៥៨-៣៥៩។

[785] ការឆ្លើយតប កថាខណ្ឌ ៥៥ យោងទៅ បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៨-៨១។

[786] ការឆ្លើយតប កថាខណ្ឌ ៥៦-៦៨ យោងទៅ ចម្លើយតប កថាខណ្ឌ ១១៥-១១៦។

[787] ការឆ្លើយតប កថាខណ្ឌ ៦១-៦៣ យោងទៅ ចម្លើយតប កថាខណ្ឌ ១២៤-១៣០។

[788] ការឆ្លើយតប កថាខណ្ឌ ៦០ យោងទៅ ចម្លើយតប កថាខណ្ឌ ១២២។

តុល្យភាពនៃភវនីយភាព ដើម្បីបង្ហាញថា អ៊ឹម ចែម ធ្លាប់ជា (ឃ) លេខាស្រុកកោះអណ្តែត និង (ង) សមាជិកគណៈកម្មាធិការតំបន់ ១៣ ឬយ៉ាងណា។

## ក. ការសំអាងទៅលើការប្រកាសរបស់ អ៊ឹម ចែម នៅក្រៅដំណើរការតាមផ្លូវតុលាការ

២៩៣. ចៅក្រមទទួលបន្ទុករឿងក្តីកត់សម្គាល់ថា ភស្តុតាងដែលជាប់ពាក់ព័ន្ធភាគច្រើនទាក់ទិននឹងមុខតំណែង តួនាទី និង ការទទួលខុសត្រូវរបស់ អ៊ឹម ចែម នៅភូមិភាគនិរតី បានមកពីសេចក្តីថ្លែងការណ៍សាធារណៈដែលគាត់បានធ្វើនៅក្រៅដំណើរការតាមផ្លូវតុលាការ។ ទោះជាយ៉ាងនេះក្តី នៅក្នុងផ្នែកនៃដីកាដំណោះស្រាយ (សំអាងហេតុ) ស្តីពីតួនាទី និងសិទ្ធិអំណាចរបស់ អ៊ឹម ចែម នៅភូមិភាគនិរតី សហចៅក្រមស៊ើបអង្កេតមិនបានពិចារណាទាល់តែសោះទៅលើសេចក្តីថ្លែងការណ៍របស់ អ៊ឹម ចែម ដែលពាក់ព័ន្ធ ដោយមិនបានផ្តល់សំអាងហេតុជាក់លាក់[789] និងបានសំអាងទៅលើសេចក្តីថ្លែងការណ៍ទាំងនោះ តែក្នុងពេលដែលបញ្ជាក់ពីមុខតំណែងរបស់គាត់ជាប្រធានសមាគមនារីប៉ុណ្ណោះ[790]។ ហេតុនេះ ការថ្លឹងថ្លែងផ្តល់ទម្ងន់ទៅលើកិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា និងផ្សេងទៀត គឺជាមូលដ្ឋានចម្បងនៃការតវ៉ារបស់ភាគីនៅក្នុងទឡ្ហីករណ៍ទី ៥ និងទី ៦ នៃបណ្តឹងឧទ្ធរណ៍[791]។

២៩៤. ចៅក្រមទទួលបន្ទុករឿងក្តីសូមរម្លឹកដល់ការសន្និដ្ឋានរបស់អង្គបុរេជំនុំជម្រះដែលថា វាជាកំហុសឆ្គងដែលធ្វើការវាយតម្លៃអំពីតម្លៃជាភស្តុតាងនៃភស្តុតាងដោយផ្អែកលើប្រភពរបស់វា ជាជាងតម្លៃពិតប្រាកដ ហើយហេតុនេះ បានផ្តល់ទម្ងន់ចំពោះសេចក្តីថ្លែងការណ៍ដែល អ៊ឹម ចែម បានផ្តល់ជូនមជ្ឈមណ្ឌលឯកសារកម្ពុជា និងអង្គភាពផ្សេងទៀត ស្រាលជាងសេចក្តីថ្លែងការណ៍ដែលគាត់បានផ្តល់ជូនការិយាល័យសហចៅក្រមស៊ើបអង្កេត [792] ។ ចៅក្រមទទួលបន្ទុករឿងក្តីរម្លឹកបន្ថែមដល់ការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលដែលថា សេចក្តីថ្លែងការណ៍ដាក់បន្ទុករបស់ជនជាប់ចោទ ដែលគាំទ្រដល់ភស្តុតាងផ្សេងទៀត អាចយកមកសំអាងបាននៅក្នុងដំណើរការតាមផ្លូវតុលាការ[793]។ ហេតុនេះ ចៅក្រមទទួលបន្ទុករឿង

---

789 ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៤៣-១៥០។

790 ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៤៨។

791 សូមមើល ចម្លើយតប កថាខណ្ឌ ១០៧, ១២០។ ការឆ្លើយតប កថាខណ្ឌ ៥៥, ៥៩។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៧ (ឯកសារ D308/3/1/19/2.1) ទំព័រ ៥១-៥៤។

792 សូមមើលខាងលើ កថាខណ្ឌ ៤៩-៥៩ និង ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៣៩។

793 សាលដីកាសំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៣៥៨-៣៥៩ យោងទៅ សាលក្រមសំណុំរឿង ០០២ (ឯកសារ

01575607



ក្តីយល់ឃើញថា សេចក្តីថ្លែងការណ៍សាធារណៈរបស់ជនត្រូវចោទផ្តល់នូវមូលដ្ឋានភស្តុតាងគ្រប់គ្រាន់ ទាក់ទិននឹងបទដ្ឋាននៃការបង្ហាញភស្តុតាងជាធរមាននៅដំណាក់កាលមុនពេលសវនាការលើអង្គសេចក្តី។ ការពិត អ៊ឹម ចែម គឺជាសាក្សីល្អបំផុតដែលផ្តល់ព័ត៌មានពាក់ព័ន្ធនឹងតួនាទី និងការទទួលខុសត្រូវរបស់គាត់ផ្ទាល់នៅភូមិភាគនិរតី ហើយសេចក្តីថ្លែងការណ៍របស់គាត់ពាក់ព័ន្ធនឹងតួនាទី និងទំនាក់ទំនងរបស់គាត់ដែលសហចៅក្រមស៊ើបអង្កេតយកមកសំអាងនៅផ្នែកផ្សេងទៀតក្នុងដីកាដំណោះស្រាយ (សំអាងហេតុ)[794]។

២៩៥. ហេតុនេះ ចៅក្រមទទួលបន្ទុករឿងក្តីសន្និដ្ឋានថា សេចក្តីថ្លែងការណ៍របស់ អ៊ឹម ចែម ពាក់ព័ន្ធនឹងប្រវត្តិផ្ទាល់ខ្លួន និងមុខតំណែងរបស់គាត់នៅភូមិភាគនិរតី មានភាពពាក់ព័ន្ធខ្លាំង ហើយនឹងយកសេចក្តីថ្លែងការណ៍ទាំងនោះមកសំអាង ដោយវាយតម្លៃទៅលើតម្លៃពិតប្រាកដរបស់វាទៅតាមករណីជាក់ស្តែងនីមួយៗ នៅពេលពិនិត្យលើទឡ្ហីករណ៍ទី ៥ និងទី ៦។

## ខ. <u>សាវតាផ្ទាល់ខ្លួនរបស់ អ៊ឹម ចែម មុនឆ្នាំ ១៩៧៥</u>

២៩៦. ចៅក្រមទទួលបន្ទុករឿងក្តីយល់ឃើញថា ជាការចាំបាច់ដែលត្រូវរៀបរាប់ដោយសង្ខេបនូវប្រវត្តិផ្ទាល់ខ្លួនរបស់ អ៊ឹម ចែម មុនឆ្នាំ ១៩៧៥ ដោយសារវាជាសាវតារជាប់ពាក់ព័ន្ធទៅនឹងការពិចារណាលើទឡ្ហីករណ៍ទី ៥ និងទី ៦ នៃបណ្តឹងឧទ្ធរណ៍។

២៩៧. អ៊ឹម ចែម កើតនៅឆ្នាំ ១៩៤៦ នៅភូមិក្បាលអូរ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ[795] និងជាកូនច្បងក្នុងចំណោមបងប្អូន ១០ នាក់[796]។ នៅពេលគាត់អាយុ ១០ ឆ្នាំ ម្តាយគាត់បានទទួលមរណភាព ហើយគាត់ត្រូវបង្ខំចិត្តឈប់រៀន ដើម្បីចិញ្ចឹមប្អូនៗប្រុសស្រី[797]។ អ៊ឹម ចែម បានភ្ជាប់ពាក្យជាមួយ ណុប ញ៉ែន

---

E313) កថាខណ្ឌ ៥០១-៥០៣។

794 សូមមើល ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៤៨, ១៥៥។

795 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា របស់ អ៊ឹម ចែម នៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c) នៅត្រង់ ERN (ភាសាខ្មែរ) 00929848។ ការជូនដំណឹងអំពីបទចោទប្រកាន់ (ឯកសារ D239.1) កថាខណ្ឌ ១។

796 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម នៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c) នៅត្រង់ ERN (ភាសាអង់គ្លេស) 00951829។

797 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម នៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c) នៅត្រង់ ERN (ភាសាខ្មែរ) 00929851, 00929854។ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ (ឯកសារ D123/1/5.1b) នៅត្រង់ ERN (ភាសាខ្មែរ) 00929766។

ដែលជាកូនប្រុសបងជីដូនមួយឪពុកគាត់ នៅអាយុ ១២ ឬ ១៥ ឆ្នាំ ហើយគាត់បានរៀបការជាមួយគ្នានៅឆ្នាំ ១៩៦៤-១៩៦៥ នៅអាយុ ១៩ ឆ្នាំ[798]។ អ្នកទាំងពីរមានកូន ៨ នាក់ តែកូន ៤ នាក់បានស្លាប់តាំងពីនៅក្មេង។ អ៊ឹម ចែម បានពន្យល់ថា ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់គ្មានពេលវេលាគ្រប់គ្រាន់ក្នុងការមើលថែទាំកូនៗគាត់ទេ ដោយសារគាត់រវល់តស៊ូ "ដើម្បីជាតិពូជសាសន៍ [របស់ខ្លួន]"[799]។

២៩៨. នៅឆ្នាំ ១៩៦៦-១៩៦៧ អ៊ឹម ចែម បានទៅរានដីធ្វើស្រែនៅម្តុំកំពង់ស្ពឺ នៅភ្នំដាច់ ជាមួយ ១០ គ្រួសារផ្សេងទៀតមកពីភូមិក្បាលអូរ[800]។ នៅពេលនោះ គាត់មិនទាន់ចូលធ្វើបដិវត្តន៍នៅឡើយទេ[801]។ គាត់បាននិយាយថា គាត់ធ្វើស្រែចម្ការនៅក្នុងព្រៃ វិលត្រឡប់មកភូមិកំណើតវិញ នៅពេលមានការបះបោរប្រដាប់អាវុធលើកដំបូងបានកើតឡើងនៅបាត់ដំបង[802]។ នៅពេលនោះ នគរបាលសម្ងាត់នៅខេត្តកំពង់ស្ពឺបានចោទប្រកាន់គ្រួសារគាត់ថាចូលរួមជាមួយពួកខ្មែរក្រហម[803]។ នៅចុងឆ្នាំ ១៩៦៨ ឬដើមឆ្នាំ ១៩៦៩ ប្អូនប្រុសគាត់ឈ្មោះ អ៊ឹម អ៊ី ដែលជានីរសាររបស់ តា ម៉ុក[804] ត្រូវបានចាប់ខ្លួន នៅពេលកំពុងប្រគល់ឯកសារ[805] ត្រូវគេយកទៅឃុំឃាំង និងសម្លាប់ចោល[806]។

---

[798] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម នៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c) នៅត្រង់ ERN (ភាសាខ្មែរ) 00929848, 00929855-00929856។ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ (ឯកសារ D123/1/5.1b) នៅត្រង់ ERN (ភាសាខ្មែរ) 00929766។

[799] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម នៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c) នៅត្រង់ ERN (ភាសាខ្មែរ) 00929850។

[800] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម នៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c) នៅត្រង់ ERN (ភាសាខ្មែរ) 00929856-00929857។ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ (ឯកសារ D123/1/5.1b) នៅត្រង់ ERN (ភាសាខ្មែរ) 00929766។

[801] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម នៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c) នៅត្រង់ ERN (ភាសាខ្មែរ) 00929857។

[802] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ (ឯកសារ D123/1/5.1b) នៅត្រង់ ERN (ភាសាខ្មែរ) 00929767។

[803] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ (ឯកសារ D123/1/5.1b) នៅត្រង់ ERN (ភាសាខ្មែរ) 00929767។

[804] កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម នៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c) នៅត្រង់ ERN (ភាសាខ្មែរ) 00929857-00929859។

[805] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម នៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c) នៅ

២៩៩. នៅឆ្នាំ ១៩៦៩ អ៊ឹម ចែម ត្រូវបានចាប់ខ្លួនដោយសារគាត់ជាខ្មែរឧទ្ទាម ត្រូវទាហានទ័ពស្រួចឃុំឃាំងនៅឃុំជាងទងអស់រយៈពេលមួយឆ្នាំយ៉ាងតិច[807] ហើយត្រូវបានដោះលែងនៅឆ្នាំ ១៩៧០។ ក្រោយពេលរដ្ឋប្រហារ គាត់បានចូលរួមជាមួយចលនាខ្មែរក្រហមនៅខេត្តតាកែវ[808]។ នៅឆ្នាំ ១៩៧១ អ្នកដែលបានភៀសខ្លួនចូលព្រៃមួយឆ្នាំ បានលួចវិលត្រឡប់មកវិញដោយស្ងាត់ៗ[809]។ បន្ទាប់មក គាត់ត្រូវគេចោទថាបានបង្កើតសមាគមប្រវាស់ដៃ ក្នុងការបង្កបង្កើនផល និងដឹកនាំអ្នកភូមិ[810]។ ចាប់ពីពេលនោះមក គាត់ដឹងពីរបៀបគ្រប់គ្រងការប្រជុំ[811]។ អង្គការនោះបានរីកដុះដាលពេញឃុំជាងទងទាំងមូល ហើយ អ៊ឹម ចែម ក៏បានក្លាយជាប្រធានឃុំ[812]។ ចៅក្រមទទួលបន្ទុករឿងក្តីកត់សម្គាល់បន្ថែមថា អ៊ឹម ចែម មានទំនាក់ទំនង

---

ត្រង់ ERN (ភាសាខ្មែរ) 00929857- 00929859។ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ (ឯកសារ D123/1/5.1b) នៅត្រង់ ERN (ភាសាខ្មែរ) 00929767។

[806] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ (ឯកសារ D123/1/5.1b) នៅត្រង់ ERN (ភាសាខ្មែរ) 00929767។ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម នៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c) នៅត្រង់ ERN (ភាសាខ្មែរ) 00929859។

[807] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម នៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c) នៅត្រង់ ERN (ភាសាខ្មែរ) 00929860-00929862។ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ (ឯកសារ D123/1/5.1b) នៅត្រង់ ERN (ភាសាខ្មែរ) 00929767។

[808] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ (ឯកសារ D123/1/5.1b) នៅត្រង់ ERN (ភាសាខ្មែរ) 00929767។ កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម នៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c) នៅត្រង់ ERN (ភាសាខ្មែរ) 00929860, 00929862-00929863។

[809] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម នៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c) នៅត្រង់ ERN (ភាសាខ្មែរ) 00929862-00929863។

[810] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម នៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c) នៅត្រង់ ERN (ភាសាខ្មែរ) 00929863។ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ (ឯកសារ D123/1/5.1b) នៅត្រង់ ERN (ភាសាខ្មែរ) 00929768-00929769។

[811] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម នៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c) នៅត្រង់ ERN (ភាសាខ្មែរ) 00929863។

[812] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ (ឯកសារ D123/1/5.1b) នៅត្រង់ ERN (ភាសាខ្មែរ) 00929769-00929770។ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម នៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c) នៅត្រង់ ERN (ភាសាខ្មែរ) 00929863។ សំណុំរឿង ០០៤/១ ប្រតិចារឹកនៃកិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ជាមួយផលិតកម្ម Smiling Toad Productions ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ ឯកសារ D1.3.12.1 ("កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ (ឯកសារ D1.3.12.1)") នៅត្រង់ ERN (ភាសាខ្មែរ) 00234190-00234191។ សំណុំ

យ៉ាងជិតស្និទ្ធជាមួយ តា ម៉ុក [813] ដែលមកពីភូមិកំណើតជាមួយគ្នា ហើយដែលគាត់បានស្គាល់តាំងពីទសវត្សរ៍ឆ្នាំ ១៩៧០ មក[814]។

៣០០. ចៅក្រមទទួលបន្ទុករឿងក្តីសន្និដ្ឋានជារួមថា ភ័ស្តុតាងពាក់ព័ន្ធនឹងប្រវត្តិផ្ទាល់ខ្លួនរបស់ អ៊ឹម ចែម បង្ហាញថា គាត់បានស្ថិតនៅជាមួយថ្នាក់លើ [815] និងជាសមាជិកពេញសិទ្ធិរបស់បក្សតាំងពីយូរមកហើយ នៅពេលគាត់មានសកម្មភាពក្នុងតំបន់ ១៣[816]។ ហេតុនេះ អ៊ឹម ចែម ត្រូវបានគេរាយការណ៍ថា គាត់មានសមត្ថភាពធ្វើជាលេខាស្រុក ឬសមាជិកគណៈកម្មាធិការតំបន់[817]។ ការពិត សមាជិកពេញសិទ្ធិរបស់បក្សត្រូវបានចាត់តាំងឱ្យកាន់តំណែងនៅថ្នាក់ស្រុក ឬខ្ពស់ជាងនេះ[818]។

### គ. មុខងាររបស់ អ៊ឹម ចែម ជាប្រធានសមាគមនារីនៅតំបន់ ១៣

៣០១. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា អ៊ឹម ចែម មិនមែនជាលេខាស្រុកកោះអណ្តែត ឬជាសមាជិកគណៈកម្មាធិការតំបន់ ១៣ ទេ តែគាត់ត្រឹមតែជាលេខាសមាគមនារីក្នុងតំបន់ ១៣ ប៉ុណ្ណោះ[819]។

---

រឿង ០០៤/១ ប្រតិចារឹកនៃកិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម គ្មានចុះកាលបរិច្ឆេទ ឯកសារ D6.1.75 ("ប្រតិចារឹកនៃកិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម (ឯកសារ D6.1.75)") នៅត្រង់ ERN (ភាសាខ្មែរ) 00978475។

[813] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៥៥។

[814] សំណុំរឿង ០០៤/១ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ ឯកសារ D123/1/5.1a ("កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម នៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ (ឯកសារ D123/1/5.1a)") នៅត្រង់ ERN (ភាសាខ្មែរ) 00929749, 00929752។ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម នៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c) នៅត្រង់ ERN (ភាសាខ្មែរ) 00929858-00929859។

[815] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធឿន ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D118/274 នៅត្រង់ ERN (ភាសាខ្មែរ) 00999994 (ឆ.៥៥)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម ហឿន ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ D118/242 នៅត្រង់ ERN (ភាសាខ្មែរ) 00998737 (ឆ.១០៥)។

[816] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D118/259 នៅត្រង់ ERN (ភាសាខ្មែរ) 00997034 (ឆ.៨១)។

[817] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D118/259 នៅត្រង់ ERN (ភាសាខ្មែរ) 00997034 (ឆ.៨៣, ឆ.៨៥)។

[818] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម ហឿន ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ D118/242 នៅត្រង់ ERN (ភាសាខ្មែរ) 00998735 (ឆ.៩៣)។

[819] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៤៣, ១៤៦, ១៤៨, ១៥០។

៣០២. ចៅក្រមទទួលបន្ទុករឿងក្ដីយល់ថា វាពុំសមហេតុសមផលទេ ដែលសន្និដ្ឋានច្បាស់លាស់ថា អ៊ឹម ចែម មិនអាចបានកាន់មុខតំណែងណាក្រៅពីជាប្រធានសមាគមនារីនោះ។ ពុំមានភ័ស្ដុតាងណាមួយដែលបានដកស្រង់នៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ)[820] លើកឡើងថា វាជាមុខតំណែងតែមួយដែលគាត់កាន់នៅភូមិភាគនិរតីនោះឡើយ។ ផ្ទុយទៅវិញ សម្រង់កំណត់ហេតុនានា បានផ្ដល់ភ័ស្ដុតាងអំពីមុខតំណែងរបស់គាត់ជាប្រធានសមាគមនារី ដោយមិនបាននិយាយថា គាត់មិនបានកាន់តួនាទីណាផ្សេងទេ[821] ឬ បានផ្ដល់ភ័ស្ដុតាងផ្ទុយដែលថា គាត់បានកាន់មុខតំណែងនេះរួមជាមួយមុខតំណែងផ្សេងទៀត[822] ហើយមានភារកិច្ចជាច្រើនដែលហួសពីការដឹកនាំសមាគមនោះ[823]។ ឧទាហរណ៍ សហចៅក្រមស៊ើបអង្កេតបានសំអាងទៅលើភ័ស្ដុតាងពីសាក្សី ពេជ្រ ជឹម ក្នុងការសន្និដ្ឋានថា អ៊ឹម ចែម បានកាន់តួនាទីនេះតែមួយគត់ ដោយមិនពិចារណាទៅលើចម្លើយរបស់សាក្សីដដែលនេះដែលថា គាត់មិនត្រឹមតែទទួលបន្ទុកកិច្ចការនារីប៉ុណ្ណោះទេ តែក៏ជាអនុប្រធានស្រុកអង្គរជ័យ ហើយត្រូវបានរាយការណ៍ថា គាត់មានតួនាទីនៅក្នុងគណៈក

[820] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៤៨, ១៥០។

[821] សូមមើលឧទាហរណ៍ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី តឹប ភី ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ D219/521 នៅត្រង់ ERN (ភាសាខ្មែរ) 01149836 (ឆ.៦៣)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ុន ធឿន ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ D119/149 នៅត្រង់ ERN (ភាសាខ្មែរ) 01022478 (ឆ.៣២)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ុន ធឿន ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ D6.1.688 នៅត្រង់ ERN (ភាសាខ្មែរ) 00368607។

[822] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ុន ធឿន ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D118/274 នៅត្រង់ ERN (ភាសាខ្មែរ) 00999991 (ឆ.២៨-ឆ.២៩)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D118/259 នៅត្រង់ ERN (ភាសាខ្មែរ) 00997024-00997025 (ឆ.១៨-ឆ.១៩), ERN (ភាសាខ្មែរ) 00997028 (ឆ.៤០-ឆ.៤៥)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/83 នៅត្រង់ ERN (ភាសាខ្មែរ) 00975684 (ឆ.១៨-ឆ.១៩)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/84 នៅត្រង់ ERN (ភាសាខ្មែរ) 00975692 (ឆ.២០), ERN (ភាសាខ្មែរ) 00975696 (ឆ.៣៣)។

[823] សូមមើល ឧទាហរណ៍ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ុន ធឿន ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ D6.1.688 នៅត្រង់ ERN (ភាសាខ្មែរ) 00368608។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ុន ធឿន ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D118/274 នៅត្រង់ ERN (ភាសាខ្មែរ) 00999992-00999993 (ឆ.៤១-៤២), ERN (ភាសាខ្មែរ) 00999997 (ឆ.៧២)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឆឹង ជឿន ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ D119/156 នៅត្រង់ ERN (ភាសាខ្មែរ) 01024772 (ឆ.១៥-ឆ.១៩)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D118/259 នៅត្រង់ ERN (ភាសាខ្មែរ) 00997028 (ឆ.៤០-ឆ.៤៥), ERN (ភាសាខ្មែរ) 00997034 (ឆ.៨៥)។

01575612



ម្ចាធិការតំបន់[824]។ សហចៅក្រមស៊ើបអង្កេតក៏មិនបានកត់សម្គាល់ថា អ៊ឹម ចែម ក៏បានឡើងជាសមាជិកសភាតំណាងប្រជាជននៅថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៧៦[825] ក្នុងចំណោមតំណាងរាស្ត្រចំនួន ២៥០ នាក់ ដែលជាកត្តាជាប់ពាក់ព័ន្ធមួយដើម្បីវាយតម្លៃពីកម្រិតនៃឥទ្ធិពលរបស់គាត់។ ជារួម គាត់មានសមត្ថកិច្ចទូលំទូលាយ និងមានសិទ្ធិអំណាចទៅលើ "សាខា" ជាច្រើនដែលស្ថិតនៅក្រោមតំបន់[826]។

៣០៣. ចៅក្រមទទួលបន្ទុករឿងក្តីកត់សម្គាល់បន្ថែមពីការខ្វះខាតនៃការធ្វើសេចក្តីសន្និដ្ឋាននៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) ពាក់ព័ន្ធនឹងកម្រិតនៃសិទ្ធិអំណាចដែល អ៊ឹម ចែម ទទួលបានក្នុងនាមជាប្រធានសមាគមនារីក្នុងតំបន់ ១៣[827]។ ទោះបី ភ័ស្តុតាងមួយចំនួននៅក្នុងសំណុំរឿងបង្ហាញថា មុខតំណែងនេះពុំមានតួនាទីដែលមានអំណាច[828] ក៏ដោយ តែសាក្សីភាគច្រើនបានរាយការណ៍ថា ប្រធានសមាគមនារីគឺជាអង្គការចម្បងមួយ ហើយថា អ៊ឹម ចែម ទទួលខុសត្រូវចំពោះស្ត្រីរាប់ពាន់នាក់[829] ដែលគាត់បានចាត់តាំងឱ្យកាន់មុខតំណែងនានានៅគ្រប់លំដាប់ថ្នាក់ទាំងអស់ក្នុងរចនាសម្ព័ន្ធរដ្ឋបាល[830]។ ការពិនិត្យយ៉ាងល្អិតល្អន់ទៅលើភ័ស្តុតាងពិតជាបង្ហាញថា សមាគមនារីតំបន់អាចចូលរួមទៅក្នុងគណៈកម្មាធិការតំបន់ [831]

---

[824] សូមមើល សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D118/259 នៅត្រង់ ERN (ភាសាខ្មែរ) 00997028 (ឆ.៤០)។

[825] សំណុំរឿង ០០៤/១ ប្រតិចារឹកនៃការផ្សាយតាមវិទ្យុពីថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៧៦ ឯកសារ D119/84.1 នៅត្រង់ ERN (ភាសាខ្មែរ) 00975703។ សូមមើលផងដែរ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មួល អេង ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ D219/294 នៅត្រង់ ERN (ភាសាខ្មែរ) 01095255-01095257 (ឆ.១២៨-ឆ.១៣៩)។

[826] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួត មុត ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ D219/37 នៅត្រង់ ERN (ភាសាខ្មែរ) 01032103 (ឆ.២៥)។

[827] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៤៨។

[828] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធឿន ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D118/274 នៅត្រង់ ERN (ភាសាខ្មែរ) 00999995 (ឆ.៥៦-ឆ.៥៧)។

[829] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គីប ភី ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ D219/521 នៅត្រង់ ERN (ភាសាខ្មែរ) 01149835 (ឆ.៥៣)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/84 នៅត្រង់ ERN (ភាសាខ្មែរ) 00975694 (ឆ.៣០)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម ហឿន ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ D118/242 នៅត្រង់ ERN (ភាសាខ្មែរ) 00998737 (ឆ.១០៩)។

[830] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/84 នៅត្រង់ ERN (ភាសាខ្មែរ) 00975694 (ឆ.២៩)។

[831] សូមមើល ឧទាហរណ៍ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ

ហើយថា អ៊ឹម ចែម មានវត្តមាននៅក្នុងការប្រជុំថ្នាក់តំបន់ទាំងអស់[832] និងបានរាយការណ៍ផ្ទាល់ទៅលេខាតំបន់ ១៣[833]។

៣០៤. ទាក់ទិននឹងចំណុចនានាដែលបានលើកឡើងខាងលើ ចៅក្រមទទួលបន្ទុករឿងក្តីយល់ឃើញថា ពុំមានយុត្តិកម្មសមហេតុសមផលឡើយចំពោះសហចៅក្រមស៊ើបអង្កេត ដែលប្រើប្រាស់ភស្តុតាងដែលថា អ៊ឹម ចែម ជាប្រធានសមាគមនារីតំបន់ ១៣ ដោយមិនបានរាប់បញ្ចូល ឬ មិនបានផ្តល់ការថ្លឹងថ្លែងដល់ភស្តុតាងដែលថា គាត់បានកាន់មុខតំណែងផ្សេងៗទៀតនៅភូមិភាគនិរតី។ ការពិត ភស្តុតាងពិតជាចង្អុលបង្ហាញថា គាត់បានកាន់មុខតំណែងមានសិទ្ធិអំណាចជាច្រើននៅតំបន់ ១៣។

## ឃ. មុខងាររបស់ អ៊ឹម ចែម ក្នុងនាមជាលេខាស្រុកកោះអណ្តែត

៣០៥. ចៅក្រមទទួលបន្ទុករឿងក្តីពិចារណាឃើញថា សហចៅក្រមស៊ើបអង្កេតមានកំហុសនៅក្នុងការបកស្រាយភស្តុតាងដែលមានស្រាប់នៅពេលសម្រេចថា អ៊ឹម ចែម ពុំមែនជាលេខាស្រុកកោះអណ្តែត[834] ហើយភស្តុតាងនៅក្នុងសំណុំរឿង នៅពេលវាយតម្លៃប្រកបដោយភាពសមហេតុផល មានភាពគ្រប់គ្រាន់ជាក់លាក់ និងស៊ីសង្វាក់គ្នាក្នុងការបង្ហាញថា គាត់កាន់មុខតំណែងនេះ។

៣០៦. មូលដ្ឋានសំខាន់បំផុតនៃទឡ្ហីករណ៍ទី ៥ និងទឡ្ហីករណ៍ទី ៦ នៅក្នុងបណ្តឹងឧទ្ធរណ៍ គឺការអះអាងថា សហចៅក្រមស៊ើបអង្កេតខកខានមិនបានវាយតម្លៃឱ្យបានសមស្រប ឬ ពិចារណាពេញលេញលើភស្តុតាងនៅក្នុងសំណុំរឿង។ ក្នុងន័យនេះ ចៅក្រមទទួលបន្ទុករឿងក្តីសូមរំលឹកឡើងវិញនូវគោលការណ៍សច្ចធារណ៍

២០១៤ ឯកសារ D119/83 នៅត្រង់ ERN (ភាសាខ្មែរ) 00975684 (ឆ.១៩)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/84 នៅត្រង់ ERN (ភាសាខ្មែរ) 00975694-00975695 (ឆ.២៩-ឆ.៣១)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ D219/488 នៅត្រង់ ERN (ភាសាខ្មែរ) 01136706 (ឆ.៣៦)។ សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម ហឿន ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ D118/242 នៅត្រង់ ERN (ភាសាខ្មែរ) 00998732-00998733 (ឆ.៧៥-ឆ.៧៩), ERN (ភាសាខ្មែរ) 00998737 (ឆ.១០៥-ឆ.១០៩)។

[832] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធឿន ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D118/274 នៅត្រង់ ERN (ភាសាខ្មែរ) 00999997 (ឆ. ៧២)។

[833] សំណុំរឿង ០០៤/១ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D118/259 នៅត្រង់ ERN (ភាសាខ្មែរ) 00997039 (ឆ.១២៥)។

[834] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៤៣-១៤៦, ១៤៩-១៥០។

01575614



ថា សហចៅក្រមស៊ើបអង្កេតបានវាយតម្លៃគ្រប់ភស្តុតាងទាំងអស់ ហើយពុំចាំបាច់លើកឡើងគ្រប់ភស្តុតាងនៅក្នុងសំណុំរឿងនោះទេ ដរាបណាពុំមានការបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេតច្រានចោលទាំងស្រុងនូវគ្រប់ភស្តុតាងទាំងអស់នោះ សច្ចធារណ៍នេះអាចជំទាស់តវ៉ាបាននៅពេលភស្តុតាងដែលពាក់ព័ន្ធយ៉ាងច្បាស់នឹងការរកឃើញ ពុំបានលើកឡើងនៅក្នុងសំអាងហេតុ[835]។ ពាក់ព័ន្ធនឹងបញ្ហាតវ៉ានេះ សហចៅក្រមស៊ើបអង្កេតច្រានចោលដោយពុំបានធ្វើត្រឹមត្រូវតាមច្បាប់លើចម្លើយរបស់ អ៊ឹម ចែម[836] ហើយនឹងភស្តុតាងស៊ីសង្វាក់ពាក់ព័ន្ធយ៉ាងជាក់លាក់ផ្សេងទៀត ដូចបានរៀបរាប់លម្អិតខាងក្រោមនេះ។

៣០៧. ពីដំបូងឡើង ចៅក្រមទទួលបន្ទុករឿងក្តីកត់សម្គាល់ឃើញថា អ៊ឹម ចែម បានពន្យល់ថា គាត់ត្រូវបាន "បន្តតែងតាំងតម្លើងតំណែងទៅថ្នាក់ខ្ពស់" នៅក្នុងការងាររបស់គាត់ ហើយត្រូវបាន "ជ្រើសរើសជាមេដឹកនាំម្នាក់" [837] ។ ចាប់តាំងពីឆ្នាំ១៩៧២ មក គាត់ទទួលខុសត្រូវលើកងនារីនៅខេត្តតាកែវទាំងមូល [838] ។ ក្រោយមក គាត់ត្រូវបានចាត់តាំងឱ្យទទួលខុសត្រូវលើការរៀបចំប្រជាជននៅក្នុងស្រុកអង្គរជ័យ និងកោះអណ្តែត [839] ។ នៅក្នុងឆ្នាំ១៩៧៤ តាម៉ុក បានបញ្ជូនគាត់ទៅអង្គរជ័យ ហើយគាត់ត្រូវបានតែងតាំងឱ្យធ្វើការងារនៅមន្ទីរស្រុក [840] ដែលនៅទីនោះគាត់ជាមនុស្សម្នាក់គត់ទទួលខុសត្រូវលើ [841] ការរៀបចំ និងការ

---

[835] ICTR, រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Zigiranyirazo, ICTR-01-73-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ("សាលដីកាក្នុងរឿងក្តី Zigiranyirazo") កថាខណ្ឌ ៤៥។ ICTY, រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Perišić, IT-04-81-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ("សាលដីកាក្នុងរឿងក្តី Perišić") កថាខណ្ឌ ៩២។

[836] សូមមើលខាងលើ កថាខណ្ឌ ៤៩-៥៩, ២៩២-២៩៤ ។

[837] កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ (ឯកសារ D1.3.12.1), ERN (ភាសាខ្មែរ) 00234191-00234192។ សូមមើលផងដែរ ERN (ភាសាខ្មែរ) 00234199-00234200។

[838] សំណុំរឿង ០០៤/១ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ Dឯកសារ D123/1/5.1c), ERN (ភាសាខ្មែរ) 00929864-00929865។ សំណុំរឿង ០០៤/១ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ (ឯកសារ D123/1/5.1b), ERN (ភាសាខ្មែរ) 00929770-00929771។ សូមមើលផងដែរ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D118/259 ERN (ភាសាអង់គ្លេស) 01000672ទំព័រ ៩ (ឆ. 45)។

[839] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ (ឯកសារ D123/1/5.1b), ERN (ភាសាខ្មែរ) 00929771-00929772។ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c), ERN (ភាសាខ្មែរ) 00929867។ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ (ឯកសារ D123/1/5.1a), ERN (ភាសាខ្មែរ) 00929738-00929739។

[840] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ (ឯកសារ D1.3.12.1), ERN

គ្រប់គ្រងប្រជាជន[842]។ យ៉ាងហោចណាស់ មានសាក្សីពីរនាក់មានភ័ស្តុតាងស៊ីសង្វាក់គ្នាជាមួយនឹង អ៊ឹម ចែម ដែលថាគាត់មានតួនាទីដឹកនាំនៅអង្គរជ័យ[843]។ គាត់បានរៀបចំប្រជាជន និងផ្តោតលើសេដ្ឋកិច្ច[844] ជាពិសេស ការបង្កបង្កើនផល[845] ហើយទទួលជោគជ័យនៅក្នុងការសម្រេចផែនការបង្កបង្កើនផលកំណត់ដោយ ប៉ុល ពត[846]។ នៅក្នុងឆ្នាំ ១៩៧៦ គាត់ត្រូវបាន តាម៉ុក និង ប៉ុល ពត បញ្ជូនទៅកោះអណ្តែតដោយសារលទ្ធផលការងារល្អ[847]។

៣០៨. ក្រោយពេលបដិសេធកាលពីដំបូងថា គាត់ពុំមែនជាលេខាស្រុកកោះអណ្តែត[848] អ៊ឹម ចែម ខ្លួនឯងបានទទួលស្គាល់ថា គាត់ត្រូវបានតែងតាំងជាមេដឹកនាំស្រុក នៅពេល សៀង អតីតលេខា ត្រូវបានផ្ទេរទៅគី

---

(ភាសាខ្មែរ) 00234193-00234194។ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c), ERN (ភាសាខ្មែរ) 00929868។

[841] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c), ERN (ភាសាខ្មែរ) 00929867។

[842] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ (ឯកសារ D123/1/5.1b), ERN (ភាសាខ្មែរ) 00929771-00929772។ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c), ERN (ភាសាខ្មែរ) 00929867។

[843] សូមមើល សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ អ៊ុល ហឿន ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ D118/208, ERN (ភាសាខ្មែរ) 00980089 (ឆ.60-ឆ.64)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ អ៊ុល ហឿន ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ D118/209, ERN (ភាសាខ្មែរ) 00980115 (ឆ.128-ឆ.129)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D118/259, ERN (ភាសាខ្មែរ) 00997024 (ឆ.18), ERN (ភាសាខ្មែរ) 00997028 (ឆ.40)។

[844] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c), ERN (ភាសាខ្មែរ) 00929872។

[845] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c), ERN (ភាសាខ្មែរ) 00929867។

[846] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c), ERN (ភាសាខ្មែរ) 00929866-00929868។

[847] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c), ERN (ភាសាខ្មែរ) 00929871-00929876។ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ (ឯកសារ D123/1/5.1b), ERN (ភាសាខ្មែរ) 00929772-00929773។ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ (ឯកសារ D123/1/5.1a), ERN (ភាសាខ្មែរ) 00929749-00929751។

[848] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ (ឯកសារ D123/1/5.1b), ERN

វីវង្ស ដោយសារជម្លោះញឹកញាប់នៅក្នុងគណៈកម្មាធិការ[849]។ គាត់បានបញ្ជាក់ថា អនុប្រធានរបស់គាត់គឺ តាសាន ដែលជាបង/ប្អូនថ្លៃតាម៉ុក ចំណែកសមាជិកគណៈកម្មាធិការគឺ តាចាន់[850]។ ក្នុងនាមជាលេខាស្រុកកោះអណ្ដែត អ៊ឹម ចែម បានជួបជាមួយ និងបានទទួលការណែនាំពី តាម៉ុក[851] រៀបចំប្រជាជន និងការងារ[852] និងរៀបចំប្រជុំធំៗ[853]។ អ៊ឹម ចែម បាននិយាយបន្ថែមទៀតថា គាត់នៅកោះអណ្ដែតរយៈពេលមួយឆ្នាំនៅមុន តាម៉ុក បញ្ជូនគាត់ទៅទីរួមខេត្តតាកែវ[854] ទីស្នាក់ការធំរបស់តំបន់ ១៣[855]។ នៅខេត្តតាកែវ គាត់បានបន្តធ្វើជាលេខាស្រុកកោះអណ្ដែតបន្តទៀត[856]។

៣០៩. ភស្តុតាងនៅក្នុងសំណុំរឿង ស៊ីសង្វាក់គ្នាជាមួយនឹងការទទួលស្គាល់របស់ អ៊ឹម ចែម ពាក់ព័ន្ធនឹងតួនាទីដឹកនាំរបស់គាត់នៅស្រុកកោះអណ្ដែត។ នាង អ៊ូច ហៅ សាន បានទទួលស្គាល់ថា អ៊ឹម ចែម "មកធ្វើការងារជាប្រធានស្រុក" នៅមុនពេលកែចម្លើយ ហើយលើកឡើងថា គាត់ពុំបានដឹងថាតើគាត់កាន់តួនាទី

(ភាសាខ្មែរ) 00929771-00929772។

[849] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c), ERN (អង់គ្លេស) 00951846-00951846។

[850] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c), ERN (ភាសាខ្មែរ) 00929873-00929876។

[851] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c), ERN (ភាសាខ្មែរ) 00929874-00929875។

[852] សូមមើល កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ (ឯកសារ D123/1/5.1b), ERN (ភាសាខ្មែរ) 00929771-00929772។ សំណុំរឿង ០០៤/១ ប្រតិចារឹកនៃបទសម្ភាសន៍របស់ អ៊ឹម ចែម ជាមួយ Youth for Peace ឆ្នាំ ២០១១ ឯកសារ D219/264.1, ERN (ភាសាខ្មែរ) 01107002-01107004។

[853] See សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ សុខ រ៉ុំ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ D119/108, ERN (ភាសាខ្មែរ) 00979405 (ឆ.47-ឆ.48)។

[854] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c), ERN (ភាសាខ្មែរ) 00929873-00929877.

[855] សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ ម៉ឹង វេត ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/84, ERN (ភាសាខ្មែរ) 00975692 (ឆ.18)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ ខឹម បឿន ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ D118/242, ERN (ភាសាខ្មែរ) 00998731 (ឆ.64)។

[856] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c), ERN (ភាសាខ្មែរ) 00929876-00929877.

នេះឬយ៉ាងណាទេ[857]។ កៅ ឆេង គិតថា អ៊ឹម ចែម ធ្វើការងារនៅស្រុក ១០៨ (ពោលគឺ ស្រុកកោះអណ្តែត)[858]។ សុខ រ៉ុម ដែលសហចៅក្រមស៊ើបអង្កេតពុំពិចារណាភ័ស្តុតាងរបស់គាត់ពាក់ព័ន្ធនឹងមុខងាររបស់ អ៊ឹម ចែម ប៉ុន្តែ ដែលគាត់ខ្លួនឯងធ្វើការងារនៅស្រុកកោះអណ្តែត បានលើកឡើងថា អ៊ឹម ចែម "គឺជាគណៈស្រុក"[859]។ គាត់បានរំលឹកថា គាត់បានឃើញ អ៊ឹម ចែម នៅក្នុងឆ្នាំ១៩៧៦ ជួបប្រជុំនៅស្រុកកោះអណ្តែត ដែលមានប្រជាជនប្រុសស្រីចំនួន ១.៥០០ នាក់ ចូលរួម[860]។ រៀល ស៊ន ពេទ្យទទួលខុសត្រូវសេដ្ឋកិច្ចនៅរោងជាងជិតស្រុក[861] ហើយដែលបានអះអាងថា គាត់បានស្គាល់ អ៊ឹម ចែម ច្បាស់ ក៏បានលើកឡើងផងដែរថា អ៊ឹម ចែម នៅក្នុងគណៈកម្មាធិការ ហើយក្រោយមកត្រូវបានតែងតាំងជាគណៈស្រុក[862] ហើយថា អ៊ឹម ចែម "មានអំណាចខ្លាំងជាង យាយធឿន ទៀត"[863] នៅស្រុក ១០៥ ដែលក្រោយមកគណៈស្រុក ១០៦[864]។ ចៅក្រមទទួលបន្ទុករឿងក្តី រកឃើញថា ចម្លើយនេះស៊ីសង្វាក់គ្នាជាមួយនឹងចម្លើយរបស់ អ៊ឹម ចែម ដែលនៅក្នុងនោះ គាត់ទទួលស្គាល់ថាធ្លាប់បានទទួលខុសត្រូវដំបូងលើភូមិក្នុងឃុំជាងទង[865] នៅមុនពេលឡើងទៅកាន់ស្រុក[866]។

---

[857] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ នាង អ៊ួច ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៤ ឯកសារ D119/82, ERN (ភាសាខ្មែរ) 00971375 (ឆ.64-ឆ.65)។

[858] សំណុំរឿង ០០៤/១ កិច្ចសម្ភាសន៍របស់ការិយាល័យសហព្រះរាជអាជ្ញាជាមួយ កៅ ឆេង ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៨ ឯកសារ D1.3.11.19, ERN (ភាសាខ្មែរ) 00848195-00848196។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ កៅ ឆេង ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D119/16, ERN (ភាសាខ្មែរ) 00893284 (ឆ.26)។

[859] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ សុខ រ៉ុ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ D119/108, ERN (ភាសាខ្មែរ) 00979416 (ឆ.105)។

[860] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ សុខ រ៉ុ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ D119/108, ERN (ភាសាខ្មែរ) 00979405 (ឆ.47-ឆ.49)។

[861] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ រៀល សន ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D118/181, ERN (ភាសាខ្មែរ) 00975623-00975624 (ឆ.8-ឆ.13)។

[862] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ រៀល សន ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D118/181, ERN (ភាសាខ្មែរ) 00975645 (ឆ.224)។

[863] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ រៀល សន ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D118/181, ERN (ភាសាខ្មែរ) 00975645 (ឆ.227-ឆ.228)។

[864] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ រៀល សន ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D118/181, ERN (ភាសាខ្មែរ) 00975641 (ឆ.180)។

[865] កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5/1c), ERN (EN) 00951838។ កិច្ច

៣១០. ចម្លើយ អ៊ឹម ចែម ពាក់ព័ន្ធនឹងសមាសភាពគណៈកម្មាធិការស្រុកកោះអណ្ដែត ក៏មានស៊ីសង្វាក់គ្នាជាមួយជាមួយនឹងភ័ស្តុតាងនៅក្នុងសំណុំរឿងផងដែរ។ សាក្សីជាច្រើនបានបញ្ជាក់ថា មានពេលមួយនោះ សៀង គឺជាលេខាស្រុកកោះអណ្តែង[867] ប៉ុន្តែ មានការផ្លាស់ប្ដូរច្រើននៅស្រុកកោះអណ្ដែតពីពេលមួយទៅពេលមួយ[868]។ សាក្សីក៏បានរាយការណ៍ផងដែរថា នាង អ៊ួច ហៅ សាន ស្ថិតនៅក្នុងគណៈកម្មាធិការកោះអណ្ដែត[869] ទោះបីជាគាត់បានទទួលស្គាល់ថាធ្លាប់ជា "ជំនួយការស្រុកកោះអណ្ដែត" ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ ១៩៧៦[870]។

---

សម្ភាសន៍របស់ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ (ឯកសារ D123/1/5.1b), ERN (ភាសាខ្មែរ) 00929769-00929771។ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ (ឯកសារ D1.3.12.1), ERN (ភាសាខ្មែរ) 00234190-00234191។ ប្រតិចារឹកនៃបទសម្ភាសន៍របស់ អ៊ឹម ចែម (ឯកសារ D6.1.75), ERN (ភាសាខ្មែរ) 00978475។

[866] កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ (ឯកសារ D1.3.12.1), ERN (ភាសាខ្មែរ) 00234193-00234194។ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c), ERN (ភាសាខ្មែរ) 00929866។ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ (ឯកសារ D123/1/5.1b), ERN (ភាសាខ្មែរ) 00929771-00929772។

[867] សូមមើល ឧទាហរណ៍ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ D6.1.651, ERN (ភាសាខ្មែរ) 00373386-00373387។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/84, ERN (ភាសាខ្មែរ) 00975693 (ឆ.21)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ នាង អ៊ួច ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៤ ឯកសារ D118/172, ERN (ភាសាខ្មែរ) 00971354 (ឆ.6) (លើកឡើងថា ទាំង សៀង ទាំង ចាន់ ស្ថិតនៅក្នុងគណៈកម្មាធិការ)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ នាង អ៊ួច ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៤ ឯកសារ D119/82, ERN (ភាសាខ្មែរ) 00971368 (ឆ.17), ERN (ភាសាខ្មែរ) 00971370 (ឆ.27)។

[868] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ខឹម បឿន ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ D118/242, ERN (ភាសាខ្មែរ) 00998733 (ឆ.81)។

[869] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ កៅ ឆេង ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D119/16, ERN (ភាសាខ្មែរ) 00893281 (ឆ.6)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ D6.1.651, ERN (ភាសាខ្មែរ) 00373386-00373387។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ អ៊ុល ហឿន ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ D219/34, ERN (ភាសាខ្មែរ) 01032069 (ឆ.18)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ បាវ ណោម ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៣ ឯកសារ D119/63, ERN (ភាសាខ្មែរ) 00951944 (ឆ.4)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ខឹម បឿន ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ D118/242, ERN (ភាសាខ្មែរ) 00998727-00998728 (ឆ.30)។

[870] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ នាង អ៊ួច ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៤ ឯកសារ D119/82, ERN (ភាសាខ្មែរ) 00971368-00971369 (ឆ.17-ឆ.18, ឆ.20), ERN (ភាសាខ្មែរ) 00971379 (ឆ.84)។ សំណុំរឿង ០០៤/១

៣១១. ផ្ទុយមកវិញ សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតថា អ៊ឹម ចែម ពុំមែនជាលេខាស្រុកកោះអណ្តែត សំអាងចំបងលើភ័ស្តុតាងរបស់សាក្សីនានា[871] ដែលទំនងជាគ្មានព័ត៌មានទាល់តែសោះ។ ជាពិសេស ប៊ុន ធឿន បានពន្យល់ថា គាត់ពុំដែលទៅស្រុកកោះអណ្តែត ដូច្នេះ គាត់ពុំមានព័ត៌មានអំពីតួនាទីរបស់ អ៊ឹម ចែម នៅទីនោះទេ[872]។ អ៊ុល ហឿន ដែលបានអះអាងថា អ៊ឹម ចែម គឺជាលេខានៅជិតស្រុក ១០៦ (ពោលគឺ ស្រុកអង្គរជ័យ)[873] "មិនប្រាកដ" ថាតើគាត់ត្រូវបានតែងតាំងនៅក្នុងគណៈកម្មាធិការស្រុកកោះអណ្តែតដែរឬទេ[874]។ ពេជ្រ ជឹម បាននិយាយថា គាត់បានដឹងថា អ៊ឹម ចែម ធ្លាប់ជាអនុប្រធានស្រុកអង្គជ័យ[875] ហើយ សៀង គឺជាលេខាស្រុកកោះអណ្តែត[876] ប៉ុន្តែ គាត់ពុំច្បាស់ថាតើគាត់បានដឹងអំពីមុខងាររបស់ អ៊ឹម ចែម នៅក្នុងគណៈកម្មាធិការស្រុក និងសមាសភាពគណៈកម្មាធិការ ក្រោយពេល សៀង ត្រូវបានដកចេញនៅក្នុងឆ្នាំ១៩៧៦ មែនឬមិនមែននោះទេ[877]។

៣១២. យោងតាមសំអាងហេតុខាងលើ ចៅក្រមទទួលបន្ទុករឿងក្តីយល់ឃើញថា ភ័ស្តុតាងនៅក្នុងសំណុំរឿងបង្ហាញនូវភាពស៊ីសង្វាក់គ្រប់គ្រាន់ទៅនឹងការទទួលស្គាល់របស់ អ៊ឹម ចែម ពាក់ព័ន្ធនឹងតួនាទីរបស់គាត់

---

កំណត់ហេតុស្តាប់ចម្លើយ នាង អ៊ួច ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៤ ឯកសារ D118/172, ERN (ភាសាខ្មែរ) 00971353-00971354 (ឆ.3-ឆ.4)។

[871] See ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៤៦, ១៤៩។

[872] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ធឿន ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ D119/149, ERN (ភាសាខ្មែរ) 01022478 (ឆ.29-ឆ.31)។

[873] សូមមើល សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ អ៊ុល ហឿន ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ D118/208, ERN (ភាសាខ្មែរ) 00980089 (ឆ.60-ឆ.64)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ អ៊ុល ហឿន ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ D118/209, ERN (ភាសាខ្មែរ) 00980115 (ឆ.128-ឆ.130)។

[874] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ អ៊ុល ហឿន ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ D219/34, ERN (ភាសាខ្មែរ) 01032069 (ឆ.13)។

[875] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D118/259, ERN (ភាសាខ្មែរ) 00997028 (ឆ.40)។

[876] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D118/259, ERN (ភាសាខ្មែរ) 00997028 (ឆ.39)។

[877] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D118/259, ERN (ភាសាខ្មែរ) 00997028 (ឆ.43)។

01575620



ជាលេខាស្រុកកោះអណ្ដែត ហើយមានមូលដ្ឋានសមហេតុផលជឿជាក់ថា គាត់កាន់តួនាទីនេះ ដោយផ្អែកលើគុណូបការភាពនៃភវនីយភាព។

## ង. មុខងាររបស់ អ៊ឹម ចែម ក្នុងនាមជាសមាជិកគណៈកម្មាធិការតំបន់ ១៣

៣១៣. ចៅក្រមទទួលបន្ទុករឿងក្ដីក៏ពិចារណាឃើញផងដែរថា សហចៅក្រមស៊ើបអង្កេតមានកំហុសនៅក្នុងការរកឃើញថា គ្មានភស្តុតាងគ្រប់គ្រាន់ ដើម្បីគាំទ្រសេចក្ដីសន្និដ្ឋានថា អ៊ឹម ចែម គឺជាសមាជិកគណៈកម្មាធិការតំបន់ ១៣[878]។ ភស្តុតាងនៅក្នុងសំណុំរឿង នៅពេលវាយតម្លៃប្រកបដោយភាពសមហេតុផលមានលក្ខណៈជាក់លាក់គ្រប់គ្រាន់ និងស៊ីសង្វាក់គ្នាអាចបង្ហាញថា គាត់កាន់តួនាទីនេះ ហើយសេចក្ដីសន្និដ្ឋាននេះ ពុំមែនមានភាពសំខាន់ជាងភស្តុតាងដែលថា គាត់មានតួនាទីនៅក្នុងការដឹកនាំសមាគមនារីនោះឡើយ[879]។

៣១៤. ចំណុចទីមួយ ចៅក្រមទទួលបន្ទុករឿងក្ដីសង្កេតឃើញថា អ៊ឹម ចែម ខ្លួនឯងបានទទួលស្គាល់ថាបានជំនួសប្រធានរបស់គាត់ ពោលគឺ ពូ សោម ហើយត្រូវបានតែងតាំងឡើងជាសមាជិកតំបន់ ១៣ សម្រាប់មួយរយៈពេលខ្លី ប្រហែលមួយឆ្នាំ នៅមុនពេល តាម៉ុក ផ្ទេរទៅបាត់ដំបង[880]។ ចៅក្រមទទួលបន្ទុករឿងក្ដីយល់ឃើញថា ការទទួលស្គាល់របស់ អ៊ឹម ចែម អំពីតួនាទីរបស់គាត់នៅភូមិភាគនិរតី មានចំណុចពាក់ព័ន្ធកម្រិតខ្ពស់ ដូចនឹងចម្លើយផ្សេងទៀតរបស់គាត់អំពីតួនាទី និងទំនាក់ទំនងរបស់គាត់ដែលសហចៅក្រមស៊ើបអង្កេតបានសំអាងនៅតាមផ្នែកផ្សេងទៀតនៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ)[881]។

៣១៥. ចំណុចទីពីរ ចៅក្រមទទួលបន្ទុកយល់ឃើញថា ការទទួលស្គាល់របស់ អ៊ឹម ចែម ស៊ីសង្វាក់គ្នាច្រើនជាមួយនឹងភស្តុតាងនៅក្នុងសំណុំរឿង។ សហចៅក្រមស៊ើបអង្កេតទទួលស្គាល់ថា សាក្សីបីនាក់បានលើកឡើងថា អ៊ឹម ចែម គឺជាសមាជិករបស់គណៈកម្មាធិការតំបន់ ១៣[882]។ ជៀម ជ្រាវ បានបញ្ជាក់ថា "គ្រប់គ្នាដឹង" ថា អ៊ឹម ចែម មានតួនាទីនៅក្នុង "គណៈកម្មាធិការខេត្តតាកែវ" អ៊ឹម ចែម ឱ្យគាត់ហៅប្រជា

---

[878] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៤៣-១៤៤, ១៤៧-១៤៨, ១៥០។

[879] សូមមើលខាងលើ, កថាខណ្ឌ ៣០០-៣០៣ ។

[880] កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ D123/1/5.1c), ERN (ភាសាខ្មែរ) 00929877។

[881] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៤៨, ១៥៥ យោងទៅ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ (ឯកសារ D123/1/5.1a)។ កិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ (ឯកសារ D123/1/5.1b)។

[882] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៤៨។

ជននៅក្នុងភូមិ និងឃុំ ចូលរួមប្រជុំនៅការដ្ឋានចល័ត[883] ហើយគាត់មកយូរៗម្តងដើម្បីពិនិត្យមើលកងបង្កបង្កើនផល[884]។ សួន មុត ក៏បានដឹងផងដែរថា អ៊ឹម ចែម គឺជាសមាជិកគណៈកម្មាធិការតំបន់នៅខេត្តតាកែវ ហើយបានលើកឡើងថា អ៊ឹម ចែម បានមកកន្លែងគាត់រស់នៅ ដើម្បីបើកកិច្ចប្រជុំ និងការងារ[885]។ សាក្សីទាំងពីរបានទាក់ទងជាមួយ អ៊ឹម ចែម នៅក្នុងអំឡុងពេលពាក់ព័ន្ធ និងបានដឹងអំពីមុខងាររបស់គាត់ដោយខ្លួនឯងផ្ទាល់[886]។ អន សុភាព បានពិពណ៌នាបន្ថែមអំពីរូបថត អ៊ឹម ចែម ដែលគាត់បានឃើញនៅក្នុងទស្សនាវដ្តីក្នុងឆ្នាំ១៩៧៥ ឬ ឆ្នាំ១៩៧៦ ដោយមានចំណងជើងថា "អ៊ឹម ចែម គណៈតំបន់ ១៣"[887]។ ទោះបីជាចៅក្រមទទួលបន្ទុករឿងក្តីយល់ស្របថា ចម្លើយទាំងនេះផ្តល់ជូនដោយមាន "ភាពច្បាស់លាស់ និងជាក់លាក់ក្នុងកម្រិតខុសៗគ្នាក៏ដោយ"[888] ក៏ពួកគេចាត់ទុកថាវាពាក់ព័ន្ធ នឹងស៊ីសង្វាក់គ្នាជារួមនឹងការទទួលស្គាល់របស់ អ៊ឹម ចែម ថា គាត់នៅក្នុងគណៈតំបន់ ១៣។ ផ្ទុយមកវិញ ចៅក្រមទទួលបន្ទុករឿងក្តីសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតពុំបានដកស្រង់ភស្តុតាងដើម្បីគាំទ្រការរកឃើញរបស់ពួកគេថា អ៊ឹម ចែម ពុំមែនស្ថិតនៅក្នុងគណៈតំបន់ ១៣ នោះឡើយ។

៣១៦. ចៅក្រមទទួលបន្ទុករឿងក្តីក៏សង្កេតឃើញផងដែរថា សាក្សីមួយចំនួន ដែលសហចៅក្រមស៊ើបអង្កេតបានយកមកធ្វើជាសំអាងដើម្បីសន្និដ្ឋានថា អ៊ឹម ចែម គឺជាប្រធានសមាគមនារី[889] បានផ្តល់ភស្តុតាង

---

[883] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ជាម ជ្រៀវ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D119/13, ERN (ភាសាខ្មែរ) 00893264 (ឆ.6)។

[884] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ជាម ជ្រៀវ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D119/13, ERN (ភាសាខ្មែរ) 00893265 (ឆ.17)។

[885] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ សួន មុត ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ D219/37 ERN (ភាសាខ្មែរ) 01032102-01032103 (ឆ.11-ឆ.22)។ សូមមើលផងដែរ ERN (ភាសាខ្មែរ) 01032103 (ឆ.20), ERN (ភាសាខ្មែរ) 01032103 (ឆ.25)។

[886] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ជាម ជ្រៀវ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D119/13, ERN (ភាសាខ្មែរ) 00893264 (ឆ.6), ERN (ភាសាខ្មែរ) 00893265 (ឆ.17)។ សំណុំរឿង ០០៤ កំណត់ហេតុស្តាប់ចម្លើយ សួន មុត ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ D219/37, ERN (ភាសាខ្មែរ) 01032102-01032103 (ឆ.11-ឆ.22)។

[887] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ អន សុភាព ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ D118/78, ERN (ភាសាខ្មែរ) 00934396-00934397 (ឆ.8-ឆ.9)។

[888] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ 148.

[889] សូមមើលខាងលើ កថាខណ្ឌ ៣០១-៣០៤ ។

ថា សមាគមនារីនៅក្នុងតំបន់អាចជាផ្នែកមួយនៃគណៈតំបន់[890] អ៊ឹម ចែម ជាការពិត គឺជាគណៈតំបន់ ១៣[891] គាត់មានវត្តមាននៅគ្រប់កិច្ចប្រជុំទាំងអស់នៅថ្នាក់តំបន់[892] ឬ យ៉ាងហោចណាស់ តួនាទី និងការទទួលខុសត្រូវរបស់គាត់នៅថ្នាក់តំបន់គឺលើសពីធ្វើជាប្រធានដឹកនាំសមាគមនារីទៅទៀត[893]។ ជាពិសេស ម៉ឹង វេត ក្នុងនាមជានិរសាតំបន់ ១៣ បានលើកឡើងជាក់លាក់ថា អ៊ឹម ចែម គឺជាសមាជិកគណៈអចិន្ត្រៃយ៍[894] ហើយគាត់ខ្លួនឯងបានឃើញនៅលើខ្នងសំបុត្រ ដែលតាសោម ផ្ញើជូនគាត់ដោយចារលើខ្នងសំបុត្រ

---

[890] សូមមើល ឧទាហរណ៍ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/83, ERN (ភាសាខ្មែរ) 00975684 (ឆ.19)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/84, ERN (ភាសាខ្មែរ) 00975694-00975695 (ឆ.29-ឆ.31)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ D219/488, ERN (ភាសាខ្មែរ) 01136706 (ឆ. 36)។ សំណុំរឿង ០០៤/១ ខឹម ហឿន, កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ D118/242, ERN (ភាសាខ្មែរ) 00998732-00998733 (ឆ.74-ឆ.79), ERN (ភាសាខ្មែរ) 00998737(ឆ.105-ឆ.109)។

[891] សូមមើល ឧទាហរណ៍ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/83, ERN (ភាសាខ្មែរ) 00975684 (ឆ.18-ឆ.19)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/84, ERN (ភាសាខ្មែរ) 00975692 (ឆ.19-ឆ.20), ERN (ភាសាខ្មែរ) 00975696 (ឆ.33)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ D219/488, ERN (ភាសាខ្មែរ) 01136706 (ឆ.36), ERN (ភាសាខ្មែរ) 01136721 (ឆ.119)។ សំណុំរឿង ០០៤/១ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ D119/84.2, ERN (ភាសាខ្មែរ) 00975721។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D118/259, ERN (ភាសាខ្មែរ) 00997028 (ឆ.40), ERN (ភាសាខ្មែរ) 00997028 (ឆ.45)។

[892] សូមមើល ឧទាហរណ៍ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ធឿន ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D118/274, ERN (ភាសាខ្មែរ) 00999997 (ឆ.72)។

[893] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ធឿន ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ D6.1.688, ERN (ភាសាខ្មែរ) 00384406។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ធឿន ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D118/274, ERN (ភាសាខ្មែរ) 00999992-00999993 (ឆ.41-ឆ.42), ERN (ភាសាខ្មែរ) 00999994 (ឆ.55), ERN (ភាសាខ្មែរ) 00999997 (ឆ.72)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ឆឹង ជឿន ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ D119/156, ERN (ភាសាខ្មែរ) 01024772 (ឆ.15-ឆ.19)។ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D118/259, ERN (ភាសាខ្មែរ) 00997028 (ឆ.40-ឆ.45), ERN (ភាសាខ្មែរ) 00997034 (ឆ.85)។

[894] សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/83, ERN (ភាសាខ្មែរ) 00975684 (ឆ.18-ឆ.19). សូមមើលផងដែរ សំណុំរឿង ០០៤/១ កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ D219/488, ERN (ភាសាខ្មែរ) 01136706 (ឆ.36)។

នោះថា "សមមិត្តនារី ចែម គណៈអចិន្ត្រៃយ៍តំបន់ ១៣"[895]។ ចៅក្រមទទួលបន្ទុករឿងក្ដីពិចារណាឃើញថា ភស្តុតាងនេះមានលក្ខណៈជាក់លាក់ និងជាភស្តុតាងគួរឱ្យជឿជាក់បង្ហាញអំពីតួនាទីរបស់ អ៊ឹម ចែម ក្នុងនាមជាប្រធានសមាគមនារី។

៣១៧. លើសពីនេះ ចៅក្រមទទួលបន្ទុករឿងក្ដីសង្កេតឃើញថា ដីកាដំណោះស្រាយ (សំអាងហេតុ) ខកខានមិនបានលើកឡើងអំពីភស្តុតាងពាក់ព័ន្ធផ្សេងទៀត ដែលជាប់ទាក់ទងយ៉ាងច្បាស់ និងផ្ទុយគ្នានឹងសេចក្ដីសន្និដ្ឋានថា អ៊ឹម ចែម ពុំមែននៅក្នុងគណៈតំបន់ ១៣។ ភស្តុតាងនេះរួមមានភស្តុតាងរបស់ ឃឹម វ៉ៃ និរសាតំបន់ ១៣ នៅមុនពេលគាត់បានធ្វើដំណើរទៅកាន់ភូមិភាគពាយ័ព្យជាមួយ អ៊ឹម ចែម[896] ដែលអាចបញ្ជាក់អះអាងច្បាស់ថា អ៊ឹម ចែម នៅក្នុងគណៈតំបន់ ១៣[897]។ មូល អេង ក៏បានបញ្ជាក់ផងដែរថា អ៊ឹម ចែម គឺជាកម្មាភិបាលជាន់ខ្ពស់[898] ហើយកាន់មុខនាទីពីរ ទាំងជាប្រធានគណៈមេដឹកនាំនារី និងលេខាតំបន់ ១៣ ជាមួយ តាសោម[899] ដែលតាមរបាយការណ៍គឺជាការដឹងទូទៅនៅក្នុងចំណោមបុគ្គលិកយោធា ដែលស្គាល់គាត់[900]។ អ៊ុល ហឿន[901] និង សុខ រុន[902] ក៏បានបញ្ជាក់បន្ថែមផងដែរថា អ៊ឹម ចែម គឺជាគណៈតំបន់ ១៣ ហើយស្ថិតនៅលេខ ៣។ ការខកខានមិនបានវាយតម្លៃភស្តុតាងនេះនៅក្នុងដីកាដំណោះស្រាយ (សំអាង

[895] សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ ម៉ឹង វេត ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D119/84, ERN (ភាសាខ្មែរ) 00975692 (ឆ.19-ឆ.20)។

[896] សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ ខឹម វ៉ៃ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D219/636, ERN (ភាសាខ្មែរ) 01184406 (ឆ.62)។

[897] សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ ខឹម វ៉ៃ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D219/636, ERN (ភាសាខ្មែរ) 01184402 (ឆ.38)។

[898] សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ មូល អេង ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ D219/294, ERN (ភាសាខ្មែរ) 01095239-01095240 (ឆ.24-ឆ.31), ERN (ភាសាខ្មែរ) 01095255-01095258 (ឆ.127-ឆ.148)។

[899] សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ មូល អេង ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ D219/294, ERN (ភាសាខ្មែរ) 01095257 (ឆ.143)។

[900] សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ មូល អេង ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ D219/294, ERN (ភាសាខ្មែរ) 01095255 (ឆ.130), ERN (ភាសាខ្មែរ) 01095257 (ឆ.140)។

[901] សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ អ៊ុល ហឿន ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ D219/34, ERN (ភាសាខ្មែរ) 01032068 (ឆ.10-ឆ.11), ERN (ភាសាខ្មែរ) 01032070 (ឆ.22)។

[902] សំណុំរឿង ០០៤/១ កំណត់ហេតុស្ដាប់ចម្លើយ សុខ រុំ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ D119/108, ERN (ភាសាខ្មែរ) 00979405 (ឆ.45)។

ហេតុ) ទំនងជាការបដិសេធសច្ចធារណ៍ដែលថា សហចៅក្រមស៊ើបអង្កេតបានវាយតម្លៃយ៉ាងត្រឹមត្រូវលើភ័ស្តុតាងទាំងអស់នៅក្នុងសំណុំរឿង[903]។

៣១៨. ចំណុចចុងក្រោយ ចៅក្រមទទួលបន្ទុករឿងក្តីសូមរំលឹកការសម្រេចរបស់អង្គបុរេជំនុំជម្រះថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានដាក់ក្នុងគោលបំណងចូលរួមចំណែកក្នុងកិច្ចស៊ើបសួរ តម្រូវឱ្យមានការពិចារណាឱ្យបានហ្មត់ចត់ និងមិនគួរទទួលបាន "តម្លៃភ័ស្តុតាងទោះបីតិចតួចក៏ដោយក្តី"[904]។ ការពិនិត្យមើលសំណុំរឿងបង្ហាញថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនបានកំណត់ អ៊ឹម ចែម ថាបានដឹកនាំតំបន់ ១៣ ជាលេខា ឬ សមាជិកលេខា ហើយក្នុងមុខតំណែងនោះហើយដែលដើមបណ្តឹងរដ្ឋប្បវេណីចាត់ទុកថាគាត់ទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ[905]។ ចៅក្រមទទួលបន្ទុករឿងក្តីពិចារណាវារួមគ្នាថាមានភាពពាក់ព័ន្ធនៅពេលវាយតម្លៃថា តើចម្លើយរបស់ អ៊ឹម ចែម មានភាពស៊ីសង្វាក់គ្នាដែរឬទេ។

៣១៩. អាស្រ័យហេតុនេះ ចៅក្រមទទួលបន្ទុករឿងក្តីយល់ឃើញថាភ័ស្តុតាងទាំងនេះមានភាពជាក់លាក់គ្រប់គ្រាន់ និងមានភាពស៊ីសង្វាក់គ្នាក្នុងការបង្ហាញថា អ៊ឹម ចែម គឺជាសមាជិកជាគណៈតំបន់ ១៣ មែននៅពេលវាយតម្លៃយ៉ាងត្រឹមត្រូវទៅលើតុល្យភាពនៃភវនីយភាព។

## ៣. សេចក្តីសន្និដ្ឋាន

៣២០. ចៅក្រមទទួលបន្ទុកលើរឿងក្តីយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមានកំហុសនៅក្នុងការសម្រេចថា ពុំមានភ័ស្តុតាងគ្រប់គ្រាន់បង្ហាញថា អ៊ឹម ចែម កាន់តួនាទីជាលេខាស្រុកកោះអណ្តែត និង

---

[903] សូមមើល សាលដីកាក្នុងរឿងក្តី Zigiranyirazo កថាខណ្ឌ ៤៥។ សាលដីកាក្នុងរឿងក្តី Perišić កថាខណ្ឌ ៩២។

[904] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៤៧។ សូមមើលផងដែរ ខាងលើ កថាខណ្ឌ ៤៩-៥៦ ។

[905] សូមមើល ឧទាហរណ៍ សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ តែម ជ្រន ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១២ ឯកសារ D5/1133, ERN (ភាសាខ្មែរ) 01026736-01026737។ សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ គង់ សាមី ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ D5/1303, ERN (ភាសាខ្មែរ) 01037769។ សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ភ្លី លី ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ D5/1615, ERN (ភាសាខ្មែរ) 01092550-01092551។ សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ធង ភូន ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ D5/1304, ERN (ភាសាខ្មែរ) 01037783។ សំណុំរឿង ០០៤/១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ យ៉ាយ គឹមលៀង ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ D5/1528, ERN (ភាសាខ្មែរ) 01081273។

សមាជិកគណៈតំបន់ ១៣។ កំហុសទាំងនេះមានផលប៉ះពាល់ ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់គាត់ចំពោះទីតាំងឧក្រិដ្ឋកម្មនៅភូមិភាគនិរតី។ ករណីថាតើ កំហុសទាំងនេះជាកត្តាកំណត់យ៉ាងសំខាន់នៃការសម្រេចអំពីយុត្តាធិការបុគ្គល ឬយ៉ាងណានោះ នឹងត្រូវបកស្រាយនៅក្នុងសេចក្តីសន្និដ្ឋានខាងក្រោម។

## ច. សេចក្តីសន្និដ្ឋានអំពីយុត្តាធិការបុគ្គល

៣២១. តាំងពីដំបូង ចៅក្រមទទួលបន្ទុករឿងក្តីរម្លឹកឡើងវិញថា ក្នុងគោលបំណងដើម្បីសម្រេចអំពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ការកំណត់អត្តសញ្ញាណបុគ្គលដែលស្ថិតក្នុងចំណោម "បុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុត" តម្រូវឱ្យមានការវាយតម្លៃទាំងទៅលើភាពធ្ងន់ធ្ងររបស់ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងកម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យ[906]។ តាមការយល់ឃើញរបស់ចៅក្រមទទួលបន្ទុករឿងក្តីការវាយតម្លៃនេះត្រូវធ្វើឡើងដោយផ្អែកទាំងទៅលើបរិមាណវិស័យ និងគុណវិស័យ។ ពុំមានបញ្ជីជាក់លាក់ស្តីអំពីកត្តានានាដែលត្រូវយកមកពិចារណា ក្នុងការពិនិត្យទៅលើចំណុចនេះទេ ហើយក៏ពុំមានលក្ខខណ្ឌបែបគណិតវិទ្យាចំពោះការស្លាប់និងរបួស ឬបទដ្ឋានកំហិតអំពីតួនាទីនៅក្នុងឋានានុក្រមដែរ។ ផ្ទុយទៅវិញ ការកំណត់អំពីយុត្តាធិការបុគ្គលតម្រូវឱ្យមានការវាយតម្លៃទៅតាមករណីជាក់ស្តែងនីមួយៗ ដោយពិចារណាទៅលើបរិបទទូទៅ និងកាលៈទេសៈផ្ទាល់ខ្លួនរបស់ជនសង្ស័យ។

៣២២. អនុលោមទៅតាមបទដ្ឋានជាធរមាននៃការពិនិត្យលើបណ្តឹងឧទ្ធរណ៍ នាពេលនេះ ចៅក្រមទទួលបន្ទុករឿងក្តីនឹងពិចារណាថា តើកំហុសឆ្គងផ្នែកអង្គច្បាប់ និងអង្គហេតុដែលបានកំណត់នៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) ជាកត្តាកំណត់យ៉ាងសំខាន់ចំពោះការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និងចំពោះតួនាទី និងការទទួលខុសត្រូវរបស់ អ៊ឹម ចែម

---

[906] សាលក្រមនៃសំណុំរឿង ០០១ (ឯកសារ E188) កថាខណ្ឌ ២២។ *សូមមើលផងដែរ* តុលាការ SCSL *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Fofana* សំណុំរឿងលេខ SCSL-04-14-PT-026 សេចក្តីសម្រេចលើសំណើបឋមរបស់មេធាវីការពារក្តី ស្តីពីកង្វះយុត្តាធិការបុគ្គល ដែលបានដាក់ក្នុងនាមជនជាប់ចោទ Fofana អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៤ កថាខណ្ឌ ៣៨។ តុលាការ ICC *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Ntaganda* សំណុំរឿងលេខ ICC-01/04-169 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ I មានចំណងជើងថា "សេចក្តីសម្រេចលើពាក្យសុំរបស់រដ្ឋអាជ្ញាដែលស្នើសុំដីកាឃាត់ខ្លួន មាត្រា ៥៨" អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៦ កថាខណ្ឌ ៧៦។ តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Lukić និងជនផ្សេងទៀត* សំណុំរឿងលេខ IT-98-32/1-PT សេចក្តីសម្រេចលើការផ្ទេររឿងក្តី អនុលោមតាមវិធាន១១ស្ទួន ជាមួយឧបសម្ព័ន្ធ ក និង ខ សម្ងាត់ ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តីរបស់តុលាការ ICTY ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០៧ កថាខណ្ឌ ២៦។

01575626



ហើយជាចុងក្រោយ ចំពោះការសម្រេចជារួមរបស់សហចៅក្រមស៊ើបអង្កេតទៅលើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬយ៉ាងណា។

## ១. សេចក្តីសង្ខេបនៃការសន្និដ្ឋាន

៣២៣. ចៅក្រមទទួលបន្ទុករឿងក្តីសូមរម្លឹកអំពីសេចក្តីសន្និដ្ឋានជាទូទៅរបស់ខ្លួនថា សហចៅក្រមស៊ើបអង្កេតពុំបានបើកកិច្ចស៊ើបសួរឱ្យបានពេញលេញ និងធ្វើការកំណត់តាមផ្លូវច្បាប់ឱ្យបានត្រឹមត្រូវទៅលើការចោទប្រកាន់ទាំងអស់អំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងតំបន់ ១៣ នៃភូមិភាគនិរតី និងតំបន់ ៥ នៃភូមិភាគពាយ័ព្យឡើយ ទោះបីបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមយកមកពិនិត្យទាន់ពេលវេលាក៏ដោយ។ ចៅក្រមទទួលបន្ទុករឿងក្តីបានពិនិត្យថែមទៀតទៅលើភស្តុតាងដែលប្រមូលបានក្នុងអំឡុងពេលកិច្ចស៊ើបសួរ និងបានសន្និដ្ឋានថា បើតាមបទដ្ឋានតម្រូវចាំបាច់នៅដំណាក់កាលមុនការជំនុំជម្រះលើអង្គសេចក្តី មានភស្តុតាងគ្រប់គ្រាន់បង្ហាញអំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មជាច្រើនដែលត្រូវបានចោទប្រកាន់ ព្រមទាំងការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មទាំងនោះ។

៣២៤. ទាក់ទិននឹងតួនាទី និងអំពើរបស់ អ៊ឹម ចែម នៅក្នុងភូមិភាគនិរតី ចៅក្រមទទួលបន្ទុករឿងក្តីបានសន្និដ្ឋានថា ពាក់ព័ន្ធនឹងទឡ្ហីករណ៍ទី៥ និងទី៦ នៃបណ្តឹងឧទ្ធរណ៍ មានភស្តុតាងគ្រប់គ្រាន់បង្ហាញថា គាត់បានកាន់កាប់មុខតំណែងជាលេខាស្រុកកោះអណ្តែត និងជាសមាជិកគណៈកម្មាធិការតំបន់ ១៣ ពីឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៧[907]។ ចៅក្រមទទួលបន្ទុករឿងក្តីក៏បានសន្និដ្ឋានផងដែរថា ពាក់ព័ន្ធនឹងទឡ្ហីករណ៍ទី២ នៃបណ្តឹងឧទ្ធរណ៍ អ៊ឹម ចែម អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការបាត់ខ្លួនដោយបង្ខំ ទៅលើប្រជាជនខ្មែរក្រោមនៅវត្តអង្គសិរីមាលី និងព្រៃសុខុន[908]។ ភស្តុតាងអាចធ្វើឱ្យសហព្រះរាជអាជ្ញាមានហេតុផលដែលជឿជាក់បន្ថែមថា ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តទៅលើប្រជាជនផ្សេងៗទៀតនៅតាមទីតាំងទាំងនេះ[909]។

៣២៥. ទាក់ទិននឹងតួនាទី និងអំពើរបស់ អ៊ឹម ចែម នៅភូមិភាគពាយ័ព្យក្នុងនាមជាលេខាព្រះនេត្រព្រះ និងជាសមាជិកគណៈកម្មាធិការតំបន់ ១៣ ពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៩ ចៅក្រមទទួលបន្ទុករឿងក្តីសន្និដ្ឋាន

---

[907] *សូមមើល ខាងលើ* កថាខណ្ឌ ៣០៥-៣២០ ។

[908] *សូមមើល ខាងលើ* កថាខណ្ឌ ២១១។

[909] *សូមមើល ខាងលើ* កថាខណ្ឌ ២១០។

ថា ពាក់ព័ន្ធនឹងទឡ្ហីករណ៍ទី ២ នៃបណ្តឹងឧទ្ធរណ៍ មានភស្តុតាងគ្រប់គ្រាន់បង្ហាញថា គាត់អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវក្នុងនាមជាសមាជិកសហឧក្រិដ្ឋកម្មរួម ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយសារការបោសសម្អាតនៅភូមិភាគពាយ័ព្យ។ ឧក្រិដ្ឋកម្មទាំងនេះ ដែលត្រូវបានប្រព្រឹត្តមិនត្រឹមតែចំពោះកម្មាភិបាលប៉ុណ្ណោះទេ តែថែមទាំងទៅលើប្រជាជនទូទៅយ៉ាងហោចណាស់នៅទូទាំងតំបន់ ៥ ទាំងមូលនៃភូមិភាគពាយ័ព្យ រួមទាំងការសម្លាប់ជាទ្រង់ទ្រាយធំ ការចាប់ខ្លួន និងការឃុំឃាំងដោយខុសច្បាប់ ការបាត់ខ្លួនដោយបង្ខំ និង អំពើអមនុស្សធម៌ផ្សេងៗទៀត ព្រមទាំងការធ្វើទុក្ខបុកម្នេញចំពោះកម្មាភិបាលនៅភូមិភាគពាយ័ព្យ[910] ប្រជាជនវៀតណាម[911] និងអតីតមន្ត្រីសាធារណរដ្ឋខ្មែរ[912]។

៣២៦. ពាក់ព័ន្ធនឹងទឡ្ហីករណ៍ទី២ ទី៣ និងទី៤ នៃបណ្តឹងឧទ្ធរណ៍ ចៅក្រមទទួលបន្ទុករឿងក្តីបានពិចារណាថែមទៀតថា ប្រសិនបើសហចៅក្រមស៊ើបអង្កេតអនុវត្តតាមនិយមន័យត្រឹមត្រូវរបស់ឧក្រិដ្ឋកម្ម និងបទដ្ឋានភស្តុតាងចាំបាច់ សហចៅក្រមស៊ើបអង្កេតនឹងសន្និដ្ឋានថា អ៊ឹម ចែម អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មជាច្រើនផ្សេងទៀតដែលបានប្រព្រឹត្តនៅតំបន់ ៥ នៃភូមិភាគពាយ័ព្យ។ ឧក្រិដ្ឋកម្មទាំងនេះរួមមាន ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទារុណកម្ម[913] ការសម្លាប់រង្គាល[914] និងអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការបាត់ខ្លួនដោយបង្ខំ នៅមន្ទីរសន្តិសុខភ្នំត្រយោង[915] អំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការបាត់ខ្លួនដោយបង្ខំនៅការដ្ឋានប្រឡាយស្ពានស្រែង[916] អំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ និងអំពើអមនុស្សធម៌ផ្សេងៗទៀតនៅការដ្ឋានទំនប់ត្រពាំងថ្ម[917] ការដាក់ក្នុងមន្ទីរឃុំឃាំង អំពើមនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀតនៅវត្តព្រះនេត្រព្រះ និងទីតាំងពាក់ព័ន្ធនានា[918] ការដាក់ក្នុងមន្ទីរឃុំឃាំង អំពើមនុស្សឃាត និងការ

---

[910] *សូមមើល ខាងលើ* កថាខណ្ឌ ១៣២-១៤២, ១៧១-១៧២។

[911] *សូមមើល ខាងលើ* កថាខណ្ឌ ១៣២-១៤២,១៤៧-១៦០។

[912] *សូមមើល ខាងលើ* កថាខណ្ឌ ១៣២-១៤២,១៧៣-១៧៨។

[913] *សូមមើល ខាងលើ* កថាខណ្ឌ ១៩៩-២០១។

[914] *សូមមើល ខាងលើ* កថាខណ្ឌ ២៦៣ ។

[915] *សូមមើល ខាងលើ* កថាខណ្ឌ ២៨១។

[916] *សូមមើល ខាងលើ* កថាខណ្ឌ ២៨២។

[917] *សូមមើល ខាងលើ* កថាខណ្ឌ ២២៥។

[918] *សូមមើល ខាងលើ* កថាខណ្ឌ ២៣២។



PRE-TRIAL ... EC

01575628



សម្លាប់រង្គាល នៅមន្ទីរសន្តិសុខភូមិចក្រី និងទីតាំងសម្លាប់ព្រៃតារុត[919] និងអំពើទារុណកម្ម[920] អំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងៗទៀតនៅមន្ទីរសន្តិសុខវត្តចម្ការខ្នុរ និងទីតាំងសម្លាប់[921]។ ភស្តុតាងក៏អាចធ្វើឱ្យសហព្រះរាជអាជ្ញាមានហេតុផលជឿជាក់បានផងដែរថា ឧក្រិដ្ឋកម្មនៃការរៀបការដោយបង្ខំត្រូវបានប្រព្រឹត្តនៅតំបន់ ៥ និង តំបន់ ១៣[922]។

## ២. ការវាយតម្លៃទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់

៣២៧. ចៅក្រមទទួលបន្ទុករឿងក្ដីរម្លឹកឡើងវិញថា ការវាយតម្លៃទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ សំអាងទៅលើកត្តានានា *ក្នុងចំណោមនោះ* ដូចជាចំនួនជនរងគ្រោះ ដែនកំណត់ភូមិសាស្ត្រ និងពេលវេលា និងរបៀបដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត ព្រមទាំងចំនួននៃអង្គហេតុនីមួយៗដែលកើតមានឡើង[923]។ ចំណែកលក្ខណៈ វិសាលភាព និងរបៀបនៃការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ព្រមទាំងផលប៉ះពាល់របស់ឧក្រិដ្ឋកម្មទាំងនោះទៅលើជនរងគ្រោះ ក៏ជាសូចនាករបង្ហាញពីភាពធ្ងន់ធ្ងរនៃអំពើនោះដែរ[924]។

៣២៨. ក្នុងការកំណត់ថា អ៊ឹម ចែម មិនស្ថិតក្នុងចំណោមបុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុត សហចៅក្រមស៊ើបអង្កេតបានពិចារណាទៅលើលក្ខណៈ និងចំនួននៃការចោទប្រកាន់ ព្រមទាំងភាពធ្ងន់ធ្ងរនៃផលវិបាក និងកម្រិតរបស់វាដែលកើតចេញពីភស្តុតាងនៅក្នុងសំណុំរឿង[925]។ សហចៅក្រមស៊ើបអង្កេតបានសំអាងទៅលើ "លក្ខខណ្ឌអប្បបរមាកម្រិតទាប" នៃចំនួនជនរងគ្រោះដោយសារអំពើមនុស្សឃាតចំនួន ២.០០០ នាក់ ដែលរួមបញ្ចូលគ្នារវាងទីតាំងឧក្រិដ្ឋកម្មចំនួនពីរ ដែលគាត់ត្រូវបានចោទប្រកាន់ ដោយ

---

[919] *សូមមើល ខាងលើ* កថាខណ្ឌ ២៤១។

[920] *សូមមើល ខាងលើ* កថាខណ្ឌ ២០១។

[921] *សូមមើល ខាងលើ* កថាខណ្ឌ ២៤៨។

[922] *សូមមើល ខាងលើ* កថាខណ្ឌ ១៤៦។

[923] សាលក្រមនៃសំណុំរឿង ០០១ (ឯកសារ E188) កថាខណ្ឌ ២២។

[924] តុលាការ ICC *រឿងក្ដី ស្ថានភាពស្ដីពីនាវារបស់សហភាព* Comoros *ដែលបានចុះបញ្ជី សាធារណរដ្ឋ* Hellenic *និងព្រះរាជាណាចក្រកម្ពុជា (Situation on Registered Vessels of the Union of the Comoros, the Hellenic Republic and the Kingdom of Cambodia)* សំណុំរឿងលេខ ICC-01/13-34 សេចក្ដីសម្រេចទៅលើសំណើរបស់សហភាព Comoros ដែលសុំឱ្យពិនិត្យឡើងវិញនៅការសម្រេចរបស់រដ្ឋអាជ្ញា ដែលមិនបើកការស៊ើបអង្កេត អង្គបុរេជំនុំជម្រះ I ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៥ កថាខណ្ឌ ២១។

[925] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣១៧។

កត់សម្គាល់អំពីភាពមិនសមទំនងនៃការកំណត់ចំនួនជនរងគ្រោះដោយសារឧក្រិដ្ឋកម្មផ្សេងៗទៀត ហើយ និងតួលេខ "ដែលរឹតតែមានភាពមិនច្បាស់លាស់ថែមទៀត" នៅឯទីតាំងឧក្រិដ្ឋកម្មដែលមិនបានចោទប្រកាន់[926] ។ ជាងនេះទៀត សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ថា ការចោទប្រកាន់ពីការចូលរួមចំណែករបស់ អ៊ឹម ចែម ទៅក្នុងសហឧក្រិដ្ឋកម្មរួមត្រូវបានកម្រិតត្រឹមស្រុកមួយ[927] ហើយថា ការកំណត់ប្រភេទបទល្មើសជាច្រើនដែលអាចមាន សម្រាប់អង្គហេតុតែមួយ មិនបានបង្កើនភាពធ្ងន់ធ្ងរនៃសកម្មភាពរបស់គាត់ឡើយ[928]។

៣២៩. ចៅក្រមទទួលបន្ទុករឿងក្តីយល់ឃើញថា នៅពេលពិចារណាពេញលេញទៅលើអំពើឧក្រិដ្ឋរបស់គាត់ ទំហំ វិសាលភាព និងផលប៉ះពាល់នៃឧក្រិដ្ឋកម្មដែល អ៊ឹម ចែម អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវមានលក្ខណៈធំធេងជាងអ្វីដែលសហចៅក្រមស៊ើបអង្កេតយកមកពិចារណាក្នុងការវាយតម្លៃពីភាពធ្ងន់ធ្ងរ។ មិនត្រឹមតែកម្រិតតែទីតាំងឧក្រិដ្ឋកម្មចំនួនពីរនៅក្នុងស្រុកមួយ "ជាចម្បង" ហើយត្រឹមតែរយៈពេលចាប់ពីពាក់កណ្តាលឆ្នាំ ១៩៧៧[929] ប៉ុណ្ណោះទេ តែការទទួលខុសត្រូវរបស់ អ៊ឹម ចែម លាតសន្ធឹងទៅដល់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅតាមទីកន្លែងជាច្រើនក្នុងតំបន់ ៥ ទាំងមូលនៃភូមិភាគពាយ័ព្យ ព្រមទាំងតំបន់ ១៣ នៃភូមិភាគនិរតី ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល។ ជាពិសេស ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តនៅក្នុងបរិបទនៃការបោសសម្អាតនៅភូមិភាគពាយ័ព្យ[930] "តួនាទីសម្របសម្រួល"[931] ដែលបានបណ្តាលឱ្យមានការវាយប្រហារជាទ្រង់ទ្រាយធំ និងជាប្រព័ន្ធទៅលើប្រជាជនស៊ីវិលនៅយ៉ាងហោចណាស់ទូទាំងតំបន់ ៥ ទាំងមូល នៃភូមិភាគពាយ័ព្យ។ លក្ខណៈ និងផលប៉ះពាល់នៃយុទ្ធនាការនេះ និងឧក្រិដ្ឋកម្មជាច្រើនដែលកើតចេញពីយុទ្ធនាការនេះ រួមទាំងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការសម្លាប់រង្គាល អំពើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញ ការធ្វើទារុណកម្ម ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងៗទៀត នៅតាមទីកន្លែងជាច្រើន គឺជាសូចនាករដ៏រឹងមាំដែលបង្ហាញពីភាពធ្ងន់ធ្ងរនៃសកម្មភាពរបស់ អ៊ឹម ចែម។

---

[926] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣២០-៣២២។

[927] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣១៣។

[928] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣២៣។

[929] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣០៦-៣១១, ៣១៣។

[930] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៥១-១៥៧, ៣១៦។ *សូមមើលផងដែរ ខាងលើ* កថាខណ្ឌ ១៣២-១៤២ ។

[931] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣១៦។

៣៣០. ដូចបានវាយតម្លៃលម្អិតពាក់ព័ន្ធនឹងទឡ្ហីករណ៍ទី២ នៃបណ្តឹងឧទ្ធរណ៍ អនុលោមតាមបទដ្ឋានភវនីយភាពចាំបាច់ ភស្តុតាងបានគាំទ្រយ៉ាងពេញលេញថែមទៀតចំពោះសេចក្តីសន្និដ្ឋានថា មានប្រជាជនមិនតិចជាងរាប់ម៉ឺននាក់ទេដែលជាជនរងគ្រោះនៅតាមទីតាំងដែលបានចោទប្រកាន់ និងមិនបានចោទប្រកាន់ ដែល អ៊ឹម ចែម អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវ។ ទាក់ទិននឹងចំណុចនេះ ចៅក្រមទទួលបន្ទុករឿងក្តីកត់សម្គាល់ថា តួលេខនៃការស្លាប់មិនមែនជាសូចនាករតែមួយនៃចំនួនជនរងគ្រោះ ឬផលប៉ះពាល់នៃអំពើឧក្រិដ្ឋនោះទេ។ ឧទាហរណ៍ មានភស្តុតាងគ្រប់គ្រាន់ដែលថា ក្នុងវិសាលភាពនៃពេលវេលាដែលពាក់ព័ន្ធ នៅឯការដ្ឋានទំនប់ត្រពាំងថ្មតែមួយ មានប្រជាជន យ៉ាងហោចណាស់ ជាច្រើនពាន់នាក់ និងទៅដល់ខ្ទង់ម៉ឺននាក់គឺជាជនរងគ្រោះដោយការធ្វើការងារដោយបង្ខំ និង ស្ថានភាពរស់នៅ និងធ្វើការយ៉ាងអមនុស្សធម៌[932]។ បើផ្តែកលើតុល្យភាពនៃ ភវនីយភាព ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលសំអាងលើលក្ខខណ្ឌអប្បបរមាកម្រិតទាប [933] ដោយមិនពិចារណាទៅលើទំហំនៃចំនួនជនរងគ្រោះ ព្រមទាំងអំពើជាច្រើន វិសាលភាព និងផលប៉ះពាល់ទៅលើជនរងគ្រោះផ្ទាល់ និងមិនផ្ទាល់ បានបណ្តាលឱ្យមានការវាយតម្លៃមិនពេញលេញអំពីភាពធ្ងន់ធ្ងរ។

៣៣១. ចុងក្រោយ ចៅក្រមទទួលបន្ទុករឿងក្តីពិចារណាឃើញថា ការណ៍ដែលសហចៅក្រមស៊ើបអង្កេតមិនយកការកំណត់បទល្មើសតាមច្បាប់មួយចំនួនមកពិចារណា ដូចជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀតតាមរយៈការបាត់ខ្លួនដោយបង្ខំ ដូចបានធ្វើការកត់សម្គាល់លម្អិតពាក់ព័ន្ធនឹងទឡ្ហីករណ៍ទី៣ និងទី៤ នៃបណ្តឹងឧទ្ធរណ៍ គឺជាការមិនបានយកចិត្តទុកដាក់ទៅលើ *ចេតនាឧក្រិដ្ឋ*ជាក់លាក់របស់ជនសង្ស័យ និងព្យសនកម្មជាក់លាក់ដែលបង្កឡើងដោយអំពើទាំងនោះ ហើយមិនបានពិចារណាទៅលើផលប៉ះពាល់រួមរបស់អំពើទាំងនោះ ទៅលើជនរងគ្រោះ[934]។ ការពិតទោះបីឧក្រិដ្ឋកម្មទាំងនេះអាចសំអាងទៅលើអង្គហេតុជាមូលដ្ឋានតែមួយដូចគ្នានឹងឧក្រិដ្ឋកម្មនៃអំពើមនុស្សឃាតក៏ដោយ តែលក្ខណៈពិធម្មជាតិរបស់វា វិសាលភាព និងការបង្កការឈឺចាប់ថែមទៀតដល់ជនរងគ្រោះមានភាពខុសគ្នាច្រើន។ ហេតុនេះ ចៅក្រមទទួលបន្ទុករឿងក្តីយល់ឃើញថា ការកំណត់បទល្មើសច្រើនពិតជាបង្កើនការទទួលខុសត្រូវរួមរបស់ អ៊ឹម ចែម។

---

[932] *សូមមើល ខាងលើ* កថាខណ្ឌ២២០-២២១-២២៣ ។

[933] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣២០-៣២២។

[934] សាលដីកានៃសំណុំរឿង ០០១ (ឯកសារ F28) កថាខណ្ឌ ២៩៩ *យោងទៅ* តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Jelisić* សំណុំរឿងលេខ IT-95-10-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០១ មតិយោបល់ដោយឡែកមួយផ្នែករបស់ចៅក្រម Shahabuddeen កថាខណ្ឌ ៤២។

### ៣. ការវាយតម្លៃលើតួនាទី និងការទទួលខុសត្រូវរបស់ អ៊ឹម ចែម

៣៣២. ចៅក្រមទទួលបន្ទុកលើរឿងក្ដី សូមរំលឹកថា កម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យអាចត្រូវបានវាយតម្លៃដោយផ្អែកលើការពិចារណា ដូចជា កម្រិតនៃការចូលរួមក្នុងឧក្រិដ្ឋកម្មនានា ឋានានុក្រម ឬមុខតំណែង រួមទាំង ចំនួនបុគ្គលិកក្រោមបង្គាប់ និងថ្នាក់លើតាមឋានានុក្រម ព្រមទាំ ភាពអចិន្ត្រៃយ៍នៃមុខតំណែង[935]។

៣៣៣. សហចៅក្រមស៊ើបអង្កេត បានកំណត់ថា អ៊ឹម ចែម មិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬ បុគ្គលក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតទេ ដូច្នេះ គាត់ស្ថិតនៅក្រៅយុត្តាធិការរបស់ អ.វ.ត.ក ផ្អែកតាមការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតថា ឋានៈផ្លូវការរបស់គាត់គឺកំណត់ត្រឹមលេខានៅក្នុងស្រុកមួយក្នុងចំណោមបុគ្គលជាងមួយរយនាក់ទៀតនៅក្នុងប្រទេស ដោយមានតួនាទី និងសិទ្ធិអំណាចមិនច្បាស់លាស់នៅថ្នាក់តំបន់[936]។ តួនាទីដ៏សំខាន់របស់គាត់ និង "តួនាទីសម្របសម្រួល" នៅក្នុងការបោសសម្អាតភូមិភាគពាយ័ព្យទោះបីជាតួនាទីនេះ "មិនលើសពីលេខាស្រុកទូទៅក៏ដោយ" ពុំមែនជាកត្តាកំណត់លើការវាយតម្លៃរបស់ពួកគេទេ[937]។ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា កេរ្តិ៍ឈ្មោះរបស់ អ៊ឹម ចែម ថាមានភាព "កាចសាហាវ" មិនហួសពីបទដ្ឋាននៃ "ភាពកាចសាហាវ និងការភ័យខ្លាច" ដែលកើតមាននៅក្នុងកម្ពុជាប្រជាធិបតេយ្យនោះទេ ដូច្នេះ មិនបង្កើនការទទួលខុសត្រូវរបស់គាត់ឡើយ[938]។

៣៣៤. ពីដំបូង ចៅក្រមទទួលបន្ទុកលើរឿងក្ដីសង្កេតឃើញថា "ផលវិបាកជាក់ស្ដែងដំបូង" ដែលតួនាទីផ្លូវការរបស់បុគ្គលម្នាក់មាននៅក្នុងឋានានុក្រម ដូចដែលបានអនុវត្តដោយសហចៅក្រមស៊ើបអង្កេត[939] មិនគួរមិនរាប់បញ្ចូលដោយស្វ័យប្រវត្តិបុគ្គលនៅថ្នាក់ទាបៗ ដែលពាក់ព័ន្ធដោយផ្ទាល់នៅក្នុងអំពើឃោរឃៅដ៏ធ្ងន់ធ្ងរបំផុតនោះឡើយ[940]។ នៅក្នុងករណីនេះ ចៅក្រមទទួលបន្ទុកលើរឿងក្ដី សូមយោងលើការវាយតម្លៃ

---

[935] សាលក្រមលើសំណុំរឿង ០០១ (ឯកសារ E188) កថាខណ្ឌ ២២។

[936] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣០៩, ៣១៥-៣១៦។

[937] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣០៩, ៣១៦។

[938] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣២៤។

[939] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣៩។

[940] សំណុំរឿង ០០៤/០១ ឧបសម្ព័ន្ធ ខ៖ របាយការណ៍របស់ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា ដែលត្រូវបានបង្កើតឡើងអនុលោមតាមសេចក្ដីសម្រេចមហាសន្និបាតលេខ ៥២/១៣៥ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ១៩៩៩ ឯកសារ D251/4.3 កថាខណ្ឌ ១១០។

របស់ចៅក្រម ពាក់ព័ន្ធនឹងមូលដ្ឋានទី ២ ដល់ ទី ៦ អំពីព័ត៌មានលម្អិតនៃការដឹកនាំ *តាមព្រឹត្តហេតុ* និង*តាមផ្លូវច្បាប់*របស់ អ៊ឹម ចែម និងការចូលរួមក្នុងឧក្រិដ្ឋកម្មជាច្រើន ដែលត្រូវបានចោទប្រកាន់ដាក់បន្ទុក។

៣៣៥. ជាពិសេស ចៅក្រមទទួលបន្ទុកលើរឿងក្ដី ចាត់ទុកថាមានភាពចាំបាច់ត្រូវពិចារណាលើវិសាលភាពដ៏ធំធេងនៃមុខតំណែង*តាមផ្លូវច្បាប់*ទាំងអស់របស់ អ៊ឹម ចែម នៅពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។ ដូចបានសម្រេចពាក់ព័ន្ធនឹងមូលដ្ឋានទី ៥ និងទី ៦ ចៅក្រមឃើញមានភស្តុតាងគ្រប់គ្រាន់ ក្រៅពីមុខងាររបស់គាត់នៅភូមិភាគពាយ័ព្យ អ៊ឹម ចែម ក៏ជាលេខាស្រុកកោះអណ្ដែត និងជាសមាជិកគណៈកម្មាធិការតំបន់ ១៣ នៅមុនឆ្នាំ ១៩៧៧ នៅភូមិភាគនិរតីផងដែរ ព្រមទាំងជាប្រធានសមាគមនារីក្នុងតំបន់ ១៣។ ហេតុដូច្នេះ គាត់នៅតែបន្តកាន់តំណែងជាន់ខ្ពស់នៅក្នុងឋានានុក្រម នៅតាមតំបន់ភូមិសាស្ត្រជាច្រើន ក្នុងពេលរបបខ្មែរក្រហមកាន់កាប់អំណាច[941] ។ នៅក្នុងតួនាទីទាំងនេះជាកម្មាភិបាលនៅថ្នាក់ស្រុក និងតំបន់ អ៊ឹម ចែម អាចជាបុគ្គលចំបងចូលរួមនៅក្នុងការអនុវត្តគោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យ[942]។ លើសពីនេះទៀត ដូចដែលបានកត់សម្គាល់ពាក់ព័ន្ធនឹងមូលដ្ឋានទី ២ ដល់ទី ៤ នៃសាលដីកានេះ ក្រោយពីពិចារណាតួនាទីទាំងនេះ អ៊ឹម ចែម បានចូលរួមដោយផ្ទាល់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មជាច្រើនដែលត្រូវបានចោទប្រកាន់ដាក់បន្ទុក ហើយបានចេញបញ្ជាឱ្យអ្នកផ្សេងប្រព្រឹត្តឧក្រិដ្ឋកម្ម។

៣៣៦. ចៅក្រមទទួលបន្ទុកលើរឿងក្ដី កត់សម្គាល់ថា អ៊ឹម ចែម ក៏មានតួនាទី និងការទទួលខុសត្រូវសំខាន់ៗ*តាមព្រឹត្តហេតុ* ដែលតួនាទី និងការទទួលខុសត្រូវទាំងនេះលើសពីការងារទូទៅជាលេខាស្រុក។ ដូចបានរៀបរាប់លម្អិតនៅក្នុងមូលដ្ឋានទី ២ នៃបណ្ដឹងឧទ្ធរណ៍ ឧទាហរណ៍សំខាន់មួយគឺតួនាទីសំខាន់ដែលគាត់បានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ក្នុងការបោសសម្អាតភូមិភាគពាយ័ព្យ រួមទាំង ការដឹកនាំក្រុមគ្រួសារវាប់រយគ្រួសារពីខេត្តតាកែវទៅកាន់ភូមិភាគពាយ័ព្យ និងការចូលរួមនៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលនាំឱ្យក្លាយឧក្រិដ្ឋកម្មប្រឆាំងនឹងកម្មាភិបាល និងប្រជាជនទូទៅ យ៉ាងហោចណាស់នៅក្នុងតំបន់ ៥ ទាំងមូល[943]។ ចៅក្រមទទួលបន្ទុកលើរឿងក្ដី ចាត់ទុកតួនាទីដ៏សំខាន់នៅក្នុងការបោសសម្អាតភូមិភាគពាយ័

---

[941] *សូមមើលផងដែរ* កិច្ចសម្ភាសន៍ អ៊ឹម ចែម ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៧ (ឯកសារ D1.3.12.1) ត្រង់ ERN 00234190-00234191។

[942] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៦៨, ១៧១-១៧២។

[943] *សូមមើល* កថាខណ្ឌ ១៣២-១៤២ ។ *សូមមើលផងដែរ* ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៥១-១៥៧, ៣១៦។

ព្យ ថាជា ភ័ស្តុតាងបង្ហាញអំពីការទទួលខុសត្រូវកម្រិតខ្ពស់របស់ អ៊ឹម ចែម និងអំពីឋានៈរបស់គាត់ក្នុងនាមជាបុគ្គលម្នាក់ "ក្នុងចំណោមអ្នកទទួលខុសត្រូវបំផុត"។

៣៣៧. លើសពីនេះទៀត ចៅក្រមទទួលបន្ទុកលើរឿងក្តី ពិចារណាលើអង្គហេតុដែលថា អ៊ឹម ចែម យោងតាមការទទួលស្គាល់របស់គាត់ ស្ថិតនៅក្នុងជួរបក្សក្នុងឋានានុក្រមខ្មែរក្រហម។ ដោយសារគាត់មានទំនាក់ទំនងជិតស្និទ្ធជាមួយ តាម៉ុក[944] គាត់មានសិទ្ធិទាក់ទងជាមួយថ្នាក់លើរបស់អង្គការ ដូចជា ប៉ុល ពត[945]ដែលគាត់បានទទួលការគាំទ្រផ្ទាល់ ជាច្រើនលើកច្រើនសា[946]។ ទោះបីមិនមែនជាកត្តាកំណត់ថា គាត់គឺជាមេដឹកនាំជាន់ខ្ពស់ក៏ដោយ[947] នេះគឺជាការបង្ហាញអំពីឋានៈ អំណាចក្រៅផ្លូវការ និងសិទ្ធិពិសេស ដែលគាត់មានលើសពីតួនាទីធម្មតាក្នុងនាមជាលេខាស្រុក ។ តាមការទទួលស្គាល់ផ្ទាល់របស់គាត់ អ៊ឹម ចែម អាចតបតនឹងបញ្ជារបស់ តាញ៉ឹម ឱ្យចាប់ខ្លួនគាត់ នៅក្នុងភូមិភាគពាយ័ព្យ ទោះបីជាគាត់ជំទាស់ និងមិនគោរពតាមការណែនាំរបស់គណៈកម្មាធិការភូមិភាគក៏ដោយ[948]។ អ៊ឹម ចែម ក៏មិនភ័យខ្លាចប្រឈមមុខជាមួយ តាម៉ុក ឬ រាយការណ៍ព័ត៌មានមិនល្អ ខណៈដែលកម្មាភិបាលដទៃទៀតមិនហ៊ានធ្វើដូច្នេះឡើយ ដោយសារកេរ្តិ៍ឈ្មោះរបស់គាត់[949]។ អ៊ឹម ចែម នៅតែពិណ៌នាថា តាម៉ុក ជាអ្នកសង្គ្រោះគាត់[950] ហើយ ប៉ុល ពត ជាមនុស្សមិនឃោរឃៅឡើយ[951]។

---

[944] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៥៥។ *សូមមើលផងដែរ* កិច្ចសម្ភាសន៍ អ៊ឹម ចែម ថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០០៨ (ឯកសារ D123/1/5.1b) ត្រង់ ERN (EN) 00951812។

[945] សំណុំរឿង ០០៤/០១ ប្រតិចារឹកនៃកិច្ចសម្ភាសន៍របស់យុវសន្តិភាពជាមួយ អ៊ឹម ចែម ឆ្នាំ២០១១ ឯកសារ219/264.1 ត្រង់ ERN (EN) 01117970។

[946] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៥៥។ *សូមមើលផងដែរ* កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា អ៊ឹម ចែម ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៨ (ឯកសារ D123/1/5.1b) ត្រង់ ERN (EN) 00951802-00951803, 00951809។ *សូមមើលផងដែរ* កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា អ៊ឹម ចែម ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៧ (ឯកសារ D1.3.12.1) ត្រង់ ERN (EN) 00217524។

[947] *សូមមើល* ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣១៥។

[948] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា អ៊ឹម ចែម ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៨ (ឯកសារ D123/1/5.1b) ត្រង់ ERN (EN) 00951800, 00951808-00951810។ *សូមមើលផងដែរ* កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា អ៊ឹម ចែម ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៧ (ឯកសារ D1.3.12.1) ត្រង់ ERN (EN) 00217525។

[949] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា អ៊ឹម ចែម ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៨ (ឯកសារ D123/1/5.1b) ត្រង់ ERN (EN) 00951812។

[950] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា អ៊ឹម ចែម ថ្ងៃទី៦ ខែមេសា ឆ្នាំ២០១២ (ឯកសារ D123/1/5,1c) ត្រង់ ERN (EN)

៣៣៨. ចំណុចចុងក្រោយ ចៅក្រមទទួលបន្ទុកលើរឿងក្ដី សូមគូសបញ្ជាក់ការទទួលស្គាល់ផ្ទាល់របស់ អ៊ឹម ចែម ថា គាត់ "ត្រូវបានគេតម្លើងឋានៈនៅក្នុងជួរដឹកនាំ" ក្នុងមុខនាទីរបស់គាត់ ហើយ "តែងតែត្រូវបានជ្រើសរើសឱ្យធ្វើជាមេដឹកនាំ"[952]។ គាត់មិនដែលបដិសេធចំពោះការប្រកាន់ខ្ជាប់ក្រឹត្យក្រម និងការអនុវត្តនៃរបបកម្ពុជាប្រជាធិបតេយ្យ [953] និងការតស៊ូរបស់គាត់ "ដើម្បីប្រជាជាតិ និងពូជសាសន៍របស់គាត់នោះឡើយ"[954]។

## ៤. សេចក្ដីសន្និដ្ឋាន

៣៣៩. ដោយយោងសំអាងហេតុខាងលើ ចៅក្រមទទួលបន្ទុកលើរឿងក្ដី ពិចារណាឃើញថា សហចៅក្រមស៊ើបអង្កេតមិនបានពិចារណាអំពីវិសាលភាពធំធេងនៃភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ដាក់បន្ទុកលើ អ៊ឹម ចែម ព្រមទាំង តួនាទី និងការទទួលខុសត្រូវរបស់គាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ក្រោយពីបានពិនិត្យឡើងវិញលើវិសាលភាពនៃការចោទប្រកាន់ដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ព្រមទាំងវិសាលភាពដែលការចោទប្រកាន់ទាំងនេះមានភស្តុតាងគាំទ្រ ដូចបានរកឃើញក្នុងអំឡុងពេលស៊ើបសួរនោះ ចៅក្រមទទួលបន្ទុលើរឿងក្ដីយល់ឃើញថា អ៊ឹម ចែម គឺស្ថិតនៅក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ដូច្នេះស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។

៣៤០. អលទ្ធភាពក្នុងការឈានទៅដល់ការឯកភាពគ្នាជាឯកច្ឆ័ននៅក្នុងអង្គជំនុំជម្រះនេះលើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក មិនអាចរារាំងការពិចារណាសម្រេចចោទប្រកាន់លើឧក្រិដ្ឋកម្មធ្ងន់ធ្ងរចំពោះ អ៊ឹម ចែម នៅចំពោះមុខតុលាការជាតិនោះទេ ដោយសារប្រទេសកម្ពុជាមានយុត្តាធិការជាប់មករហូតលើរឿងក្ដី

---

00951879។

[951] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា អ៊ឹម ចែម ថ្ងៃទី៦ ខែមេសា ឆ្នាំ២០១២ (ឯកសារ D123/1/5,1c) ត្រង់ ERN (EN) 00951880។

[952] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា អ៊ឹម ចែម ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៧ (ឯកសារ D1.3.12.1) ត្រង់ ERN (EN) 00217516, 00217525។

[953] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា អ៊ឹម ចែម ថ្ងៃទី៦ ខែមេសា ឆ្នាំ២០១២ (ឯកសារ D123/1/5,1c) ត្រង់ ERN (EN) 00951879។

[954] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា អ៊ឹម ចែម ថ្ងៃទី៦ ខែមេសា ឆ្នាំ២០១២ (ឯកសារ D123/1/5,1c) ត្រង់ ERN (EN) 00951826។

នៅក្នុងសម័យខ្មែរក្រហម ដែល អ.វ.ត.ក មិនបានទទួលរឿងក្តី ឬ មិនអាចមានសមត្ថកិច្ចទទួលរឿងក្តីទាំងនោះ[955]។

**ភ្នំពេញ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨**

**Olivier BEAUVALLET** **Kang Jin BAIK**

[955] *សូមមើល ខាងលើ* កថាខណ្ឌ ៨០។